# វិសុទ្ធិមគ្គបត្ថម្ភក
# សីលនិទ្ទេស

វត្តនិគ្រោធវ័ន

រៀបរៀងដោយ
ព្រះមហាសទ្ធម្មធរជោតិកៈ
សុវណ្ណជោតោ ឡូង~សុវណ្ណ

ពុទ្ធសករាជ ២៥៥៨

- សៀវភៅ **វិសុទ្ធិមគ្គបត្ថម្ភក សីលនិទ្ទេស**
- រៀបរៀងដោយ **ព្រះមហាសទ្ធម្មធរជោតិកៈ**

**សុវណ្ណជោតោ ភួង-សុវណ្ណ**

ជាអាចារ្យបង្រៀនព្រះវិន័យ ឧត្តមសិក្សានៃវត្តនិគ្រោធវ័ន

- អ្នកជួយពិនិត្យ

**ភិក្ខុ សទ្ធម្មាលង្ការោ ឆោម-វិបុល**

**ភិក្ខុ វិនយធរោ គុន-ប៊ុនសាយ**

**ភិក្ខុ មង្គលបាលិតោ នី-សុភក្ត្រ**

- ទីកន្លែងធ្វើ **វត្តនិគ្រោធវ័ន "គល់ទទឹង" រាជធានីភ្នំពេញ**

និង **វត្តវិសុទ្ធិមគ្គ ខេត្តសៀមរាប** ។

- សម្រាប់ជាធម្មទាន
- ពុទ្ធសករាជ ២៥៥៨

# អារម្ភកថា

**ព្រះនិព្វាន** ដែលប្រាសចាកមន្ទិលទាំងពួង បរិសុទ្ធដោយចំណែកមួយ ឈ្មោះថា ជាវិសុទ្ធិ (សេចក្តីបរិសុទ្ធ)។ ឈ្មោះថា វិសុទ្ធិមគ្គ ព្រោះអត្ថថា ជាផ្លូវនៃវិសុទ្ធិនោះ ។ ឧបាយជាគ្រឿងត្រាស់ដឹង ហៅថា **មគ្គ** ។ ក្នុងដីកាបរមត្ថមញ្ជុសា ពោលថា "ក៏លោកុត្តរមគ្គ គប្បីជ្រាបថា វិសុទ្ធិមគ្គដោយត្រង់ ចំណែកផ្លូវដែលជាបុព្វភាគ និងពាក្យប្រព័ន្ធ ដែលជាទីអាស្រ័យរបស់ផ្លូវដែលជាបុព្វភាគនោះ ក៏ហៅថា វិសុទ្ធិមគ្គ ដូចគ្នា ព្រោះជាឧបាយនៃលោកុត្តរមគ្គនោះ" ។ ចំណែកក្នុងដីកាសង្ខេបត្ថជោតនីថា "**មគ្គ** ដែលជាចំណែកខាងដើម ជាឧបាយដើម្បីសេចក្តីបរិសុទ្ធិនោះ និងគម្ពីរជាគ្រឿងបើកបង្ហាញផ្លូវនៃសេចក្តីបរិសុទ្ធិនោះ ដោយហេតុនោះ លោកទើបពោលថា ឧបាយជាគ្រឿងត្រាស់ដឹង" ។

ដូច្នេះ "លោកុត្តរមគ្គ ជា វិសុទ្ធិមគ្គដោយត្រង់ និងផ្លូវដែលជាបុព្វភាគ ជាឧបាយនៃលោកុត្តរមគ្គនោះ ក៏ហៅថា វិសុទ្ធិមគ្គ" ។ វិសុទ្ធិមគ្គ គឺជាផ្លូវនៃសេចក្តីបរិសុទ្ធ ដែលសង្គ្រោះដោយគុណមានសីលជាដើម ជាផ្លូវដ៏ក្សេម និងត្រង់ ដែលសាធុជនទាំងឡាយគ្រប់គ្នាអ្នកប្រាថ្នានូវសេចក្តីបរិសុទ្ធ គប្បីផ្ចង់ចិត្តស្តាប់ សិក្សាដោយគោរព ។

ខ្ញុំព្រះករុណា បានឆ្លៀតពេលពីការបង្ហាត់បង្រៀន សរសេរសៀវភៅនេះឡើង ក៏ដើម្បីបានជាឧបករណ៍ជាជំនួយដល់គ្រូផង ដល់សមណ-សិស្សផងដែរ ក្នុងការសិក្សាគម្ពីរវិសុទ្ធិមគ្គនេះ ។ ក្នុងសៀវភៅនេះ ខ្ញុំព្រះករុណា បានលើកយកចំណុចដែលសម្តែងពីសីល ដែលមានក្នុងគម្ពីរវិសុទ្ធមគ្គ និងដីកាខ្លះៗ មកអធិប្បាយតាមសមគួរ, តែមិនបានសព្វគ្រប់ទាំងអស់ទេ គ្រាន់តែជាគោលសម្រាប់សិក្សាប៉ុណ្ណោះ ។ ព្រោះហេតុនោះ សៀវភៅនេះ ខ្ញុំដាក់ឈ្មោះថា **វិសុទ្ធិមគ្គបត្ថម្ភក** ។

ក្នុងគម្ពីរវិសុទ្ធិមគ្គនោះ ព្រះពុទ្ធឃោសៈ លោកពណ៌នានូវអត្ថដ៏ផ្សេងគ្នា ដោយគុណមានសីលជាដើម តាមសេចក្តីពិតនៃព្រះគាថាដែលព្រះពុទ្ធទ្រង់ស្វែងរកគុណដ៏ធំ ទ្រង់សម្តែងហើយ លោកពោលនូវវិសុទ្ធិមគ្គ ដែលអាស្រ័យនូវន័យនៃទេសនារបស់ព្រះមហាថេរៈទាំងឡាយដែលគង់នៅក្នុងមហាវិហារ ជាមគ្គ មានវិនិច្ឆ័យដ៏បរិសុទ្ធស្អាត ជាគ្រឿងធ្វើអំណរដល់ព្រះយោគីទាំងឡាយណា "ដែលបាននូវបព្វជ្ជា ដែលគេបានដោយក្រណាស់ ក្នុងជិនសាសនានេះ" ហើយមិនដឹងតាមពិតនូវផ្លូវនៃសេចក្តីបរិសុទ្ធ ដែលសង្គ្រោះដោយគុណមានសីលជាដើម ជាផ្លូវដ៏ក្សេមនិងត្រង់ សូម្បីចង់បរិសុទ្ធហើយព្យាយាម យ៉ាងណា ក៏នៅតែមិនបាននូវសេចក្តីបរិសុទ្ធនោះដែរ កាលបើខ្ញុំពោលនូវផ្លូវនៃសេចក្តីបរិសុទ្ធនោះ

សាធុជនទាំងឡាយគ្រប់គ្នា អ្នកប្រាថ្នានូវសេចក្តីបរិសុទ្ធ ចូរផ្ចង់ចិត្ត ស្តាប់ដោយគោរព ។

ព្រោះហេតុនោះ កុលបុត្រគប្បីតាំងចិត្តសិក្សា និងការបដិបត្តិ ដោយល្អ ។ ព្រោះថា ការកើតឡើងនៃព្រះពុទ្ធ ជារបស់បានដោយក្រ, ការបព្វជ្ជានិងការឧបសម្បទា ជារបស់បានដោយក្រក្រៃលែងជាងនោះ ។ ម្យ៉ាងទៀត "ដែលឈ្មោះថា បព្វជ្ជាមានសេចក្តីបរិសុទ្ធិនៃចិត្ត ជាប្រយោជន៍, ចូរកុំប្រមាទ បំពេញសមណធម៌ចុះ" ។

ដោយអានុភាពនៃបុណ្យទាំងពួងនេះ សូមពួកញាតិនិងសព្វសត្តនិករ មួយអន្លើដោយពុទ្ធបរិស័ទទាំងឡាយ ចូរបានសេចក្តីសុខ ចូរជាអ្នកសោយរសនៃព្រះសទ្ធម្ម របស់ព្រះមានព្រះភាគចុះ ។ សូមបានជាឧបនិស្ស័យនៃការត្រាស់ដឹងនូវធម៌ ដល់ព្រមដោយបដិសម្ភិទា ក្នុងសាសនារបស់ព្រះមានព្រះភាគ ក្នុងកាលជាអនាគត ។ សូមអនុមោទនា !!

ថ្ងៃ ០៥ កើត ខែស្រាពណ៍ ព.ស.២៥៥៨

**ភិក្ខុ សុវណ្ណជោតោ ឝួខ~សុវណ្ណ**

# សន្លឹកប្រាប់មាតិកា

**មាតិកា** **ទំព័រ**

## វិសុទ្ធិមគ្គបត្ថម្ភក


-និទានាទិកថា ... ... ... ... ... ... ... ... ... ... ... ... ..... ០១

-សេចក្តីអធិប្បាយព្រះគាថា ... ... ... ... ... ... ... ... ... ០៥

-សីលនិទ្ទេស ... ... ... ... ... ... ... ... ... ... ... ... ...... ៣១

-សីលសរូបាទិកថា ... ... ... ... ... ... ... ... ... ... ... .... ៣១

-វិស្សជ្ជនាបញ្ហាកម្ម ទី១ ... ... ... ... ... ... ... ... .... ៣២

-វិស្សជ្ជនាបញ្ហាកម្ម ទី២ ... ... ... ... ... ... ... ... ... ... ៣៨

-វិស្សជ្ជនាបញ្ហាកម្ម ទី៣ ... ... ... ... ... ... ... ... ... ... ៤២

-វិស្សជ្ជនាបញ្ហាកម្ម ទី៤ ... ... ... ... ... ... ... ... ... ... ៤៧

-វិស្សជ្ជនាបញ្ហាកម្ម ទី៥ (សីលប្បភេទ) ... ... ... ... ... ៥៥

អធិប្បាយសីលពួកពីរ ... ... ... ... ... ... ... ... ... ៥៩

អធិប្បាយសីលពួកបី ... ... ... ... ... ... ... ... ... ៧៥

អធិប្បាយសីលពួកបួន ... ... ... ... ... ... ... ... ... ៨៤

-អធិប្បាយបាតិមោក្ខសំវរៈ ... ... ... ... ... ... ... ... ៩៣

អនាចារ និងអាចារ

អនាចារ ... ... ... ... ... ... ... ... ... ... ... ... ៩៨

អាចារ ... ... ... ... ... ... ... ... ... ... ... ... ... ១០២

អគោចរ ... ... ... ... ... ... ... ... ... ... ... ... ១០៣

គោចរ ... ... ... ... ... ... ... ... ... ... ... ... ... ១០៤

គោចរ ៣ យ៉ាង ... ... ... ... ... ... ... ... .... ១១៤

-អធិប្បាយក្នុងឥន្ទ្រិយសំវរសីល ... ... ... ... .... ១២១

-អធិប្បាយអាជីវបារិសុទ្ធិសីល ... ... ... ... ... ... ១៣២

បាបធម៌ ៥ យ៉ាង ... ... ... ... ... ... ... ..... ១៣៤

កុហនវត្ថុ ៣ យ៉ាង ... ... ... ... ... ... ... ... ... ១៣៨

ពាក្យថា អាជីវបារិសុទ្ធិ ... ... ... ... ... ... ... ... ១៤៩

-អធិប្បាយបច្ចយសន្និស្សិតសីល ... ... ... ... .... ១៤០

អធិប្បាយបច្ចវេក្ខណៈវិធី ... ... ... ... ... ... ... ១៤៣

ដែនរបស់ប្រយោជន៍ក្នុងការបរិភោគបច្ច័យ ... ... ១៤៦

ចីវរប្បច្ច័យ ... ... ... ... ... ... ... ... ... ... ... ... ១៤៦

បិណ្ឌបាតប្បច្ច័យ ... ... ... ... ... ... ... ... ... ... ១៤៨

សេនាសនប្បច្ច័យ ... ... ... ... ... ... ... ... ... ... ១៥៦

គិលានប្បច្ច័យ ... ... ... ... ... ... ... ... ... ... ... ១៥៩

## ចតុបារិសុទ្ធិសម្បាទនវិធិ

១-បាតិមោក្ខសំវរសីល ... ... ... ... ... ... ... ... ... ... ... ១៦៥

២-ឥន្ទ្រិយសំវរសីល ... ... ... ... ... ... ... ... ... ... ... ... ១៧១

៣-អាជីវបារិសុទ្ធិសីល ... ... ... ... ... ... ... ... ... ... ... ១៧៩

៤-បច្ចយសន្និស្សិតសីល ... ... ... ... ... ... ... ... ... ..... ១៨៦

អធិប្បាយបច្ចវេក្ខណៈ ... ... ... ... ... ... ... ..... ១៨៧

ការបរិភោគមាន ៤ យ៉ាង ... ... ... ... ... ... ... ១៩១

សុទ្ធិមាន ៤ យ៉ាង ... ... ... ... ... ... ... ... ... ១៩៨

អធិប្បាយសីលពួក ៥ ក្រុមទី១ ... ... ... ... ... .... ២០៧

អធិប្បាយសីលពួក ៥ ក្រុមទី២ ... ... ... ... ... ... ២១១

-វិស្សជ្ជនាបញ្ហាកម្ម ទី៦ (សំកិលេសនៃសីល) ... ... ... ២១៦

មេថុនសំយោគ ៧ ... ... ... ... ... ... ... ... ... ២១៧

-វិស្សជ្ជនាបញ្ហាកម្ម ទី៧ (វោទាននៃសីល) ... ... ... ..... ២២១

ទោសនៃសីលវិបត្តិ ... ... ... ... ... ... ... ... ... ២២៥

អានិសង្សនៃសីលសម្បត្តិ ... ... ... ... ... ... ... ២៣០

## ២-ធុតង្គនិទ្ទេស

-ធុតង្គនិទ្ទេស ... ... ... ... ... ... ... ... ... ... ... ... ... ... ២៣៥

ធុតង្គ ១៣ ... ... ... ... ... ... ... ... ... ... ..... ២៣៦

ធុតង្គវិនិច្ឆ័យ ... ... ... ... ... ... ... ... ... ... ... ២៣៨

១ វិនិច្ឆ័យតាមអត្ថ

វិនិច្ឆ័យបំសុកូលិកង្គតាមអត្ថ ... ... ... ... ... ... ២៣៩

វិនិច្ឆ័យតេចីវរិកង្គតាមអត្ថ ... ... ... ... ... ... ២៤០

វិនិច្ឆ័យបិណ្ឌបាតិកង្គតាមអត្ថ ... ... ... ... ... ... ២៤០

វិនិច្ឆ័យសបទានចារិកង្គតាមអត្ថ ... ... ... ... ... ២៤១

វិនិច្ឆ័យឯកាសនិកង្គតាមអត្ថ ... ... ... ... ... ... ២៤១

វិនិច្ឆ័យបត្តបិណ្ឌិកង្គតាមអត្ថ ... ... ... ... ... ... ២៤២

វិនិច្ឆ័យខលុបច្ឆាភត្តិកង្គតាមអត្ថ ... ... ... ... ... ២៤២

វិនិច្ឆ័យអារញ្ញិកង្គតាមអត្ថ ... ... ... ... ... ... ... ២៤៣

វិនិច្ឆ័យរុក្ខមូលិកង្គតាមអត្ថ ... ... ... ... ... ... ... ២៤៤

វិនិច្ឆ័យយថាសន្ថតិកង្គតាមអត្ថ ... ... ... ... ..... ២៤៤

វិនិច្ឆ័យនេសជ្ជិកង្គតាមអត្ថ ... ... ... ... ... ... ... ២៤៥

២ វិនិច្ឆ័យធុតង្គដោយលក្ខណៈជាដើម ... ... ... ... .... ២៤៥

៣ វិធីសមាទានធុតង្គ ... ... ... ... ... ... ... ... ... ..... ២៥០

៣.១-ពោលដោយបង្សុកូលិកង្គ ... ... ... ... ... ២៥៤

៣.២-ពោលដោយតេចីវរិកង្គ ... ... ... ... ... ... ២៦១

៣.៣-ពោលដោយបិណ្ឌបាតិកង្គ ... ... ... ... ... ២៦៦

៣.៤-ពោលដោយសបទានចារិកង្គ ... ... ... ... ២៧២

៣.៥-ពោលដោយឯកាសនិកង្គ ... ... ... ... ..... ២៧៧

៣.៦-ពោលដោយបត្តបិណ្ឌិកង្គ ... ... ... ... ..... ២៨២

៣.៧-ពោលដោយខលុបច្ឆាភត្តិកង្គ ... ... ... ... ២៨៦

៣.៨-ពោលដោយអារញ្ញិកង្គ ... ... ... ... ... ... ២៨៩

៣.៩-ពោលដោយរុក្ខមូលិកង្គ ... ... ... ... ... ... ២៩៧

៣.១០-ពោលដោយអព្ភោកាសិកង្គ ... ... ... ... ៣០០

៣.១១-ពោលដោយសោសានិកង្គ ... ... ... ..... ៣០៤

៣.១២-ពោលដោយយថាសន្ថតិកង្គ ... ... ... ... ៣០៨

៣.១៣-ពោលដោយនេសជ្ជិកង្គ ... ... ... ... ... ៣១១

៤ បកិណ្ណកកថានៃធុតង្គ ... ... ... ... ... ... ... ... ..... ៣១៥

៤.១ វិនិច្ឆ័យដោយកុសលត្តិកៈ ... ... ... ... .... ៣១៥

៤.២ វិនិច្ឆ័យដោយវិភាគ ... ... ... ... ... ... ... ៣១៨

៤.៣ ធុតង្គដោយសង្ខេប ... ... ... ... ... ... .... ៣២៥

៤.៤ វិនិច្ឆ័យធុតង្គដោយពិស្តារ ... ... ... ... ... ៣២៧

នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស

*សូមនមស្ការ ចំពោះព្រះមានព្រះភាគ*

*ជាអរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។*

# វិសុទ្ធិមគ្គបត្ថម្ភក

## និទានាទិកថា

សីលេ បតិដ្ឋាយ នរោ សបញ្ញោ

ចិត្តំ បញ្ញញ្ច ភាវយំ

អាតាបី និបកោ ភិក្ខុ

សោ ឥមំ វិជដយេ ជដំ ។

*នរជនមានប្រាជ្ញា បានតាំងមាំក្នុងសីល ហើយចម្រើននូវសមាធិចិត្ត និងវិបស្សនាបញ្ញា ជាអ្នកមានព្យាយាមដុតកំដៅកិលេស ប្រកបដោយបាដិហារិយប្បញ្ញា ជាអ្នកឃើញភ័យក្នុងសង្សារ បុគ្គលនោះទើបកាប់ឆ្ការនូវតណ្ហា ជាគ្រឿងចាក់ស្រេះនេះបាន ។*

*ក៏ពាក្យនេះ ព្រះមានព្រះភាគ ត្រាស់ទុកដូច្នេះ ។*

*ក៏ព្រោះហេតុអ្វី ទើបបានត្រាស់ពាក្យនេះទុក ?*

បានឮថា មានទេវបុត្រមួយអង្គ ចូលទៅគាល់ព្រះមានព្រះ-ភាគ ក្នុងវេលារាត្រី ក្នុងក្រុងសាវត្ថី ហើយសួរនូវបញ្ហានេះ ដើម្បីនឹងដកចេញនូវសេចក្តីសង្ស័យរបស់ខ្លួនថា ៖

អន្តោ ជដា ពហិ ជដា ជដាយ ជដិតា បជា

តំ តំ គោតម បុច្ឆាមិ កោ ឥមំ វិជដយេ ជដំ។

តណ្ហាជាគ្រឿងចាក់ស្រេះខាងក្នុងក៏មាន តណ្ហាជាគ្រឿងចាក់ស្រេះខាងក្រៅក៏មាន ពពួកសត្វត្រូវតណ្ហាជាគ្រឿងចាក់ស្រេះរួបរឹតហើយ បពិត្រព្រះគោតម ព្រោះហេតុនោះ ខ្ញុំព្រះអង្គសូមសួរព្រះអង្គថា អ្នកណាអាចកាប់ឆ្ការនូវគ្រឿងចាក់ស្រេះ គឺតណ្ហានេះបាន ។

នេះជាសេចក្តីសង្ខេប នៃបញ្ហានោះ ។

ពាក្យថា **គ្រឿងចាក់ស្រេះនុ៎ះ** ជាឈ្មោះនៃតណ្ហា ជាបណ្តាញ ។ សេចក្តីថា តណ្ហានោះ ឈ្មោះថា **ជដា** ដោយអត្ថថា ជាគ្រឿងចាក់ស្រេះរួបរឹត ដូចគ្រឿងចាក់ស្រេះគឺខ្នែងនៃគុម្ពឈើទាំងឡាយ មានគុម្ពឫស្សីជាដើម ព្រោះកើតឡើងរឿយៗ ក្នុងអារម្មណ៍ទាំងឡាយមានរូបារម្មណ៍ជាដើម ដោយអំណាចនៃកិរិយាប្រព្រឹត្តទៅក្នុងខាងក្រោមនិងខាងលើ ។ តណ្ហានោះឯង ដែលលោកពោលថា ជាគ្រឿងចាក់ស្រេះខាងក្នុង ជាគ្រឿងចាក់ស្រេះខាងក្រៅ ព្រោះកើតឡើងក្នុងបរិក្ខាររបស់ខ្លួន និងបរិក្ខាររបស់

បុគ្គលដទៃ ក្នុងអត្តភាពរបស់ខ្លួន និងអត្តភាពរបស់បុគ្គលដទៃ ក្នុងអាយតនៈខាងក្នុង និងអាយតនៈខាងក្រៅ ។

ពួកសត្វដែលគ្រឿងចាក់ស្រែះ គឺតណ្ហានោះ កាលកើតឡើង ហើយរួបរឹតយ៉ាងនេះ ។ សេចក្តីអធិប្បាយថា ប្រៀបដូចជាឈើទាំងឡាយ មានគុម្ពឫស្សីជាដើម ដែលគ្រឿងចាក់ស្រែះមានខ្នែងនៃឫស្សីជាដើមរួបរឹត ព័ន្ធព័ទ្ធចាក់ស្រែះហើយ ពួកសត្វពោលគឺសត្តនិកាយទាំងអស់នេះ ដែលគ្រឿងចាក់ស្រែះ គឺតណ្ហារួបរឹតព័ន្ធព័ទ្ធ ចាក់ស្រែះ ក៏យ៉ាងនោះដែរ ។ មួយវិញទៀត ពួកសត្វដែលគ្រឿងចាក់ស្រែះ គឺតណ្ហារឹតឆ្វាក់ហើយយ៉ាងនេះ ព្រោះហេតុណា ព្រោះហេតុនោះ ខ្ញុំព្រះអង្គទើបសួរព្រះអង្គថា បពិត្រព្រះគោតម ព្រោះហេតុនោះ ខ្ញុំព្រះអង្គសូមសួរព្រះអង្គ ។ ទេវបុត្រ ហៅព្រះមានព្រះភាគ តាមគោត្រថា **គោតម** ។

ពាក្យថា **អ្នកណាអាចកាប់ឆ្ការនូវគ្រឿងចាក់ស្រែះ គឺតណ្ហានេះបាន** មានសេចក្តីថា ទេវបុត្រទូលសួរព្រះមានព្រះភាគថា អ្នកណាគប្បីត្រដោះ គឺថាអ្នកណាអាចដើម្បីត្រដោះគ្រឿងចាក់ស្រែះនេះ ដែលចាក់នូវត្រៃធាតុ ដែលតាំងនៅហើយយ៉ាងនេះ ។

ព្រះមានព្រះភាគ មានកិរិយាត្រាច់ទៅនៃព្រះញាណ មិនមានទើសទាល់ក្នុងធម៌ទាំងពួងទាំងឡាយ ព្រះអង្គជាទេវតារបស់ទេវតា

ព្រះអង្គជាទេវតា ប្រសើរលើសជាងទេវតាទាំងឡាយ ព្រះអង្គជាព្រះឥន្ទ ប្រសើរលើសជាងព្រះឥន្ទទាំងឡាយ ព្រះអង្គជាព្រះព្រហ្ម ប្រសើរលើសជាងព្រហ្មទាំងឡាយ ព្រះអង្គមានសេចក្ដីក្លៀវក្លា ដោយចតុវេសារជ្ជញ្ញាណ ព្រះអង្គទ្រទ្រង់នូវទសពលញ្ញាណ ព្រះអង្គមានព្រះញាណមិនទើសទាល់ ព្រះអង្គមានសមន្តចក្ខុ គឺសព្វញ្ញុតញ្ញាណ ដែលទេវបុត្រនោះសួរព្រះអង្គយ៉ាងនេះហើយ ទ្រង់ដោះស្រាយនូវសេចក្ដីនោះ ទើបទ្រង់ត្រាស់គាថានេះថា ៖

សីលេ បតិដ្ឋាយ នរោ សបញ្ញោ
ចិត្តំ បញ្ញញ្ច ភាវយំ
អាតាបី និបកោ ភិក្ខុ
សោ ឥមំ វិជដយេ ជដំ ។

នរជនមានប្រាជ្ញា បានតាំងមាំក្នុងសីល ហើយចម្រើននូវសមាធិចិត្ត និងវិបស្សនាបញ្ញា ជាអ្នកមានព្យាយាមដុតកំដៅកិលេស ប្រកបដោយបាដិហារិយបញ្ញា ជាអ្នកឃើញភ័យក្នុងសង្សារ បុគ្គលនោះទើបកាប់ផ្ដាច់នូវតណ្ហា ជាគ្រឿងចាក់ស្រេះនេះបាន ។

## សេចក្ដីអធិប្បាយព្រះគាថា

តត្ថ **វិសុទ្ធី**តិ សព្វមលវិរហិតំ អច្ចន្តបរិសុទ្ធំ និព្វានំ វេទិតព្វំ ។ តស្សា វិសុទ្ធិយា មគ្គោតិ វិសុទ្ធិមគ្គោ ។ **មគ្គោ**តិ អធិគមូបាយោ វុច្ចតិ ។ តំ វិសុទ្ធិមគ្គំ ភាសិស្សាមីតិ អត្ថោ ។

*ក្នុងបទថា **វិសុទ្ធិមគ្គ** នោះ គប្បីជ្រាបថា ព្រះនិព្វានដែលប្រាសចាកមន្ទិលទាំងពួង បរិសុទ្ធដោយចំណែកមួយ ឈ្មោះថាជា**វិសុទ្ធិ** (សេចក្ដីបរិសុទ្ធិ) ។ ឈ្មោះថា **វិសុទ្ធិមគ្គ** ព្រោះអត្ថថាជាផ្លូវនៃវិសុទ្ធិនោះ ។ ឧបាយជាគ្រឿងត្រាស់ដឹង ហៅថា **មគ្គ** ។ សេចក្ដីថា ខ្ញុំ (ព្រះពុទ្ធឃោសៈ) នឹងពោល**វិសុទ្ធិមគ្គ** នោះ ។*

*ក្នុងដីកា បរមត្ថមញ្ជូសា ភាគ១ លោកពន្យល់ទុកថា ៖*

*ពាក្យថា សព្វមលវិរហិតំ (ប្រាសចាកមន្ទិលទាំងពួង) សេចក្ដីថា ប្រាសចាក គឺស្វាត់ចាកមន្ទិលគឺកិលេសមានរាគៈជាដើមទាំងពួង និងចាកមន្ទិលគឺសង្កិលេសទាំងពួង ។ ព្រោះហេតុនោះឯង ទើបឈ្មោះថា បរិសុទ្ធិក្រៃលែង, អធិប្បាយថា បរិសុទ្ធិគ្រប់កាល និងគ្រប់ប្រការ ។ បុគ្គលរមែងស្វែងរក គឺគប់រកការត្រាស់ដឹងសេចក្ដីបរិសុទ្ធ តាមដែលពោលហើយដោយធម៌នេះ*

ហេតុនោះ ធម៌នេះទើបឈ្មោះថា **វិសុទ្ធិមគ្គ** ប្រែថា ធម៌ជាហេតុស្វែងរកសេចក្តីបរិសុទ្ធ ។ ដោយហេតុនោះ លោកអាចារ្យទើបពោលថា “ឧបាយជាគ្រឿងត្រាស់ដឹង ហៅថា **មគ្គ**” ។

វិសុទ្ធិមគ្គោតិ ច និប្បរិយាយេន លោកុត្តរមគ្គោ វេទិតព្វោ, តទុបាយត្តា បន បុព្វភាគមគ្គោ, តន្និស្សយោ កថាបពន្ធោ ច តថា វុច្ចតិ ។

ក៏លោកុត្តរមគ្គ គប្បីជ្រាបថា វិសុទ្ធិមគ្គដោយត្រង់ ចំណែកផ្លូវដែលជាបុព្វភាគ និងពាក្យប្រព័ន្ធ ដែលជាទីអាស្រ័យរបស់ផ្លូវដែលជាបុព្វភាគនោះ ក៏ហៅថា វិសុទ្ធិមគ្គដូចគ្នា ព្រោះជាឧបាយនៃលោកុត្តរមគ្គនោះ ។

ក្នុងដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ពាក្យថា សព្វមលវិរហិតំ (ប្រាសចាកមន្ទិលទាំងពួង) សេចក្តីថា ប្រាសចាកមន្ទិល មានរាគៈជាដើមទាំងអស់ ។ ព្រោះប្រាសចាកមន្ទិលនោះឯង ទើបឈ្មោះថា បរិសុទ្ធក្រៃលែង, អរិយមគ្គ ឈ្មោះថា **វិសុទ្ធិមគ្គ** ព្រោះអត្ថថា ជាគ្រឿងស្វែងរក និងស្វះស្វែងរក បានដល់ ជាគ្រឿងសម្រេចសេចក្តីបរិសុទ្ធ ។ មគ្គ ដែលជាចំណែកខាងដើម ជាឧបាយដើម្បីសេចក្តីបរិសុទ្ធនោះ និងគម្ពីរ

ជាគ្រឿងបើកបង្ហាញផ្លូវនៃសេចក្តីបរិសុទ្ធនោះ ដោយហេតុនោះ លោកទើបពោលថា "ឧបាយជាគ្រឿងត្រាស់ដឹង" ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ ៖

ក៏វិសុទ្ធិមគ្គនោះ ត្រង់កន្លែងខ្លះ ព្រះមានព្រះភាគទ្រង់សម្តែងដោយអំណាចនៃវិបស្សនាប៉ុណ្ណោះ ។ ដូចទ្រង់សម្តែងថា ៖

សព្វេ សង្ខារា អនិច្ចាតិ យទា បញ្ញាយ បស្សតិ
អថ និព្វិន្ទតិ ទុក្ខេ ឯស មគ្គោ វិសុទ្ធិយា ។

កាលណា បុគ្គលយល់ឃើញដោយប្រាជ្ញាថា សង្ខារទាំងពួងមិនទៀង ដូច្នេះ កាលណោះ រមែងនឿយណាយ ក្នុងសេចក្តីទុក្ខ នេះជាផ្លូវនៃសេចក្តីបរិសុទ្ធិ ។

ក្នុងដីកា បរមត្ថមញ្ជូសា ពន្យល់ថា ៖

លោកអាចារ្យប្រាថ្នានឹងសម្តែងថា វិសុទ្ធិមគ្គនោះ ព្រះសាស្តាទ្រង់សម្តែងដោយន័យផ្សេងៗ ដោយការទេសនាវិលាស និងដោយអធ្យាស្រ័យនៃវេនេយ្យ, បណ្តាន័យទាំងនោះ ន័យនេះក៏ជាន័យមួយដែលព្រះសាស្តាទ្រង់កាន់យក ទើបផ្តើមពាក្យថា "ក៏វិសុទ្ធិមគ្គនោះ" ដូច្នេះជាដើម ។

ក្នុងពាក្យទាំងនោះ ពាក្យថា **ក្នុងទីកន្លែងខ្លះ** បានដល់ ក្នុងព្រះសូត្រខ្លះ ។ ដោយអវធារណៈថា **វិបស្សនាមត្តវសេនេវ** (ដោយអំណាចនៃវិបស្សនាប៉ុណ្ណោះ) លោករមែងហាមសមថៈ ។ ព្រោះថា សមថៈនោះ មានការប្រកបដែលផ្ទុយនឹងវិបស្សនានោះ ធម៌មានសីលជាដើម មិនមែនជាធម៌មានការប្រកបដែលផ្ទុយគ្នាទេ ។ និងដោយ**មត្តសព្ទ** ដែលមានសេចក្ដីសំដៅហាមភាពផ្សេង លោកអាចារ្យរមែងហាមសមាធិដែលមានភាពផ្សេងគ្នា ។ ដែលមានប្រភេទជាឧបចារសមាធិ និងអប្បនាសមាធិ មិនមែនហាមត្រឹមតែសមាធិ ព្រោះធ្វើពាក្យអធិប្បាយថា ជាទេសនាសម្រាប់យោគាវចរដែលជាវិបស្សនាយានិកៈ ។ មែនពិត វៀរខណិកសមាធិចេញ វិបស្សនារមែងមិនសម្រេច ។

ក៏ពាក្យថា **វិបស្សនា** គប្បីជ្រាបអនុបស្សនាទាំង ៣ យ៉ាង មិនមែនអនិច្ចានុបស្សនាតែម្យ៉ាងទេ ។ ព្រោះការត្រាស់ដឹងសច្ចៈរមែងមាន ដោយត្រឹមតែឃើញការមិនទៀងក៏ទេ ។ តែក្នុងព្រះគាថាដែលព្រះមានព្រះភាគ ទ្រង់ធ្វើការកាន់យកអនិច្ចលក្ខណៈតែម្យ៉ាងក៏ដោយអំណាចនៃយោគី អ្នកមានអនិច្ចលក្ខណៈនោះប៉ុណ្ណោះប្រាកដច្បាស់ល្អក្រៃលែង ។ ព្រោះយោគីសូម្បីនោះ ក៏បានធ្វើលក្ខណៈ ២ ក្រៅនេះ ឲ្យជាក់ច្បាស់ ពិចារណាហើយត្រាស់ដឹងគុណវិសេស, មិនមែនអនិច្ចលក្ខណៈតែម្យ៉ាងទេ ។

ពាក្យថា សព្វេ សង្ខារា **(សង្ខារទាំងពួង)** សេចក្ដីថា សង្ខារទាំងពួង ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ។ ព្រោះសង្ខារទាំងនោះគួរពិចារណា ។ ពាក្យថា អនិច្ចា **(មិនទៀង)** បានដល់ មិនមែនជារបស់ទៀង គឺមិនយឺនយូរ (ឥត្តរ) មានការទ្រុឌទ្រោមគ្រប់ខណៈ ។ ពាក្យថា បញ្ញាយ **(ដោយបញ្ញា)** គឺដោយវិបស្សនាបញ្ញា ។ ពាក្យថា បស្សតិ **(រមែងឃើញ)** បានដល់ រមែងពិចារណា ។ ពាក្យថា អថ **(កាលនោះ)** បានដល់ ខាងក្រោយ គឺក្នុងកាលតអំពីញាណទាំងឡាយមានឧទយព្វយញាណជាដើមកើតឡើង។ ពាក្យថា និព្វិន្ទតិ ទុក្ខេ **(រមែងនឿយណាយ ក្នុងសេចក្ដីទុក្ខ)** គឺរមែងនឿយណាយ បានដល់ រមែងបាននិព្វិទាញាណក្នុងទុក្ខ ពោលគឺខន្ធ ៥ ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលត្រាស់ថា "**សព្វេ សង្ខារា : សង្ខារទាំងពួង**" ដែលបានឃើញដោយអាការមិនទៀងនោះៗឯង។ ពាក្យថា ឯស មគ្គោ វិសុទ្ធិយា **(នេះជាផ្លូវនៃសេចក្ដីបរិសុទ្ធិ)** សេចក្ដីថា នេះគឺជាធម៌ ពោលគឺនិព្វិទានុបស្សនា ជាហេតុនៃធម៌ទាំងឡាយមានវិរាគៈជាដើម ជាឧបាយសម្រេចព្រះនិព្វាន ។

*ក្នុងគម្ពីរវិសុទ្ធិមគ្គ ៖*

*ត្រង់កន្លែងខ្លះ ព្រះអង្គសម្តែងដោយអំណាចនៃឈាន និង បញ្ញា ។ ដូចទ្រង់សម្តែងថា ៖*

"យម្ហិ ឈានញ្ច បញ្ញា ច, ស វេ និព្វានសន្តិកេ"

*ឈាននិងប្រាជ្ញា មានក្នុងបុគ្គលណា បុគ្គលនោះឯង ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន ។*

*ត្រង់កន្លែងខ្លះ ព្រះអង្គសម្តែងដោយអំណាចនៃគុណជាតមាន កម្មជាដើម ។ ដូចទ្រង់សម្តែងថា ៖*

"កម្មំ វិជ្ជា ច ធម្មោ ច សីលំ ជីវិតមុត្តមំ

ឯតេន មច្ចា សុជ្ឈន្តិ ន គោត្តេន ធនេន វា"

*សត្វទាំងឡាយ រមែងបរិសុទ្ធដោយគុណជាតនេះ គឺ កម្ម ១ វិជ្ជា ១ ធម្ម ១ សីល ១ ជីវិតដ៏ឧត្តម ១ មិនមែនបរិសុទ្ធ ដោយគោត្រ ឬដោយទ្រព្យទេ ។*

*ត្រង់កន្លែងខ្លះ ព្រះអង្គសម្តែងដោយអំណាចនៃគុណមាន សីលជាដើម ។ ដូចទ្រង់សម្តែងថា ៖*

"សព្វទា សីលសម្បន្នោ បញ្ញវា សុសមាហិតោ

អារទ្ធវីរិយោ បហិតត្តោ ឱឃំ តរតិ ទុត្តរំ" ។

បុគ្គលបរិបូរណ៍ដោយសីលសព្វកាល មានបញ្ញា មានចិត្តតាំងមាំប្រពៃ មានព្យាយាមប្រារព្ធហើយ មានខ្លួន (ចិត្ត) បញ្ជូនទៅហើយ រមែងឆ្លងនូវឱឃៈ (ជំនន់កិលេស) ដែលគេឆ្លងបានដោយកម្រ ។

ត្រង់កន្លែងខ្លះ ដោយអំណាចនៃសតិប្បដ្ឋានជាដើម ។ ដូចទ្រង់សម្តែងថា ៖

"ឯកាយនោ អយំ, ភិក្ខវេ, មគ្គោ សត្តានំ វិសុទ្ធិយា ។បេ។ និព្វានស្ស សច្ឆិកិរិយាយ, យទិទំ ចត្តារោ សតិបដ្ឋានា" ម្នាលភិក្ខុទាំងឡាយ ផ្លូវគឺសតិប្បដ្ឋានទាំង ៤ នេះ ជាផ្លូវមូលតែមួយ (ប្រព្រឹត្តទៅ) ដើម្បីសេចក្តីបរិសុទ្ធនៃសត្វទាំងឡាយ ។ល។ ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

សូម្បីក្នុងធម៌ទាំងឡាយ មានសម្មប្បធានជាដើម ក៏ន័យនេះឯង ។ ឯផ្លូវព្រះនិព្វានក្នុងបញ្ហាព្យាករណ៍នេះ ព្រះមានព្រះភាគទ្រង់សម្តែងហើយ ដោយអំណាចនៃគុណមានសីលជាដើម ។ នេះជាការពណ៌នាដោយសង្ខេប ក្នុងបញ្ហាព្យាករណ៍នោះ ។

ក្នុងដីកា បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖

ពាក្យថា ឈានបញ្ញាវសេន (ដោយអំណាចឈាន និង

បញ្ញា) សេចក្តីថា ដោយអំណាចសមថៈនិងវិបស្សនា ។ ពាក្យថា **ឈាន** នេះ ទ្រង់ប្រាថ្នាយកឈានដែលជាបាទនៃវិបស្សនា ។ បទថា **យម្ហិ** សេចក្តីស្មើគ្នា **យស្មឹ** ប្រកប **បុគ្គលេ** ប្រែថា ក្នុងបុគ្គលណា ។ ពាក្យថា ឈានញ្ច បញ្ញា ច (ឈាននិងបញ្ញា) នេះ មានសេចក្តីដូច្នេះថា បុគ្គលណាធ្វើឈានឲ្យជាបាទ ផ្តើមវិបស្សនា ហើយធ្វើវិបស្សនានោះ ឲ្យឈានទៅមុខ ។ ពាក្យថា ស វេ និព្វានសន្តិកេ **(បុគ្គលនោះឯង ឈ្មោះថា បិតនៅក្នុងទីជិតនៃព្រះនិព្វាន)** សេចក្តីថា បុគ្គលនោះ រមែងជិតនិព្វានដោយវិសេស គឺរមែងសម្រេចព្រះនិព្វានដោយចំណែកមួយ ។

ពាក្យថា **កម្មំ** បានដល់ មគ្គចេតនា ។ ព្រោះថា មគ្គចេតនានោះ រមែងនាំមកនូវសេចក្តីបរិសុទ្ធដល់សត្វទាំងឡាយ ព្រោះជាអបចយគាមីធម៌ (ធម៌ជាហេតុឲ្យដល់និព្វាន) ។ ពាក្យថា **វិជ្ជា** បានដល់ សម្មាទិដ្ឋិ ។ ពាក្យថា **សីល** បានដល់ សម្មាវាចា សម្មាកម្មន្តៈ ។ ពាក្យថា **ជីវិតមុត្តមំ** បានដល់ សម្មាអាជីវៈ ។ ពាក្យថា **ធម្ម** បានដល់ ធម៌គឺអរិយមគ្គ ៤ ដ៏សេស ។

ម្យ៉ាងទៀត ពាក្យថា **កម្មំ** លោកកាន់យកសម្មាកម្មន្តៈ ។ ព្រោះបាលីថា **"យា ចាវុសោ វិសាខ, សម្មាទិដ្ឋិ, យោ ច សម្មាសង្កប្បោ, ឥមេ ធម្មា បញ្ញាក្ខន្ធេ សង្គហិតា :**

ម្នាលអាវុសោវិសាខៈ សម្មាទិដ្ឋិណា និងសម្មាសង្កប្បៈណា ធម៌ទាំងនេះសង្គ្រោះចូលក្នុងបញ្ញាខន្ធ” ដូច្នេះ ។ ពាក្យថា **វិជ្ជា** លោកកាន់យកសម្មាទិដ្ឋិ និងសម្មាសង្កប្បៈ ។ ពាក្យថា **ធម៌** បានដល់សមាធិ ដូចក្នុងពាក្យថា “**ឯវំ ធម្មា តេ ភគវន្តោ អហេសុំ** : ព្រះមានព្រះភាគទាំងនោះ ទ្រង់មានធម៌ (សមាធិ) យ៉ាងនេះ” បានមានហើយយ៉ាងនេះជាដើម ។ ដោយស័ព្ទថា សមាធិនោះៗឯងគប្បីឃើញការកាន់យកសូម្បីសម្មាវាយាមៈ និងសម្មាសតិផង ព្រោះមានព្រះបាលីថា “**យោ ចាវុសោ វិសាខ, សម្មាវាយាមោ, យា ច សម្មាសតិ, យោ ច សម្មាសមាធិ, ឥមេ ធម្មា សមាធិក្ខន្ធេ សង្គហិតា** : ម្នាលអាវុសោវិសាខៈ **សម្មាវាយាមណា** និង **សម្មាសតិណា** ធម៌ទាំងនេះសង្គ្រោះចូលក្នុងសមាធិខន្ធ” ដូច្នេះ ។

ពាក្យថា **សីល** គប្បីឃើញលោកកាន់យកសូម្បីសម្មាវាចា និងសម្មាអាជីវៈ ។ ពាក្យថា **ជីវិតមុត្តមំ** អធិប្បាយថា អរិយមគ្គមានអង្គ ៨ គប្បីជ្រាបថា លោកពោលទុកក្នុងពាក្យថា **ជីវិតឧត្តម** នេះ យ៉ាងនេះថា ជីវិតរបស់ព្រះអរិយបុគ្គលបែបនេះ ជាជីវិតឧត្តម។

ពាក្យថា សីលាទិវសេន (ដោយអំណាចសីលជាដើម) គឺដោយអំណាចសីល សមាធិ បញ្ញា និងវិរិយៈ ។ ពាក្យថា **សព្វទា** (សព្វកាល) គឺរហូតកាលទាំងពួង ចាប់ដើមតាំងពីសមាទាន ។

ពាក្យថា សីលសម្បន្នោ (បរិបូរណ៍ដោយសីល) គឺបរិបូរណ៍ បានដល់ ដល់ព្រមដោយចតុបារិសុទ្ធិសីលសម្បទា ។ ពាក្យថា បញ្ញវា (មានបញ្ញា) គឺប្រកបដោយបញ្ញាដែលជាលោកិយៈ និង លោកុត្តរៈ ។ ពាក្យថា សុសមាហិតោ **(មានចិត្តតាំងមាំប្រពៃ)** គឺមានចិត្តតាំងមាំហើយដោយល្អ ដោយសមាធិដែលសម្បយុត្ត ដោយបញ្ញានោះ ។

ពាក្យថា អារទ្ធវីរិយោ **(មានព្យាយាមប្រារព្ធហើយ)** គឺ មានព្យាយាមដែលផ្គងហើយ ដើម្បីការលះអកុសលធម៌ ដើម្បីការ ញុំាងកុសលធម៌ ឲ្យចូលទៅដល់ព្រម ។ ពាក្យថា បហិតត្តោ (មានខ្លួនបញ្ជូនទៅហើយ) គឺមានចិត្តមិនសម្លឹងក្នុងកាយនិងជីវិត ព្រោះភាពជាអ្នកមានខ្លួនដែលបញ្ជូនទៅចំពោះកាន់និព្វាន ។ ពាក្យ ថា ឱឃំ (ឱឃៈ) បានដល់ ឱឃៈទាំង ៤ យ៉ាង មានកាមោឃៈ ជាដើម ឬបានដល់ ឱឃៈធំ គឺសង្សារនោះឯង ។

ពាក្យថា ឯកាយនោ **(ជាផ្លូវមូលតែមួយ)** គឺផ្លូវឯក ។ មែនពិត **អយនសព្ទ**ក្នុងទីនេះ ជាបរិយាយរបស់ **មគ្គ** គឺប្រែថា ផ្លូវ ព្រោះហេតុនោះ ទើបមានសេចក្តីថា ម្នាលភិក្ខុទាំងឡាយ ផ្លូវនេះ ជាផ្លូវឯក គឺមិនមែនផ្លូវបែកជាពីរ ។ម្យ៉ាងទៀត មានអត្ថវិគ្រោះថា ឈ្មោះថា **ឯកាយន** ព្រោះអត្ថថា **ដល់** គឺទៅកាន់ធម៌ឯក បានដល់

និព្វាន,ម្យ៉ាងទៀត ឈ្មោះថា **ឯកាយន** ព្រោះអត្ថថា **ដែលបុគ្គលតែម្នាក់** គឺអ្នកលះការច្រឡូកច្រឡំដោយពួកចេញហើយ គឺអ្នកប្រាថ្នាគប្បីដល់ គឺគប្បីបដិបត្តិ, ម្យ៉ាងទៀត ធម៌ឈ្មោះថា **អយន** ព្រោះអត្ថថា **ជាគ្រឿងដល់**, ធម៌ជាគ្រឿងដល់របស់ព្រះទ្រង់ជាឯក គឺអ្នកប្រសើរបំផុត បានដល់ ព្រះមានព្រះភាគ ព្រោះភាពជាធម៌ដែលព្រះអង្គទ្រង់ឲ្យកើតឡើង ហេតុនោះ ទើបឈ្មោះថា **ឯកាយន**, ម្យ៉ាងទៀត **ធម៌ជាគ្រឿងដល់ក្នុងធម៌ដែលឯក** គឺក្នុងព្រះធម៌វិន័យនេះប៉ុណ្ណោះ ហេតុនោះ ទើបឈ្មោះថា **ឯកាយន** ។

ពាក្យថា សត្តានំ វិសុទ្ធិយា (ដើម្បីសេចក្ដីបរិសុទ្ធនៃសត្វទាំងឡាយ) គឺដើម្បីប្រយោជន៍ដល់សេចក្ដីបរិសុទ្ធ បានដល់ គឺដើម្បីប្រយោជន៍ដល់សេចក្ដីបរិសុទ្ធនៃសត្វទាំងឡាយ ចាកមន្ទិល គឺកិលេសមានរាគៈជាដើម និងចាកឧបក្កិលេស មានអភិជ្ឈាវិសមលោភជាដើម ។ បទថា យទិទំ ជានិបាត សេចក្ដីស្មើគ្នា **យេ ឥមេ** ។ ព្រះមានព្រះភាគ ត្រាស់ថា "**ចត្តារោ សតិបដ្ឋានា**" ដូច្នេះ ព្រោះធម៌ដែលត្រាស់ថា មគ្គដោយលក្ខណៈព្រមទាំងកិច្ច ក្នុងកាលមុន និងដោយអត្ថថា ផ្លូវនោះឯង ជាធម៌មាន ៤ យ៉ាង ដោយសេចក្ដីផ្សេងនៃអារម្មណ៍ មានកាយជាដើម ។

ដោយអាទិស័ព្ទក្នុងបទថា សម្មប្បធានាទីសុ (ក្នុងធម៌ទាំង

ឡាយ មានសម្មប្បធានជាដើម គប្បីជ្រាបការសង្គ្រោះធម៌ទាំងឡាយ មានការត្រេកអរក្រៃលែងក្នុងសេចក្តីមិនប្រមាទជាដើម ។ មែនពិត ក្នុងទីកន្លែងខ្លះ ព្រះមានព្រះភាគ ក៏ទ្រង់សម្តែងវិសុទ្ធិមគ្គសូម្បីដោយអំណាចធម៌ មានការត្រេកអរក្នុងសេចក្តីមិនប្រមាទជាដើម ។ ដូចដែលទ្រង់ត្រាស់ទុកថា ៖

"អប្បមាទរតោ ភិក្ខុ បមាទេ ភយទស្សិ វា
អភព្វោ បរិហានាយ និព្វានស្សេវ សន្តិកេ ។

*ភិក្ខុអ្នកត្រេកអរក្នុងសេចក្តីមិនប្រមាទ ឬឃើញភ័យ ក្នុងសេចក្តីប្រមាទ ជាអ្នកមិនគួរនឹងសាបសូន្យចាកគុណធម៌ឈ្មោះថា ឋិតនៅក្នុងទីជិតនៃព្រះនិព្វាន" ដូច្នេះ ។*

**ក្នុងគម្ពីរវិសុទ្ធិមគ្គ** លោកពោលទុកទៀតថា ៖

ពាក្យថា **តាំងនៅស៊ប់ក្នុងសីលហើយ** មានសេចក្តីថាស្ថិតនៅហើយក្នុងសីល ។ ក៏ក្នុងបទនេះ នរជនដែលញ៉ាំងសីលឲ្យបរិបូរណ៍ ហៅថា តាំងនៅហើយក្នុងសីល ព្រោះហេតុនោះឈ្មោះថា ស្ថិតនៅស៊ប់ហើយក្នុងសីល ដោយកិរិយាញ៉ាំងសីលឲ្យបរិបូរណ៍ដូច្នេះ នេះជាសេចក្តីអធិប្បាយក្នុងបទនុ៎ះ ។ សត្វឈ្មោះថា **នរៈ** ។

ពាក្យថា **អ្នកប្រកបដោយបញ្ញា** បានសេចក្ដីថា អ្នកមានបញ្ញាដែលជាប់ដោយបដិសន្ធិ ប្រកបដោយត្រៃហេតុកើតអំពីកម្ម ។ ពាក្យថា **ចម្រើននូវចិត្តផង នូវបញ្ញាផង** មានសេចក្ដីថា ចម្រើននូវសមាធិផង វិបស្សនាផង ។ ព្រោះថា សមាធិក្នុងបញ្ហាព្យាករណ៍នេះ ព្រះអង្គទ្រង់សម្ដែងដោយប្រធាន គឺចិត្ត ចំណែកវិបស្សនាទ្រង់សម្ដែងដោយឈ្មោះ គឺបញ្ញា ។ នរជនមានសេចក្ដីប្រឹងប្រែងឈ្មោះថា មានអាតាបៈ គឺព្យាយាម ។ សេចក្ដីថា ព្យាយាមដែលព្រះមានព្រះភាគ ឲ្យឈ្មោះថា អាតាបៈ ដោយអត្ថថា ដុតកំទេចមិនឲ្យសេសសល់ និងដុតបំផ្លាញនូវកិលេសទាំងឡាយ សេចក្ដីព្យាយាមនោះ មានដល់ភិក្ខុនោះ ហេតុនោះ ភិក្ខុនោះ ឈ្មោះថា អាតាបៈ គឺព្យាយាម ។

ពាក្យថា **អ្នកមាននេបកៈ គឺបញ្ញាចាស់ក្លា** មានសេចក្ដីថា បញ្ញា លោកហៅថា **នេបកៈ** នរជនប្រកបដោយនេបកបញ្ញានោះឯង ។ ឯព្រះមានព្រះភាគ ទ្រង់សម្ដែងបារិហារិកបញ្ញា ដោយបទនេះ ។ ព្រោះបញ្ញា ក្នុងបញ្ហាព្យាករណ៍នេះ មកអស់វារៈ ៣ ដង ។

បណ្ដាបញ្ញា ៣ ដងនោះ បញ្ញាទី ១ ជា**សជាតិបញ្ញា** បញ្ញាទី ២ ជា**វិបស្សនាបញ្ញា** បញ្ញាទី ៣ ជា**បារិហារិកបញ្ញា** ជាបរិនាយិកាក្នុងកិច្ចទាំងអស់ ។

សំសារេ ភយំ ឥក្ខតីតិ **ភិក្ខុ** ។

ពាក្យថា **អ្នកឃើញភ័យក្នុងវដ្ដៈ** មានសេចក្ដីថា នរជនអ្នកឃើញភ័យក្នុងសង្សារ ឈ្មោះថា ភិក្ខុ ។

ពាក្យថា **នរជននោះ គប្បីត្រដោះនូវគ្រឿងចាក់ស្រេះ គឺតណ្ហាបាន** មានសេចក្ដីថា នរជននោះ ជាភិក្ខុប្រកបហើយដោយធម៌ទាំងឡាយ ៦ យ៉ាង គឺដោយសីលនេះ ១ ដោយសមាធិ ដែលព្រះអង្គសម្ដែងចេញហើយដោយប្រធានគឺចិត្តនេះ ១ ដោយបញ្ញា ៣ យ៉ាងនេះ ១ ដោយអាតាបៈ គឺសេចក្ដីព្យាយាមនេះ ១ ដូចជាបុរសឈរស៊ប់នៅលើផែនដី លើកឡើងនូវសស្ត្រាដែលខ្វនសំលៀងមុតហើយ គប្បីឆ្ការនូវឫស្សីដ៏ធំ (យ៉ាងណា ភិក្ខុនោះ) ស្ថិតនៅស៊ប់លើផែនដី គឺសីល លើកឡើងនូវសស្ត្រា គឺវិបស្សនាបញ្ញាដែលខ្វនសំលៀងមុតហើយដោយថ្ម គឺសមាធិ ដោយដៃ គឺបារិហារិកបញ្ញា ដែលខ្វនផ្គងហើយដោយកម្លាំងនៃសេចក្ដីព្យាយាម គប្បីកាប់ឆ្ការ គប្បីកាប់ចិញ្ច្រាំ គប្បីកាប់បំបែកនូវគ្រឿងចាក់ស្រេះ គឺតណ្ហានោះទាំងអស់ ដែលធ្លាក់ចុះក្នុងសន្ដាននៃខ្វនយ៉ាងនោះដែរ ។ ក៏ក្នុងខណៈនៃមគ្គ លោកឈ្មោះថា កំពុងត្រដោះគ្រឿងចាក់ស្រេះ គឺតណ្ហានោះ ។ លុះក្នុងខណៈនៃផល ឈ្មោះថា ជាអ្នកត្រដោះនូវគ្រឿងចាក់ស្រេះ គឺតណ្ហានោះបានហើយ រមែងឈ្មោះថា

ជាទក្ខិណេយ្យបុគ្គលដ៏ប្រសើររបស់លោក ព្រមទាំងទេវតា ។ ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់សម្តែងថា ៖

"នរជន មានប្រាជ្ញា បានតាំងមាំក្នុងសីលហើយ ចម្រើននូវសមាធិចិត្ត និងវិបស្សនាបញ្ញា ជាអ្នកមានព្យាយាមដុតកំដៅកិលេស ប្រកបដោយបាដិហារិយប្បញ្ញា ជាអ្នកឃើញភ័យក្នុងសង្សារ បុគ្គលនោះទើបកាប់ឆ្ការនូវតណ្ហាជាគ្រឿងចាក់ស្រេះនេះបាន" ដូច្នេះ ។

ក្នុងគាថានោះ នរជននេះ ដែលព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ប្រកបដោយបញ្ញាដូច្នេះ ដោយបញ្ញាណា កិច្ចដែលនរជននោះគប្បីធ្វើ មិនមានក្នុងបញ្ញានោះទេ ។ ព្រោះថា បញ្ញានោះសម្រេចហើយដល់បុគ្គលនោះ ដោយអានុភាពនៃកម្ម ដែលមានមកក្នុងកាលមុនតែម្យ៉ាង ។ ក៏នរជននោះ ដែលជាអ្នកធ្វើរឿយៗ និងជាអ្នកធ្វើនូវការជីងខ្លួនដោយអំណាចនៃវីរិយៈ និងដោយអំណាចនៃបញ្ញា ដែលព្រះអង្គទ្រង់សម្តែងត្រង់បទនេះថា អ្នកមានអាតាបៈ គឺសេចក្តីព្យាយាម មាននេបកៈ គឺបញ្ញាចាស់ក្លា ដូច្នេះ គប្បីប្រតិ-ស្ឋានក្នុងសីល ហើយចម្រើននូវសមថៈនិងវិបស្សនា ដែលព្រះអង្គទ្រង់សម្តែងដោយអំណាចនៃចិត្ត និងបញ្ញា ។ ក្នុងទីនោះ ព្រះមាន-ព្រះភាគ ទ្រង់សម្តែងនូវផ្លូវនៃព្រះនិព្វាននេះ ដោយប្រធាននៃសីល សមាធិ និង បញ្ញា ។

ក៏ដោយហេតុមានប្រមាណប៉ុណ្ណេះ សិក្ខា ៣, សាសនាមានលំអ ៣ យ៉ាង, ឧបនិស្ស័យនៃគុណទាំងឡាយ មានភាពនៃបុគ្គលបានវិជ្ជា ៣ ជាដើម, ការវៀរនូវប្រជុំពីរនៃផ្លូវអម និងកិរិយាសេពនូវមជ្ឈិមបដិបត្តិ, ឧបាយជាគ្រឿងប្រព្រឹត្តកន្លងនូវទុក្ខមានអបាយទុក្ខជាដើម, ការលះបង់នូវកិលេស ដោយអាការទាំង ៣ យ៉ាង, ធម៌ជាសត្រូវដល់ទោសទាំងឡាយ មានទោសព្រោះប្រព្រឹត្តកន្លងជាដើម, ការជម្រះនូវប្រជុំ ៣ នៃសង្កិលេស, ការធ្វើនូវភាពនៃបុគ្គល មានបុគ្គលជាសោតបន្នជាដើម, ឈ្មោះថា ជាគុណជាតដែលព្រះអង្គប្រកាសហើយ ។

ព្រោះហេតុអ្វី ? ព្រោះ**អធិសីលសិក្ខា** ព្រះអង្គទ្រង់ប្រកាសហើយដោយសីល **អធិចិត្តសិក្ខា** ព្រះអង្គទ្រង់ប្រកាសហើយដោយសមាធិ **អធិបញ្ញាសិក្ខា** ព្រះអង្គទ្រង់ប្រកាសហើយដោយបញ្ញា ក្នុងព្រះគាថានេះ ។

ម្យ៉ាងទៀត ភាវៈនៃសាសនា មានលំអក្នុងខាងដើម ព្រះអង្គទ្រង់ប្រកាសហើយដោយសីល ។ មែនពិត សីលជាខាងដើមនៃសាសនា ព្រោះព្រះបាលីថា “**កោ ចាទិ កុសលានំ ធម្មានំ, សីលញ្ច សុវិសុទ្ធំ** : ចុះអ្វីជាខាងដើមនៃធម៌ទាំងឡាយជាកុសល, បានដល់សីលដ៏បរិសុទ្ធស្អាតហ្មឹងឯងផង” ដូច្នេះ និងព្រោះមានព្រះពុទ្ធវចនៈថា “**សព្វបាបស្ស អករណំ** : កិរិយាមិនធ្វើនូវបាបទាំងពួង”

ជាដើម ។ សីលនោះឯងជាលំអ ព្រោះភាពនៃកិរិយានាំមកនូវគុណ មានកិរិយាមិនក្តៅក្រហាយជាដើម ។

ភាពនៃសាសនា មានលំអត្រង់កណ្តាល ព្រះអង្គទ្រង់ប្រកាសហើយដោយ**សមាធិ** ។ ព្រោះថា សមាធិ ជាលំអត្រង់កណ្តាលនៃសាសនា ព្រោះព្រះបាលីថា “**កុសលស្ស ឧបសម្បទា :** ការញ៉ាំងកុសលធម៌ឲ្យដល់ព្រម” ជាដើម ។ ម្យ៉ាងទៀត សមាធិនោះមានលំអ ព្រោះភាពនៃកិរិយានាំមកនូវគុណ មានឥទ្ធិវិធិ-ញាណ ជាដើម ។

ភាពនៃសាសនា មានលំអក្នុងទីបំផុត ព្រះអង្គទ្រង់ប្រកាសហើយដោយ**បញ្ញា** ។ ព្រោះថា បញ្ញា ជាលំអក្នុងទីបំផុតនៃសាសនា ព្រោះព្រះបាលីថា “**សចិត្តបរិយោទបនំ, ឯតំ ពុទ្ធាន សាសនំ :** ការជម្រះចិត្តរបស់ខ្លួនឲ្យផូរផង់ នោះជាពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ” ដូច្នេះ និងព្រោះមានបញ្ញាជាគុណខ្ពស់បំផុត ។ ម្យ៉ាងទៀត បញ្ញានោះជាលំអ ព្រោះភាពនៃកិរិយានាំមកនូវតាទិភាព (ភាពហ្នឹងធឹង) ក្នុងឥដ្ឋារម្មណ៍ និងអនិដ្ឋារម្មណ៍ទាំងឡាយ ។

សមពិតដូចជាពុទ្ធវចនៈ ដែលព្រះអង្គទ្រង់សម្តែងថា ៖

"សេលោ យថា ឯកឃនោ វាតេន ន សមីរតិ
ឯវំ និន្ទាបសំសាសុ ន សមិញ្ជន្តិ បណ្ឌិតា" ។

ដុំថ្មតាន់មួយដុំ រមែងមិនកម្រើកដោយខ្យល់ យ៉ាងណា បណ្ឌិតទាំងឡាយ រមែងមិនញាប់ញ័រ ក្នុងសេចក្ដីនិន្ទានិងសរសើរ ទាំងឡាយក៏យ៉ាងនោះដែរ ។

ឧបនិស្ស័យនៃភាពនៃបុគ្គលបានវិជ្ជា ៣ ព្រះអង្គទ្រង់ប្រកាស ហើយដោយសីលដូចគ្នា ។ មែនពិត មិនមែនបុគ្គលបានសម្រេច នូវវិជ្ជា ៣ ព្រោះអាស្រ័យធម៌ដទៃក្រៅអំពីសីលសម្បត្តិនោះទេ ។ ឧបនិស្ស័យនៃភាពជាអ្នកបានអភិញ្ញា ៦ ជាការដែលព្រះអង្គទ្រង់ ប្រកាសហើយដោយ**សមាធិ** ។ មែនពិត ភិក្ខុសម្រេចអភិញ្ញា ៦ បាន ព្រោះអាស្រ័យការដល់ព្រមនៃសមាធិ, មិនមែនសម្រេច អភិញ្ញា ៦ បាន ព្រោះអាស្រ័យធម៌ដទៃក្រៅអំពីសមាធិសម្បទា នោះទេ ។ ឧបនិស្ស័យនៃការបែកធ្លាយក្នុងបដិសម្ភិទា ជាការដែល ព្រះអង្គទ្រង់ប្រកាសហើយដោយ**បញ្ញា** ។ មែនពិត ភិក្ខុសម្រេច បដិសម្ភិទា ៤ បាន ព្រោះអាស្រ័យបញ្ញាសម្បត្តិ, មិនមែនសម្រេច បដិសម្ភិទា ៤ បាន ព្រោះអាស្រ័យហេតុដទៃ (ក្រៅអំពីបញ្ញា-សម្បត្តិនោះទេ) ។

ម្យ៉ាងទៀត ការវៀរនូវផ្លូវអមដែលហៅថា **កាមសុខល្លិកា-នុយោគ** គឺព្រះអង្គទ្រង់ប្រកាសទុកដោយ**សីល**, ការវៀរនូវ ផ្លូវអមដែលហៅថា **អត្តកិលមថានុយោគ** គឺព្រះអង្គទ្រង់ប្រកាស

ទុកដោយ**សមាធិ** ។ កិរិយាសេពនូវមជ្ឈិមាបដិបត្តិ ជាការដែលព្រះអង្គទ្រង់ប្រកាសទុកដោយ**បញ្ញា** ។

យ៉ាងនោះដូចគ្នា ឧបាយជាគ្រឿងប្រព្រឹត្តកន្លងអបាយ ជាការដែលព្រះអង្គទ្រង់ប្រកាសទុកដោយ**សីល**, ឧបាយជាគ្រឿងប្រព្រឹត្តកន្លងកាមធាតុ ជាការដែលព្រះអង្គទ្រង់ប្រកាសទុកដោយ**សមាធិ**, ឧបាយជាគ្រឿងប្រព្រឹត្តកន្លងកាមភពទាំងពួង ជាការដែលព្រះអង្គទ្រង់ប្រកាសទុកដោយ**បញ្ញា** ។

ម្យ៉ាងទៀត ការលះបង់កិលេស ដោយអំណាចតទង្គប្បហាន ជាការដែលព្រះអង្គទ្រង់ប្រកាសទុកដោយ**សីល**, ការលះបង់កិលេសដោយអំណាចវិក្ខម្ភនប្បហាន ជាការដែលព្រះអង្គទ្រង់ប្រកាសទុកដោយ**សមាធិ**, ការលះបង់កិលេស ដោយអំណាចសមុច្ឆេទប្បហាន ជាការដែលព្រះអង្គទ្រង់ប្រកាសទុកដោយ**បញ្ញា** ។

យ៉ាងនោះដូចគ្នា ធម៌ដែលជាបដិបក្ខចំពោះវីតិក្កមៈ (ការប្រព្រឹត្តកន្លង) នៃកិលេសទាំងឡាយ ជាការដែលព្រះអង្គ ទ្រង់ប្រកាសទុកដោយ**សីល**, ធម៌ដែលជាបដិបក្ខចំពោះបរិយុដ្ឋានៈ ជាការដែលព្រះអង្គទ្រង់ប្រកាសទុកដោយ**សមាធិ**, ធម៌ដែលជាបដិបក្ខចំពោះអនុស័យ ជាការដែលព្រះអង្គទ្រង់ប្រកាសទុកដោយ**បញ្ញា** ។

ម្យ៉ាងទៀត ការជម្រះសង្កិលេសគឺទុច្ចរិត ជាការដែលទ្រង់ប្រកាសទុកដោយ**សីល**, ការជម្រះសង្កិលេសគឺតណ្ហា ជាការដែល

ទ្រង់ប្រកាសទុកដោយ**សមាធិ**, ការជម្រះសន្តិលេសគឺទិដ្ឋិ ជាការដែលទ្រង់ប្រកាសទុកដោយ**បញ្ញា** ។

យ៉ាងនោះដូចគ្នា ហេតុនៃភាពជាសោតបន្ន និងសកទាគាមី ជាការដែលទ្រង់ប្រកាសទុកដោយ**សីល**, ហេតុនៃភាពជាអនាគាមី ជាការដែលទ្រង់ប្រកាសទុកដោយ**សមាធិ**, ហេតុនៃភាពជាព្រះ-អរហន្ត ជាការដែលទ្រង់ប្រកាសទុកដោយ**បញ្ញា** ។ មែនពិត ព្រះសោតាបន្ន គឺទ្រង់ត្រាស់ថា "**សីលេសុ បរិបូរការី** : ជាអ្នកធ្វើឲ្យបរិបូរណ៌ក្នុងសីលទាំងឡាយ", ព្រះសកទាគាមី ក៏ទ្រង់ត្រាស់យ៉ាងនោះដូចគ្នា ។ តែព្រះអនាគាមី គឺទ្រង់ត្រាស់ថា "**សមាធិស្មឹ បរិបូរការី** : ជាអ្នកធ្វើឲ្យបរិបូរណ៌ក្នុងសមាធិ" ។ ចំណែកព្រះអរហន្ត គឺទ្រង់ត្រាស់ថា "**បញ្ញាយ បរិបូរការី** : ជាអ្នកធ្វើឲ្យបរិបូរណ៌ក្នុងបញ្ញា" ។

ដោយព្រះទេសនាត្រឹមប៉ុណ្ណេះ ជាការដែលព្រះមានព្រះភាគទ្រង់ប្រកាសគុណ ៩ ប្រការទាំងនេះគឺ សិក្ខា ៣, ព្រះសាសនាមានលំអ ៣ យ៉ាង, ឧបនិស្ស័យនៃគុណវិសេស មានភាពជាអ្នកបានវិជ្ជា ៣ ជាដើម, ការវៀរនូវផ្លូវអម ២ និងកិរិយាសេពនូវមជ្ឈិមបដិបត្តិ, ឧបាយជាគ្រឿងប្រព្រឹត្តកន្លងអបាយជាដើម, ការលះបង់នូវកិលេសដោយអាការទាំង ៣ យ៉ាង, ធម៌ជាបដិបក្ខចំពោះវីតិក្កមកិលេសជាដើម, ការជម្រះសន្តិលេស ៣ យ៉ាង, និង

ហេតុនៃភាពជាអរិយបុគ្គល មានព្រះសោតបន្នជាដើម, ដោយប្រការដូចពោលហើយនេះ និងគុណពួក ៣ ដទៃទៀត ដែលមានសភាពដូចគ្នា ជាការដែលទ្រង់ប្រកាសហើយ ។

ក្នុងដីកា បរមត្ថមញ្ជូសា ភាគ១ លោកពន្យល់ទុកថា ៖

*សីល* ជាហេតុនៃការរួចផុតចាកអបាយទាំងឡាយ ៤ ព្រោះញ៉ាំងបុគ្គលអ្នកមានសេចក្តីព្រមព្រៀងដោយសីលនោះ ឲ្យកើតក្នុងកាមសុគតិភពប៉ុណ្ណោះ ហេតុនោះ លោកអាចារ្យទើបពោលថា "រមែងជាការប្រកាសឧបាយជាគ្រឿងឈានកន្លងអបាយ ដោយសីល" ដូច្នេះ ពិតមែន ការលះបង់បាបកម្ម មានបាណាតិបាតជាដើម រមែងមិននាំមកនូវសេចក្តីសៅហ្មងក្នុងទុគ្គតិ រមែងញ៉ាំងបុគ្គលឲ្យផុតចាកកាមភពទាំងអស់ ដោយការញ៉ាំងបុគ្គលអ្នកមានសេចក្តីដល់ព្រមដោយសមាធិនោះ ឲ្យកើតក្នុងមហគ្គតភូមិនោះឯងហេតុនោះ លោកអាចារ្យទើបពោលថា រមែងជាការប្រកាសឧបាយជាគ្រឿងឈានកន្លងកាមធាតុដោយសមាធិ ដូច្នេះ ។ មែនពិតឈានដែលរារាំងនីវរណធម៌មានកាមឆន្ទៈជាដើម ដែលបំពេញកម្លាំងឲ្យដល់កាមាវចរកម្ម រមែងមិនជាធម្មជាតិនាំសេចក្តីសៅហ្មងក្នុងកាមធាតុមកឲ្យ ។ ក៏ក្នុងសេចក្តីនេះ មិនគប្បីសម្តែងដល់ឧបចារឈាន ព្រោះលោកប្រាថ្នាយកអប្បនាសមាធិ ។ ទាំងមិនមែនជាឱកាសក្នុងការនិយាយថា "សេចក្តីដែលអបាយភព គប្បីកន្លងបង់

ដោយសីលប៉ុណ្ណោះ គប្បីកន្លងបង់បានដោយសមាធិ” ដូច្នេះ ។ អ្នកឈានកន្លងសូម្បីសុគតិភពបានហើយ នឹងបាច់និយាយទៅថ្វី ដល់ការឈានកន្លងទុគ្គតិឡើយ ។ ពាក្យថា **ឧបាយជាគ្រឿងឈានកន្លងភពទាំងពួង** បានដល់ ឧបាយជាគ្រឿងឈានកន្លងភពទាំង ៩ មានកាមភពជាដើម ។ ភពទាំងឡាយសូម្បីឈានកន្លងហើយដោយសីល និងសមាធិ ក៏នៅមិនទាន់ជាការឈានកន្លងនោះឯង ព្រោះនៅលះបង់ហេតុមិនទាន់បាន ។ តែភពទាំងនោះ ជាការឈានកន្លងពិត ព្រោះលះបង់ហេតុនោះបានយ៉ាងល្អ ដោយបញ្ញា ។

ពាក្យថា **ការលះបង់កិលេសដោយអំណាចតទង្គប្បហាន** សេចក្តីថា ដោយអំណាចលះអង្គនៃអកុសលនោះៗ ដោយអង្គនៃកុសលនោះៗ ដែលទៅក្នុងបុញ្ញកិរិយាវត្ថុ ដូចលះសេចក្តីងងឹតបានដោយពន្លឺនៃប្រទីប ដូច្នោះ ។ ពាក្យថា **ការលះបង់កិលេស ដោយអំណាចវិក្ខម្ភនប្បហាន** ជាការដែលទ្រង់ប្រកាសទុកដោយសមាធិ សេចក្តីថា ការលះបង់កិលេសដោយអំណាចលះនីវរណធម៌នោះៗ ដោយការហាមការប្រព្រឹត្តិទៅ ដូចជាការហាមនូវចកសារាយដែលនៅលើផ្ទៃទឹក ដោយការប្រើឆ្នាំងបណ្តែតទៅ ជាការដែលព្រះអង្គទ្រង់ប្រកាសទុកដោយសមាធិ ដែលផ្សេងដោយឧបចារៈ និងអប្បនា ។ ពាក្យថា **ដោយបញ្ញា** បានដល់ ដោយអរិយមគ្គបញ្ញា ។

ពាក្យថា **ដោយអំណាចសមុច្ឆេទប្បហាន** សេចក្ដីថា ដោយអំណាចការលះបង់កាត់ផ្ដាច់ ពោលគឺមិនប្រព្រឹត្តទៅយ៉ាងពិតប្រាកដរបស់ពួកកិលេស ដែលចាត់នៅក្នុងផ្នែកនៃសមុទ័យ ដូចដែលទ្រង់ត្រាស់ទុកដោយន័យថា "ដើម្បីលះទិដ្ឋិ" ជាដើម ក្នុងសន្ដានរបស់ខ្លួនរបស់បុគ្គលដែលមានមគ្គនោះៗ, ព្រោះបានញ៉ាំងអរិយមគ្គ ៤ ឲ្យកើតឡើងហើយ ។

ពាក្យថា **ធម៌ដែលជាបដិបក្ខចំពោះវីតិក្កមកិលេស** សេចក្ដីថា ធម៌ដែលជាបដិបក្ខចំពោះវីតិក្កមៈ គឺការប្រព្រឹត្តកន្លងផ្លូវកាយទ្វារ និងវចីទ្វារ នៃសង្កិលេសធម៌ ឬកម្មកិលេសទាំងឡាយ រមែងជាការដែលព្រះអង្គទ្រង់ប្រកាសហើយដោយ**សីល**, ព្រោះសីលមានសភាវៈមិនប្រព្រឹត្តកន្លង ។ កិលេសតាំងឡើង គ្របសង្កត់ការប្រព្រឹត្តិទៅនៃកុសលក្នុងចិត្ត ដោយអំណាចការមិនឲ្យឱកាសឈ្មោះថា **បរិយុដ្ឋានៈ** ។ សមាធិ រមែងសង្កត់សង្កិនបរិយុដ្ឋានៈនោះដូច្នោះ លោកទើបពោលថា "ធម៌ដែលជាបដិបក្ខចំពោះបរិយុដ្ឋានៈ រមែងជាការដែលទ្រង់ប្រកាសហើយដោយ**សមាធិ**, ព្រោះសមាធិ ជាធម៌លះបរិយុដ្ឋានៈ ។ កិលេសដែលដេកនៅរឿយៗ ក្នុងសន្ដាន ព្រោះនៅលះមិនបាន កាលបានហេតុគួរដល់ការកើតឡើង ឈ្មោះថា អនុស័យ, ក៏អនុស័យពួកនោះ បានហេតុដែលសមគួរហើយ ក៏គួរនឹងកើតឡើង គប្បីជ្រាបថា បានដល់

កិលេស ៧ មានកាមរាគៈជាដើមដែលខ្លាំងក្លា ។ កិលេសទាំងនោះដែលលះបានដោយប្រការទាំងពួង ក៏ដោយអរិយមគ្គបញ្ញា ដូច្នោះលោកទើបពោលថា "ធម៌ដែលជាបដិបក្ខចំពោះអនុស័យ រមែងជាការដែលទ្រង់ប្រកាសហើយដោយបញ្ញា" ។

ធម្មជាតិ ឈ្មោះថា **ទុច្ចរិត** ព្រោះអត្ថថា ការប្រព្រឹត្តិអាក្រក់មានកាយទុច្ចរិតជាដើម, ឬការប្រព្រឹត្តិដែលត្រូវកិលេសប្រទូស-រ៉ាយហើយ, ទុច្ចរិតនោះនុ៎ះឯង កើតឡើងក្នុងសន្តានបុគ្គលណា, ក៏ធ្វើសន្តាន (របស់បុគ្គល) នោះ ឲ្យសៅហ្មង គឺឲ្យលំបាក, និងចូលទៅកាន់សេចក្ដីក្ដៅក្រហាយ ដូច្នោះទើបឈ្មោះថា សង្កិលេស, ការជម្រះសង្កិលេសនោះ គឺការលះដោយអំណាចតទង្គប្បហានដោយសីល ព្រោះសីលជាបដិបក្ខចំពោះសេចក្ដីសៅហ្មង ។ ការជម្រះសង្កិលេស គឺតណ្ហា គឺលះដោយអំណាចវិក្ខម្ភនប្បហាន ព្រោះសមាធិ ជាបដិបក្ខចំពោះបរិយុដ្ឋានៈ, និងព្រោះសមាធិនោះក៏ជាបដិបក្ខដោយត្រង់ចំពោះតណ្ហា ។ ការជម្រះសង្កិលេស គឺទិដ្ឋិ គឺលះដោយអំណាចសមុច្ឆេទប្បហាន ព្រោះបញ្ញា ជាបដិបក្ខចំពោះអនុស័យ និងព្រោះបញ្ញាមានប្រក្រតីកាន់យកតាមសេចក្ដីពិត ដែលជាបដិបក្ខដោយត្រង់ចំពោះទិដ្ឋិ ដែលមានប្រក្រតីកាន់យកតាមសេចក្ដីដែលមិនពិត ។

ពាក្យថា **ហេតុ** គឺ ឧបនិស្សយបច្ច័យ ។ ពាក្យថា **ជាអ្នកធ្វើឲ្យបរិបូរណ៍ក្នុងសីលទាំងឡាយ** សេចក្តីថា ព្រោះលោកមិនប្រព្រឹត្តកន្លងសិក្ខាបទដែលជាមហាសីល ពោលគឺបារាជិក និងសង្ឃាទិ-សេស ដែលជាអាទិព្រហ្មចរិយកសិក្ខា ព្រោះជាខាងដើមរបស់មគ្គព្រហ្មចរិយ កាលលោកត្រូវអាបត្តិតូចៗ កិច្ចណាដែលគប្បីធ្វើក្នុងសីលទាំងឡាយ ដោយការចេញចាកអាបត្តិតូចៗ ទាំងនោះភ្លាមៗ លោករមែងធ្វើកិច្ចនោះឲ្យបរិបូរណ៍ គឺឲ្យគ្រប់ ព្រោះហេតុនោះ ទើបឈ្មោះថា ជាអ្នកធ្វើឲ្យបរិបូរណ៍ក្នុងសីលទាំងឡាយ ។ ដោយ **តថាស័ព្ទ** ក្នុងពាក្យថា តថា សកទាគាមី រមែងលើកពាក្យនេះថា "សីលេសុ បរិបូរីការី" មក ។

ក៏ព្រះអរិយៈ ២ ជំពូកនេះ សូម្បីកាលចម្រើនសមាធិ និងបញ្ញា ព្រោះហេតុដែលលោកដកចេញមិនទាន់បានដោយប្រការទាំងពួងនូវកាមរាគៈ និងព្យាបាទៈ ដែលជាអន្តរាយចំពោះសមាធិ, និងមោហៈ បិទបាំងសច្ចៈ ដែលជាអន្តរាយដល់បញ្ញា ក៏រមែងធ្វើកិច្ចដែលគប្បីធ្វើក្នុងសមាធិនិងបញ្ញា តែល្មមប្រមាណត្រឹមតែចំណែកខ្លះប៉ុណ្ណោះ ដូច្នោះ អ្នកមានប្រក្រតីធ្វើដោយប្រមាណក្នុងសមាធិនិងបញ្ញា លោកក៏ហៅថា (ជាអ្នកមានប្រក្រតីធ្វើឲ្យបរិបូរណ៍ក្នុងសីលទាំងឡាយ) ដូចគ្នា ។ ចំណែកព្រះអនាគាមី ឈ្មោះថា

មានប្រក្រតីធ្វើឲ្យបរិបូរណ៍ក្នុងសមាធិ ព្រោះដកកាមរាគៈ និងព្យាបាទៈ បានដាច់ស្រឡះហើយ ។ ព្រះអរហន្ត ឈ្មោះថា ធ្វើឲ្យបរិបូរណ៍ហើយក្នុងបញ្ញា ព្រោះដកសម្មោហៈ បានដាច់ស្រឡះហើយដោយប្រការទាំងពួង ។

សមពិត ដូចព្រះមានព្រះភាគ ត្រាស់ថា ៖

“ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ជាអ្នកធ្វើឲ្យបរិបូរណ៍ក្នុងសីល, ជាអ្នកធ្វើល្មមប្រមាណក្នុងសមាធិ, ជាអ្នកធ្វើល្មមប្រមាណក្នុងបញ្ញា ។ លោករមែងប្រព្រឹត្តកន្លងសិក្ខាបទខ្លះ រមែងចេញចាកអាបត្តិខ្លះ ។ សេចក្ដីនោះ ព្រោះហេតុអ្វី ? ម្នាលភិក្ខុទាំងឡាយ ព្រោះមិនមាននរណាពោលសេចក្ដីជាមនុស្សអភព្វ ព្រោះការកន្លងសិក្ខាបទនេះ ។ តែថា សិក្ខាបទទាំងនោះ ជាខាងដើមនៃព្រហ្មចរិយៈ សមគួរដល់ព្រហ្មចរិយៈ លោកជាអ្នកមានសីលជានិច្ច និងជាអ្នកមានសីលមាំទាំ ក្នុងសិក្ខាបទទាំងនោះ, សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ។ លោកជាសោតាបន្ន ព្រោះសំយោជនៈ ៣ អស់ទៅ ជាអ្នកមានសេចក្ដីមិនធ្លាក់ចុះជាធម្មតា ជាអ្នកទៀងនឹងត្រាស់ដឹងក្នុងខាងមុខ ។ល។

(ចាកដីកា បរមត្ថមញ្ជុសា ភាគ១)

# ១, សីលនិទ្ទេស

## សីលសង្ខាធិកថា

១–កឹ សីលំ, *អ្វីឈ្មោះថា សីល ?*

២–កេនដ្ឋេន សីលំ, *សីលដោយអត្ថថា ដូចម្ដេច ?*

៣–កានស្ស លក្ខណរសបច្ចុបដ្ឋានបទដ្ឋានានិ, *លក្ខណៈ កិច្ច អាការប្រាកដឡើង (ផល) និងអាសន្នហេតុ (ហេតុជិតកៀកផ្ទាល់) សីលនោះ ដូចម្ដេច ?*

៤–កិមានិសំសំ សីលំ, *សីលមានអានិសង្សដូចម្ដេច ?*

៥–កតិវិធំ ចេតំ សីលំ, *ចុះសីលនោះ មានប្រការៈប៉ុន្មានយ៉ាង ?*

៦–កោ ចស្ស សំកិលេសោ, *ចុះអ្វីជាគ្រឿងសៅហ្មងរបស់សីល ?*

៧–កឹ វោទានន្តិ, *អ្វីជាគ្រឿងផូរផង់របស់សីល ?*

# វិស្សជ្ជនាបញ្ហាកម្ម ទី១

១-កឹ សីលំ, អ្វីឈ្មោះថា សីល ?

ឆ្លើយថា ចាណាតិចាតាទីហិ វា វិរមន្តស្ស វត្តប្ប-ដិបត្តឹ វា បូរេន្តស្ស ចេតនាទយោ ធម្មា ។ **ធម៌ទាំងឡាយ**មានចេតនាជាដើម របស់បុគ្គលកាលវៀរចាកទោសទាំងឡាយ មានបាណាតិបាតជាដើមក្ដី កំពុងបំពេញនូវវត្តបដិបត្តិ (មានឧបជ្ឈាយវត្តជាដើម) ក្ដី ។

សមដូចពាក្យដែលព្រះសារីបុត្រពោលហើយ ក្នុងគម្ពីរបដិ-សម្ភិទាមគ្គថា អ្វីឈ្មោះថាសីល ? ចេតនា ឈ្មោះថា **សីល**, ចេតសិក ឈ្មោះថា **សីល**, សេចក្ដីសង្រួម ឈ្មោះថា **សីល**, កិរិយាមិនប្រព្រឹត្តកន្លង ឈ្មោះថា **សីល** ។

- បណ្ដាសីលទាំងនោះ **ចេតនា**របស់បុគ្គលកំពុងវៀរចាកទោសទាំងឡាយ មានបាណាតិបាតជាដើមក្ដី ចេតនារបស់បុគ្គលកំពុងបំពេញវត្តបដិបត្តិក្ដី ឈ្មោះថា **ចេតនាសីល** ។

- **វិរតិ**របស់បុគ្គលកំពុងវៀរចាកទោសទាំងឡាយ មានបាណាតិបាតជាដើម ឈ្មោះថា **ចេតសិកសីល** ។

ម្យ៉ាងទៀត **ចេតនាក្នុងកម្មបថ** ៧ របស់បុគ្គលកំពុងលះបង់នូវទោសទាំងឡាយ មានបាណាតិបាតជាដើម ឈ្មោះថា **ចេតនាសីល** ។

ធម៌ទាំងឡាយ គឺអនភិជ្ឈា អព្យាបាទ និងសម្មាទិដ្ឋិ ដែលលោកពោលហើយដោយន័យមានដូច្នេះជាដើមថា ភិក្ខុលះបង់នូវការសំឡឹងរំពៃ មានចិត្តប្រាសចាកការសំឡឹងរំពៃហើយនៅ ឈ្មោះថា **ចេតសិកសីល** ។

- សំវរៈ ក្នុងពាក្យសំវរសីលនុ៎ះ បណ្ឌិតគប្បីជ្រាបដោយចំណែក ៥ យ៉ាង គឺ បាតិមោក្ខសំវរៈ ១ សតិសំវរៈ ១ ញាណសំវរៈ ១ ខន្តិសំវរៈ ១ វីរិយសំវរៈ ១ ។

បណ្ដាសំវរៈទាំងនោះ ភិក្ខុអ្នកចូលទៅដល់ហើយ ចូលទៅជិតព្រមហើយ ដោយកិរិយាសង្រួមក្នុងបាតិមោក្ខ នេះឈ្មោះថា **បាតិមោក្ខសំវរៈ** ។

ភិក្ខុរក្សានូវចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ នេះឈ្មោះថា **សតិសំវរៈ** ។

ព្រះមានព្រះភាគ ត្រាស់នឹងអជិតមាណពថា "ម្នាលអជិតៈ ខ្សែទាំងឡាយណាក្នុងលោក សតិជាគ្រឿងបិទខ្សែទាំងនោះ តថាគតពោលនូវការបិទខ្សែទាំងឡាយ ខ្សែទាំងនុ៎ះ បុគ្គលបិទបានដោយបញ្ញា" ដូច្នេះនេះ ឈ្មោះថា **ញាណសំវរៈ** ។ សូម្បីការសេពចំពោះ

នូវបច្ច័យ ក៏ដល់នូវការរាប់បញ្ចូលក្នុងញាណសំវរៈនោះដែរ ។

សំវរៈណាដែលមកហើយដោយន័យ មានន័យដូច្នេះជាដើម ថា ភិក្ខុជាអ្នកអត់ទ្រាំបានចំពោះត្រជាក់និងក្តៅ នេះឈ្មោះថា **ខន្តិសំវរៈ** ។

សំវរៈណាដែលមកហើយដោយន័យ មានដូច្នេះជាដើមថា ភិក្ខុមិនទទួលនូវកាមវិតក្កៈដែលកើតឡើងហើយ នេះឈ្មោះថា **វិរិយសំវរៈ** ។ សូម្បីសេចក្តីបរិសុទ្ធនៃការចិញ្ចឹមជីវិត ក៏ដល់នូវការរាប់បញ្ចូលក្នុងវិរិយសំវរៈនោះដែរ ។

ដូច្នេះ ការសង្រួមទាំង ៥ យ៉ាងនេះក្តី កិរិយាវៀរចាកនូវវត្ថុដែលដល់ព្រមនៃកុលបុត្តទាំងឡាយ ដែលជាអ្នកតក់ស្លុតចំពោះអំពើបាបណាក្តី បណ្ឌិតគប្បីជ្រាបថា កិរិយាសង្រួមនិងកិរិយាវៀរទាំងអស់នោះ ឈ្មោះថា **សំវរសីល** ។

- កិរិយាមិនប្រព្រឹត្តកន្លង ឈ្មោះថា សីល មានសេចក្តីថា កិរិយាមិនប្រព្រឹត្តកន្លងដែលប្រកបដោយកាយ ដោយវាចា នៃបុគ្គលដែលមានសីលសមាទានហើយ ។

**ដីកា បរមត្ថមញ្ជូសា ពន្យល់ថា ៖**

ពាក្យថា វិរមន្តស្ស (របស់បុគ្គលអ្នកវៀរចាក) បានដល់របស់បុគ្គលអ្នកវៀរចាក ដោយអំណាចសមាទានវិរតិ និងដោយ

សម្បត្តវិរតិ ។

ក៏ក្នុងអធិការនេះ លោកពោលចេតនាសីល សំដៅសេចក្តីនេះថា កាលណាចេតនាដែលវិសេសជាងការហាមឃាត់វៀរចាកបាណាតិបាតជាដើមនោះ ដែលជាបដិបក្ខចំពោះបាណាតិបាតជាដើម ដោយព្រះបាលីថា "ម្នាលភិក្ខុទាំងឡាយ កាយសញ្ចេតនា ៣ យ៉ាង កាយកម្មផ្នែកកុសល" ដូច្នេះជាដើម ដែលប្រព្រឹត្តទៅហើយដូច្នោះ រមែងឲ្យសម្រេចជាការវៀរចាកចំពោះបាណាតិបាតជាដើម ដោយភាពជាប្រធាន, ដូច្នោះ វិរតិនិងអនភិជ្ឈាជាដើមដែលសម្បយុត្តដោយចេតនានោះ ចាត់ចូលក្នុងផ្នែកចេតនា ឬជាអព្វោហារិក ។

លោកពោលចេតសិកសីល សំដៅសេចក្តីនេះថា តែកាលណា វិរតិនិងអនភិជ្ឈាជាដើម ដែលវិសេសជាងចេតនាដែលប្រព្រឹត្តទៅដោយអាការដែលវៀរចាកបាណាតិបាតជាដើម របស់អ្នកមានសេចក្តីវៀរចាកបាណាតិបាតជាដើម រមែងឲ្យសម្រេចកិច្ច ដោយភាពជាប្រធានក្នុងសេចក្តីនោះៗ, កាលចេតនាដែលសម្បយុត្តដោយវិរតិ និងអនភិជ្ឈាជាដើម ចាត់ចូលក្នុងផ្នែករបស់វិរតិជាដើម ឬជាអព្វោហារិក ។

*ឥឡូវនេះ ដើម្បីសម្តែងចែកចេតនាសីល និងចេតសិកសីល ដោយទាក់ទងនឹងកុសលកម្មបទ ១០ តាមន័យដែលមកក្នុងព្រះ-សូត្រ ទើបពោលពាក្យមានជាដើមថា “**អបិច**” តទៅ ។*

*ពាក្យថា **របស់បុគ្គលអ្នកលះ** សេចក្តីថា របស់បុគ្គលអ្នកលះ ដោយមិនប្រព្រឹត្តកន្លងសូម្បីវត្ថុដែលជួប ដោយតាំងចិត្តថា “ចាប់ផ្តើមពីនេះទៅ យើងនឹងមិនធ្វើ” ដូច្នេះ ដោយអំណាចការសមាទាន ។ ពាក្យថា **ចេតនាក្នុងកម្មបទ ៧** បានដល់ ចេតនាក្នុងកុសលកម្មបទ ៧ ដោយលំដាប់ ឲ្យសម្រេចការលះបាណាតិ-បាតជាដើម ។ សត្វធ្វើកម្មណា មានការចូរទៅសេពនូវកិរិយានៃបុគ្គលដទៃជាដើម ដោយអំណាចអភិជ្ឈាជាដើម, អនភិជ្ឈាជាដើមដែលលះកម្មនោះ ឈ្មោះថា **ជាសីល** ដូច្នោះ លោកទើបពោលថា “ធម៌ គឺអនភិជ្ឈា អព្យាបាទ ។ល។ និងសម្មាទិដ្ឋិ ឈ្មោះថា **ចេតសិកសីល**” ដូច្នេះ ។*

*ដូចយ៉ាងបុគ្គលធ្វើមិច្ឆាចារ និង បាណាតិបាតជាដើម ដោយអំណាចអភិជ្ឈា និងព្យាបាទយ៉ាងណា, មិច្ឆាចារនិងព្យាបាទជាដើមទាំងនោះ បុគ្គលធ្វើក៏ដើម្បីប្រយោជន៍ មានការឃើញដល់មុខបុគ្គជាដើម ដោយអំណាចការឃើញខុសខ្វះ ដូច្នោះ ។ ក៏ធម៌មានអនភិជ្ឈាជាដើម ជាតួលះធម៌មានអភិជ្ឈាជាដើមនោះ ដូច្នេះឯង ។*

**បាតិមោក្ខសំវរោ** ចារិត្តវារិត្តវិភាគំ វិនយបរិយាបន្នំ សិក្ខាបទសីលំ ។ *ដែលឈ្មោះថា បាតិមោក្ខសំវរសីល គឺសិក្ខាបទដែលរាប់បញ្ចូលក្នុងព្រះវិន័យ ចែកចេញជាចារិត្តសីល និងវារិត្តសីល ។*

**សតិសំវរោ** មនច្ឆដ្ឋានំ ឥន្ទ្រិយានំ អារក្ខា, សា ច តថាបវត្តា សតិយេវ ។ ***សតិសំវរ*** *បានដល់ ការរក្សាឥន្ទ្រិយទាំងឡាយ មានចិត្តជាគម្រប់ ៦, ក៏ការរក្សានោះ គឺសតិដែលប្រព្រឹត្តទៅហើយដោយប្រការដូច្នោះឯង ។*

**ញាណសំវរោ** បញ្ញា ។ ***ញាណសំវរ*** *បានដល់ បញ្ញា ។*

**ខន្តិសំវរោ** អធិវាសនា ។ ***ខន្តិសំវរ*** *បានដល់ អធិវាសនៈ (សេចក្តីអត់សង្កត់) ។ ក៏សេចក្តីអត់សង្កត់នោះ គឺខន្ធទាំងឡាយដែលមានអទោសៈជាប្រធាន ដែលប្រព្រឹត្តទៅដោយប្រការនោះ, ឬអទោសនោះឯង ។ ដែលឈ្មោះថា* ***វីរិយសំវរ*** *បានដល់ សេចក្តីព្យាយាម ដែលប្រព្រឹត្តទៅជាប់ដោយការបន្ទោបង់កាមវិតក្កៈជាដើម ។*

# វិសជ្ជនាបញ្ហាកម្ម ទី២

២-គេឧទ្ទេស សីលំ, *សីលដោយអត្ថថា ដូចម្ដេច ?*

<u>*ឆ្លើយថា*</u> សីលនទ្ទេស សីលំ *សីលដោយអត្ថថាប្រក្រតី ។*

*ធម្មជាតិដែលឈ្មោះថាប្រក្រតីនេះ ដូចម្ដេច ?*

សមាធានំ វា, កាយកម្មាទីនំ សុសីល្យវសេន អវិប្បកិណ្ណតាតិ អត្ថោ ។ ឧបធារណំ វា, កុសលានំ ធម្មានំ បតិដ្ឋានវសេន អាធារភាវោតិ អត្ថោ ។

សមាធាន *(កិរិយារួបរួមទុក), អធិប្បាយថា ភាវៈនៃកម្ម ទាំងឡាយមានកាយកម្មជាដើម មិនរាត់រាយ ដោយអំណាចភាវៈ នៃបុគ្គលអ្នកមានសីល ។*

ឧបធារណា ឬ*(កិរិយាចូលទៅទ្រទ្រង់ទុកទៅ) ដោយអំណាច នៃកិរិយាប្រតិស្ឋាននៃធម៌ទាំងឡាយជាកុសលម្យ៉ាង ។ ដ្បិតថា អ្នកប្រាជ្ញ ដែលដឹងច្បាស់នូវលក្ខណៈនៃសព្ទក្នុងបទសីលសព្ទនេះ តែងអនុញ្ញាតនូវប្រជុំពីរនៃអត្ថត្រឹមប៉ុណ្ណោះ ។*

*ចំណែកអាចារ្យឯទៀត ពណ៌នានូវអត្ថ ក្នុងសីលសព្ទនេះ ដោយន័យមានយ៉ាងនេះជាដើមដែរថា* សិរដ្ឋោ *សីលមានអត្ថថា*

ជាកំពូល សីសដ្ឋោ មានអត្ថថា ជាប្រធាន សីតលដ្ឋោ មានអត្ថថា ត្រជាក់ សិវដ្ឋោ មានអត្ថថា ក្សេមក្សាន្ត ។

**ក្នុងគម្ពីរដីកា បរមត្ថមញ្ជុសា ពន្យល់ថា ៖**

សមាធានំ សណ្ឋបនំ ។ ទុស្សីល្យវសេន ហិ បវត្តា កាយកម្មាទយោ សម្ពតិ, អាយតិញ្ច អហិតទុក្ខាវហា,

សមាធានំ ប្រែថា ការតាំងទុកដោយល្អ ។ ពិតមែន កម្មទាំងឡាយមានកាយកម្មជាដើម ដែលប្រព្រឹត្តទៅហើយដោយអំណាចភាពជាអ្នកទ្រុស្តសីល មានការនាំវត្ថុដែលមិនមែនជាប្រយោជន៍ និងសេចក្តីទុក្ខមកឲ្យទាំងក្នុងបច្ចុប្បន្ន និងក្នុងកាលតទៅ, ឈ្មោះថា មិនតាំងទុកដោយល្អ ព្រោះមិនតាំងនៅហើយដោយប្រពៃ ឈ្មោះថា (វិប្បកិណ្ណ) រាត់រាយ និងឈ្មោះថា (វិសដ្ឋ) លះបង់ទៅហើយ, ចំណែកកាយកម្មជាដើម ដែលប្រព្រឹត្តទៅហើយដោយភាពជាអ្នកមានសីលល្អ ឈ្មោះថា តាំងទុកដោយប្រពៃហើយ មិនរាត់រាយដោយបរិយាយខុសអំពីភាពជាអ្នកមានសីលល្អនោះ និងមិនលះបង់ទៅហើយ ដូចភាពជាអ្នកមានភ្នែកដាក់ចុះហើយ មានការមិនយោលដៃជាដើមដូច្នោះ ។ ព្រោះដូច្នោះ លោកទើបពោលអធិប្បាយថា ភាពជាអ្នកមានកាយកម្មជាដើមមិនរាត់រាយហើយ ដោយអំណាច

នៃភាពជាអ្នកមានសីលល្អ ដោយពាក្យនេះ លោកទើបសម្រេច សេចក្តីគ្រប់គ្រងឲ្យប្លែកផ្សេងចេញអំពីកិច្ចសមាធិ ។

ក៏សេចក្តីតាំងមាំនៃសមាធិនោះ បានដល់ សេចក្តីជាហេតុនៃការមិនរាយមាយចិត្ត របស់សម្បយុត្តធម៌ទាំងឡាយ ។ ក៏សេចក្តីនេះ ជាសេចក្តីតាំងមាំ គឺការសង្រួមកាយកម្មជាដើម ។ សេចក្តីនៃការអធិដ្ឋាន គឺភាពជាមូល ឈ្មោះថា ការចូលទៅទ្រទ្រង់ទុក ។ ពិតយ៉ាងនោះ សីលនោះលោកពោលថា ជាការប្រព្រឹត្តិក្នុងខាងដើមជាអាទិ ។ ព្រោះហេតុនោះ ការឃុំគ្រង លោកធ្វើឲ្យផ្សេងអំពីកិច្ចនៃបឋវីធាតុ ។ ពិតមែន បឋវីធាតុនោះ រមែងប្រព្រឹត្តទៅព្រោះជាទីទ្រទ្រង់រូបធម៌ដែលកើតរួមគ្នា ។ ចំណែកការឃុំគ្រងនេះ រមែងប្រព្រឹត្តទៅដោយការៈជាមូល និងជាទីតាំងនៃធម៌ដែលរកទោសមិនបាន ។ ព្រោះហេតុនោះ លោកទើបពោលថា នៃកុសលធម៌ទាំងឡាយជាដើម ។

ក្នុងពាក្យថា នៃកុសលធម៌ទាំងឡាយជាដើមនោះ ដែលឈ្មោះថា កុសលធម៌ បានដល់ មហគ្គតធម៌ និងលោកុត្តរធម៌ ព្រមទាំងធម៌ដែលជាបុព្វភាគ ។

សិរដ្ឋោតិ យថា សិរសិ ភិន្នេ សព្វោ អត្តភាវោ វិនស្សតិ, ឯវំ សីលេ ភិន្នេ សព្វំ គុណសរីរំ វិនស្សតិ។

*បទថា **សិរដ្ឋោ** អធិប្បាយថា កាលក្បាលត្រូវកាត់ហើយ អត្តភាពទាំងមូល រមែងវិនាសទៅយ៉ាងណា, សីល ក៏យ៉ាងនោះ កាលបែកធ្លាយហើយ វិនាសហើយ រាងកាយគឺគុណទាំងពួង ក៏វិនាសទៅ ។ ព្រោះហេតុនោះ សីល ទើបមានអត្ថថា អវយវៈ ខ្ពស់បំផុត ឈ្មោះថា សីសដ្ឋោ ឬកាលគួរនឹងពោលថា "សិរោ សីសំ" លោកពោលថា "សីលំ" ដោយនិរុត្តិន័យ ។ អត្ថថា ស្ងប់សេចក្តីក្តៅក្រហាយ ឈ្មោះថា សីតលដ្ឋោ ។ ដោយពាក្យនោះ លោកសម្តែងថា លុប ត អក្សរ ហើយពោលថា សីលំ ដោយនិរុត្តិន័យដូចគ្នា ។*

*ពិតយ៉ាងនោះ សីលនេះ ដែលឲ្យសម្រេចហើយ ដោយសេចក្តីព្យាយាម ក៏នឹងធ្វើឲ្យរម្ងាប់សេចក្តីក្តៅក្រហាយ គឺកិលេសទាំងពួង ។ ដោយអាទិសព្ទថា ឯវមាទិនា គប្បីឃើញថា លោកសង្គ្រោះពាក្យមានជាដើមយ៉ាងនេះថា កាលសីលនេះមាន អកុសលធម៌ទាំងឡាយក៏ដេកនៅ គឺនៅមិនទាន់ប្រាសទៅដូច្នោះ ទើបឈ្មោះថា សីល, ឬឈ្មោះថា សីល ព្រោះទុច្ចរិតទាំងមូល មានសេចក្តីឧស្សាហៈ ដែលកុសលធម៌នោះកំចាត់ហើយ, ឬឈ្មោះថា សីល ព្រោះអត្ថថា ជាសាលា (ទីអាស្រ័យ) គួរដល់ការចូលទៅនៃកុសលធម៌ទាំងអស់ ដូចនេះ ។*

# វិសុទ្ធិនាបញ្ហាកម្ម ទី៣

៣-កានសុ្ល លក្ខណរសបច្ចុបដ្ឋានបទដ្ឋានានិ,
*លក្ខណៈ កិច្ច អាការប្រាកដឡើង (ផល) និងអាសន្នហេតុ (ហេតុជិតកៀកផ្ទាល់) នៃសីលនោះ ដូចម្ដេច ?*

*<u>ឆ្លើយថា</u>* **:** ***ប្រក្រតី*** *ជាលក្ខណៈនៃសីលនោះ ទោះបីផ្សេងគ្នាជាអនេក ដូចភាពជាគ្រឿងឃើញដោយភ្នែក ជាលក្ខណៈនៃរូបដែលផ្សេងគ្នាជាអនេកដែរ ។*

*សេចក្ដីឧបមាថា ភាពជាគ្រឿងឃើញដោយភ្នែក ជាលក្ខណៈនៃរូបាយតនៈ ទោះបីផ្សេងគ្នាជាអនេក ដោយប្រភេទនៃរូបមានពណ៌ខៀវ និងពណ៌លឿងជាដើម ព្រោះមិនប្រព្រឹត្តកន្លងនូវភាពជាគ្រឿងឃើញដោយភ្នែករបស់រូប សូម្បីផ្សេងដោយប្រភេទ មានរូបខៀវជាដើមយ៉ាងណា ប្រក្រតីណាដែលលោកពោលហើយដោយអំណាចនៃកិរិយាតាំងទុកដ៏ល្អនូវកម្មទាំងឡាយ មានកាយកម្មជាដើមក្ដី ដោយអំណាចនៃកិរិយាប្រតិស្ឋាននៃធម៌ទាំងឡាយជា-កុសលក្ដី ប្រក្រតីនោះឯង ជាលក្ខណៈនៃសីល ទោះបីផ្សេងគ្នាជាអនេកដោយប្រភេទនៃសីល មានចេតនាជាដើម ព្រោះមិនកន្លងហួសនូវភាពនៃកិរិយាតាំងទុកដ៏ល្អ និងប្រតិស្ឋាននៃសីល សូម្បី*

ផ្សេងគ្នាជាអនេក ដោយប្រភេទនៃសីល មានចេតនាសីលជាដើម យ៉ាងនោះដែរ ។

ន័យមួយទៀត សីលដែលមានលក្ខណៈយ៉ាងនេះនោះមាន លោកពោលថា មានភាពនៃកិរិយាកំចាត់បង់នូវភាពនៃបុគ្គលទ្រុស្ត- សីល និងមានគុណ គឺភាពមិនមានទោស ជារស ដោយអត្ថថា ជាកិច្ច និងជាសម្បត្តិ ព្រោះហេតុនោះ ឈ្មោះថា សីលនេះ គប្បី ជ្រាបថា មានកិរិយាកំចាត់បង់នូវភាពនៃបុគ្គលទ្រុស្តសីល ជាកិច្ច ដោយរស មានកិច្ចជាអត្ថ មានការៈមានទោសមិនមាន ជាសម្បត្តិ ដោយរស មានសម្បត្តិជាអត្ថ ព្រោះថា បណ្តាអាការៈទាំងឡាយ មានលក្ខណៈជាដើម កិច្ចក្តី សម្បត្តិក្តី លោកហៅថា **រស** ។

សោចេយ្យប្បច្ចុបដ្ឋានំ តយិទំ តស្ស វិញ្ញុហិ
ឱត្តប្បញ្ច ហិរិ ចេវ បទដ្ឋានន្តិ វណ្ណិតំ ។

សីលនោះ មានសេចក្តីស្អាតជាផល មានសេចក្តីតក់ស្លុតបាប និងសេចក្តីខ្មាសខ្ពើមបាប អ្នកប្រាជ្ញទាំងឡាយពណ៌នាថា ជាទីតាំងនៃសីលនោះ ។

ព្រោះថា សីលនោះ មានសេចក្តីស្អាតជាគ្រឿងប្រាកដ ដែល លោកពោលយ៉ាងនេះថា សេចក្តីស្អាតកាយ ស្អាតវាចា ស្អាតចិត្ត ប្រាកដឡើងដោយការៈនៃសេចក្តីស្អាត ដល់នូវភាពនៃកិរិយាកាន់

*យក ។ ក៏ឯហិរិនិងឱត្តប្បៈ អ្នកប្រាជ្ញទាំងឡាយពណ៌នាថា ជាទីតាំង (បទដ្ឋាន) នៃសីលនោះ ។*

*សេចក្តីអធិប្បាយថា ជាហេតុជិត (អាសន្នហេតុ) ។ ដ្បិតថា កាលបើ ហិរិនិងឱត្តប្បៈមាន សីលរមែងកើតឡើងផង តាំងនៅផង កាលបើហិរិនិងឱត្តប្បៈ មិនមានទេ សីលក៏មិនកើតឡើង មិនតាំងនៅ លក្ខណៈ កិច្ច ផល និងហេតុជាទីតាំងនៃសីល បណ្ឌិតគប្បីជ្រាបយ៉ាងនេះ ។*

***ដីកា បរមត្ថមញ្ជូសា ភាគ១ លោកអធិប្បាយថា ៖***

*ពាក្យថា **មានកិរិយាកំចាត់បង់នូវភាពនៃបុគ្គលទ្រុស្តសីល ជារស** សេចក្តីថា មានការៈកិច្ចកំចាត់សេចក្តីទ្រុស្តសីល ផ្សេងដោយការមិនសង្រួមផ្លូវកាយជាដើម ។ ពាក្យថា **មានគុណដែលរកទោសមិនបាន ជារស** សេចក្តីថា មានគុណដែលអ្នកណាៗតិះដៀលមិនបាន ជាសម្បត្តិ គឺដល់ព្រមដោយភាពជាអ្នកដែលបុគ្គលណាមួយមិនតិះដៀល ឬដល់ព្រមដោយភាពជាចំណែកដែលរកទោសមិនបាន ។ ពាក្យថា **ក្នុងលក្ខណៈជាដើម** សេចក្តីថា ក្នុងលក្ខណៈនិងរសជាដើម ដែលកំពុងពោលកិច្ចនោះឯង ឬសម្បត្តិលោកហៅថា **រស**, អធិប្បាយថា មិនមែនអាយតនៈ មានរសាយតនៈជាដើម ឈ្មោះថារសទេ ។*

ចំណែកអាចារ្យពួកខ្លះ ពោលថា **អវធារណ** ក្នុងពាក្យថា "**កិច្ចមេវ**" ដើម្បីសម្តែងថា រសនោះមានកម្លាំងជាងរសក្រៅនេះ, ពាក្យនោះ ត្រឹមតែជាមតិរបស់អាចារ្យពួកនោះ ព្រោះលោកប្រាប្ថា សេចក្តីនេះថា កិច្ចនោះឯង ឬសម្បត្តិ ឈ្មោះថា **រស** ។

ពាក្យថា **មានសេចក្តីស្អាតជាបច្ចុប្បដ្ឋាន** សេចក្តីថា សីលរមែងប្រាកដដោយភាពជាធម្មជាតិស្អាត ទាំងកាយទ្វារជាដើម ។

បទថា គហណភាវំ ប្រែថា ភាពជាគុណដែលគប្បីកាន់យកបាន ។ ដោយពាក្យនោះ លោកពោលបច្ចុប្បដ្ឋាន ដោយអត្ថថា អាការដែលប្រាកដ, តែដោយអត្ថថា ផល លោកពោលបច្ចុបដ្ឋាន មានសេចក្តីមិនក្តៅក្រហាយក្នុងកាលខាងក្រោយជាដើម, ឬបច្ចុបដ្ឋាន គឺសមាធិប្រាកដ ។ ពិតមែន សីលសម្រេចសេចក្តីមិនក្តៅក្រហាយ ឲ្យប្រាកដក្នុងបច្ចុប្បន្ន, សម្រេចសមាធិ ឲ្យប្រាកដក្នុងកាលខាងមុខ ។ ចំណែកផលគឺអានិសង្សនេះ លោកអាចារ្យនឹងពោលតទៅក្នុងកថាពោលដោយអានិសង្ស ដូច្នោះ គប្បីឃើញថា លោកមិនកាន់យកក្នុងទីនេះ ។ តែអាចារ្យពួកខ្លះពោលថា លោកមិនកាន់យកក្នុងទីនេះ ព្រោះលោកមិនត្រូវការផល, សេចក្តីនោះមិនត្រូវ ព្រោះផលមានច្រើនយ៉ាង ព្រោះសូម្បីសីលមានលោកិយ-សីលជាដើម លោកក៏ចែក ។ ពិតយ៉ាងនោះ លោកអាចារ្យនឹង

ពោលតទៅថា "ដោយអំណាចនៃនិស្សិតសីល និងអនិស្សិតសីល" ដូចនេះជាដើម ។

លោកអាចារ្យកាលនឹងសម្តែងថា បឋវីធាតុមានកម្មជាដើម ជាហេតុឆ្ងាយ មានកូត ៣ ដ៏សេសជាហេតុជិត យ៉ាងណា, មួយទៀត សំពត់មានជាងតម្បាញត្បាញបបុស និងផ្ទៃជាដើម ជាហេតុឆ្ងាយ, មានសសៃអំបោះ ជាហេតុជិតយ៉ាងណា, សីលមាន ការស្តាប់ធម៌ជាដើម ជាហេតុឆ្ងាយ សីលនោះមានហិរិនិងឱត្តប្បៈ ជាហេតុជិត ក៏ដូច្នោះ ដូចនេះ ទើបពោលពាក្យថា ក៏ឯហិរិឱត្តប្បៈ ដូច្នេះជាដើម ។

**ហិរោត្តប្បេ ហីតិ**អាទិ តស្ស អាសន្នការណា-ការសាធនំ ។ តត្ថ **ឧប្បជ្ជតិ** សមាទានវសេន, **តិដ្ឋតិ** អវីតិក្កមវសេនាតិ វេទិតព្វំ ។

ពាក្យថា **ពិតមែន កាលហិរិឱត្តប្បៈ**ដូច្នេះជាដើម ជាពាក្យ សម្រេចសេចក្តីជាហេតុជិតរបស់សីលនោះឲ្យសម្រេច ។ ក្នុងពាក្យ នោះ គប្បីជ្រាបថា សីលកើតឡើងដោយអំណាចការសមាទាន តាំងនៅដោយអំណាចសេចក្តីមិនប្រព្រឹត្តកន្លង ។

# វិសជ្ជនាបញ្ហាកម្ម ទី៤

៤-កិមានិសំសំ សីលំ, សីលមានអានិសង្សដូចម្តេច ?

ឆ្លើយថា : **សីល** មានកិរិយាបានចំពោះនូវគុណជាអនេក មានសេចក្តីមិនក្តៅក្រហាយជាដើមជាអានិសង្ស ។

សមដូចពាក្យនេះ ដែលព្រះអង្គទ្រង់សម្តែង (មានក្នុងអង្គុត្តរនិកាយ) ថា "អវិប្បដិសារត្ថានិ ខោ, អានន្ទ, កុសលានិ សីលានិ អវិប្បដិសារានិសំសានិ : ម្នាលអានន្ទ សីលទាំងឡាយជាកុសល មានកិរិយាមិនក្តៅក្រហាយជាប្រយោជន៍មែនពិត មានកិរិយាមិនក្តៅក្រហាយជាអានិសង្ស ។

សូម្បីពាក្យដទៃទៀត ព្រះអង្គទ្រង់ត្រាស់ថា ម្នាលគហបតីទាំងឡាយ អានិសង្ស ៥ នេះ នៃសីលសម្បទារបស់បុគ្គលមានសីល ។ អានិសង្ស ៥ គឺអ្វីខ្លះ ។

ម្នាលគហបតីទាំងឡាយ បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលក្នុងលោកនេះ តែងបាននូវគំនរនៃសម្បត្តិដ៏ច្រើន ហេតុមកពីសេចក្តីមិនប្រមាទ នេះជាអានិសង្សទី ១ នៃបុគ្គលមានសីល ឬបរិបូរណ៍ដោយសីល ។

ម្នាលគហបតីទាំងឡាយ ប្រការមួយទៀត បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលហើយ តែងមានកិត្តិស័ព្ទដ៏ពីរោះខ្ចរខ្ចាយ

ទៅ នេះជាអានិសង្សទី ២ នៃបុគ្គលមានសីល ឬបរិបូរណ៍ដោយសីល ។

ម្នាលគហបតីទាំងឡាយ ប្រការមួយទៀត បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលហើយ (បើ) ចូលទៅកាន់បរិស័ទណា ទោះបីជាខត្តិយបរិស័ទក្តី ជាព្រាហ្មណបរិស័ទក្តី ជាគហបតីបរិស័ទក្តី ជាសមណបរិស័ទក្តី ក៏ក្លៀវក្លា មិនឱនមុខចុះ គឺជាមិនក្រអឺមក្រអៀន ហើយដើរចូលទៅ នេះជាអានិសង្សទី ៣ នៃបុគ្គលមានសីល ឬបរិបូរណ៍ដោយសីល ។

ម្នាលគហបតីទាំងឡាយ ប្រការមួយទៀត បុគ្គលអ្នកមានសីល ឬបរិបូរណ៍ដោយសីលហើយ លុះវេលាទៀបស្លាប់ក៏មិនវង្វេងស្មារតីឡើយ នេះជាអានិសង្សទី ៤ នៃបុគ្គលមានសីល ឬបរិបូរណ៍ដោយសីល ។

ម្នាលគហបតីទាំងឡាយ ប្រការមួយទៀត បុគ្គលមានសីល ឬបរិបូរណ៍ដោយសីលហើយ លុះរំលាយខន្ធ បន្ទាប់អំពីមរណៈរមែងទៅកាន់មនុស្សលោក ឬទេវលោក នេះជាអានិសង្សទី ៥ នៃបុគ្គលមានសីល ឬបរិបូរណ៍ដោយសីល ។

នៅមានអានិសង្សសីលដ៏ច្រើនដទៃទៀត ដែលមានភាពជាទីស្រឡាញ់ និងជាទីគាប់ចិត្តជាដើម មានកិរិយាអស់ទៅនៃអាសវៈ

ជាទីបំផុត ដែលព្រះមានព្រះភាគ ត្រាស់ហើយដោយន័យមានដូច្នេះជាដើម (ក្នុងអង្គុត្តរនិកាយ ទសកនិបាត **អាកង្ខសូត្រ** បិដកលេខ ៥០ ទំព័រ២៨៨) ថា "អាកង្ខេយ្យ ចេ, ភិក្ខវេ, ភិក្ខុ សព្រហ្មចារីនំ បិយោ ច អសិ្ស មនាបោ ច គរុ ច ភាវនីយោ ចាតិ, សីលេស្វេវស្ស បរិបូរការី : ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រាថ្នាថា អាត្មាអញគប្បីជាទីស្រឡាញ់ផង ជាទីគាប់ចិត្តផង ជាទីគោរពផង នៃសព្រហ្មចារីទាំងឡាយ ដូច្នេះ គប្បីជាអ្នកធ្វើឲ្យពេញលេញក្នុងសីលទាំងឡាយមែនពិត" ។

នៅក្នុងគម្ពីរបរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

ពាក្យថា **ជាទីគោរព** សេចក្តីថា ជាអ្នកនៅក្នុងឋានៈដែលធ្ងន់ប្រាកដដូចជាឆត្រថ្ម ។ ពាក្យថា **ជាទីគាប់ចិត្ត** សេចក្តីថា គប្បីជាទីដែលជនថា "អ្នកមានអាយុនេះ ដឹងវត្ថុដែលគួរដឹង ឃើញវត្ថុដែលគួរឃើញពិត" ។ ពាក្យថា **គប្បីជាអ្នកធ្វើឲ្យពេញលេញក្នុងសីលទាំងឡាយមែនពិត** សេចក្តីថា គប្បីជាអ្នកធ្វើឲ្យបរិបូរណ៍ក្នុងចតុបារិសុទ្ធិសីលតែម្តង, គឺមិនធ្វើឲ្យអន់ថយ គប្បីជាអ្នកប្រកបហើយដោយអាការដែលបរិបូរណ៍ ។ ពាក្យថា "**ដោយន័យជាដើមថា**" នេះ លោករួបរួមអានិសង្សសីល ១៧ ប្រការ ដែលមកក្នុងសូត្រដែលសរសើរសីល មានពាក្យជាដើមយ៉ាងនេះថា

“ប្រកបរឿយៗ នូវការរម្ងាប់នូវចិត្តខាងក្នុង មានឈានមិនសាប-សូន្យ ប្រកបដោយវិបស្សនាញាណ ជាអ្នកចម្រើននូវសុញ្ញាគារៈ (ផ្ទះស្ងាត់)” ដូច្នេះ ។

**សីលមានគុណដ៏ច្រើន មានសេចក្តីមិនក្តៅក្រហាយជាដើម ជាអានិសង្សនេះ ។**

សាសនេ កុលបុត្តានំ បតិដ្ឋា នត្ថិ យំ វិនា

អានិសំសបរិច្ឆេទំ តស្ស សីលស្ស កោ វទេ ។

ទីពឹងនៃកុលបុត្រទាំងឡាយក្នុងសាសនាមិនមាន ព្រោះវៀរនូវសីលណា នរណាគប្បីពោលនូវការកំណត់អានិសង្សនៃសីលនោះបាន ។

នៅក្នុងគម្ពីរបរមត្ថមញ្ជូសា ពន្យល់ថា : ឥឡូវនេះ លោកអាចារ្យផ្តើមពាក្យជាដើមថា ន័យម្យ៉ាងទៀត ដូចនេះ ក៏ដើម្បីនឹងសម្តែងអានិសង្សសីលទាំងនោះថា មិនមែនមានអានិសង្ស គឺសេចក្តីមិនក្តៅក្រហាយចិត្តជាដើម ទាំងនេះតែម្យ៉ាងប៉ុណ្ណោះទេ, ដោយពិត នៅមានអានិសង្សសីលសូម្បីដទៃជាច្រើនទៀត ។

បណ្តាពាក្យទាំងនោះ ពាក្យថា **ក្នុងព្រះសាសនា** សេចក្តីថា ក្នុងសត្ថុសាសនានេះ ដែលនឹងនាំគុណដែលជាលោកិយៈ និងលោកុត្តរៈទាំងអស់មក ។ ពង្រីកសេចក្តីថា ទីពឹង គឺទីអាស្រ័យ

របស់កុលបុត្ត អ្នកមានអាចារៈទាំងឡាយ វៀរសីលណាចេញហើយ រមែងមិនមាន, អ្នកណានឹងគប្បីពោល គឺអ្នកណាអាចនឹងគប្បីប្រាប់ការកំណត់ គឺប្រមាណនៃអានិសង្សរបស់សីលនោះដែលមានអានុភាពច្រើនយ៉ាងនេះបាន ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ លោកពោលគាថានេះទៀតថា ៖

ន គង្គា យមុនា វាបិ សរភូ វា សរស្សតី
និន្នគា វា ចិរវតី មហី វាបិ មហានទី
សក្កុណន្តិ វិសោធេតុំ តំ មលំ ឥធ បាណិនំ
វិសោធយតិ សត្តានំ យំ វេ សីលជលំ មលំ ។

ស្ទឹងគង្គាក្តី យមុនាក្តី សរភូក្តី សរស្សតីក្តី អចិរវតីក្តី មហីក្តី សុទ្ធតែជាស្ទឹងយ៉ាងធំៗ ក៏មិនអាចដើម្បីនឹងជម្រះនូវមន្ទិលរបស់សត្វទាំងឡាយក្នុងលោកនេះបានឡើយ មានតែទឹក ពោលគឺសីលនេះឯងហើយ ទើបអាចជម្រះនូវមន្ទិលរបស់សត្វទាំងឡាយបាន ។

ន តំ សជលទា វាតា ន ចាបិ ហរិចន្ទនំ
នេវ ហារា ន មណយោ ន ចន្ទកិរណង្កុរា
សមយន្តីធ សត្តានំ បរិឡាហំ សុរក្ខិតំ
យំ សមេតីទំ អរិយំ សីលំ អច្ចន្តសីតលំ ។

ខ្យល់ទាំងឡាយដែលប្រកបដោយទឹកក្តី ខ្លឹមចន្ទន៍ក្រហមក្តី កែវមុក្តាហារទាំងឡាយក្តី កែវមណីទាំងឡាយក្តី រស្មីនៃព្រះចន្ទ្រដ៏ទន់ក្តី មិនអាចនឹងរម្ងាប់នូវសេចក្តីក្រហល់ក្រហាយរបស់សត្វទាំងឡាយ ក្នុងលោកនេះបានឡើយ មានតែសីលដ៏ប្រសើរ ដែលបុគ្គលរក្សាហើយដោយប្រពៃ ជាគុណជាតិត្រជាក់យ៉ាងក្រៃលែងនេះ ទើបអាចដើម្បីរម្ងាប់បាន ។

សីលគន្ធសមោ គន្ធោ កុតោ នាម ភវិស្សតិ
យោ សមំ អនុវាតេ ច បដិវាតេ ច វាយតិ ។

ក្លិនឯណាផ្សាយទៅស្មើ ក្នុងទីបណ្តោយខ្យល់ និងច្រាសខ្យល់ ក្លិននោះ ស្មើដោយក្លិនគឺសីលនឹងមានមកអំពីណា ។

សគ្គារោហណសោបានំ អញ្ញំ សីលសមំ កុតោ
ទ្វារំ វា បន និព្វាន- នគរស្ស បវេសនេ ។

ធម្មជាតិដទៃដែលជាជណ្តើរ សម្រាប់ឡើងទៅកាន់ស្ថានសួគ៌ ឬថា ទ្វារសម្រាប់ញ៉ាំងជនឱ្យចូលទៅកាន់នគរ គឺនិព្វាន ឱ្យស្មើដោយសីល នឹងមានមកអំពីណា ។

សោភន្តេវំ ន រាជានោ មុត្តាមណិវិភូសិតា
យថា សោភន្តិ យតិនោ សីលភូសនភូសិតា ។

ស្តេចទាំងឡាយ ដែលស្អិតស្អាងហើយដោយកែវមុក្តា និង កែវមណី ក៏មិនល្អដូចជាព្រះយោគីទាំងឡាយ ដែលស្អិតស្អាងហើយ ដោយគ្រឿងស្អិតស្អាង គឺសីល ។

អត្តានុវាទាទិភយំ វិទ្ធំសយតិ សព្វសោ
ជនេតិ កិត្តិំ ហាសញ្ច សីលំ សីលវតំ សទា ។

សីលនៃបុគ្គលអ្នកមានសីលទាំងឡាយ រមែងកំចាត់នូវភ័យទាំងពួង មានអត្តានុវាទភ័យជាដើម ដោយសព្វគ្រប់ តែងញុំាងកិត្តិសព្ទ និងសេចក្តីរីករាយឱ្យកើតសព្វកាល ។

គុណានំ មូលភូតស្ស ទោសានំ ពលឃាតិនោ
ឥតិ សីលស្ស វិញ្ញេយ្យំ អានិសំសកថាមុខំ ។

ប្រធាននៃពាក្យពោលនូវអានិសង្សរបស់សីល ដែលជាមូលនៃគុណទាំងឡាយ ជាគ្រឿងសម្លាប់នូវកម្លាំងនៃទោសទាំងឡាយ បណ្ឌិតគប្បីជ្រាបតាមន័យដែលបានពោលមកនេះចុះ ។

**នៅក្នុងគម្ពីរដីកា បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖**

ដោយពាក្យនេះ លោកអាចារ្យកាលសម្តែងថា សីលប៉ុណ្ណោះជាឫសគល់របស់គុណទាំងឡាយ ដែលជាលោកិយនិងលោកុត្តរៈពិតដូចនេះ តអំពីនោះ កាលនឹងសម្តែងថា មិនមានគុណយ៉ាងដទៃ ដែលនាំប្រយោជន៍សុខមកឲ្យដល់សត្វទាំងឡាយស្មើដោយ

សីល ដោយការជម្រះមន្ទិល, ដោយរម្ងាប់សេចក្តីក្តៅក្រហាយ, ដោយការខ្ចរខ្ចាយទៅនៃក្លិនក្រអូបបញ្ច្រាសខ្យល់, ដោយការៈជាឧបាយឲ្យសម្រេចសួគ៌ និងព្រះនិព្វាន, ដោយឲ្យសម្រេចដោយគ្រឿងប្រដាប់អលង្ការដែលល្អវិចិត្រ, ដោយកម្ចាត់ភ័យអន្តរាយ, និងដោយឲ្យកើតកិត្តិយសនិងសេចក្តីមោទនភាព, ដូចនេះ បានភាសិតគាថាទាំងឡាយមានជាដើមថា "ន គង្គា" ដូច្នេះ ប្រែថា សូម្បីទឹកគង្គា ក៏មិនអាចជម្រះមន្ទិលរបស់សត្វក្នុងលោកនេះបាន ។ល។

ក្លិន គឺកិត្តិសព្ទ ដែលមានសីលជាសមុដ្ឋាន លោកហៅថា "សីលគន្ធោ" (ក្លិនគឺសីល) ព្រោះការៈដែលត្រជាក់ចិត្ត, និងព្រោះផ្សាយទៅក្នុងទិសទាំងឡាយ ក៏ក្លិនសីលនោះ រមែងប្រព្រឹត្តទៅសូម្បីច្រាសខ្យល់ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគ ទើបត្រាស់ថា "ក៏ក្លិនរបស់សប្បុរស រមែងផ្សាយទៅច្រាសខ្យល់បាន" គប្បីជ្រាបថា ការប្រព្រឹត្តិកន្លងវត្ថុ ឈ្មោះថា កម្លាំងនៃទោស, សីលកាលមិនឲ្យធ្វើការប្រព្រឹត្តិកន្លងវត្ថុនោះ របស់ទោសទាំងនោះ ឈ្មោះថា មានប្រក្រតី កំចាត់កម្លាំងរបស់ទោសទាំងឡាយ ។

# វិសុទ្ធិនាបញ្ហាកម្ម ទី៥ សីលប្បភេទ

៥–កតិវិធំ ចេតំ សីលំ,

ចុះសីលនោះ មានប្រការប៉ុន្មានយ៉ាង ?

ក្នុងបញ្ហាកម្មនោះ មានកិរិយាដោះស្រាយ ដូចតទៅនេះ ។

### *សីលមានបការតែ ១*

សព្វមេវ តាវ ឥទំ សីលំ អត្តនោ សីលនលក្ខណេន **ឯកវិធំ** ។ *សីលទាំងអស់នេះឯង បើតាមប្រក្រតី ជាលក្ខណៈរបស់ខ្លួន មានបការៈតែ ១ ដោយពិត ។*

### *ក្រុមសីល ២ (ចែកជា ៧ ពួក)*

ពួកទី១ *ដោយអំណាចនៃចារិត្តសីល និង វារិត្តសីល*

ពួកទី២ *ដោយអំណាចនៃអាភិសមាចារិកសីល និង អាទិព្រហ្មចរិយកសីល ។*

ពួកទី៣ *ដោយអំណាចនៃវិរតិសីល និង អវិរតិសីល*

ពួកទី៤ *ដោយអំណាចនៃនិស្សិតសីល និងអនិស្សិតសីល*

ពួកទី៥ *ដោយអំណាចនៃកាលបរិយន្តសីល និង អាបាណកោដិកសីល*

ពួកទី៦ ដោយអំណាចនៃសបរិយន្តសីល និង អបរិយន្តសីល

ពួកទី៧ ដោយអំណាចនៃលោកិយសីល និង លោកុត្តរសីល ។

### *ក្រុមសីល ៣ (ចែកជា ៥ ពួក)*

ពួកទី១ ដោយអំណាចនៃហីនសីល ១ មជ្ឈិមសីល ១ បណីតសីល ១

ពួកទី២ ដោយអំណាចនៃអត្តាធិបតេយ្យសីល ១ លោកាធិបតេយ្យសីល ១ ធម្មាធិបតេយ្យសីល ១

ពួកទី៣ ដោយអំណាចនៃបរាមដ្ឋសីល ១ អបរាមដ្ឋសីល ១ បដិបស្សទ្ធិសីល ១

ពួកទី៤ ដោយអំណាចនៃវិសុទ្ធិសីល ១ អវិសុទ្ធិសីល ១ វេមតិកសីល ១

ពួកទី៥ ដោយអំណាចនៃសេក្ខសីល ១ អសេក្ខសីល ១ នេវសេក្ខានាសេក្ខសីល ១

## *ក្រុមសីល ៤ (ចែកជា ៤ ពួក)*

ពួកទី១ *ដោយអំណាចនៃហានភាគិយសីល ១ ឋិតិភាគិយសីល ១ វិសេសភាគិយសីល ១ និព្វេធភាគិយសីល ១*

ពួកទី២ *ដោយអំណាចនៃភិក្ខុសីល ១ ភិក្ខុនីសីល ១ អនុបសម្បន្នសីល ១ គហដ្ឋសីល ១*

ពួកទី៣ *ដោយអំណាចនៃបកតិសីល ១ អាចារសីល ១ ធម្មតាសីល ១ បុព្វហេតុកសីល ១*

ពួកទី៤ *ដោយអំណាចនៃបាតិមោក្ខសំវរសីល ១ ឥន្ទ្រិយសំវរសីល ១ អាជីវបារិសុទ្ធិសីល ១ បច្ចយសន្និស្សិតសីល ១ ។*

## *ក្រុមសីល ៥ (ចែកជា ២ ពួក)*

ពួកទី១ *ដោយអំណាចនៃសីលមាន **បរិយន្តបារិសុទ្ធិ-សីល** (សីលមានទីបំផុត ព្រោះមិនមានប្រមាណ និងមានសេចក្តីបរិសុទ្ធិ) សីលនៃអនុបសម្បន្នទាំងឡាយ ដែលមានសិក្ខាបទជាទីបំផុត ដោយអំណាចនៃកិរិយាភប់ ១*

*អបរិយន្តបារិសុទ្ធិសីល* (សីលមិនមានទីបំផុត ព្រោះមិនមានប្រមាណ និងសេចក្ដីបរិសុទ្ធិ) សីលនៃឧបសម្បន្នទាំងឡាយ ដែលមានសិក្ខាបទ មិនមានទីបំផុត ១

*បរិបុណ្ណបារិសុទ្ធិសីល* (សីលដែលបរិបូរណ៍ដោយប្រការទាំងពួង និងមានសេចក្ដីបរិសុទ្ធិ) សីលរបស់ពួកកល្យាណបុថុជ្ជនដែលប្រកបក្នុងកុសលធម៌ អ្នកមានប្រក្រតីធ្វើឲ្យពេញលេញក្នុងទីបំផុតនៃសេក្ខៈ មិនអាឡោះអាល័យក្នុងកាយនិងជីវិត មានជីវិតលះបង់ហើយ ១

*អបរាមដ្ឋបារិសុទ្ធិសីល* (សីលរបស់ពួកសេក្ខៈ) ព្រោះមិនពាល់ត្រូវដោយអំណាចនៃទិដ្ឋិ, មិនពាល់ត្រូវដោយអំណាចកតរបស់ពួកបុថុជ្ជន គប្បីជ្រាបថា អបរាមដ្ឋបារិសុទ្ធិសីលដែរ ១ ។

*បដិបស្សទ្ធិបារិសុទ្ធិសីល* (សីលរបស់ព្រះខីណាស្រព ជាសាវកនៃព្រះតថាគត និងរបស់ព្រះបច្ចេកពុទ្ធ និងរបស់ព្រះតថាគត ជាអរហន្តសម្មាសម្ពុទ្ធ) គប្បីជ្រាបថា បដិបស្សទ្ធិបារិសុទ្ធិសីល ព្រោះភាវៈនៃសីលនោះ បរិសុទ្ធិដោយស្ងប់ចាកសេចក្ដីក្រវល់ក្រវាយទាំងពួង ១ ។

ពួកទី២ *ដោយអំណាចនៃបហានសីល ១ វេរមណីសីល ១ ចេតនាសីល ១ សំវរសីល ១ អវីតិក្កមសីល ១ ។*

# អធិប្បាយសីលពួកពីរ

*ក្នុងចំណែកនៃសីលមានបការៈ ២ យ៉ាង មានវិនិច្ឆ័យដូច្នេះ៖*

*ក្នុងពួកពីរគូទី១* **គប្បីជ្រាបដូច្នេះថា ៖**

*យំ ភគវតា "ឥទំ កត្តព្វ"ន្តិ បញ្ញត្តសិក្ខាបទ-បូរណំ, តំ* **ចារិត្តំ** *។ ការបំពេញនូវសិក្ខាបទណា ដែលព្រះមានព្រះភាគ ទ្រង់បញ្ញត្តហើយថា* **"នេះលោកគប្បីធ្វើ"** *ដូច្នេះ នោះឈ្មោះថា* **ចារិត្តសីល** *។*

*យំ "ឥទំ ន កត្តព្វ"ន្តិ បដិក្ខិត្តស្ស អករណំ, តំ* **វារិត្តំ** *។ ការមិនធ្វើនូវអំពើណា ដែលព្រះមានព្រះភាគ ហាមឃាត់ហើយថា* **"នេះលោកមិនគប្បីធ្វើ"** *ដូច្នេះ នោះឈ្មោះថា* **វារិត្តសីល** *។*

*ក្នុងសីលពីរយ៉ាងនោះ មានអត្ថវិគ្រោះដូចតទៅនេះ ជនទាំងឡាយប្រព្រឹត្តក្នុងសីលនោះ គឺថា ប្រព្រឹត្តទៅដោយភាពជាអ្នកមានប្រក្រតីធ្វើឲ្យពេញក្នុងសីលទាំងឡាយ ហេតុដូច្នេះ សីលនោះឈ្មោះថា* **ចារិត្តសីល** *។*

*ជនទាំងឡាយការពារ គឺថា រក្សានូវសិក្ខាបទដែលព្រះមាន-ព្រះភាគ ហាមឃាត់ហើយដោយសីលនោះ ហេតុដូច្នោះ សីលនោះឈ្មោះថា* **វារិត្តសីល** *។*

បណ្ដាសីលពីរយ៉ាងនោះ **ចារិត្តសីល** សម្រេចដោយសទ្ធា និង វិរិយៈ, **វារិត្តសីល** សម្រេចដោយសទ្ធា ។

ក្នុងដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

សីល ឈ្មោះថា **ចរិត្ត** ព្រោះអត្ថថា ជាហេតុប្រព្រឹត្ត គឺចូលដល់ភាពជាអ្នកធ្វើឲ្យបរិបូរណ៍ក្នុងសីលទាំងឡាយ, ចរិត្តនោះឯង ជាចារិត្តសីល ។ ឈ្មោះថា **វារិត្ត** ព្រោះអត្ថថា ជាហេតុបញ្ឈប់ គឺរក្សាខ្លួនទុកចាកសេចក្ដីដែលទ្រង់ហាម ។

ក្នុងគម្ពីរដីកា សង្ខេបត្ថជោតនី ភាគ១ ថា ៖

ឈ្មោះថា **ចរិត្តសីល** ព្រោះអត្ថថា ជាហេតុប្រព្រឹត្ត គឺធ្វើសីលដែលទ្រង់អនុញ្ញាតហើយដោយកាយទ្វារ និងវចីទ្វារ, ចរិត្តសីលនោះឯង ឈ្មោះថា **ចារិត្តសីល** បានដល់ សីលដែលមានការធ្វើជាសមុដ្ឋាន ។ ឈ្មោះថា **វារិត្តសីល** ព្រោះអត្ថថា ជាហេតុហាម គឺធ្វើសេចក្ដីជាវត្ថុដែលទ្រង់ហាម, ម្យ៉ាងទៀត ឈ្មោះថា **វារិត្តសីល** ព្រោះអត្ថថា បំពេញ គឺរក្សាខ្លួនចាកខដែលទ្រង់ហាមហើយនោះ បានដល់ សីលដែលមានការមិនធ្វើជាសមុដ្ឋាន ។

ក្នុងដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

ពាក្យថា "ឥទំ កត្តព្វ"ន្តិ បញ្ញត្តសិក្ខាបទបូរណំ **(ការបំពេញនូវសិក្ខាបទ ដែលទ្រង់បញ្ញត្តហើយថា វត្ថុនេះគួរធ្វើ)**

សេចក្តីថា ការបំពេញសីលគឺសិក្ខាបទដែលទ្រង់បញ្ញត្តទុកយ៉ាងនេះថា អាភិសមាចារិកសីលនេះ គួរធ្វើ គួរបដិបត្តិ ដូច្នេះ ។ ក៏អ្នកបំពេញសីលគឺសិក្ខាបទ ឈ្មោះថា បំពេញ គឺរក្សាសូម្បីនូវសិក្ខាបទ ។ ម្យ៉ាងទៀត សិក្ខានោះឯង ឈ្មោះថា សិក្ខាបទ ព្រោះត្រូវសិក្សា និងព្រោះត្រូវបដិបត្តិ ។ គប្បីប្រកបពាក្យថា **តស្ស បូរណំ** (បំពេញសិក្ខាបទនោះ) ចូលផង ។

ក្នុងដីកា សង្ខេបត្ថជោតនី ភាគ១ ថា ៖

ពាក្យថា បញ្ញត្តសិក្ខាបទបូរណំ **(ការធ្វើឲ្យបរិបូរណ៍ ក្នុងសិក្ខាបទដែលទ្រង់បញ្ញត្តទុក)** បានដល់ ការធ្វើឲ្យបរិបូរណ៍ ចំណែកនៃសិក្ខាបទដែលព្រះអង្គទ្រង់បញ្ញត្តទុកដោយសិក្ខាបទ, ម្យ៉ាងទៀត បានដល់ ការធ្វើឲ្យបរិបូរណ៍ក្នុងសិក្ខាបទនោះឯង ។ មែនពិត ក្នុងសិក្ខាបទទាំងនោះ ភិក្ខុកាលបំពេញសិក្ខាបទមួយឲ្យបរិបូរណ៍ ក៏ឈ្មោះថា ធ្វើឲ្យបរិបូរណ៍ក្នុងសិក្ខាបទសូម្បីក្រៅនេះផង ដូចគ្នា ។

ក្នុងដីកា បរមត្ថមញ្ជូសា ភាគ១ ថា ៖

ពាក្យថា "ឥទំ ន កត្តព្វ"ន្តិ បដិក្ខិត្តស្ស អករណំ **(ការមិនធ្វើនូវអំពើដែលទ្រង់ហាមឃាត់ហើយថា វត្ថុនេះ លោកមិនគប្បីធ្វើ)** សេចក្តីថា ការមិនធ្វើគឺការវៀរខដែលព្រះមានព្រះ-ភាគ ទ្រង់ហាមទុកថា "នេះជាទុច្ចរិត មិនគួរធ្វើ" ដូច្នេះ ។

ដោយបទថា ចរន្តិ តស្មឹ លោកអាចារ្យកាលនឹងអធិប្បាយការដែលសីលជាអធិករណៈថា បុគ្គលអ្នកមានសេចក្តីដល់ព្រមដោយសីលនោះទាំងឡាយ រមែងប្រព្រឹត្តក្នុងសីលនោះ ទើបសម្តែងការដែលសីលជាឋានៈដែលប្រព្រឹត្តទៅ របស់បុគ្គលអ្នកមានសេចក្តីដល់ព្រមដោយសីលនោះទាំងនោះ ដោយបទថា **រមែងប្រព្រឹត្តក្នុងសីលនោះ** ។ ព្រោះហេតុនោះ លោកទើបពោលថា "រមែងប្រព្រឹត្តទៅ ដោយភាពជាអ្នកធ្វើឲ្យបរិបូរណ៍ក្នុងសីលទាំងឡាយ" ។

ពាក្យថា វារិតំ (ដែលទ្រង់ហាម) សេចក្តីថា ដែលហាមទុកថា នេះមិនគួរធ្វើ គឺជាអកប្បិយៈ ។ ពាក្យថា តាយំ (បញ្ឈប់) សេចក្តីថា រមែងបញ្ឈប់ទុកដោយការមិនធ្វើនោះឯង ។ ដែលហាមទុកថា នេះមិនគួរធ្វើ គឺជាអកប្បិយៈ ។ ពាក្យថា តេន (ដោយសីលនោះ) លោកពោលដល់វារិតសីល ។ ឈ្មោះថា **វារិតសីល** ព្រោះអត្ថថា ជាទីហាម ឬជាគ្រឿងហាមរបស់ព្រះសាស្តា បានដល់សិក្ខាបទ ។ ឈ្មោះថា **វារិត្តសីល** ព្រោះអត្ថថា ជាហេតុបញ្ឈប់ទុករបស់អ្នកមិនញុំាងសិក្ខាបទនោះឲ្យកម្រើក ។

ពាក្យថា សទ្ធាវិរិយសាធនំ (សម្រេចដោយសទ្ធា និងវិរិយៈ) សេចក្តីថា គប្បីឲ្យសម្រេចដោយសទ្ធានិងដោយវិរិយៈ គឺសេចក្តីព្យាយាម ។ ក៏បុគ្គលមិនមានសទ្ធា និងខ្ជិលច្រអូស នឹង

ញុាំងវត្តបដិបត្តិឲ្យបរិបូរណ៍មិនបានឡើយ, អ្នកមានសទ្ធាប៉ុណ្ណោះ មានប្រក្រតីឃើញភ័យក្នុងទោស សូម្បីមានប្រមាណតិច ដែលព្រះសាស្តាទ្រង់ហាមទុក រមែងសមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ ដូច្នោះ លោកទើបពោលថា "វារិត្តសីល សម្រេចដោយសទ្ធា" ដូច្នេះ ។

ក្នុងគម្ពីរដីកា សង្ខេបត្ថជោតនី ភាគ១ ថា ៖

ពាក្យថា សទ្ធាវីរិយសាធនំ សេចក្តីថា ព្រះថេរៈសំដៅយក ការលើកឡើងនូវសិក្ខាបទ ទើបពោលថា ការញុាំងវត្តផ្លូវកាយវាចាឲ្យសម្រេចដោយព្យាយាម ។ ក្នុងកាលមិនមានការធ្វើក្នុងសីលដែលទ្រង់ហាម ទើបមិនមានកិច្ចដោយព្យាយាម ដោយហេតុនោះ លោកទើបពោលថា "វារិត្តសីល សម្រេចដោយសទ្ធាតែម្យ៉ាង" ដូច្នេះ ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ :

<u>ក្នុងពួកពីរ នៃគូទី២</u> គប្បីជ្រាបដូច្នេះថា ៖

ការប្រព្រឹត្តិល្អដ៏ប្រសើរ ឈ្មោះថា **អភិសមាចារៈ** ។ អភិសមាចារហ្នឹងឯង ឈ្មោះថា **អាភិសមាចារិក** ។ ម្យ៉ាងទៀត សីលដែលព្រះអង្គបញ្ញត្តហើយ ព្រោះប្រារព្ធនូវអភិសមាចារ ឈ្មោះថា **អាភិសមាចារិកសីល** ។ ពាក្យនេះ ជាឈ្មោះនៃសីល

ដ៏សេសអំពីអាជីវដ្ឋមកៈ ។ សីល ដែលមានភាពជាខាងដើមនៃមគ្គព្រហ្មចរិយៈ ហេតុដូច្នេះ ឈ្មោះថា **អាទិព្រហ្មចរិយកសីល** ។ ពាក្យនេះ ជាឈ្មោះនៃអាជីវដ្ឋមកសីល (សីលមានអាជីវៈជាគម្រប់ ៨) ។ ដ្បិតថា សីលនោះ មានភាពជាខាងដើមនៃមគ្គ ព្រោះសីលនោះ គឺបុគ្គលគប្បីជម្រះក្នុងចំណែកខាងដើមតែម្យ៉ាង ។ ព្រោះហេតុនោះ ទើបព្រះអង្គត្រាស់ថា "ក៏កាយកម្ម វចីកម្ម អាជីវៈនៃបុគ្គលនោះ ជាសភាវៈបរិសុទ្ធល្អ ក្នុងខាងដើមមែនពិត" ។ ម្យ៉ាងទៀត សិក្ខាបទទាំងឡាយណា ដែលព្រះអង្គត្រាស់ថា ជាសិក្ខាបទតូចនិងតូចដោយលំដាប់ ដូច្នេះនេះ ឈ្មោះថា **អាភិសមាចារិកសីល** ។ សិក្ខាបទដ៏សេស ឈ្មោះថា អាទិព្រហ្មចរិយកសីល ។

ម្យ៉ាងទៀត សីល ដែលរាប់បញ្ចូលក្នុងឧភតោវិភង្គ ឈ្មោះថា **អាទិព្រហ្មចរិយកសីល**, ដែលរាប់បញ្ចូលក្នុងខន្ធកវត្ត ឈ្មោះថា **អាភិសមាចារិកសីល** ។ អាទិព្រហ្មចរិយកសីល តែងសម្រេចដោយការសម្រេចនៃអាភិសមាចារិកនោះ ។ ព្រោះហេតុនោះឯង ទើបព្រះអង្គត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ តាមពិតភិក្ខុនោះ មិនបំពេញធម៌ឈ្មោះអាភិសមាចារិកៈហើយ នឹងបំពេញធម៌ឈ្មោះអាទិព្រហ្មចរិយកៈ ដូច្នេះនេះ មិនមែនជាហេតុ ជាទីតាំងទេ" ។

*ដីកា បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖*

*សមាចារដ៏ក្រៃលែង ឈ្មោះថា **អភិសមាចារ**, សីលប្រកបហើយក្នុងអភិសមាចារនោះ, ឬអភិសមាចារនោះ ជាប្រយោជន៍ដល់សីលនេះ ហេតុនោះ សីលនេះ ទើបឈ្មោះថា **អាភិសមាចារិក** ប្រែថា ប្រកបក្នុងអភិសមាចារ ឬមានអភិសមាចារជាប្រយោជន៍ ។*

*សីលឈ្មោះថា **អាទិព្រហ្មចរិយៈ** ព្រោះអត្ថថា ជាខាងដើមនៃព្រហ្មចរិយ, អាទិព្រហ្មចរិយនោះឯង **ជាអាទិព្រហ្មចរិយកំ** ។*

*ដីកា បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖*

*ការប្រព្រឹត្តដោយអើពើដោយល្អ ដែលវិសេសដ៏ក្រៃលែង ព្រោះរាប់បញ្ចូលក្នុងអធិសីលសិក្ខា ឈ្មោះថា **អភិសមាចារ** ដូច្នោះ លោកទើបពោលថា "**ឧត្តមសមាចារោ**" ការប្រព្រឹត្តិដោយអើពើខ្ពស់បំផុត ។ អធិប្បាយថា **អភិសមាចារោ** នោះឯង ជា **អាភិសមាចារិកំ** ដូចយ៉ាងថា **វេនយិកោ** ។ អភិសមាចារ ដោយនិទ្ទេសយ៉ាងឧក្រិដ្ឋ បានដល់ សីលក្នុងមគ្គ និងសីលក្នុងផល, សីលដែលទ្រង់បញ្ញត្តប្រារព្ធចំពោះអភិសមាចារនោះ មានអភិសមាចារនោះជាផល មានអភិសមាចារនោះជាប្រយោជន៍ ឈ្មោះថា **អាភិសមាចារិកសីល** ។ សីលនេះគឺ កាយកម្ម ៣ ដ៏បរិសុទ្ធ វចីកម្ម ៤ ដ៏បរិសុទ្ធ អាជីវៈដ៏បរិសុទ្ធ ឈ្មោះថា **អាជីវដ្ឋមកសីល** (សីលមានអាជីវៈជាគម្រប់ ៨) ។*

ក្នុងអាជីវដ្ឋមកសីលនោះ ការវៀរចាកទុច្ចរិត ៧ ប្រការ ដែលមានអាជីវៈជាហេតុ ឈ្មោះថា **សម្មាអាជីវៈ** ព្រោះដូច្នោះ សូម្បីសម្មាអាជីវៈនោះ ក៏មាន ៧ ប្រការដោយពិត, សូម្បីយ៉ាងនោះ ព្រះមានព្រះភាគ ក៏ត្រាស់ធ្វើអាជីវៈនោះ ឲ្យជាធម៌យ៉ាងដោយភាពជាសម្មាអាជីវៈស្មើគ្នា ។

ម្យ៉ាងទៀត ត្រាស់រួមការវៀរចាកមិច្ឆាជីវៈ ដែលមានមិច្ឆាជីវៈមានកុហនវត្ថុ ៣ ប្រការ ជាទីអាស្រ័យចូលផងថា "អាជីវៈបរិសុទ្ធ" ដូច្នេះ ។ មគ្គនោះឯង ឈ្មោះព្រហ្មចារ្យ ព្រោះជាការប្រព្រឹត្តដ៏ប្រសើរ ដូច្នោះ ទើបឈ្មោះថា មគ្គព្រហ្មចរិយៈ, នៃព្រហ្មចរិយៈនោះ ។

បទថា អាទិភាវក្ខុតំ សេចក្តីថា ដល់ហើយគឺសម្រេចហើយនូវភាពជាធម៌គួរបម្រើន គឺគប្បីឲ្យសម្រេចក្នុងខាងដើម ឈ្មោះថា **អាទិភាវកូតំ** ។

កិញ្ចាបិ ទេសនានុក្កមេន សម្មាទិដ្ឋិ អាទិ, បដិបត្តិក្កមេន បន អាជីវដ្ឋមកសីលំ អាទីតិ ។ សូម្បីសម្មាទិដ្ឋិនឹងជាខាងដើម ដោយលំដាប់នៃទេសនាក៏ពិត, សូម្បីយ៉ាងនោះ អាជីវដ្ឋមកសីល ក៏ជាខាងដើមដោយលំដាប់នៃការបដិបត្តិ ដូច្នេះឯង ។

*បទថា តស្ស សម្បត្តិយា សេចក្តីថា **អាទិព្រហ្មចរិយក-សីលនឹងដល់ព្រម** ក៏ព្រោះអាភិសមាចារិកសីលដល់ព្រម គឺបរិបូរណ៍ ។ ក៏អ្នកណាវៀរសិក្ខាបទសូម្បីដែលស្រាល មាន-ទោសតិចបាន អ្នកនោះនឹងវៀរសិក្ខាបទដែលធ្ងន់មានទោសច្រើន មានសេចក្តីខុសច្រើនបាន ព្រោះដូច្នោះ ទើបមិនមានពាក្យដែលត្រូវពោលតែម្តងដូច្នេះ ។ ក៏ព្រះសូត្ររមែងញ៉ាំងសេចក្តីនេះឲ្យជាក់ច្បាស់ដោយន័យផ្សេងគ្នា ។ បណ្តាពាក្យទាំងនោះ ពាក្យថា ធម្មំ បានដល់ សីល ។ ក៏សីលនោះ លោកហៅថា ធម៌ ព្រោះអត្ថថា ទ្រទ្រង់ទុកនូវគុណវិសេសក្រៃលែងៗ ឡើងទៅ ។*

*<u>ក្នុងពួកពីរនៃគូទី៣</u> គប្បីជ្រាបដូច្នេះថា ៖*

*ហេតុត្រឹមតែការវៀរចាកកម្មទាំងឡាយ មានបាណាតិបាតជាដើម ឈ្មោះថា **វិរតិសីល** ។ ចេតនាជាដើមដ៏សេស ឈ្មោះថា **អវិរតិសីល** ។ (ចាកវិសុទ្ធិមគ្គ)*

*<u>ដីកា</u> បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖*

*សីលឈ្មោះថា **វិរតិ** ព្រោះអត្ថថា ជាគ្រឿងវៀរចាក, ម្យ៉ាងទៀត ឈ្មោះថា **វិរតិ** ព្រោះអត្ថថា វៀរខ្លួនឯង, ម្យ៉ាងទៀត ការវៀរ ឈ្មោះថា **វិរតិ**, ឈ្មោះថា **អវិរតិ** ព្រោះអត្ថថា មិនវៀរ ។*

_ដីកា_ បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖

ដើម្បីនឹងសម្តែងថា វិរតិសីល មិនលាយគ្នានឹងសីលក្រៅនេះ ទាំងកាលមានការសម្បយោគជាដើម (សម្បយោគ គឺការប្រកប ជាមួយគ្នា) លោកទើបពោលថា (ហេតុត្រឹមតែការវៀរ) ដូច្នេះ ។

_ក្នុងពួកពីរនៃគូទី៤_ គប្បីជ្រាបដូច្នេះថា ៖

និស្ស័យពីរយ៉ាងគឺ តណ្ហានិស្ស័យ ១ ទិដ្ឋិនិស្ស័យ ១ ឈ្មោះថា **និស្ស័យ** ។ ក្នុងពីរយ៉ាងនោះ សីលណាដែលបុគ្គល កាលប្រាថ្នានូវសម្បត្តិក្នុងភព ឲ្យប្រព្រឹត្តទៅយ៉ាងនេះថា អាត្មាអញ នឹងបានជាទេវតា ឬថា ជាទេវតាអង្គណាមួយ ដោយសីលនេះ ឈ្មោះថា **តណ្ហានិស្ស័យ** ។

សីលណា ដែលបុគ្គលឲ្យប្រព្រឹត្តទៅហើយ ដោយទិដ្ឋិ ដ៏បរិសុទ្ធ យ៉ាងនេះថា សេចក្តីស្អាតនឹងមានដោយសីលនេះ ឈ្មោះ ថា **ទិដ្ឋិនិស្សិតសីល** (ព្រោះអត្ថថា អាស្រ័យទិដ្ឋិ) ។ ចំណែក សីលណា ជាលោកុត្តរៈផង និងជាលោកិយៈដែលជាគ្រឿងគាំទ្រ (ជាហេតុ) ដល់លោកុត្តរៈនោះផង នេះឈ្មោះថា **អនិស្សិតសីល** (ព្រោះអត្ថថា មិនអាស្រ័យហើយ) ។

*ដីកា បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖*

*បទថា សុទ្ធិទិដ្ឋិយា (ដោយទិដ្ឋិដ៏បរិសុទ្ធ) បានដល់ ដោយទិដ្ឋិដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា សេចក្តីបរិសុទ្ធនៃសង្សារនឹងមានដោយប្រការដូច្នេះ, អធិប្បាយថា លោកុត្តរសីល ។ បទថា តស្សេវ សេចក្តីថា សីលជាអង្គ គឺជាហេតុនៃលោកុត្តរៈនោះឯង, សំដៅសេចក្តីថា ជាឧបនិស្ស័យនៃវិវដ្តៈ ។*

*ដីកា សារត្ថបត្ថជោតនី ភាគ១ ពន្យល់ថា ៖*

*បទថា សុទ្ធិទិដ្ឋិយា (ដោយទិដ្ឋិដ៏បរិសុទ្ធ) បានដល់ ដោយទិដ្ឋិដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា សេចក្តីបរិសុទ្ធនៃសង្សារវដ្តនឹងមានបានដោយហេតុត្រឹមតែសីល ។*

***ក្នុងពួកពីរនៃគូទី៥ គប្បីជ្រាបដូច្នេះថា ៖***

កាលបរិច្ឆេទំ កត្វា សមាទិន្នំ សីលំ **កាលបរិយន្តំ** ។ យាវជីវំ សមាទិយិត្វា តថេវ បវត្តិតំ **អាបាណកោដិកន្តិ** ។

*សីលដែលបុគ្គលធ្វើនូវកិរិយាកំណត់កាល ហើយសមាទានឈ្មោះថា **កាលបរិយន្តសីល** ។ សីលដែលបុគ្គលសមាទានដរាបដល់អស់ជីវិត ហើយឲ្យប្រព្រឹត្តទៅដោយបការៈដូច្នេះឈ្មោះថា **អាបាណកោដិកសីល** ។*

*ដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖*

*ពីរបទថា* កាលបរិច្ឆេទំ កត្វា *(ធ្វើនូវកិរិយាកំណត់កាល) សេចក្តីថា ធ្វើនូវកិរិយាកំណត់ដោយអំណាចកាលវេលា ដោយពាក្យថា* "អជ្ជ រត្តឹ, អជ្ជ ទិវំ : *អស់យប់មួយ និងថ្ងៃមួយ" ជាដើម ។ ដើម្បីសម្តែងថា សីលដែលបុគ្គលសូម្បីមិនធ្វើការកំណត់កាលសមាទានហើយដាច់ក្នុងចន្លោះ សូម្បីសីលដែលបុគ្គលប្រព្រឹត្តហើយដរាបអស់ជីវិត ដោយអំណាច**សម្បត្ត-វិរតិ** មិនជាសីលមានអាបាណកោដិកសីល (ដរាបអស់ជីវិត) ដូច្នេះ ទើបពោលថា* "យាវជីវំ សមាទិយិត្វា តថេវ បវត្តិតំ : *សីលដែលបុគ្គលសមាទានដរាបអស់ជីវិត ហើយឲ្យប្រព្រឹត្តទៅ" ។*

*ក្នុងពួកពីរនៃគូទី៦ គប្បីជ្រាបដូច្នេះថា ៖*

លាភយសញាតិអង្គជីវិតវសេន ទិដ្ឋបរិយន្តំ **សបរិយន្តំ** នាម ។ វិបរីតំ **អបរិយន្តំ** ។ *សីលមានទិដ្ឋិ (ការយល់ឃើញ)ជាទីបំផុត ដោយអំណាចនៃលាភ យស ញាតិ អវយវៈ និងជីវិត ឈ្មោះថា **សបរិយន្តសីល** ។ សីលដែលផ្ទុយគ្នា ឈ្មោះថា **អបរិយន្តសីល** ។*

សមដូចពាក្យដែលព្រះសារីបុត្ត ពោលហើយក្នុងគម្ពីរបដិ-សម្ភិទាថា "សីល ឈ្មោះថា សបរិយន្តសីលនោះ ដូចម្ដេច ? សីលមានលាភជាទីបំផុត ក៏មាន សីលមានយសជាទីបំផុត ក៏មាន សីលមានញាតិជាទីបំផុត ក៏មាន សីលមានអវយវៈជាទីបំផុត ក៏មាន សីលមានជីវិតជាទីបំផុត ក៏មាន" ។

សីលមានលាភជាទីបំផុតនោះ ដូចម្ដេច ?

បុគ្គលពួកខ្លះក្នុងលោកនេះ ប្រព្រឹត្តកន្លងនូវសិក្ខាបទតាមដែលខ្លួនសមាទានហើយ ព្រោះហេតុនៃលាភ ព្រោះបច្ច័យនៃលាភ ព្រោះដំណើរនៃលាភ សីលនេះឯងឈ្មោះថា **លាភបរិយន្តសីល** ។ សូម្បីសីលទាំងឡាយក្រៅនេះ បណ្ឌិតគប្បីឲ្យពិស្ដារដោយឧបាយនេះចុះ ។

សូម្បីពាក្យក្នុងកិរិយាដោះស្រាយនូវអបរិយន្តសីល ព្រះសារី-បុត្ត ពោលថា សីលមិនឈ្មោះថា លាភបរិយន្តនោះ ដូចម្ដេច ?

បុគ្គលពួកខ្លះក្នុងលោកនេះ មិនញុំាងសូម្បីត្រឹមតែចិត្តឲ្យកើតឡើង ដើម្បីប្រព្រឹត្តកន្លងនូវសិក្ខាបទ តាមដែលខ្លួនសមាទានហើយ ព្រោះហេតុនៃលាភ ព្រោះបច្ច័យនៃលាភ ព្រោះដំណើរនៃលាភ បុគ្គលនោះ នឹងប្រព្រឹត្តកន្លងដូចម្ដេចបាន សីលនេះឯងមិនឈ្មោះថា **លាភបរិយន្តសីល** ។ សូម្បីសីលទាំងឡាយក្រៅនេះ បណ្ឌិតគប្បីឲ្យពិស្ដារ ដោយឧបាយនេះដែរ ។

*ក្នុងពួកពីរនៃគូទី៧* *គប្បីជ្រាបដូច្នេះថា ៖*

សព្វម្បិ សាសវំ សីលំ **លោកិយំ** ។ អនាសវំ **លោកុត្តរំ** ។ *សីលសូម្បីទាំងអស់ដែលប្រកបដោយអាសវៈ ឈ្មោះថា* ***លោកិយសីល*** *។ សីលមិនមានអាសវៈ ឈ្មោះថា* ***លោកុត្តរសីល*** *។*

*ដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖*

តេភូមកធម្មជាតន្តិ សីលំ តប្បរិយាបន្នន្តិ អាហ "**សាសវំ សីលំ លោកិយ**"ន្តិ ។ *លោកអាចារ្យពោលថា "សីលដែលប្រកបដោយអាសវៈ ឈ្មោះថា* ***លោកិយសីល****" ដូច្នេះ ព្រោះជាធម្មជាតប្រព្រឹត្តទៅក្នុងភូមិ ៣ ហេតុនោះ សីលទើបរាប់បញ្ចូលក្នុងភូមិ ៣ នោះ ។*

*ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖*

លោកោ បញ្ចុបាទានក្ខន្ធេន យុត្តំ **លោកិយំ** ។ តំ លោកំ ឧត្តរតីតិ **លោកុត្តរំ** ។ *សីលដែលប្រកបដោយឧបាទានក្ខន្ធទាំងឡាយ ៥ ក្នុងលោក ឈ្មោះថា* ***ជាលោកិយៈ*** *។ ឈ្មោះថា* ***លោកុត្តរសីល*** *ព្រោះអត្ថថា កន្លងផុតលោកនោះទៅ ។*

គម្ពីរវិសុទ្ធិមគ្គ លោកពោលទៀតថា ៖

បណ្តាសីល ២ យ៉ាងនោះ លោកិយសីល តែងនាំមកនូវភព ដ៏វិសេសផង និងជាសម្ភារៈនៃការរលាស់ចេញចាកភព ។

ដូចព្រះមានព្រះភាគ ត្រាស់ថា **វិន័យ** ដើម្បីប្រយោជន៍ដល់សេចក្តីសង្រួម, **សេចក្តីសង្រួម** ដើម្បីប្រយោជន៍ដល់សេចក្តីមិនក្តៅក្រហាយចិត្ត, **សេចក្តីមិនក្តៅក្រហាយចិត្ត** ដើម្បីប្រយោជន៍ដល់បាមោជ្ជៈ គឺសេចក្តីរីករាយទន់, **បាមោជ្ជៈ** ដើម្បីប្រយោជន៍ដល់បីតិ គឺសេចក្តីរីករាយដ៏ក្លា, **បីតិ** ដើម្បីប្រយោជន៍ដល់បស្សទ្ធិ គឺសេចក្តីស្ងប់រម្ងាប់, **បស្សទ្ធិ** ដើម្បីប្រយោជន៍ដល់សុខៈ, **សុខៈ** ដើម្បីប្រយោជន៍ដល់សមាធិ, **សមាធិ** ដើម្បីប្រយោជន៍ដល់យថាភូតញ្ញាណទស្សនៈ គឺតរុណវិបស្សនា (វិបស្សនាទន់ខ្ចី), **យថាភូតញ្ញាណទស្សនៈ** ដើម្បីប្រយោជន៍ដល់និព្វិទា គឺពលវិបស្សនា (វិបស្សនាមានកម្លាំង), **និព្វិទា** ដើម្បីប្រយោជន៍ដល់វិរាគៈ គឺអរិយមគ្គ, **វិរាគៈ** ដើម្បីប្រយោជន៍ដល់វិមុត្តិ គឺអរហត្តផល, **វិមុត្តិ** ដើម្បីប្រយោជន៍ដល់វិមុត្តិញ្ញាណទស្សនៈ គឺបច្ចវេក្ខណញ្ញាណ, **វិមុត្តិញ្ញាណទស្សនៈ** ដើម្បីប្រយោជន៍ដល់អនុបាទាបរិនិព្វាន គឺរំលត់មិនឲ្យមានបច្ច័យជាគ្រឿងប្រកាន់តទៅ ។

ព្រះអរហត្តផល ឬព្រះនិព្វានជាគ្រឿងរួចចាកសេចក្តីសៅហ្មងនៃចិត្ត ព្រោះមិនមានឧបាទានជាគ្រឿងប្រកាន់ណា ការពោល

នូវព្រះវិន័យ មានព្រះអរហត្តផល ឬព្រះនិព្វានទុ៎ះជាប្រយោជន៍ ការប្រឹក្សានូវវិន័យ មានព្រះអរហត្តផល ឬព្រះនិព្វានទុ៎ះជាប្រយោជន៍ ការពិចារណានូវវិន័យ មានព្រះអរហត្តផល ឬព្រះ-និព្វានទុ៎ះជាប្រយោជន៍ ការប្រុងស្តាប់នូវវិន័យ ក៏មានព្រះអរហត្ត-ផល ឬព្រះនិព្វានទុ៎ះជាប្រយោជន៍ ។

លោកុត្តរសីល ជាសីលនាំមកនូវការរលាស់ចេញចាកភពផង ជាភូមិនៃបច្ចវេក្ខណញាណផង ។

ដីកា បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖

ភពវិសេសទាំងឡាយ បានដល់ សម្បត្តិភព ។

**លោកុត្តរំ** មគ្គផលចិត្តសម្បយុត្តំ អាជីវដ្ឋមកសីលំ ។ តត្ថ មគ្គសីលំ **ភវនិស្សរណាវហំ ហោតិ, បច្ចវេក្ខណ-ញាណស្ស ច ភូមិ,** ផលសីលំ បន បច្ចវេក្ខណាញាណស្សេវ ភូមិ ។ ***លោកុត្តរសីល*** *បានដល់ សីលដែលមានអាជីវៈជាគម្រប់ ៨ ដែលប្រកបដោយមគ្គចិត្តនិងផលចិត្ត ។ ក្នុងលោកុត្តរសីលនោះ សីលក្នុងមគ្គ* ***ជាគ្រឿងនាំចេញចាកភព និងជាភូមិរបស់បច្ចវេក្ខ-ណញាណ,*** *ចំណែកសីលក្នុងផល ជាភូមិរបស់បច្ចវេក្ខណញាណតែម្យ៉ាង ។*

## អធិប្បាយសីលពួកបី

***សីលពួក ៣ នៃក្រុមទីមួយ*** *គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖*

*សីល ដែលបុគ្គលឲ្យប្រព្រឹត្តទៅដោយឆន្ទៈក្តី ដោយចិត្តក្តី ដោយវីរិយៈក្តី ដោយវិមំសាក្តី ក៏ថោកទាប ឈ្មោះថា* ***ហីនសីល*** *(សីលថោកទាប) ។*

*សីល ដែលបុគ្គលឲ្យប្រព្រឹត្តទៅហើយ ដោយឆន្ទៈជាដើម យ៉ាងកណ្តាល ឈ្មោះថា* ***មជ្ឈិមសីល*** *។*

*សីល ដែលបុគ្គលឲ្យប្រព្រឹត្តទៅហើយ ដោយឆន្ទៈជាដើម ដ៏ប្រណីត ឈ្មោះថា* ***បណីតសីល*** *។*

*ម្យ៉ាងទៀត សីលដែលបុគ្គលសមាទានហើយ ដោយភាពនៃខ្លួនជាអ្នកប្រាថ្នាយស ឈ្មោះថា* ***ហីនសីល*** *។ សីលដែលបុគ្គលសមាទានហើយ ដោយភាពនៃខ្លួនចង់បានផលនៃបុណ្យ ឈ្មោះថា* ***មជ្ឈិមសីល*** *។ សីលដែលបុគ្គលសមាទានហើយ ព្រោះអាស្រ័យនូវភាពជាព្រះអរិយៈ ដោយគិតថា “សីលនេះ គឺយើងគប្បីធ្វើពិត” ឈ្មោះថា* ***បណីតសីល*** *។*

*ម្យ៉ាងទៀត សីលដែលសៅហ្មងហើយដោយទោសទាំងឡាយ មានកិរិយាលើកតម្កើងខ្លួន និងពោលបន្ទាប់អ្នកដទៃជាដើម យ៉ាងនេះថា “អញជាបុគ្គលបរិបូរណ៍ដោយសីល ឯភិក្ខុទាំងឡាយដទៃ*

ជាអ្នកទ្រុស្តសីល មានធម៌ដ៏លាមក” ឈ្មោះថា **ហីនសីល** ។ លោកិយសីល ដែលមិនសៅហ្មងដោយទោសទាំងឡាយ ឈ្មោះថា **មជ្ឈិមសីល** ។ លោកុត្តរសីល ឈ្មោះថា **បណីតសីល** ។

ម្យ៉ាងទៀត សីលដែលបុគ្គលឲ្យប្រព្រឹត្តទៅហើយ ដើម្បីប្រ-យោជន៍ដល់ភព និងភោគៈ ដោយអំណាចនៃតណ្ហា ឈ្មោះថា **ហីនសីល** ។ សីលដែលបុគ្គលឲ្យប្រព្រឹត្តទៅហើយ ដើម្បីប្រយោជន៍ដល់ការរួចផុតរបស់ខ្លួន ឈ្មោះថា **មជ្ឈិមសីល** ។ បារមិតាសីល ដែលព្រះពោធិសត្វធ្វើឲ្យប្រព្រឹត្តទៅ ដើម្បីប្រយោជន៍ដល់ការដោះនូវសត្វទាំងពួង (ឲ្យរួចចាកទុក្ខ) ឈ្មោះថា **បណីតសីល** ។

ដីកា បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖

ឈ្មោះថា **ហីន** (ថោកទាប) ព្រោះអត្ថថា អាក្រក់ជាង មជ្ឈិមសីល និងបណីតសីល ដោយបច្ច័យនិងដោយផល, ឬ សាបសូន្យអំពីគុណទាំងឡាយនៃសីលទាំងនោះ ។ ឈ្មោះថា **បណីតសីល** ព្រោះអត្ថថា នាំទៅកាន់ភាពជាប្រធាន ដោយបច្ច័យទាំងឡាយរបស់ខ្លួន ។ សីលនៅត្រង់កណ្តាល របស់សីលទាំងពីរនោះឯង ឈ្មោះថា **មជ្ឈិមសីល** ។

ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ឈ្មោះថា **ហីនសីល** ព្រោះអត្ថថា សាបសូន្យចាកគុណ

ទាំងឡាយ ។ ឈ្មោះថា **បណីតសីល** ព្រោះអត្ថថា នាំទៅកាន់ភាពជាប្រធាន ។

ដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

គប្បីឃើញថា ការដែលអធិបតីធម៌មានឆន្ទៈជាដើម ជាធម៌អាក្រក់ ក៏ដោយអំណាចអធិមុត្តិដែលអាក្រក់ ។ ជាធម៌ប្រណីតក៏ដោយអំណាចអធិមុត្តិដែលប្រណីត ។ ជាធម៌កណ្តាលៗ ក៏ដោយអំណាចនៅកណ្តាលភាវៈនៃធម៌អាក្រក់និងប្រណីតទាំង ២ នោះ ។ ដូចយ៉ាងថា កម្មជាការដែលលោកចែកដោយប្រភេទ ជាកម្មអាក្រក់ជាដើម ដោយអំណាចការប្រមូលមក យ៉ាងណា, សូម្បីអធិបតីធម៌មានឆន្ទៈជាដើម ក៏យ៉ាងនោះ ជាការដែលលោកចែកដោយអំណាចអាការដែលប្រព្រឹត្តទៅ ។ ក៏អាការដែលប្រព្រឹត្តទៅរបស់អធិបតីធម៌មានឆន្ទៈជាដើមទាំងនោះ គប្បីជ្រាបដោយប្រភេទនៃអធិមុត្តិ ។

ពាក្យថា **ដោយសេចក្តីប្រាថ្នាយស** សេចក្តីថា ដោយសេចក្តីប្រាថ្នាកិត្តិស័ព្ទ និងសេចក្តីសរសើរ ឬដោយសេចក្តីប្រាថ្នាយសបរិវារ ។ ឈ្មោះថា **ព្រោះអាស្រ័យនូវភាពជាព្រះអរិយៈ** សេចក្តីថា ព្រោះខ្ពើមរអើមបាប ដោយគិតថា “មនុស្សដូចយើងគប្បីធ្វើកម្មដូចនេះបានយ៉ាងណា” ។ ពាក្យថា **ដែលមិនសៅហ្មង**

ដោយការលើកតម្កើងខ្លួន និងបន្ទាប់អ្នកដទៃជាដើម និងដែលមិនសៅហ្មងដោយឧបក្កិលេសពួកដទៃ ។ ពាក្យថា **ដើម្បីប្រយោជន៍ដល់ភពនិងភោគៈ** សេចក្តីថា ដើម្បីត្រូវការសម្បត្តិក្នុងភព និងដើម្បីត្រូវការសម្បត្តិ គឺភោគៈ ។

ពាក្យថា **សីលដែលបុគ្គលឲ្យប្រព្រឹត្តទៅហើយ ដើម្បីប្រយោជន៍ដល់ការរួចផុតរបស់ខ្លួន** លោកពោលដល់សីលរបស់ព្រះសាវកពោធិសត្វ និងព្រះបច្ចេកពោធិសត្វ ។ ពាក្យថា **ដើម្បីប្រយោជន៍ដល់ការដោះនូវសត្វទាំងពួង** សេចក្តីថា ដើម្បីប្រយោជន៍ដល់ការដោះសត្វទាំងឡាយចាកគ្រឿងចងគឺសង្សារវដ្ត ។ **បារមិតាសីល** បានដល់ សីលរបស់ព្រះមហាសត្វ ។ ដែលភាពជាសីលបារមី កំណាត់ដោយករុណា និងឧបាយកោសល្ល ប្រារព្ធរកពោធិញាណប្រព្រឹត្តទៅ មានការស្អាត និងការដុះខាត់ដែលខ្ពស់ឡើងឧក្រិដ្ឋក្រៃលែង វៀរចាកការកំណាត់ទេសៈ កាល និងសត្វជាដើម។

<u>ក្នុងពួកបីនៃក្រុមទី២</u> គប្បីជ្រាបដូច្នេះ ៖

សីល ដែលបុគ្គលអ្នកធ្ងន់ក្នុងខ្លួន ចង់ដើម្បីលះបង់នូវមារយាទមិនសមគួរដល់ខ្លួន ឲ្យប្រព្រឹត្តទៅហើយ ដោយសេចក្តីគោរពក្នុងខ្លួន ឈ្មោះថា **អត្តាធិបតេយ្យសីល** (សីលមានខ្លួនជាធំក្រៃលែង) ។ សីល ដែលបុគ្គលអ្នកធ្ងន់ក្នុងលោក ចង់ដើម្បី

ចៀសវៀងនូវសេចក្តីតិះដៀលក្នុងលោកឲ្យប្រព្រឹត្តទៅហើយ ដោយសេចក្តីគោរពក្នុងលោក ឈ្មោះថា **លោកាធិបតេយ្យសីល** ។ សីល ដែលបុគ្គលអ្នកធ្ងន់ក្នុងធម៌ ចង់ដើម្បីបូជានូវភាពនៃធម៌ជាធំ ប្រព្រឹត្តទៅហើយដោយសេចក្តីគោរពក្នុងធម៌ ឈ្មោះថា **ធម្មាធិប-តេយ្យសីល** ។

ដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

ធម្មោ នាមាយំ មហានុភាវោ ឯកន្តនិយ្យានិកោ, សោ ច បដិបត្តិយាវ បូជេតព្វោ ។ តស្មា "ធំ សីល-សម្បទាយ បូជេស្សាមី"តិ ឯវំ **ធម្មមហត្តំ បូជេតុកាមេន**។ ធម្មតាថា ធម៌នេះមានអានុភាពច្រើន ជានិយ្យានិកធម៌ ដោយចំណែកមួយ ក៏ធម៌នោះបុគ្គលគប្បីបូជាដោយការបដិបត្តិនោះឯង ។ ព្រោះហេតុនោះ បុគ្គលអ្នកប្រាថ្នាដើម្បីបូជានូវភាពធំនៃធម៌ ក៏ដោយសេចក្តីគិតយ៉ាងនេះថា "យើងនឹងបូជាធម៌នោះ ដោយសេចក្តីដល់ព្រមនៃសីល" ។

<u>ក្នុងពួកបីនៃក្រុមទី៣</u> គប្បីជ្រាបដូច្នេះ ៖

សីលណា ដែលខ្ញុំពោលថា និស្សិតសីល ក្នុងសីលពួកពីរ សីលនោះ ឈ្មោះថា **បរាមដ្ឋសីល** ព្រោះភាពនៃសីលនោះ គឺតណ្ហានិងទិដ្ឋិទាំងឡាយស្ទាបអង្អែលហើយ ។ សីលដែលជាគុណ

ទំនុកបម្រុងមគ្គ នៃកល្យាណបុថុជ្ជន និងប្រកបដោយមគ្គនៃសេក្ខ-បុគ្គលទាំងឡាយ ឈ្មោះថា **អបរាមដ្ឋសីល** ។ សីលដែលប្រកបដោយផលនៃសេក្ខបុគ្គលទាំងឡាយ ឈ្មោះថា **បដិបស្សទ្ធិសីល** ។

ដីកា បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖

សីល ឈ្មោះថា **បរាមដ្ឋ** ព្រោះអត្ថថា ដែលតណ្ហា ឬទិដ្ឋិស្ទាបអង្អែលហើយ កម្ចាត់ហើយ ។ ដោយន័យផ្ទុយគ្នានឹងបរាមដ្ឋៈនោះ សីល ឈ្មោះថា **អបរាមដ្ឋៈ** ។ សីល ដែលមានកិលេសស្ងប់ហើយ ឈ្មោះថា **បដិបស្សទ្ធិ** ។

ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

សីល ដែលត្រូវតណ្ហានិងទិដ្ឋិ ធ្វើឲ្យនៅក្នុងវិស័យ ឈ្មោះថា **បរាមដ្ឋសីល** ។ សីល ដែលផ្ទុយគ្នាពីបរាមដ្ឋសីលនោះ ឈ្មោះថា **អបរាមដ្ឋៈ** ។ សីល ដែលមានកិលេសស្ងប់ហើយ ឈ្មោះថា **បដិបស្សទ្ធិ** ។

ដីកា បរមត្ថមញ្ជុសា ភាគ១ ថា ៖

បទថា បរាមដ្ឋត្តា សេចក្ដីថា ដែលតណ្ហានិងទិដ្ឋិ ស្ទាប-អង្អែលហើយ ដោយអំណាចសេចក្ដីសាបសូន្យ ។ ពិតមែន តណ្ហានិងទិដ្ឋិទាំងឡាយ ស្ទាបអង្អែលសីលរបស់បុគ្គលអ្នកប្រព្រឹត្តទៅហើយ ដោយការគិតថា "ដោយសីលនេះ យើងនឹងជាទេព (ដូចជា

មហារាជទាំង ៤) ឬទេវតាអង្គណាមួយ (បណ្ដាទេវតាទូទៅដែលមិនប្រាកដ), សេចក្ដីបរិសុទ្ធចាកសង្សារនឹងមានដោយសីលរបស់យើងនេះ” ញ៉ាំងបុគ្គលនោះឲ្យដល់សេចក្ដីសាបសូន្យ ព្រោះការធ្វើមិនឲ្យជាឧបនិស្សយបច្ច័យដល់មគ្គ ។

ពាក្យថា បុថុជ្ជនកល្យាណកស្ស (នៃកល្យាណបុថុជ្ជន) នៃបុគ្គលដែលជាមនុស្សល្អក្នុងបុថុជ្ជនទាំងឡាយ ។ ក៏បុគ្គលដែលជាមនុស្សល្អនោះ សូម្បីជាបុថុជ្ជន ក៏ប្រកបដោយសីលជាដើមដែលមានភាពល្អ ។ ឈ្មោះថា **អបរាមដ្ឋសីល** ព្រោះអត្ថថាដែលកិលេសគ្រឿងស្ទាបអង្អែលទាំងនោះ មិនស្ទាបអង្អែលហើយព្រោះសង្កត់សង្កិន និងព្រោះកាត់ផ្ដាច់ នូវកិលេសគ្រឿងស្ទាបអង្អែលទាំងឡាយបាន ។ ឈ្មោះថា **បដិបស្សទ្ធិសីល** ព្រោះស្ងប់រម្ងាប់ គឺស្ងប់សេចក្ដីខ្វល់ខ្វាយ គឺកិលេសនោះៗ ។

<u>ក្នុងពួកបីនៃក្រុមទី៤</u> គប្បីជ្រាបដូច្នេះថា ៖

សីលណា ដែលភិក្ខុមិនត្រូវអាបត្តិ ធ្វើឲ្យពេញបានហើយ ឬថា ត្រូវហើយ ត្រឡប់ធ្វើតបឲ្យបរិសុទ្ធវិញ សីលនោះ ឈ្មោះថា **វិសុទ្ធសីល** ។ សីលណា ដែលមិនទាន់បានធ្វើតប របស់ភិក្ខុអ្នកត្រូវអាបត្តិហើយ សីលនោះ ឈ្មោះថា **អវិសុទ្ធសីល** ។ សីល

នៃភិក្ខុអ្នកវៀរសក្នុងវត្ថុ ឬក្នុងអាបត្តិ ឬក៏ក្នុងអជ្ឈាចារ ឈ្មោះថា **វេមតិកសីល** ។

បណ្ដាសីលទាំងនោះ សីលដែលមិនបរិសុទ្ធ ព្រះយោគី ត្រូវតែជម្រះឲ្យបរិសុទ្ធ, ក្នុងវេមតិកសីល សេចក្ដីសង្ស័យ គឺព្រះ-យោគី មិនគប្បីធ្វើនូវកិរិយាប្រព្រឹត្តកន្លងនូវវត្ថុ គប្បីបន្ទោបង់ឲ្យស្រឡះនូវសេចក្ដីសង្ស័យ សេចក្ដីសុខនឹងមានដល់ព្រះយោគីនោះ ដោយប្រការយ៉ាងនេះ ។

ដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

ពាក្យថា កតបដិកម្មំ (ធ្វើតបហើយ) សេចក្ដីថា ដែលធ្វើតបវត្តដែលធ្វើហើយតាមធម៌ដោយវុដ្ឋានវិធី និងទេសនាវិធី ។ ក៏ដោយអាការដូចពោលមកនេះ សីលនោះទើបនឹងតាំងនៅតាមប្រក្រតីដើម ។ ព្រោះដូច្នោះ លោកទើបពោលថា “សីលនោះឈ្មោះថា **វិសុទ្ធសីល**” ។

"កតបដិកម្ម"ន្តិ ឥមិនា ច "ន បុនេវំ ករិស្ស"ន្តិ អធិដ្ឋានម្បិ សង្គហិតន្តិ ទដ្ឋព្វំ ។ ម្យ៉ាងទៀត ដោយពាក្យថា **កតបដិកម្មំ** នេះ គប្បីឃើញថា លោករួមសេចក្ដីសូម្បីតាំងចិត្តថា “**ន បុនេវំ ករិស្សំ** : យើងនឹងមិនធ្វើយ៉ាងនេះទៀត” ដូច្នេះទុកផង ។

*ក្នុងពួកបីនៃក្រុមទី៥ គប្បីជ្រាបដូច្នេះថា ៖*

*សីល ដែលសម្បយុត្តហើយដោយអរិយមគ្គ ៤ និងដោយសាមញ្ញផល ៣ ឈ្មោះថា* ***សេខសីល*** *។ សីលដែលសម្បយុត្តដោយអរហត្តផល ឈ្មោះថា* ***អសេខសីល*** *។ សីលក្រៅពីនោះ (គឺលោកិយសីលទាំងអស់) ឈ្មោះថា* ***នេវសេខានាសេខសីល*** *។ សីលមានបការៈ ៣ យ៉ាង ដោយអំណាចនៃសីល មានសេខសីលជាដើមយ៉ាងនេះ ។*

*ដីកា បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖*

*សីល ឈ្មោះថា* ***សេខៈ*** *ព្រោះអត្ថថា កើតក្នុងសិក្ខា, ឬសីលនេះ ជារបស់ព្រះសេខៈ ។ ដែលរាប់បញ្ចូលក្នុងអសេក្ខធម៌ ព្រោះមានកិច្ចនៃសិក្ខាស្រេចអស់ហើយ ឈ្មោះថា* ***អសេខៈ*** *។ ឈ្មោះថា* ***នេវសេខានាសេខៈ*** *ព្រោះផុយគ្នាអំពីសីលទាំងពីរនោះ ។*

*ក្នុងគម្ពីរវិសុទ្ធិមគ្គ ថា ៖*

*ឯក្នុងគម្ពីរបដិសម្ភិទាមគ្គ លោកពោលទុកថា សូម្បីប្រក្រតីរបស់សត្វទាំងឡាយនោះៗ ក្នុងលោក ក៏គេហៅថា សីលដែរ, ព្រោះជនទាំងឡាយតែងពោលថា បុគ្គលនេះ មានសេចក្តីសុខជាប្រក្រតី បុគ្គលនេះ មានសេចក្តីទុក្ខជាប្រក្រតី បុគ្គលនេះ*

មានជម្ងោះ បុគ្គលនេះ មានកិរិយាប្រដាប់ជាប្រក្រតី ដូច្នេះ ដោយអាស្រ័យនូវប្រក្រតីនោះ ព្រោះហេតុណា ព្រោះហេតុនោះ តាមបរិយាយនោះ សីលមានបការៈ ៣ ដោយអំណាចនៃកុសលសីលជាដើមយ៉ាងនេះ ដូច្នេះថា សីលទាំងឡាយ ៣ គឺកុសលសីល ១ អកុសលសីល ១ អព្យាកតសីល ១ ដូច្នេះ ក៏មាន ។

បណ្ដាសីល ៣ យ៉ាងនោះ អកុសល មិនសមសូម្បីដោយអាការៈមួយក្នុងអាការៈទាំងឡាយ មានលក្ខណៈជាដើមនៃសីលដែលអធិប្បាយហើយក្នុងសេចក្ដីនេះទេ ហេតុនោះ អកុសលសីលមិនរាប់បញ្ចូលក្នុងអធិការនេះ ។ ព្រោះហេតុនោះ ភាពនៃសីលនោះមានបការៈ ៣ យ៉ាង គប្បីជ្រាបតាមន័យដែលខ្ញុំបានពោលទុកប៉ុណ្ណោះចុះ ។

## អធិប្បាយសីលពួកបួន

<u>សីលពួក ៤ ក្រុមទីមួយ</u> គប្បីជ្រាបសេចក្ដីវិនិច្ឆ័យដូច្នេះ ៖

ភិក្ខុណា ក្នុងសាសនានេះ សេពគប់នូវជនទ្រុស្តសីល មិនសេពគប់នូវជនអ្នកមានសីល ជាអ្នកល្ងង់ខ្លៅ មិនឃើញទោសក្នុងកិរិយាប្រព្រឹត្តកន្លងនូវវត្ថុ ជាអ្នកច្រើនដោយការត្រិះរិះខុស មិនរក្សាឥន្ទ្រីយ៍ទាំងឡាយ សីលរបស់ភិក្ខុប្រាកដដូច្នេះឯង រមែងឈ្មោះថា **ហានភាគិយៈ** ។

ដីកា បរមត្ថមញ្ជូសា ពន្យល់ថា ៖

សីល ឈ្មោះថា **ហានភាគិយ:** ព្រោះអត្ថថា គប់រកសេចក្ដីសាបសូន្យ ឬមានចំណែកនៃសេចក្ដីសាបសូន្យ ។ សូម្បីក្នុងបទដ៏សេស ក៏ន័យនេះដូចគ្នា ។ (ភាគ ១ ទំព័រ១៣១)

ក៏ភិក្ខុឯណា ក្នុងសាសនានេះ ជាអ្នកមានចិត្តត្រេកអរដោយសីលសម្បត្តិ មិនធ្វើសេចក្ដីប្រាថ្នាឲ្យកើតឡើងក្នុងការប្រកបរឿយៗ ក្នុងកម្មដ្ឋាន សីល ឈ្មោះថា **ឋិតិភាគិយ:** នោះ រមែងមានដល់ភិក្ខុនោះ អ្នកត្រេកអរដោយគុណត្រឹមតែសីល មិនព្យាយាមតទៅទៀត ។

ចំណែកភិក្ខុឯណា មានសីលបរិបូរណ៍ហើយ ប្រឹងប្រែងដើម្បីបានសមាធិ សីលឈ្មោះថា **វិសេសភាគិយ:** រមែងមានដល់ភិក្ខុនោះ ។

ភិក្ខុឯណា មិនត្រេកអរដោយគុណត្រឹមតែសីលទេ តែងប្រកបរឿយៗ នូវការនឿយណាយ សីលឈ្មោះថា **និព្វេធភាគិយ:** រមែងមានដល់ភិក្ខុនោះ ។

ដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

បទថា សីលសម្បត្តិយា បានដល់ ដោយសេចក្ដីបរិបូរណ៍នៃសីល គឺដោយចតុប្បារិសុទ្ធិសីល ។ ពីរបទថា អយជន្តស្ស

ឧត្តរិ (មិនព្យាយាមឡើងតទៅទៀត) សេចក្តីថា មិនព្យាយាមដើម្បីសម្រេចគុណវិសេសក្រៃលែងៗ ឡើងទៅ ។ ច្រើនបទថា ឋិតិភាគិយំ សីលំ ភវតិ (សីលឈ្មោះថា ឋិតិភាគិយៈ) សេចក្តីថា ព្រោះមិនប្រព្រឹត្តទៅព្រមដើម្បីសមាធិ ។ ព្រោះថា នឹងជាច់អស់បាន ថាសីលប្រព្រឹត្តទៅព្រមដើម្បីសមាធិ ក៏ក្នុងកាលសមាធិសម្រេចហើយ ។ បទថា សមាធត្ថាយា (ដើម្បីប្រយោជន៍ដល់សមាធិ) សេចក្តីថា ដើម្បីប្រយោជន៍ដល់ការតាំងចិត្តមាំ ដោយអំណាចសមថៈ ។ បទថា និព្វិទំ សេចក្តីថា គឺនូវវិបស្សនា ។ សព្ទថា **និព្វិទា** ក៏ដើម្បីសម្តែងដល់វិបស្សនាដែលមានកម្លាំង ព្រោះសីល នឹងសម្រេចសេចក្តីជា**និព្វេធភាគិយសីល**បាន សូម្បីដោយហេតុត្រឹមប៉ុណ្ណោះ ។

<u>ក្នុងពួកបួន ក្រុមទី២</u> គប្បីជ្រាបដូច្នេះ ៖

សិក្ខាបទណា ដែលព្រះអង្គទ្រង់បញ្ញត្តប្រារព្ធភិក្ខុទាំងឡាយ និងជាសិក្ខាបទដែលភិក្ខុទាំងនោះត្រូវរក្សាតាម ព្រោះជាបញ្ញត្ត នេះឈ្មោះថា **ភិក្ខុសីល** ។ សិក្ខាបទណា ដែលព្រះអង្គទ្រង់បញ្ញត្តប្រារព្ធភិក្ខុនីទាំងឡាយ និងជាសិក្ខាបទដែលនាងភិក្ខុនីទាំងនោះ ត្រូវរក្សាតាម ព្រោះជាបញ្ញត្ត នេះឈ្មោះថា **ភិក្ខុនីសីល** ។ សីល ១០

របស់ពួកសាមណេរ និងសាមណេរីទាំងឡាយ ឈ្មោះថា **អនុ-បសម្បន្នសីល** ។ សិក្ខាបទ ៥ ជាប់ដោយនិច្ចសីល (សីលដែលរក្សាជាប្រចាំ) របស់ឧបាសកនិងឧបាសិកាទាំងឡាយ ឬថាកាលមានសេចក្តីឧស្សាហៈ សិក្ខាបទ ១០ សិក្ខាបទ ៨ ជាប់ដោយអង្គនៃឧបោសថ នេះឈ្មោះថា **គហដ្ឋសីល** ។

<u>ក្នុងពួក៤ ក្រុមទី៤</u> គប្បីជ្រាបដូច្នេះ ៖

កិរិយាមិនប្រព្រឹត្តកន្លងនៃមនុស្សទាំងឡាយ អ្នកនៅក្នុងដែនឧត្តរកុរុ ឈ្មោះថា **បកតិសីល** ។ ភាពនៃការប្រព្រឹត្តិមារយាទរបស់ខ្លួនៗ តាមវង្សនៃត្រកូល និងប្រទេស និងលទ្ធិទាំងឡាយឈ្មោះបាសណ្ឌៈ ឈ្មោះថា **អាចារសីល** ។ សីលនៃមាតាព្រះ-ពោធិសត្វ ព្រះអង្គត្រាស់យ៉ាងនេះថា “ម្នាលអានន្ទ នេះជាធម្មតាក្នុងកាលណា ព្រះពោធិសត្វចុះកាន់ផ្ទៃមាតា សេចក្តីប្រាថ្នាក្នុងបុរសប្រកបដោយកាមគុណ មិនកើតឡើងដល់មាតានៃព្រះពោធិសត្វ” ឈ្មោះថា **ធម្មតាសីល** ។ ឯសីលនៃសត្វទាំងឡាយដែលស្អាតមានព្រះមហាកស្សបជាដើមផង របស់ព្រះពោធិសត្វផង ក្នុងជាតិនោះៗ ឈ្មោះថា **បុព្វហេតុកសីល** ។

<u>ដីកា</u> បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

ពាក្យថា **បកតិសីល** គឺសីលតាមសភាវៈ ។ ក៏ពួកអ្នកឧត្តរ-

កុរុទ្វីប មានសីលដែលកំណត់ដោយការកើតក្នុងទីនោះ ។ បទថា **មរិយាទាចារិត្តំ** (ការប្រព្រឹត្តិមារយាទ) សេចក្តីថា ការប្រព្រឹត្តិដែលបុព្វបុរសក្នុងត្រកូលជាដើមនោះៗ តាំងទុក, ដែលជាខេត្តក្នុងការមិនធ្វើវត្ថុដែលមានទោសនោះៗ ។ ក៏ធម៌ប្រចាំត្រកូល ឬធម៌ប្រចាំប្រទេស និងលទ្ធិបាសណ្ឌៈ លោកប្រាថ្នាយកថា "**អាចារសីល**" ។ ក្នុងសេចក្តីនោះ ការដែលពួកព្រាហ្មណ៍ជាដើម មិនផឹកទឹកស្រវឹងជាដើម ឈ្មោះថា ធម៌ប្រចាំត្រកូលមុន, ការដែលអ្នកជនបទកន្លែងខ្លះ មិនបៀតបៀនគ្នាជាដើម ឈ្មោះថា ធម៌ប្រចាំប្រទេស, ធម៌គឺលទ្ធិបាសណ្ឌៈ បានដល់ ឧបដិបត្តិមានយមៈ និងនិយមៈជាដើមរបស់ពួកតិត្ថិយ ។ មែនពិត លទ្ធិរបស់តិត្ថិយរមែងទៅ គឺប្រព្រឹត្តទៅដោយអន្ទាក់គឺទិដ្ឋិ និងអន្ទាក់គឺតណ្ហា ហេតុនោះ លោកទើបហៅថា "បាសណ្ឌៈ" ប្រែថា ទៅដោយអន្ទាក់, មយ៉ាងទៀត លោកហៅថា "បាសណ្ឌៈ" ព្រោះអត្ថថា បោះទៅនូវអន្ទាក់ គឺបៀតបៀនវិន័យរបស់ព្រះអរិយៈ ។

សីលគឺ សិក្ខាបទ ៥ នៃមាតាព្រះពោធិសត្វ ចាត់ជាសីលបរិបូរណ៍ ព្រោះព្រះបាលីថា "ជាធម្មតា ព្រះមាតារបស់ព្រះពោធិសត្វ ជាអ្នកមានសីល" ។

ដោយសព្ទជាដើមថា មហាកស្សបាធិនំ លោកអាចារ្យ

រមែងរួមយកបុគ្គលទាំងឡាយ មាន**នាងភទ្ទា**ជាដើមទុកផង ។ បានឮថា លោកទាំងនោះជាអ្នកមានសីលបរិសុទ្ធល្អតែម្តង រហូតអស់កាលយូរមកហើយ ។ ព្រោះដូច្នោះ លោកទើបពោលថា "របស់សត្វអ្នកបរិសុទ្ធទាំងឡាយ" ។ ពាក្យថា **ក្នុងជាតិនោះៗ** សេចក្តីថា ក្នុងជាតិមានជាតិដែលជាព្រះ**សីលវាជា** និង**មហិសរាជា**ជាដើម ។ ឈ្មោះថា **បុព្វហេតុកសីល** មានហេតុសម្រេចមកគឺក្នុងជាតិមុន ។ ក៏សីលមាន**បកតិសីល**ជាដើម វៀរចាកការសមាទាន ក៏មានលក្ខណៈមិនប្រព្រឹត្តកន្លង គប្បីឃើញថា លោកសង្គ្រោះចូលក្នុងសម្បត្តវិរតិ ។

<u>ក្នុងពួក៤ ក្រុមទី៤</u> គប្បីជ្រាបដូច្នេះ ៖

សីលឯណា ដែលព្រះមានព្រះភាគ ពោលហើយយ៉ាងនេះថា "ឥធ ភិក្ខុ សីលវា ហោតិ បាតិមោក្ខសំវរសំវុតោ វិហរតិ អាចារគោចរសម្បន្នោ អណុមត្តេសុ វជ្ជេសុ ភយទស្សាវី សមាទាយ សិក្ខតិ សិក្ខាបទេសុ, ភិក្ខុក្នុងសាសនានេះ ជាអ្នកមានសីល សង្រួមក្នុងបាតិមោក្ខសំវរៈ បរិបូរណ៍ដោយអាចារៈនិងគោចរៈ ជាអ្នកឃើញភ័យក្នុងទោសសូម្បីបន្តិចបន្តួច សមាទានសិក្សាក្នុងសិក្ខាបទទាំងឡាយ" សីលនេះ ឈ្មោះថា **បាតិមោក្ខសំវរសីល** ។

ក៏សីលឯណា ដែលព្រះអង្គត្រាស់ថា "សោ ចក្ខុនា រូបំ ទិស្វា ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី, យត្វាធិក-រណមេនំ ចក្ខុន្ទ្រិយំ អសំវុតំ វិហរន្តំ អភិជ្ឈា ទោមនស្សា ចាបកា អកុសលា ធម្មា អន្វាស្សវេយ្យុំ, តស្ស សំវរាយ បដិបជ្ជតិ, រក្ខតិ ចក្ខុន្ទ្រិយំ, ចក្ខុន្ទ្រិយេ សំវរំ អាបជ្ជតិ ។ សោតេន សទ្ទំ សុត្វា ។បេ។ ឃានេន គន្ធំ ឃាយិត្វា ។បេ។ ជិវ្ហាយ រសំ សាយិត្វា ។បេ។ កាយេន ផោដ្ឋព្វំ ផុសិត្វា ។បេ។ មនសា ធម្មំ វិញ្ញាយ ន និមិត្តគ្គាហី ហោតិ នានុព្យញ្ជនគ្គាហី ។ ភិក្ខុនោះបានឃើញរូបដោយចក្ខុហើយ តែមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ, ឯអភិជ្ឈា និងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមក តែងតែគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមចក្ខុន្ទ្រិយណា ក៏ប្រតិបត្តិដើម្បីសេចក្តីសង្រួមនូវចក្ខុន្ទ្រិយនោះ រក្សានូវចក្ខុន្ទ្រិយនោះ ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ ។ ឮសំឡេងដោយត្រចៀក ។ល។ ធំក្លិនដោយច្រមុះ ។ល។ ភ្លក់រសដោយអណ្តាត ។ល។ ប៉ះពាល់សម្ផស្ស ដោយកាយ ។ល។ ដឹងច្បាស់នូវធម្មារម្មណ៍ ដោយចិត្ត ហើយមិនកាន់យកនូវនិមិត្ត ។ល។ ដល់នូវការសង្រួមក្នុងមនិន្ទ្រិយនោះ" ដូច្នេះ សីលនេះ ឈ្មោះថា

ឥន្ទ្រិយសំវរសីល ។

ក៏កិរិយាវៀរចាកការចិញ្ចឹមជីវិតខុសណា ដែលប្រព្រឹត្តទៅហើយ ដោយអំណាចនៃកិរិយាប្រព្រឹត្តកន្លងនូវសិក្ខាបទ ៦ ដែលព្រះអង្គបញ្ញត្តហើយ ព្រោះហេតុនៃអាជីវៈ ព្រោះដំណើរនៃអាជីវៈ និងដោយអំណាចនៃបាបធម៌ទាំងឡាយ មានយ៉ាងនេះជាដើម គឺ “ការកុហក (**កុហនា**) ការលលួង (**លបនា**) ភាពនៃការធ្វើនូវនិមិត្ត (**នេមិត្តិកតា**) ភាពនៃកិរិយានិយាយកំហែង (**និប្បេសិកតា**) ភាពនៃការយកលាភទាក់លាភ (**លាភេន លាភំ និជិគីសនតា**)” សីលនេះឈ្មោះថា **អាជីវបារិសុទ្ធិសីល** ។

ការប្រើប្រាស់បច្ច័យ ៤ បរិសុទ្ធដោយការពិចារណា ដែលព្រះអង្គត្រាស់ហើយដោយន័យជាដើមថា “ភិក្ខុពិចារណាហើយដោយឧបាយនៃបញ្ញា សេពនូវចីវរត្រឹមតែដើម្បីការពារនូវត្រជាក់” ដូច្នេះជាដើម សីលនេះ ឈ្មោះថា **បច្ចយសន្និស្សិតសីល** ។

ក្នុងដីកា បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖

បទថា អាចារគោចរសម្បន្នោ (បរិបូរណ៍ដោយអាចារៈនិងគោចរៈ) នេះ ជាពាក្យសម្តែងដល់ធម៌ដែលជាឧបការៈដល់បាតិមោក្ខសំវរសីល និងគុណដែលនឹងគប្បីសម្រេចខ្ពស់ឡើងៗទៅ ។ បទទាំងឡាយថា អណុមត្តេសុ វជ្ជេសុ ភយទស្សាវី

នេះ ជាពាក្យសម្តែងថា មិនឃ្លាតចាកបាតិមោក្ខសំវរសីល ។ បទថា សមាទាយ ជាពាក្យសម្តែងដល់ការកាន់យកនូវសិក្ខាបទទាំងឡាយ ដោយមិនមានចំណែកសេសសល់ ។ បទថា សិក្ខតិ ជាពាក្យសម្តែងដល់ភាពជាអ្នកមានការព្រមព្រៀងក្នុងសិក្ខា ។ បទថា សិក្ខា-បទេសុ ជាពាក្យសម្តែងដល់ធម៌ដែលនឹងគប្បីសិក្សា ។

ពាក្យថា **ឃើញហើយ តែមិនកាន់យកនូវនិមិត្ត មិនកាន់យកនូវអនុព្យញ្ជនៈ**, សេចក្តីថា ទ្រង់សម្តែងដល់ឧបាយនៃសំវរៈ ។ ពាក្យថា **អភិជ្ឈានិងទោមនស្ស ដែលជាអកុសលធម៌ដ៏លាមកតែងតែគ្របសង្កត់នូវបុគ្គលដែលមិនសង្រួមចក្ខុន្ទ្រិយនុ៎ះ ព្រោះហេតុមិនបានសង្រួមចក្ខុន្ទ្រិយណា** សេចក្តីថា ទ្រង់សម្តែងធម៌ដែលជាបដិបក្ខចំពោះសំវរៈ និងទោសក្នុងធម៌ដែលជាបដិបក្ខចំពោះសំវរៈនោះ ។ ពាក្យថា **ប្រតិបត្តិដើម្បីសេចក្តីសង្រួម** សេចក្តីថា ទ្រង់សម្តែងដល់សេចក្តីដែលសតិ ជាធម៌ដែលគប្បីចូលទៅតាំងទុកមុនតែម្តង ។ ពាក្យថា **រក្សានូវចក្ខុន្ទ្រិយ** សេចក្តីថា ទ្រង់សម្តែងថា ការគ្រប់គ្រងចក្ខុន្ទ្រិយ ក៏គឺការញ៉ាំងសតិឲ្យចូលទៅតាំងទុកនោះឯង ។ ពាក្យថា **ដល់នូវសេចក្តីសង្រួមក្នុងចក្ខុន្ទ្រិយ** សេចក្តីថា ទ្រង់សម្តែងថា សតិនោះឯងដែលជាយ៉ាងនោះ ជាសំវរៈក្នុងចក្ខុន្ទ្រិយនេះ ។ ភ្ជាប់សេចក្តីថា ដោយអំណាចនៃការឈានចុះ ។

បរិសុទ្ធ គឺមិនសៅហ្មងដោយការពិចារណា គឺបច្ចវេក្ខណៈ ឈ្មោះថា **បដិសង្ខានបរិសុទ្ធោ** (បរិសុទ្ធដោយការពិចារណា) ។ សភាវៈឈ្មោះថា **ចតុបច្ចយបរិភោគោ** ព្រោះអត្ថថា ជាហេតុបរិភោគ បច្ច័យ ៤, បានដល់ ចេតនាដែលមិនមានទោស ដែលប្រព្រឹត្តទៅ ហើយដោយប្រការនោះ ។

## អធិប្បាយបាតិមោក្ខសំវរៈ

ពាក្យថា **ភិក្ខុ** បានសេចក្តីថា កុលបុត្តអ្នកបួសដោយសទ្ធា មានវោហារបានហើយយ៉ាងនេះ ព្រោះភាពនៃកុលបុត្តនោះ ជាអ្នក ឃើញភ័យក្នុងសង្សារ ឬអ្នកទ្រទ្រង់នូវផ្ទាំងនៃសំពត់ដែលគេកាត់ ដាច់ហើយជាដើម ។

សីល ដែលទ្រង់បញ្ញត្តជាសិក្ខាបទ ឈ្មោះថា **បាតិមោក្ខ** ។

តំ ហិ យោ នំ បាតិ រក្ខតិ តំ មោក្ខេតិ មោចយតិ អាបាយិកាទីហិ ទុក្ខេហិ តស្មា បាតិមោក្ខន្តិ វុច្ចតិ ។ ភិក្ខុឯណា ព្យាបាលរក្សាសីលនោះ សីលនោះ រមែង ញុំាងភិក្ខុនោះ ឲ្យរួចរំដោះចាកទុក្ខទាំងឡាយ មានទុក្ខដែលប្រព្រឹត្ត ទៅក្នុងអបាយជាដើម ព្រោះហេតុនោះ ទើបលោកហៅថា **បាតិមោក្ខ** ។

កិរិយាសង្រួម ហៅថា **សំវរៈ** ។ នេះជាឈ្មោះនៃការមិនប្រព្រឹត្តកន្លង ដែលប្រព្រឹត្តទៅក្នុងកាយនិងវាចា ។

សេចក្ដីសង្រួម គឺបាតិមោក្ខ ឈ្មោះថា **បាតិមោក្ខសំវរៈ** ។

ភិក្ខុអ្នកសង្រួមហើយដោយការសង្រួម គឺបាតិមោក្ខនោះ ឈ្មោះថា **បាតិមោក្ខសំវរសំវុតៈ** សេចក្ដីអធិប្បាយថា ភិក្ខុអ្នកចូលដល់ប្រកបព្រមហើយ ។ ពាក្យថា **វិហរតិ** បានសេចក្ដីថា ប្រព្រឹត្តទៅ (គឺផ្លាស់ប្ដូរឥរិយាបថ) ។ (ចាកវិសុទ្ធិមគ្គ)

នៅក្នុងគម្ពីរបរមត្ថមញ្ជូសា ពន្យល់ថា ៖

សីល ឈ្មោះថា **បាតិមោក្ខ** ព្រោះអត្ថថា ជាហេតុឲ្យសត្វឈ្មោះថា បាតីនោះ រួចផុតចាកសង្កិលេសទាំង ៣ មានតណ្ហាជាដើម ។ គប្បីជ្រាបពាក្យថា បាតិមោក្ខនោះ សម្រេចដោយសមាសដូចសព្ទទាំងឡាយ មានសព្ទថា “**កណ្ឋេកាឡោ**” ជាដើម ។

ម្យ៉ាងទៀត ចិត្ត ឈ្មោះថា បាតិ ព្រោះអត្ថថា ធ្វើឲ្យធ្លាក់ទៅ គឺឲ្យធ្លាក់វិនាសទៅក្នុងទុក្ខ ។ សមពិត ដូចទ្រង់ត្រាស់ទុកថា "ចិត្តេន នីយតិ លោកោ, ចិត្តេន បរិកិស្សតិ : ចិត្តតែងនាំសត្វលោកទៅ ចិត្តតែងកើចកន្ទ្រាក់សត្វលោកទៅ” ។

សីល ឈ្មោះថា **បាតិមោក្ខ** ព្រោះអត្ថថា ជាហេតុឲ្យចិត្តឈ្មោះថា បាតីនោះរួចផុតទៅ ម្យ៉ាងទៀត សង្កិលេសមានតណ្ហា

ជាដើម ឈ្មោះថា **បាតី** ព្រោះអត្ថថា ជាហេតុឲ្យធ្លាក់ចុះទៅក្នុងអបាយទុក្ខ និងសង្សារទុក្ខ ។ សមពិត ដូចទ្រង់ត្រាស់ទុកថា "តណ្ហា ជនេតិ បុរិសំ : តណ្ហារមែងញុំាងបុរសឲ្យកើត" និងថា "តណ្ហា ទុតិយោ បុរិសោ : បុរសមានតណ្ហា ជាសំឡាញ់ទីពីរ" ដូច្នេះជាដើម ។ ឈ្មោះថា **បាតិមោក្ខ** ព្រោះអត្ថថា ផុតចាកបាតីនោះ ។

ម្យ៉ាងទៀត អាយតនៈខាងក្នុង ៦ និងខាងក្រៅ ៦ ឈ្មោះថា បាតិ ព្រោះអត្ថថា ជាទីធ្លាក់ចុះទៅ ។ សមដូចទ្រង់ត្រាស់ថា "ឆសុ លោកោ សមុប្បន្នោ, ឆសុ កុព្វតិ សន្ថវំ : លោកកើតឡើងព្រម ព្រោះអាយតនៈ ៦ រមែងធ្វើសេចក្ដីត្រេកអរក្នុងអាយតនៈ ៦ " ។ សីល ឈ្មោះថា **បាតិមោក្ខ** ព្រោះអត្ថថា ផុតចាកបាតិ ពោលគឺអាយតនៈខាងក្នុង ៦ និងអាយតនៈខាងក្រៅ ៦ នោះ ។ ម្យ៉ាងទៀត សង្សារ ឈ្មោះថា **បាតី** ព្រោះអត្ថថា អ្នកមានការធ្លាក់ចុះទៅ គឺវិនាសទៅ ។ សីល ឈ្មោះថា **បាតិមោក្ខ** ព្រោះអត្ថថា ផុតចាកសង្សារនោះ ។

ម្យ៉ាងទៀត ព្រះមានព្រះភាគ ជាធំក្នុងធម៌ ដែលលោកហៅថា **បតិ** ព្រោះជាអធិបតីនៃលោកទាំងពួង ។ ឈ្មោះថា **បាតិមោក្ខ** ព្រោះអត្ថថា ជាហេតុរួចផុត ។ សីល ឈ្មោះថា

**បាតិមោក្ខ** ព្រោះអត្ថថា ជាគ្រឿងរួចផុតនៃព្រះមានព្រះភាគ ឈ្មោះ **បតិ** ព្រោះព្រះមានព្រះភាគ ឈ្មោះថា បតិនោះ ទ្រង់បញ្ញត្តិហើយ, បាតិមោក្ខានោះឯង ជា **បាតិមោក្ខំ** ។

ម្យ៉ាងទៀត សីលជាបតិ ព្រោះអត្ថថា ខ្ពស់បំផុត ដោយភាពជាមូលរបស់សព្វគុណទាំងឡាយនោះផង ជាមោក្ខៈ ព្រោះអត្ថតាមដែលពោលហើយផង ហេតុនោះទើបឈ្មោះថា បតិមោក្ខ ។ បតិមោក្ខនោះឯង ជា **បាតិមោក្ខ** ។ ពិតដូចលោកពោកទុកថា "បាតិមោក្ខន្តិ មុខមេតំ បមុខមេតំ : សេចក្តីថា បាតិមោក្ខនេះ សេចក្តីថា ធម្មជាតនេះជាប្រធាន ធម្មជាតនេះជាមុនដំបូង (នៃកុសលធម៌ទាំងឡាយ) ដូច្នេះ គប្បីអធិប្បាយតទៅ ។

ម្យ៉ាងទៀត សព្ទថា **ប** ជានិបាត ប្រើក្នុងអត្ថថា ប្រការ, សព្ទថា **អតិ** ជានិបាតចុះក្នុងអត្ថថា **អច្ចន្ត** (ចំណែក), ព្រោះហេតុនោះ សីលណា ឈ្មោះថា **បាតិមោក្ខ** ព្រោះញ៉ាំងសត្វឲ្យផុតដោយចំណែកមួយ, ហេតុនោះ សីលនោះ ឈ្មោះថា **បាតិមោក្ខ** ។ ក៏សីលនេះ ខ្លួនឯងរមែងញ៉ាំងសត្វឲ្យរួចផុត គឺរដោះចេញចំណែកមួយ ដោយអំណាចតទង្គប្បហានផង, ដែលប្រកបដោយសមាធិនិងប្រកបដោយបញ្ញា រមែងញ៉ាំងសត្វឲ្យរួចផុត គឺរដោះចេញដោយអំណាចវិក្ខម្ភនប្បហាន និងដោយសមុច្ឆេទប្បហាន ព្រោះ

ហេតុនោះ សីលនោះឈ្មោះថា **បាតិមោក្ខ**; ម្យ៉ាងទៀត សីលនោះឈ្មោះថា **បាតិមោក្ខ** ព្រោះអត្ថថា ជាការរួចផុតចំពោះៗ អធិប្បាយថា ជាការរួចផុតចំពោះចាកទោស គឺការប្រព្រឹត្តិកន្ទងនោះៗ, បតិ-មោក្ខនោះឯង ជា**បាតិមោក្ខ** ។

ម្យ៉ាងទៀត ពាក្យថា **បាតិមោក្ខ** បានដល់ ព្រះនិព្វាន, សីលឈ្មោះថា **បាតិមោក្ខ** ព្រោះអត្ថថា ជារូបប្រៀបត្រង់ចំពោះព្រះ-និព្វានដែលឈ្មោះ មោក្ខៈនោះ ។ មែនពិត សីលសំវរៈជាការរះឡើងគឺការរះឡើងនៃព្រះនិព្វាន ដូចការរះឡើងនៃព្រះអាទិត្យ ដូច្នោះទើបដូចជាចំណែកប្រៀបនៃព្រះនិព្វាននោះ ព្រោះជាការរំលត់កិលេសបានតាមសមគួរ, បតិមោក្ខនោះឯង ជា**បាតិមោក្ខ** ។

ម្យ៉ាងទៀត សីល ឈ្មោះថា **បតិមុក្ខ** ព្រោះអត្ថថា ប្រព្រឹត្តទៅចំពោះមោក្ខៈ (គឺព្រះនិព្វាន) ឬព្រោះអត្ថថា មានមុខចំពោះមោក្ខៈ (គឺព្រះនិព្វាន) បតិមោក្ខៈនោះឯង ជាបាតិមោក្ខ បណ្ឌិតគប្បីជ្រាបសេចក្ដីសំដៅនៃបាតិមោក្ខសព្ទក្នុងអធិការនោះ ដោយប្រការដូចពោលមកនេះ ។

ពាក្យថា ឥរិយតិ ប្រែថា រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ ។ ក៏លោកសម្ដែងការសម្រាកឥរិយាបថ (ឥរិយាបថវិហារ)

*របស់ភិក្ខុដែលតាំងនៅក្នុងសីល គឺបាតិមោក្ខសំវរៈ ដោយពាក្យថា “វិហរតិ” នេះ ។*

## **អនាចារ និងអាចារ**

### **អនាចារ**

កាយិកោ វីតិក្កមោ វាចសិកោ វីតិក្កមោ កាយិកវាចសិកោ វីតិក្កមោ, អយំ វុច្ចតិ អនាចារោ។ សព្វម្បិ ទុស្សីល្យំ អនាចារោ ។ *ការប្រព្រឹត្តិកន្លងប្រព្រឹត្តទៅក្នុងទ្វារកាយ ប្រព្រឹត្តទៅក្នុងទ្វារវាចា ប្រព្រឹត្តទៅក្នុងទ្វារកាយនិងវាចា នេះលោកហៅថា* ***អនាចារ*** *។ រួមសេចក្តីថា ភាពនៃបុគ្គលទ្រុស្តសីលទាំងអស់ ហៅថា* ***អនាចារ*** *។*

ឥធេកច្ចោ វេឡុទានេន វា បត្តទានេន វា បុប្ផ-ផលសិនានទន្តកដ្ឋទានេន វា ចាដុកម្យតាយ វា មុគ្គសូប្យតាយ វា ចារិភដ្យតាយ វា ជង្ឃបេសនិកេន វា អញ្ញតរញ្ញតរេន វា ពុទ្ធបដិកុដ្ឋេន មិច្ឆាអាជីវេន ជីវិកំ កប្បេតិ, អយំ វុច្ចតិ អនាចារោ ។

*ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ចិញ្ចឹមជីវិតដោយការឲ្យឫស្សី ឬឲ្យស្លឹកឈើ ឬឲ្យផ្កាផ្លែ លំអិតសម្រាប់ងូតកក់ និងឈើស្ទន់ ឬដោយភាពជាអ្នកប្រព្រឹត្តបន្ទាបខ្លួន ឬដោយភាពជាអ្នកពោលសម្តី*

ដូចសម្ពស់ណ្តែក ឬដោយភាពជាអ្នកឱបពន្ធូរកូននៃត្រកូល ឬដោយការបម្រើដោយស្នេហ៍ ឬដោយការចិញ្ចឹមជីវិតខុស ដែលព្រះពុទ្ធទ្រង់តិះដៀលហើយឯទៀតៗ នេះហៅថា **អនាចារ** ។

ក្នុងដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

ក្នុងព្រះបាលីនោះ លោកពោលថា “**អាចារគោចរសម្បន្នោ**” ដូច្នេះ ក៏ដើម្បីសម្តែងអាចារសមណៈ និងគោចររបស់សមណៈពិតតែសូម្បីយ៉ាងនោះ ដូចបុគ្គលកាលនឹងប្រាប់ផ្លូវដែលគួរកាន់យក គប្បីប្រាប់ផ្លូវដែលគួរវៀរមុនហើយ ទើបប្រាប់ផ្លូវដែលគួរកាន់យកថា “លោកចូរលះផ្លូវខាងឆ្វេងចេញ ចូរកាន់យកផ្លូវខាងស្តាំទុក” ដូច្នេះ យ៉ាងណា ឬដូចយ៉ាងថា អ្នកដែលបានកម្ចាត់មន្ទិលគឺញើស និងរបស់មិនល្អ ដោយការងូតទឹករាងកាយ ព្រមទាំងសីសៈហើយ ទើបសមគួរចាត់ចែងតែងខ្លួនដោយផ្កាឈើ គ្រឿងក្រអូប និងគ្រឿងលាបជាដើមយ៉ាងណា, អ្នកដែលលះបាបធម៌ហើយ ទើបសមគួរប្រកបដោយកល្យាណធម៌ ក៏ដូច្នោះ ព្រោះហេតុនោះ ព្រះមានព្រះភាគ កាលទ្រង់លើកធម៌ (ទាំង) ២ ឡើងសម្តែងថា “អាចារមាន អនាចារមាន” ដូច្នេះ ហើយទ្រង់ប្រាថ្នានឹងចែកអនាចារមុន ទើបត្រាស់ថា “ក្នុងអាចារនិងអនាចារនោះ អនាចារជាយ៉ាងណា” ដូច្នេះជាដើម ។

បណ្តាពាក្យទាំងនោះ ពាក្យថា **ការប្រព្រឹត្តិកន្លងផ្លូវកាយ** បានដល់ កាយទុច្ចរិត ៣ ។ ពាក្យថា **ការប្រព្រឹត្តិកន្លងផ្លូវវាចា** បានដល់ វចីទុច្ចរិត ៤ យ៉ាង ។ ពាក្យថា **ការប្រព្រឹត្តិកន្លងផ្លូវកាយនិងវាចា** បានដល់ ទុច្ចរិតទាំងពីរ ទាំងផ្លូវកាយនិងផ្លូវវាចានោះ ។

ព្រះមានព្រះភាគ បានត្រាស់សម្តែងការប្រព្រឹត្តិកន្លងសីលដែលមានអាជីវៈជាគម្រប់ ៨ ដោយប្រការដូច្នេះហើយ ។ ឥឡូវនេះ ដើម្បីនឹងសម្តែងអនាចារៈផ្លូវចិត្ត ទើបសម្តែងថា "ភាពជាអ្នកទ្រុស្តសីលសូម្បីទាំងអស់ ឈ្មោះថា អនាចារៈ" កាលនឹងទ្រង់សម្តែងអនាចារៈ ជាចំណែកក្នុងបណ្តាអនាចារៈទាំងនោះ ទើបត្រាស់ពាក្យជាដើមថា "ភិក្ខុរូបខ្លះ ក្នុងសាសនានេះ សម្រេចការចិញ្ចឹមជីវិតដោយការឲ្យឫស្សីជាដើម" ដូច្នេះ ។ បណ្តាពាក្យទាំងនោះ ពាក្យថា **ដោយការឲ្យឫស្សី** សេចក្តីថា ដោយការឲ្យឫស្សីដោយត្រូវការនឹងឲ្យកើតបច្ច័យ ។ សូម្បីក្នុងពាក្យ មានពាក្យថាឲ្យស្លឹកឈើជាដើម ក៏មានន័យនោះពិត ។ ពាក្យថា **ឫស្សី** បានដល់ ដើមឫស្សីយ៉ាងណាមួយ នាំមកនូវប្រយោជន៍ដល់មនុស្សទាំងឡាយ ។ **ស្លឹកឈើ** បានដល់ ស្លឹកឈើដើម្បីខ្ចប់ឲ្យក្រអូបវត្ថុដែលមានក្លិនក្រអូបជាដើម ឬស្លឹកត្នោតនិងស្លឹកដូងជាដើម ។ **ផ្កាឈើ** បានដល់ ផ្កាឈើដែលប្រើជាប្រយោជន៍បាន ដល់មនុស្សទាំងឡាយយ៉ាងណាមួយ ។ ផ្លែឈើក៏ដូចគ្នា ។ គ្រឿងងូតទឹក

បានដល់ លំអិតសម្រាប់ផ្លូត មានសិរីសចុណ្ណជាដើម ។ សូម្បីដីស្អិត ក៏សង្គ្រោះចូលក្នុងគ្រឿងផ្លូតទឹកនេះ បានពិត ។

**ឈើសួន់** ជាឈើដែលប្រើដុសជម្រះមាត់បាន ប្រភេទណាមួយ ។ ភាពជាអ្នកប្រចុបប្រចែង គឺដាក់ខ្លួនទុកក្នុងឋានៈទាបដូចទាសៈ ហើយទទួលរាប់រងពាក្យដែលខុសភ្ជាត់របស់អ្នកដទៃពោលពាក្យសសើរ ដើម្បីឲ្យគេស្រឡាញ់រាក់ទាក់ ។ ពាក្យថា **ភាពជាអ្នកមានពាក្យនិយាយដូចសត្វសេក** សេចក្ដីថា ភាពជាអ្នកស្មើដោយសម្លសណ្ដែក គឺការស្វែងរកចិញ្ចឹមជីវិតដោយពាក្យពិតនិងពាក្យឆបោក ។ ដូចយ៉ាងថា កាលសម្លឆ្អិនហើយ សណ្ដែកជាច្រើនឆ្អិន ដែលមិនឆ្អិនមានតិចតួចយ៉ាងណា, ក្នុងការចិញ្ចឹមជីវិតដែលជាប់ដោយពាក្យនិយាយ ពាក្យពិត និងពាក្យឆបោក ក៏ដូច្នោះពាក្យដែលមិនពិតច្រើន ដែលពិត មានតិចតួច ។ ឈ្មោះថា បរិភដតិ ព្រោះអត្ថថា អ្នកថែទាំ គឺអ្នកថែទាំទារករបស់អ្នកដទៃ។ ការងាររបស់អ្នកថែរក្សាទារករបស់អ្នកដទៃ ឈ្មោះថា ធារិភដ្យំ, ពាក្យនេះ ជាឈ្មោះរបស់ការថែទាំទារករបស់ត្រកូលដោយកិច្ចមានការតែងខ្លួនជាដើម ។

**ការនាំដំណឹង** និងសារទៅប្រាប់ក្នុងស្រុកដទៃ តំបន់ដទៃ

*ជាដើម របស់គ្រហស្ថនោះ ឈ្មោះថា ជង្ឃបេសនិកំ (ការនាំដំណឹងដោយស្មនជើង) ។ ពាក្យថា* ***ដោយមិច្ឆាជីវៈយ៉ាងដទៃៗ*** *សេចក្តីថា ដោយមិច្ឆាជីវៈ គឺដោយការស្វែងរកចិញ្ចឹមជីវិតយ៉ាងណាមួយ, បណ្តាការរកបរិភោគ មានការធ្វើពេទ្យ ការផ្លាស់ប្តូរវត្ថុទ្រព្យ និងការចាត់ចំណូលដល់សង្ឃ និងប្រាក់ចំណូលដល់ចេតិយ៍ជាដើម ។ ពាក្យថា* ***ដែលព្រះពុទ្ធទាំងឡាយទ្រង់តិះដៀល*** *សេចក្តីថា ដែលអ្នកប្រាជ្ញទាំងឡាយតិះដៀលហើយ គឺទ្រង់ហាមហើយ ។ ពាក្យថា* ***ដោយមិច្ឆាជីព*** *គឺមិនមែនសម្មាអាជីវៈ ។*

*ពាក្យថា* ***នេះហៅថា អនាចារៈ*** *សេចក្តីថា ទាំងអស់នេះលោកពោលថា "ជាអនាចារៈ" ។ អាចារនិទ្ទេស គប្បីជ្រាបដោយន័យដែលផ្ទុយគ្នាតាមដែលពោលហើយ ។*

## អាចារៈ

កាយិកោ អវីតិក្កមោ វាចសិកោ អវីតិក្កមោ កាយិកវាចសិកោ អវីតិក្កមោ, អយំ វុច្ចតិ អាចារោ ។ សព្វោបិ សីលសំវរោ អាចារោ ។ *ការមិនប្រព្រឹត្តកន្លងទៅក្នុងទ្វារកាយ ក្នុងទ្វារវាចា ក្នុងទ្វារកាយនិងវាចា នេះហៅថា* ***អាចារៈ*** *។ រួមសេចក្តីថា ការសង្រួមក្នុងសីលទាំងអស់ ហៅថា* ***អាចារៈ*** *។*

*ភិក្ខុពួកខ្លះ ក្នុងសាសនានេះ មិនចិញ្ចឹមជីវិតដោយការឲ្យនូវឫស្សី ស្លឹកឈើ ឬឲ្យផ្កាផ្លែ គ្រឿងលំអិត និងឈើស្ទន់ ឬភាពជាអ្នកប្រព្រឹត្តបន្ទាបខ្លួន ឬភាពជាអ្នកពោលសម្ដីដូចសម្លសណ្ដែក ឬភាពជាអ្នកឱបពនូវកូននៃត្រកូល ឬដោយការបម្រើដោយស្មង ឬដោយការចិញ្ចឹមជីវិតខុស ដែលព្រះពុទ្ធទ្រង់តិះដៀលហើយឯទៀតៗទេ នេះហៅថា* **អាចារៈ** ។

## អគោចរ

*ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ជាអ្នកត្រាច់ទៅកាន់សំណាក់ស្រីផ្កាមាស* (***វេសិយាគោចរោ***)*, ឬគោចរទៅកាន់សំណាក់ស្រីមេម៉ាយ* (***វិធវា***)*, គោចរទៅកាន់សំណាក់កុមារីដ៏ចាស់ (ក្រមុំចាស់)* (***ថុល្លកុមារិកា***)*, គោចរទៅកាន់សំណាក់មនុស្សខ្ទើយ* (***បណ្ឌក***)*, គោចរទៅកាន់សំណាក់ភិក្ខុនី* (***ភិក្ខុនី***)*, និងគោចរទៅកាន់ទៀមស្រា* (***បានាគារគោចរោ***)*, ជាអ្នកនៅប្រឡូកប្រឡំដោយពួកស្ដេច រាជ-មហាមាត្យ តិត្ថិយ សាវកនៃតិត្ថិយ, ជាអ្នកនៅប្រឡូកប្រឡំដោយគ្រហស្ថដែលមិនសមគួរ ឬថា ត្រកូលទាំងឡាយឯណា ជាអ្នកមិនមានសទ្ធា មិនជ្រះថ្លា អ្នកជេរនិងប្រទេច អ្នកមិនប្រាថ្នាប្រយោជន៍ មិនប្រាថ្នាគុណ មិនប្រាថ្នាសេចក្ដីសប្បាយ មិនប្រាថ្នាសេចក្ដីក្សេម*

ចាកយោគៈដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ចូលទៅសេពគប់ អន្តុយជិតពួកត្រកូលមានសភាពដូច្នេះនេះ ហៅថា **អគោចរ** ។

## គោចរ

ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ជាអ្នកមិនត្រេកអរត្រាច់ទៅកាន់សំណាក់ស្រីផ្កាមាស ។ល។ មិនគោចរទៅកាន់សំណាក់ទៀមស្រា ជាអ្នកមិននៅច្រឡូកច្រឡំដោយពួកស្ដេច ។ល។ សាវកនៃតិរ្ថិយ ជាអ្នកមិននៅច្រឡូកច្រឡំដោយគ្រហស្ថ ដែលមិនសមគួរ ឬថា ត្រកូលទុំះហ្នឹងឯង ជាអ្នកមានសទ្ធា មានសេចក្ដីជ្រះថ្លា ដូចជាអណ្ដូងទឹក រុងរឿងដោយសំពត់កាសាយៈ ជាទីផ្សព្វផ្សាយនៃឥសីអ្នកប្រាថ្នាប្រយោជន៍ ។ល។ ប្រាថ្នាសេចក្ដីក្សេមចាកយោគៈ ដល់ភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា ចូលទៅសេពគប់ អន្តុយជិត ពួកត្រកូលមានសភាពដូច្នេះ នេះហៅថា **គោចរ** ។

មែនពិត អនាចារ មានពីរយ៉ាងគឺ ផ្លូវកាយ ១ ផ្លូវវាចា ១។

ក្នុងពីរយ៉ាងនោះ អនាចារផ្លូវកាយ ដូចម្ដេច ?

ភិក្ខុពួកខ្លះ ក្នុងសាសនានេះ សូម្បីទៅហើយក្នុងជំនុំសង្ឃ មិនធ្វើនូវសេចក្ដីគោរព ឈរជ្រៀតជ្រែកពួកភិក្ខុជាថេរៈខ្លះ ។ល។ ឬស្ទាបអង្អែលក្បាលក្មេងតូច នេះហៅថា **អានាចារផ្លូវកាយ** ។

អនាចារផ្លូវវាចា ដូចម្ដេច ?

ភិក្ខុពួកខ្លះ ក្នុងសាសនានេះ ទោះបីក្នុងសង្ឃ មិនធ្វើនូវសេចក្តីគោរព មិនប្រាប់ពួកព្រះថេរៈ ក៏ពោលធម៌ ដោះស្រាយ-បញ្ហា សម្តែងបាតិមោក្ខ ឈរពោលខ្លះ ពោលវាសដៃខ្លះ សូម្បីចូលទៅកាន់ចន្លោះផ្ទះ និយាយយ៉ាងនេះនឹងស្ត្រី និងនាងកុមារីថា "នែស្រីឈ្មោះនេះ នែស្រីគោត្រនេះ បបរមានទេ បាយមានទេ យើងនឹងផឹកអ្វី នឹងស៊ីអ្វី បរិភោគអ្វី ឬពោលថា ពួកនាងឲ្យអ្វីដល់យើង" នេះហៅថា **អនាចារផ្លូវវាចា** ។

ឯ**អាចារៈ** បណ្ឌិតគប្បីជ្រាបដោយអំណាចនៃការផ្ទុយនឹង**អនាចារ**នោះ ។

ចំណែកឯភិក្ខុប្រកបដោយសេចក្តីគោរព ប្រកបដោយសេចក្តីកោតក្រែង ដល់ព្រមដោយហិរិនិងឱត្តប្បៈ ស្លៀកសមរម្យ ដណ្តប់សមរម្យ ឈានទៅមុខ ឈានថយក្រោយ សំឡឹងមើល ក្រឡេកមើល បត់ចូលនឹងលាតចេញ គួរជ្រះថ្លា មានចក្ខុដាក់ចុះ ដល់ព្រមហើយដោយឥរិយាបថ មានទ្វារគ្រប់គ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ អ្នកស្គាល់ប្រមាណក្នុងភោជន ប្រកបរឿយៗ ក្នុងការភ្ញាក់រលឹក ប្រកបព្រមហើយដោយសតិនិងសម្បជញ្ញៈ ជាអ្នកប្រាថ្នាតិច ជាអ្នកសន្តោស មិនច្រឡូកច្រឡំ មានព្យាយាមប្រារព្ធហើយ ធ្វើសេចក្តីគោរពក្នុងអាភិសមាចារិកៈ ច្រើនដោយសេចក្តី

គោរពនិងកោតក្រែង នេះហៅថា **អាចារៈ** ។ **អាចារៈ** បណ្ឌិតគប្បីជ្រាបត្រឹមប៉ុណ្ណេះចុះ ។

ក្នុងដីកា បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖

ពាក្យថា **គោចរ** បានដល់ ស្ថានទីគួរចូលទៅដើម្បីបិណ្ឌ-បាតជាដើម ។ ស្ថានទីដែលមិនសមគួរ (ចូលទៅដើម្បីបិណ្ឌបាតជាដើម) ឈ្មោះថា ទីអគោចរ ។ ស្ត្រីពេស្យា ជាគោចររបស់ភិក្ខុនោះ ហេតុនោះភិក្ខុនោះ ឈ្មោះថា មានស្ត្រីពេស្យាជាគោចរ, អធិប្បាយថា ស្ថានទីភិក្ខុគប្បីចូលទៅដោយអំណាចមិត្តសន្ថវៈ ។ ដែលឈ្មោះថា **ស្ត្រីពេស្យា** បានដល់ ពួកស្ត្រីដែលអាស្រ័យរូបចិញ្ចឹមជីវិត ពួកស្ត្រីពេស្យាទាំងនោះ ដែលភិក្ខុមិនគប្បីចូលទៅរកដោយអំណាចមិត្តសន្ថវៈ, ព្រោះនឹងធ្វើអន្តរាយចំពោះភាពជាសមណៈបាន សូម្បីលោកមានចិត្តបរិសុទ្ធ ក៏ជាហេតុតិះដៀលបាន, ព្រោះហេតុនោះ ទាក់ទងនឹងការថ្វាយទក្ខិណាទាន ភិក្ខុក៏ត្រូវតាំងសតិមុនហើយទើបចូលទៅ ។

ស្ត្រីដែលប្តីស្លាប់ ឬស្ត្រីដែលប្តីលែង ហៅថា **ស្រីមេម៉ាយ** ។ ពាក្យថា **ក្រមុំចាស់** បានដល់ ស្ត្រីដែលមិនបានរៀបការ នៅដល់ចាស់, ពាក្យថា **បណ្ឌកៈ** បានដល់ ខ្ទើយ ។ ក៏ពួកខ្ទើយទាំងនោះ មានកិលេសច្រើន មានសេចក្តីក្តៅក្រហាយមិនស្ងប់ ច្រើនទៅដោយការនិយាយដែលអាស្រ័យលោកាមិសៈ, ព្រោះហេតុនោះ

ភិក្ខុមិនគួរចូលជិត ។ ដែលឈ្មោះថា **ភិក្ខុនី** បានដល់ ស្ត្រីដែលប្រព្រឹត្តព្រហ្មចរិយៈលំដាប់ខ្ពស់ ។ សូម្បីភិក្ខុ ក៏ដូចគ្នា ។ អន្តរាយនៃព្រហ្មចរិយៈ គប្បីមានបានដោយថ្ងៃដ៏តិចតួចប៉ុណ្ណោះ ព្រោះការចូលទៅរកដោយការធ្លាប់ស្គាល់ ព្រោះភិក្ខុនិងភិក្ខុនីទាំងនោះ ជាវិសភាគវត្ថុនៃគ្នានឹងគ្នា ដូច្នោះ ទើបមិនគួរចូលទៅរកគ្នា ។ ក្នុងការចូលទៅរកគ្នាទាក់ទងនឹងការសួរសុខទុក្ខជម្ងឺជាដើម ក៏គប្បីតាំងសតិទុក ។

បទថា ចាណាគារំ បានដល់ រោងសុរា។ រោងសុរាជាដើមនោះ នឹងមិនស្វាត់អំពីអ្នកសុរា ។ ភិក្ខុមិនគួរចូលទៅក្នុងរោងសុរានោះ ដោយអំណាចនៃភាពជាអ្នកលេងជាដើម នឹងអ្នកលេងសុរាទាំងនោះ ព្រោះធ្វើសេចក្តីអន្តរាយដល់ព្រហ្មចរិយៈបាន ។

ក្នុងពាក្យជាដើមថា **ជាអ្នកច្រឡូកច្រឡំដោយព្រះរាជា** មានសេចក្តីថា ឈ្មោះថា ព្រះរាជា ក៏គឺអ្នកដែលគ្រងរាជសម្បត្តិ ។ ឈ្មោះថា **មហាអមាត្យនៃព្រះរាជា** គឺអ្នកប្រកបដោយគុណ ឥស្សរិយយស ដូចឥស្សរិយយសរបស់ព្រះរាជា ។ ពាក្យថា **ពួកតិត្ថិយ** គឺពួកអ្នកបួសក្រៅព្រះពុទ្ធសាសនា ដែលមានការយល់ឃើញជាវិបរិត ។ ពាក្យថា **ពួកសាវកតិត្ថិយ** គឺអ្នកដែលរាប់អានមាំទាំ ជាអ្នកដែលឲ្យបច្ច័យក្នុងពួកតិត្ថិយទាំងនោះ ។ ពាក្យថា អននុលោ-

មិគេន សំសគ្គេន *(**ដោយការប្រឡូកប្រឡំដែលមិនសមគួរ**)* *គឺដែលជាសត្រូវចំពោះសិក្ខាទាំង ៣ ដែលជាហេតុអន្តរាយដល់ព្រហ្មចរិយៈ ឬសេចក្តីសាបសូន្យនៃធម៌ជាគ្រឿងដុសខាត់ ។*

*ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖*

**អននុលោមិកេនា**តិ តិស្សន្នំ សិក្ខានំ បច្ចត្ថិកេន កាយវចីសំសគ្គេន សីលាទិវិបត្តិំ សល្លេខបរិហានិំ វា ចាបុណាតិ ។

*ពាក្យថា* អននុលោមិកេន *(**ដែលមិនសមគួរ**) សេចក្តីថា ព្រោះការប្រឡូកប្រឡំដោយផ្លូវកាយនិងវាចា ដែលជាសត្រូវរបស់សិក្ខាទាំង ៣ នោះ ភិក្ខុរមែងដល់សេចក្តីវិបត្តិចាកគុណ មានសីលជាដើម ឬរមែងដល់សេចក្តីសាបសូន្យចាកធម៌ជាគ្រឿងដុសខាត់ ។*

*ក្នុងដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖*

*ក្នុងពាក្យទាំងនោះ ពាក្យថា* អស្សទ្ធានិ *(មិនមានសទ្ធា) សេចក្តីថា វៀរចាកសទ្ធាក្នុងព្រះពុទ្ធជាដើម ។ ព្រោះហេតុនោះឯងឈ្មោះថា ក៏មិនជ្រះថ្លា,ម្យ៉ាងទៀត ព្រោះមិនមានសេចក្តីជឿក្នុងកម្មនិងផលនៃកម្ម ទើបឈ្មោះថា មិនមានសទ្ធា ។ ព្រោះមិនមាន*

សេចក្តីជ្រះថ្លាក្នុងព្រះរតនត្រ័យ ទើបឈ្មោះថា អ្នកមិនមានសេចក្តីជ្រះថ្លា ។

ពាក្យថា **អ្នកជេរ អ្នកគម្រាម** សេចក្តីថា អ្នកជេរដោយអក្កោសវត្ថុ និងដោយអាការគម្រាមកំហែងសម្តែងភ័យ ។ ឈ្មោះថា **អ្នកប្រាថ្នាសេចក្តីវិនាស** ព្រោះអត្ថថា មិនប្រាថ្នាប្រយោជន៍ ប្រាថ្នាតែសេចក្តីវិនាសប៉ុណ្ណោះ ។ ឈ្មោះថា **អ្នកប្រាថ្នាសេចក្តីមិនជាប្រយោជន៍** ព្រោះអត្ថថា មិនប្រាថ្នាប្រយោជន៍ ប្រាថ្នាតែសេចក្តីមិនជាប្រយោជន៍តែម្យ៉ាង ។ ឈ្មោះថា **អ្នកប្រាថ្នាសេចក្តីមិនជាសុខ** ព្រោះអត្ថថា មិនប្រាថ្នាសេចក្តីជាសុខ ប្រាថ្នាតែសេចក្តីមិនជាសុខតែម្យ៉ាងប៉ុណ្ណោះ ។ ឈ្មោះថា **អ្នកមិនប្រាថ្នាសេចក្តីក្សេមចាកយោគ** ព្រោះអត្ថថា មិនប្រាថ្នាសេចក្តីក្សេមចាកយោគៈ គឺសេចក្តីមិនមានភ័យ ប្រាថ្នាតែសេចក្តីមិនក្សេមចាកយោគៈតែម្យ៉ាង។

ក្នុងពាក្យថា **ដល់ភិក្ខុទាំងឡាយនេះ** រួមយកសូម្បីសាមណេរផង ។ ក្នុងពាក្យថា **ដល់ភិក្ខុនីទាំងឡាយនេះ** រួមដល់សិក្ខមានា និងសាមណេរីទាំងឡាយ ។ ក៏ពាក្យនេះ សម្តែងដល់សេចក្តីជាអ្នកប្រាថ្នាដល់អ្នកកាន់សាសនាគ្រប់ចំពូក ។ ពាក្យថា **ត្រកូលមានសភាពបែបនោះ** គឺត្រកូល មានខត្តិយត្រកូលជាដើមដូច្នោះ ។ ពាក្យថា **រមែងសេព** គឺថាអាស្រ័យចិញ្ចឹមជីវិត ។ ពាក្យថា **រមែងគប់រក** គឺចូលទៅរក ។ ពាក្យថា **រមែងចូលទៅ**

**អគ្គុយជិត** គឺចូលទៅរករឿយៗ ពាក្យថា នេះហៅថា សេចក្តីថា នេះគឺស្ត្រីពេស្យាជាដើម ១ ព្រះរាជាជាដើម ១ ត្រកូលដែលមិនមានសទ្ធាជាដើម ១ ។ ឈ្មោះថា **អគោចរ** ព្រោះអត្ថថា ជាគោចរដែលមិនសមគួរ សូម្បីទាំង ៣ ប្រការ សម្រាប់ភិក្ខុអ្នកសេពនូវគោចរនោះៗ ។

ក៏បណ្តាអគោចរទាំងនេះ ស្ត្រីពេស្យាជាដើម ឈ្មោះថា **អគោចរ** ព្រោះជាទីអាស្រ័យនៃកាមគុណ ៥ ។ ដូចទ្រង់ត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ អ្វីជាអគោចរ ជាវិស័យដទៃរបស់ភិក្ខុ ? នេះគឺកាមគុណ ៥" ដូច្នេះ ។ ព្រះរាជាជាដើមជាអគោចរ ព្រោះមិនមែនជាឧបនិស្ស័យនៃសមណធម៌ និងព្រោះជាហេតុនៃទិដ្ឋិវិបត្តិ ព្រោះត្រូវនូវ គឺលាភ និងសក្ការៈបាញ់ ។ ត្រកូលដែលមិនមានសទ្ធាជាដើម ឈ្មោះថា អគោចរ ព្រោះនាំមកនូវសេចក្តីសន្តោសនៃចិត្ត ដោយសេចក្តីសាបសូន្យសទ្ធា ។

ក្នុងនិទ្ទេសនៃគោចរ គប្បីជ្រាបពាក្យមានពាក្យថា "មិនមានស្ត្រីពេស្យាជាគោចរ" ជាដើម ព្រោះអំណាចពាក្យដែលផ្ទុយគ្នានឹងពាក្យដែលពោល ។ ពាក្យថា **ដូចជាអណ្តូងទឹក** បានដល់ដូចស្ថានទីដែលល្មមនឹងឈានចុះបានតាមសប្បាយ ដូចយ៉ាងស្រះបោក្ខរណីដែលគេជីកទុកសម្រាប់ភិក្ខុសង្ឃ និងភិក្ខុនីសង្ឃត្រង់ផ្លូវបំបែកជា ៤ ។ ពាក្យថា **រុងរឿងដោយសំពត់កាសាវពស្ត្រ**

សេចក្តីថា មានពន្លឺតែមួយ ដោយពន្លឺនៃសំពត់កាសាវពណ៌ស្រគត់ដែលភិក្ខុ និងភិក្ខុនីស្លៀកដណ្តប់នោះឯង ។

ពាក្យថា **មានខ្យល់នៃឫសីបក់ទៅមក** សេចក្តីថា មានខ្យល់ដែលកើតអំពីចីវរ មានខ្យល់ដែលកើតអំពីសរីរៈ ត្រង់ឥរិយាបថមានការបត់ចូល និងលាតចេញជាដើម ធ្វើឲ្យកើតពួកឫសី ពោលគឺភិក្ខុ និងភិក្ខុនី អ្នកចូលទៅកាន់ស្រុក និងចេញទៅ បក់ទៅមកគឺបក់ផាត់ ឬកំចាត់សេចក្តីអាក្រក់ចេញទៅ ។

ពាក្យថា **ដោយន័យនេះ** សេចក្តីថា សូម្បីដោយវិធីដែលកំពុងពោលនៅក្នុងខណៈនេះ ។

បទថា សង្ឃគតោ ប្រែថា ទៅកាន់ទីប្រជុំសង្ឃ ។

បទថា អចិត្តីការកតោ ប្រែថា មិនធ្វើសេចក្តីកោតក្រែង, អធិប្បាយថា មិនធ្វើសេចក្តីគោរព ។ បទថា **បៀតជ្រៀត** សេចក្តីថា បៀតជ្រៀតដោយរាងកាយ ឬដោយចីវរ ។ គប្បីភ្ជាប់សេចក្តីថា សូម្បីឈរនៅខាងមុខ ក៏មិនធ្វើសេចក្តីកោតក្រែង ។ ពាក្យថា **ឈរនិយាយខ្ទះ** សេចក្តីថា ឈរនិយាយនៅក្នុងទីជិតដូចឈរជាប់ លោកចរថា ។

បទថា ពាហា វិក្ខេបកោ គឺយោលដៃ ។

បទថា សឧចាហានោ ប្រែថា ពាក់ស្បែកជើង ។ ពាក្យថា ជ្រៀតជ្រែកភិក្ខុជាព្រះថេរៈ សេចក្តីថា ចូលទៅកាន់ទីដែលភិក្ខុជាថេរៈឈរ គឺចូលទៅជិតភិក្ខុជាថេរៈទាំងនោះយ៉ាងក្រៃលែង ។ ដាក់ឧសចូលទៅក្នុងរោងភ្លើង ។ រមែងដាក់ឧសទៅក្នុងចង្ក្រានភ្លើង ។

ពាក្យថា **គេចចេញ** សេចក្តីថា ឈានចេញទៅត្រង់ខាង ។ បន្ទប់តូច ជាបន្ទប់កំបាំងដោយសភាពដែលគេបិទទុក គឺបាំងទុកដោយវាំងននទនិងកំផែងជាដើម ។

បទថា អនាបុច្ឆា ប្រែថា មិនប្រាប់លា ។

បទថា អស្ស ប្រកប អនាចារស្ស (នៃអនាចារៈនោះ)។ ពាក្យថា **ម្យ៉ាងទៀត ភិក្ខុជាដើម** ជាពាក្យក្នុងអដ្ឋកថា ដែលប្រព្រឹត្តទៅហើយ ព្រោះទាក់ទងនឹងការសម្តែងអាចារបស់ភិក្ខុក្នុងទីទាំងពួងដោយពិត, មិនមែនព្រះបាលីក្នុងគម្ពីរនិទ្ទេស ។

**គរុភាព** ឬការធ្វើឲ្យធ្ងន់ ឈ្មោះថា សេចក្តីគោរព ជាហេតុនៃគុណមានសទ្ធា សីល សុតៈ និងចាគៈជាដើម, ឈ្មោះថា អ្នកមានសេចក្តីគោរព ព្រោះអត្ថថា ប្រព្រឹត្តដោយសេចក្តីគោរព ។ ការទទួលស្តាប់ដោយអំណាចសេចក្តីគោរព និងសេចក្តីខ្លាចក្រែងជាដើម ក្នុងគរុដ្ឋានីយបុគ្គលទាំងឡាយ ឈ្មោះថា សេចក្តីកោតក្រែង បានដល់ ការបដិបត្តិរបស់អ្នកមានសេចក្តីកោតក្រែង ។

ឈ្មោះថា អ្នកមានសេចក្ដីកោតក្រែង ព្រោះអត្ថថា ប្រព្រឹត្តទៅដោយសេចក្ដីកោតក្រែង ។ ឈ្មោះថា ដល់ព្រមដោយហិរិ និងឱត្តប្បៈ ព្រោះមានចិត្តអៀនខ្មាស និងព្រោះមានសេចក្ដីខ្លាចក្រែងយ៉ាងវិសេស ។ ឈ្មោះថា ស្លៀកដណ្ដប់រៀបរយ ដោយអំណាចសេចក្ដីបរិបូរណ៍ដោយសេខិយធម៌ ។

ពាក្យថា **ដឹងប្រមាណក្នុងភោជន** សេចក្ដីថា ដឹងប្រមាណក្នុងទីទាំងពួង ជាប់ដោយការស្វែងរក ការទទួល និងការបរិភោគជាដើមនូវបច្ច័យ ៤ ដូចដឹងថា ភោជន ព្រោះជាវត្ថុដែលទឹងគប្បីបរិភោគ ។ បទថា **ប្រកបរឿយៗ នូវជាគរិយធម៌** សេចក្ដីថា ប្រកបហើយរឿងៗ គឺប្រកបហើយ ប្រកបទួទៅហើយនូវជា-គរិយធម៌ ការមនសិការការនៅក្នុងខាងដើមនៃរាត្រី និងខាងចុងនៃរាត្រី គឺប្រកបហើយ សេចក្ដីព្យាយាប្រព្រឹត្តទៅរឿយៗ ហើយក្នុងជាគរិយធម៌នោះ ។ ពាក្យថា **ប្រកបដោយសតិសម្បជញ្ញៈជាដើម** ជាពាក្យសម្ដែងដល់អង្គនៃអាចារៈតាមដែលបានពោលហើយ ។

បទថា អប្បិច្ឆោ គឺមិនមានសេចក្ដីប្រាថ្នា ។ ពាក្យថា សន្តុដ្ឋោ សេចក្ដីថា ត្រេកអរហើយដោយរបស់ដែលមាន ដោយជាអ្នកសន្ដោស មានយថាលាភសន្ដោសជាដើម ។

ពាក្យថា **ធ្វើដោយគោរព** សេចក្ដីថា មានប្រក្រតីធ្វើដោយសេចក្ដីអើពើ ។ ពាក្យថា **ច្រើនទៅដោយសេចក្ដីគោរព និងកោតក្រែង** សេចក្ដីថា ច្រើនទៅដោយការធ្វើសេចក្ដីគោរពក្នុងគរុដ្ឋានីយបុគ្គលទាំងឡាយ ។ ពាក្យថា **នេះហៅថា អាចារៈ** សេចក្ដីថា នេះគឺភាពជាអ្នកមានសេចក្ដីគោរពជាដើម ហៅថា **អាចារៈ** ព្រោះបុគ្គលអ្នកប្រាថ្នានូវប្រយោជន៍ទាំងឡាយ គប្បីប្រព្រឹត្តដោយអើពើ។

## គោចរ ៣ យ៉ាង

ក្នុងគម្ពីរវិសុទ្ធិមគ្គ ៖

ចំណែកខាងគោចរមាន ៣ យ៉ាង គឺ **ឧបនិស្សយគោចរ ១ អារក្ខគោចរ ១ ឧបនិពន្ធគោចរ ១** ។

ឧបនិស្សយគោចរ ដូចម្ដេច ?

ភិក្ខុស្ដាប់នូវធម៌ដែលខ្លួនមិនដែលស្ដាប់ ញ៉ាំងធម៌ដែលខ្លួនស្ដាប់ហើយ ឲ្យច្បាស់លាស់ ឆ្លងនូវសេចក្ដីសង្ស័យ ធ្វើទិដ្ឋិឲ្យត្រង់ សម្រេចចិត្តឲ្យជ្រះថ្លា អាស្រ័យមិត្តណា, មួយវិញទៀត ភិក្ខុកាលសិក្សាតាម តែងចម្រើនដោយសទ្ធា សីល សុតៈ ចាគៈ បញ្ញា អាស្រ័យមិត្តណា មិត្តនោះ ឈ្មោះថា កល្យាណមិត្ត អ្នកប្រកបព្រមដោយគុណ គឺកថាវត្ថុ ១០ នេះហៅថា **ឧបនិស្សយគោចរ** ។

អារក្ខគោចរ ដូចម្តេច ?

ភិក្ខុក្នុងសាសនានេះ ចូលទៅកាន់ចន្លោះផ្ទះ ដើរទៅកាន់ថ្នល់ មានចក្ខុដាក់ចុះ មានប្រក្រតីមើលត្រឹមមួយជួរនឹម ដើរសង្រួម មិនដើរមើលដំរី សេះ រថ ពលថ្មើរជើង ស្ត្រី បុរស មិនដើរមើលលើ មើលក្រោម មិនដើរក្រឡេកមើលទិសតូចធំ ហៅថា **អារក្ខគោចរ** ។

ឧបនិពន្ធគោចរ ដូចម្តេច ?

ភិក្ខុចងក្រៀកចិត្តក្នុងធម៌ពួកណា ធម៌ពួកនោះ គឺសតិប្បដ្ឋាន ៤ សមដូចពាក្យនេះ ដែលព្រះមានព្រះភាគ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ ចុះគោចរនៃភិក្ខុដូចម្តេច ? សតិប្បដ្ឋាន ៤ នេះឯងជារបស់ខ្លួន ជារបស់ព្រះពុទ្ធជាបិតា ជាអារម្មណ៍ នេះហៅថា **ឧបនិពន្ធគោចរ** ។

ភិក្ខុអ្នកចូលទៅប្រកបព្រមដោយអាចារៈនេះផង ដោយគោចរៈនេះផង ដូចពណ៌នាមកនេះ ហេតុនោះឯង ហៅថា អ្នកបរិបូរណ៍ដោយអាចារៈនិងគោចរៈ ។

<u>ក្នុងដីកា</u> បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

**គោចរ** ជាទីចូលទៅអាស្រ័យនៅនៃគុណទាំងឡាយ មានសីលជាដើម ឈ្មោះថា **ឧបនិស្សយគោចរ** ។

គោចរជាគ្រឿងរក្សា (ចិត្ត) ពោលគឺសតិនោះឯង ឈ្មោះថា **អារក្ខគោចរ** ។ គោចរជាគ្រឿងចូលទៅចងចិត្តទុកពោលគឺកម្មដ្ឋាន ឈ្មោះថា **ឧបនិពន្ធគោចរ** ។ កល្យាណមិត្រប្រកបដោយគុណ ដែលជាវត្ថុនៃកថាទីអាស្រ័យវិវដ្ដៈ ១០ មានភាពជាអ្នកប្រាថ្នាតិច ជាដើម ឈ្មោះថា អ្នកប្រកបដោយគុណ គឺកថាវត្ថុ ១០ ។ ព្រោះប្រកបដោយកថាវត្ថុ ១០ នោះឯង បុគ្គលទើបឈ្មោះថា កល្យាណ-មិត្រ ព្រោះអត្ថថា ជាមិត្រមានគុណដែលបណ្ឌិតគប្បីរាប់ គឺជាមនុស្សល្អ ។ លក្ខណៈរបស់កល្យាណមិត្រនោះ នឹងមកខាងមុខ ។ វត្ថុដែលមិនធ្លាប់ស្តាប់ បានដល់ នវង្គសត្ថុសាសន៍ មានសុត្តៈ និងគេយ្យៈជាដើម ។ ពាក្យថា **រមែងបានស្តាប់** សេចក្តីថា រមែងសម្រេចសុតមយញាណឲ្យកើតឡើង ។

**អន្តរឃរ**ន្តិ អន្តរេ អន្តរេ ឃរានិ ឯត្ថ, តំ ឯត-ស្សាតិ វា "អន្តរឃរ"ន្តិ លទ្ធនាមំ គោចរគាមំ បវិដ្ឋោ ។ តត្ថ ឃរេ ឃរេ ភិក្ខាបរិយេសនាយ វីថឹ បដិបន្នោ ។

បទថា **អន្តរឃរំ (ចន្លោះផ្ទះ)** សេចក្តីថា ចូលទៅកាន់គោចរគ្រាមតាមដែលបានឈ្មោះថា "ចន្លោះផ្ទះ" ព្រោះអត្ថថា មានផ្ទះក្នុងចន្លោះៗ, ឬគោចរគ្រាមនេះ មានក្នុងចន្លោះនៃផ្ទះនោះ

*(តាមលំដាប់នៃផ្ទះ) ។ ភិក្ខុដើរទៅតាមផ្លូវដើម្បីស្វែងរកភិក្ខាតែមួយផ្ទះៗ ក្នុងគោចរគ្រាមនោះ ។*

*បទថា* **ឧបនិពន្ធតិ** *ប្រែថា នាំចូលទៅចងទុក ។ ដូចពាក្យដែលបោរាណាចារ្យពោលទុកថា ៖*

**"យថា ថម្ភេ និពន្ធេយ្យ វច្ឆំ ទមំ នរោ ឥធ**

**ពន្ធេយ្យេវំ សកំ ចិត្តំ សតិយារម្មណេ ទឡ្ហំ ។**

*"នរជនក្នុងលោកនេះ កាលចងកូនគោ គប្បីចងទុកត្រង់សសរយ៉ាងណា ភិក្ខុក៏ដូច្នោះ គប្បីចងចិត្តរបស់ខ្លួនទុកឲ្យមាំក្នុងអារម្មណ៍ដោយសតិ" ។*

*ពាក្យថា* ***ធម៌ដែលជាវិស័យជារបស់បិតានៃខ្លួន*** *សេចក្តីថា ធម៌ដែលជាវិស័យ ដែលជារបស់ព្រះសម្មាសម្ពុទ្ធជាបិតានៃខ្លួន, ដែលព្រះអង្គទ្រង់ឃើញហើយ និងទ្រង់សម្តែងហើយ ។*

***ក្នុងគម្ពីរវិសុទ្ធិមគ្គ លោកពោលទៀតថា ៖***

*ពាក្យថា* អណុមត្តេសុ វជ្ជេសុ ភយទស្សាវី ***(មានប្រក្រតីឃើញភ័យក្នុងទោសទាំងឡាយ មានប្រមាណតិច)*** *បានសេចក្តីថា អ្នកមានកិរិយាឃើញភ័យជាប្រក្រតី ក្នុងទោសទាំង*

ឡាយផ្សេងដោយទោស មានកិរិយាមិនក្លែងត្រូវសេខិយវត្ត និង កិរិយាកើតឡើងនៃចិត្តជាអកុសលជាដើម មានប្រមាណតិច ។

ពាក្យថា សមាទាយ សិក្ខតិ សិក្ខាបទេសុ **(សមាទាន សិក្សាក្នុងសិក្ខាបទទាំងឡាយ)** បានសេចក្ដីថា សិក្ខាបទណាមួយ ដែលត្រូវសិក្សាក្នុងសិក្ខាបទទាំងឡាយ កាន់យកនូវសិក្ខាបទទាំង នោះដោយប្រពៃហើយសិក្សា ។

នៅក្នុងគម្ពីរបរមត្ថមញ្ជូសា អធិប្បាយថា ៖

ពាក្យថា អណុមត្តេសុ សេចក្ដីថា គឺមានប្រមាណ តិចយ៉ាងក្រៃលែង ។ បទថា អសញ្ចិច្ច អាបន្នសេខិយ-អកុសលចិត្តុប្បាទាទិភេទេសុ បណ្ឌិតគប្បីឃើញថា **អសញ្ចិច្ច** ជាវិសេសនៈរបស់សេខិយយ៉ាងនេះថា "អសញ្ចិច្ច អាបន្នសេ-ខិយេសុអកុសលចិត្តុប្បាទាទិភេទេសុ"។ ក៏ក្នុងទីនេះ ដោយ ស័ព្ទថា **សេខិយ** លោកកាន់យកសូម្បីវត្តជាដើមថា វត្តដែលមក ក្នុងវត្តខន្ធកៈជាដើម ។ ព្រោះវត្តសូម្បីទាំងនោះ លោកក៏ប្រាថ្នា ថាជា "**សេខិយ**" ដោយអត្ថថា គួរសិក្សា ។ ពិតយ៉ាងនោះ ក្នុង មាតិកា ព្រះមានព្រះភាគ ទ្រង់មិនបានធ្វើការកំណត់សេខិយវត្តទុក ដូចជា**បារាជិក**ជាដើមទេ ។ ក៏ព្រោះធ្វើអធិប្បាយយ៉ាងនេះ ស័ព្ទថា

អសញ្ចិច្ច ថា "អសញ្ចិច្ច អាបន្ន សេខិយា" (*សេខិយវត្ត ដែលមិនមានចេតនាក្លែងកន្លង*) រមែងជាការសម្រេច ។ ក៏ក្នុង សេខិយវត្ត ៧៥ ដែលមកក្នុងមាតិកា ឈ្មោះថា **នោសញ្ញាវិមោក្ខ** មិនមាន, ក៏ក្នុងអធិការនេះ ដោយ**អសញ្ចិច្ច**ស័ព្ទនោះឯង លោក សង្គ្រោះសូម្បីការមិនមានសតិ និងការមិនដឹងទុកផង ។

តែអាចារ្យពួកខ្លះ ពោលទុកក្នុងរឿងនេះថា ដោយស័ព្ទថា **មិនមានចិត្តក្លែងកន្លង** លោកកាន់យកអាបត្តិដែលជាអចិត្តក: ពាក្យ នោះត្រឹមតែជាមតិរបស់អាចារ្យពួកខ្លះទាំងនោះ ។ ព្រោះសូម្បី បណ្ដាគរុកាបត្តិ អាបត្តិខ្លះ ជាអចិត្តកក៏មាន ព្រោះក្នុងទីនេះ ទ្រង់ ប្រាថ្នាយកទោសស្រាលជាងទោសទាំងអស់ ដែលនឹងត្រូវធ្វើតប ដោយការអធិដ្ឋាន គឺការតាំងចិត្តសង្រួមតទៅ ឬធ្វើតបដោយការ សម្ដែងអាបត្តិចេញ ។

ព្រោះដូច្នោះ លោកពោលថា "យានិ តានិ វជ្ជានិ អប្បមត្តកានិ ឱរមត្តកានិ លហុកានិ លហុសម្មតានិ" ជាដើម ។ (ទោសទាំងឡាយនេះណា មានប្រមាណតិច មាន ប្រមាណស្រាល ដឹងថាស្រាល) ។ ដោយអាទិស័ព្ទ គប្បីឃើញ ការសង្គ្រោះទោសដែលមិនដល់សេចក្ដីជាអាបត្តិ ដែលមិនគប្បី ប្រព្រឹត្តកន្លងទុក ដើម្បីសេចក្ដីបរិសុទ្ធនៃ**បាតិមោក្ខសំវរសីល** ។

**ភយទស្សាវីតិ** បរមាណុមត្តំ វជ្ជំ អដ្ឋសដ្ឋិយោជនសតសហស្សុព្វេធសិនេរុបព្វតសទិសំ កត្វា ទស្សនសភាវោ, សព្វលហុកំ វា ទុក្កដិតមត្តំ បារាជិកសទិសំ កត្វា ទស្សនសភាវោ ។

*ពាក្យថា **មានប្រក្រតីឃើញជាភ័យ** សេចក្ដីថា មានសភាវៈដែលឃើញទោសមានប្រមាណតិចយ៉ាងក្រៃលែង ធ្វើប្រាជកដូចប៉ុនភ្នំសិនេរុខ្ពស់ដល់ទៅ ៦.៨០០.០០០ យោជន៍, ឬមានសភាវៈឃើញអាបត្តិត្រឹមតែទុក្កដិត ដែលមានទោសស្រាលជាងអាបត្តិទាំងពួង ធ្វើឲ្យប្រាជកដូចប៉ុនអាបត្តិបារាជិក ។*

*ពាក្យថា* យំ កិញ្ចិ *(**សីលយ៉ាងណាមួយ**) គឺសីលដែលគប្បីសិក្សា ដែលគប្បីបដិបត្តិ ដែលគប្បីបំពេញសិក្ខាបទណាមួយដែលផ្សេងដោយមូលបញ្ញត្តិ អនុបញ្ញត្តិ សព្វត្ថបញ្ញត្តិ បទេសបញ្ញត្តិជាដើម ។ ពាក្យថា* សម្មា អាទាយ *(**កាន់យកដោយល្អ**) បានដល់ កាន់យកហើយដោយប្រពៃនោះឯង គឺដោយគោរពនិងដោយប្រការទាំងពួង ។*

*<u>សួរថា</u> ក៏សេចក្ដីដល់ព្រមដោយអាចារៈនិងគោចរៈនេះ រាប់បញ្ចូលក្នុងបាតិមោក្ខសំវរសីល ឬមិនរាប់បញ្ចូល ?*

ឆ្លើយថា រាប់បញ្ចូល ។ ក៏បើយ៉ាងនោះ ហេតុអ្វីទើបត្រូវពោលការដល់ព្រមដោយអាចារៈ និងគោចរៈទុកទៀត លោកអាចារ្យពោលពាក្យថា "ក៏ក្នុងអធិការនៃបាតិមោក្ខសំវរនេះ" សំដៅយកពាក្យជំទាស់ ពោលទុកទៀត ។

## អធិប្បាយក្នុងឥន្ទ្រិយសំវរសីល

ចំណែកឥន្ទ្រិយសំវរសីល ដែលទ្រង់សម្ដែងទុកដោយន័យជាដើមថា "**ភិក្ខុឃើញនូវរូបដោយចក្ខុ**" ដូច្នេះជាដើម ក្នុងលំដាប់នៃបាតិមោក្ខសំវរសីលនោះឯណា, ក្នុងពាក្យទាំងនោះ ពាក្យថា សោ **(នោះ)** បានដល់ ភិក្ខុនោះស្ថិតនៅហើយក្នុងបាតិមោក្ខសំវរសីល ។ ពាក្យថា ចក្ខុនា រូបំ ទិស្វា **(ឃើញរូបដោយចក្ខុ)** សេចក្ដីថា ឃើញរូបដោយចក្ខុវិញ្ញាណ ដ៏អាចក្នុងកិរិយាឃើញនូវរូប មានវោហារបានហើយថា ចក្ខុដូច្នេះ ដោយអំណាចនៃហេតុ ។ ឯពាក្យបោរាណាចារ្យពោលថា **ចក្ខុ មិនឃើញរូបទេ ព្រោះមិនមានចិត្ត សូម្បីចិត្តក៏មិនឃើញ ព្រោះមិនមានចក្ខុ លុះតែអារម្មណ៍ប៉ះនឹងទ្វារ ទើបឃើញដោយចិត្តមានចក្ខុប្បសាទជាទីតាំង** ឯពាក្យប្រាកដដូច្នោះនុ៎ះ ឈ្មោះថា ជាពាក្យប្រកបដោយសម្ភារៈ ដូចជាពាក្យក្នុងប្រយោគទាំងឡាយថា បាញ់ដោយធ្នូជាដើម ។ ព្រោះហេតុនោះ

ពាក្យថា ឃើញរូបដោយចក្ខុវិញ្ញាណនេះឯង ជាសេចក្តីអធិប្បាយក្នុងពាក្យនុ៎ះ ។

នៅក្នុងគម្ពីរបរមត្ថមញ្ជុសា ភាគ១ ទំព័រ១៩២ ពន្យល់ថា ៖

ក្នុងពាក្យថា ចក្ខុនា រូបំ ទិស្វា **(ឃើញរូបដោយចក្ខុ)** នេះ បើចក្ខុគប្បីឃើញរូបបានសោត, សូម្បីបុគ្គលអ្នកព្រមព្រៀងដោយវិញ្ញាណដទៃ ក៏នឹងគប្បីឃើញបាន, តែមិនមែនមានដូច្នោះទេ, ព្រោះហេតុអ្វី ? ព្រោះចក្ខុមិនមានចិត្ត ។ ដោយហេតុនោះលោកទើបពោលថា "**ចក្ខុ** មិនឃើញរូបទេ ព្រោះមិនមានចិត្ត" ។ បើថា វិញ្ញាណគប្បីឃើញរូបសោត, ក៏នឹងគប្បីឃើញរូបនោះសូម្បីនៅខាងក្រោជញ្ជាំងជាដើមបាន ព្រោះភាពដែលអ្វីៗ មិនបាំងគ្នា, សូម្បីខនេះក៏មិនមាន ព្រោះវិញ្ញាណគ្រប់ដួង មិនមានការឃើញ ។ ដោយហេតុនោះ លោកទើបពោលថា "ចិត្តក៏មិនឃើញ ព្រោះមិនមានចក្ខុ" ។ ក្នុងពាក្យថា **ឃើញរូបដោយចក្ខុ**នោះ មានសេចក្តីថា វិញ្ញាណដែលអាស្រ័យចក្ខុ រមែងឃើញបាន, វិញ្ញាណយ៉ាងណាមួយ មិនឃើញទេ ។ល។

<u>ក្នុងគម្ពីរវិសុទ្ធិមគ្គ</u> ៖

ន **និមិត្តគ្គាហី**តិ ឥត្ថិបុរិសនិមិត្តំ វា សុភនិមិត្តាទិកំ

វា កិលេសវត្ថុភូតំ និមិត្តំ ន គណ្ហាតិ, ទិដ្ឋមត្តេយេវ សណ្ឋាតិ ។

*ពាក្យថា* ***មិនកាន់យកដោយនិមិត្ត*** *បានសេចក្តីថា មិនកាន់យកនិមិត្ត ថាស្រី ថាប្រុស ឬនូវនិមិត្តជាវត្ថុឲ្យកើតកិលេសមានសុភនិមិត្តជាដើម គឺតាំងទុកត្រឹមតែការឃើញប៉ុណ្ណោះ ។*

*នៅក្នុងគម្ពីរបរមត្ថមញ្ជូសា ភាគ១ ទំព័រ១៩៥ ពន្យល់ថា ៖*

**ឥត្ថិបុរិសនិមិត្តំ វា**តិ ឯត្ថ ឥត្ថិសណ្ឋាននិស្សិតរូបមុខេន គយ្ហមានំ សណ្ឋានំ ថនមំសាវិសទតា និម្មស្សុមុខតា កេសពន្ធវត្ថគ្គហណំ អវិសទដ្ឋានគមនាទិ ច សព្វំ "ឥត្ថី"តិ សញ្ជាននស្ស ការណភាវតោ **ឥត្ថិនិមិត្តំ** ។

*ពាក្យថា* ***ឥត្ថិបុរិសនិមិត្តំ វា*** *នេះ សេចក្តីថា រូបរាងសណ្ឋាន ដែលបុគ្គលប្រកាន់យកដោយប្រាថ្នាដល់រូបក្តី ភាពនៃសាច់ដោះកំពុងក្តី ភាពដែលមាត់មិនមានពុកមាត់ក្តី ការចងសក់និងការប្រើសំពត់ក្តី ឥរិយាបថមានឈរ ការដើរមិនអង់អាចជាដើមក្តី ទាំងអស់អាស្រ័យសន្តានរបស់ស្រី ឈ្មោះថា "និមិត្តថាស្រី" ព្រោះជាហេតុនៃការដឹងច្បាស់ថា "ស្រី" ។*

***និមិត្តថាជាបុរស*** *គប្បីជ្រាបដោយបរិយាយផ្ទុយគ្នាអំពីពាក្យដែលពោលហើយ ។ គប្បីជ្រាបគ្រឿងសំដៅថា* ***ឬនិមិត្ត មាន***

***សុភនិមិត្តជាដើម*** *នេះ អាការដែលគួរប្រាថ្នា ដែលនឹងជាហេតុឲ្យកើតរាគៈ ឈ្មោះថា* ***សុភនិមិត្ត*** *។ ដោយ**អាទិសព្ទ** រួមដល់បដិឃ-និមិត្តជាដើម ។ ក៏បដិឃនិមិត្តនោះ គប្បីជ្រាបថា ជាអាការដែលមិនគួរប្រាថ្នាជាដើម ដែលនឹងជាហេតុឲ្យកើតទោសៈជាដើម ។*

*ក៏ក្នុងអធិការនេះ អភិជ្ឈានិងទោមនស្សប៉ុណ្ណោះ មកក្នុងព្រះ-បាលីដោយសភាព ក៏ពិត, សូម្បីយ៉ាងនោះ ក៏ត្រូវប្រាថ្នាការរួមឧបេក្ខានិមិត្តទុកផង ព្រោះសូម្បីមោហៈដែលកើតឡើង ដោយការសំឡឹងដោយមិនស្មើ ក៏ជាការមិនសង្រួមបាន ។ ពិតយ៉ាងនោះ លោកអាចារ្យនឹងពោលថា "ការវង្វេងភ្លេចសតិក្តី ការមិនដឹងក្តី" ដូច្នេះ ។ ម្យ៉ាងទៀត ពាក្យថា* ***ឧបេក្ខានិមិត្ត*** *នេះ បានដល់ អារម្មណ៍ដែលជាទីតាំងអញ្ញាណុបេក្ខា (ការព្រងើយ គឺការមិនដឹង) ១ អញ្ញាណុបេក្ខានោះ គប្បីជ្រាបដោយអំណាចសំឡឹងអារម្មណ៍នោះមិនស្មើ ។ លោកអាចារ្យពោលដល់ហេតុរបស់រាគៈ ទោសៈ និងមោហៈ ដោយសភាពយ៉ាងនេះថា "មានសុភនិមិត្តជាដើម" ដូច្នេះ ។ ដោយហេតុនោះ លោកទើបពោលថា "និមិត្តដែលជាទីតាំងរបស់កិលេស" ។*

*ពាក្យថា* ឧិដ្ឋមត្តេយេវ សណ្ឋាតិ *សេចក្តីថា រមែងតាំងនៅក្នុងវណ្ណាយតនៈដែលត្រឹមតែចក្ខុវិញ្ញាណ និងវិថីចិត្តទាំង*

ឡាយ កាន់យកប៉ុណ្ណោះ តាមន័យដែលទ្រង់ត្រាស់ទុកក្នុងព្រះសូត្រនេះថា “**ទិដ្ឋេ ទិដ្ឋមត្តំ ភវិស្សតិ :** កាលឃើញត្រឹមតែឃើញ” មិនកំណត់អាការមានស្អាតជាដើម យ៉ាងណាមួយដទៃអំពីនោះ ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ លោកពោលទៀតថា ៖

ពាក្យថា ឆានុព្យញ្ជនគ្គាហី **(មិនកាន់យកដោយអនុព្យញ្ជនៈ)** បានសេចក្ដីថា មិនកាន់យកនូវអាការៈផ្សេងគ្នា មានដៃជើង ក្បាល សំណើច ការពោលចរចា និងការរមិលមើលផ្សេងៗ ជាដើម មានវោហារបានហើយថា **អនុព្យញ្ជនៈ** ព្រោះកិរិយាប្រាកដ គឺថា ព្រោះកិរិយាធ្វើភាពឲ្យប្រាកដនៃកិលេសទាំងឡាយ គឺថា វត្ថុដែលមានក្នុងទីនោះ កាន់តែវត្ថុនោះ ដូចជា**មហាតិស្សត្ថេរ** មានកិរិយានៅក្នុងចេតិយបព៌តជាប្រក្រតី ។

ក្នុងដីកាបរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

ពាក្យថា ឆាកាដភាវករណតោ សេចក្ដីថា ព្រោះធ្វើឲ្យប្រាកដ គឺធ្វើឲ្យច្បាស់ ។ ព្រោះថា កាលបុគ្គលកំណត់ដោយការស្អាតជាដើម នូវអវយវៈមានដៃជាដើម នៃវិសភាគវត្ថុ កិលេសដែលកើតឡើងក្នុងអវយវៈទាំងនោះហើយៗ សោត ក៏នឹងជាក់ច្បាស់ឡើង ព្រោះហេតុនោះ អវយវៈទាំងនោះ ទើបឈ្មោះថា **អនុព្យញ្ជនៈ**នៃកិលេសទាំងនោះ ។

តែព្រោះអវយវៈទាំងនោះ ជាអាការដែលភូតរូប និងឧបា-ទាយរូប នៅអាស្រ័យគ្នាដោយប្រការនោះៗ អាស្រ័យគ្នា ។ ក៏លះអាការនោះចេញ មិនមានអាការអ្វីមួយ ឈ្មោះថាដៃជាដើម ដោយបរមត្ថទេ ព្រោះហេតុនោះ លោកទើបពោលថា "មិនកាន់យកនូវអាការៈផ្សេងគ្នា មានដៃជើង ក្បាល សំណើច ការពោលចរចា និងការរមិលមើលផ្សេងៗ ជាដើម" ។ លោកពោលថា **"ក្នុងសរីរៈនោះ វត្ថុណាដែលមានពិត ក៏កាន់យកវត្ថុនោះ"** ដូច្នេះ ក៏ដើម្បីនឹងជៀសវៀងពាក្យសួរថា ក៏នឹងកាន់យកអ្វី ។ម្យ៉ាងទៀត កាន់យកអាការៈត្រឹមតែថា ភូតរូប និងឧបាទាយរូប មានសក់ រោម ជាដើម ដែលមាននៅក្នុងសរីរៈនេះប៉ុណ្ណោះតាមពិត ។ លោកអាចារ្យកាលនឹងសម្តែងតួយ៉ាងនៃការកាន់យកនូវអាការមិនស្អាត ក្នុងសរីរៈនោះ ទើបនាំយករឿងរបស់ព្រះ**មហាតិស្សត្ថេរ**មកសម្តែង ដោយពាក្យមានជាដើមថា "**ព្រះមហាតិស្សត្ថេរ** មានកិរិយានៅក្នុងចេតិយ-បព៌ត" ជាដើម ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ លោកពោលទៀតថា ៖

ពាក្យថា **ព្រោះការមិនសង្រួមចក្ខុន្ទ្រិយណាជាហេតុ** ជាដើម សេចក្តីថា បុគ្គលនោះ មិនសង្រួមចក្ខុន្ទ្រិយ ដោយទ្វារគឺសតិ គឺមានចក្ខុទ្វារមិនបិទហើយ ព្រោះហេតុណា គឺព្រោះហេតុនៃការ

មិនសង្រួមចក្ខុន្ទ្រិយណា ធម៌ទាំងឡាយមានអភិជ្ឈាជាដើមគប្បីទៅតាម គឺជាប់តាម ។

ពាក្យថា **បដិបត្តិដើម្បីសង្រួមចក្ខុន្ទ្រិយនោះ** បានសេចក្តីថា បដិបត្តិដើម្បីបិទចក្ខុន្ទ្រិយនោះ ដោយទ្វារគឺសតិ ។ ក៏បដិបត្តិយ៉ាងនេះឯង លោកហៅថា រក្សាចក្ខុន្ទ្រិយ ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយ ។

ក្នុងពាក្យថា **ដល់នូវការសង្រួមក្នុងចក្ខុន្ទ្រិយនោះ** គប្បីជ្រាបថា ការដែលពិត ការសង្រួមនិងមិនសង្រួមក៏ដោយ មិនមានក្នុងចក្ខុន្ទ្រិយទេ ព្រោះសតិក្តី ភាពនៃការភ្លេចសតិក្តី មិនមែនកើតឡើងព្រោះអាស្រ័យចក្ខុប្បសាទទេ, ក៏ប៉ុន្តែ ក្នុងកាលរូបារម្មណ៍មកកាន់រង្វង់នៃចក្ខុ កាលនោះ កាលបើភវង្គចិត្តកើតឡើងអស់វារៈពីរដងហើយរលត់ទៅវិញ កិរិយាមនោធាតុ សម្រេចអាវជ្ជនកិច្ច (គឺកិរិយានឹក ឬការរំពឹង) ឲ្យសម្រេច កើតឡើងហើយរលត់ទៅ, អំពីនោះ ចក្ខុវិញ្ញាណ សម្រេចទស្សនកិច្ច (គឺកិរិយាឃើញ) ឲ្យសម្រេចកើតឡើងហើយរលត់ទៅ, អំពីនោះ វិបាកមនោធាតុ សម្រេចសម្បដិច្ឆន្នកិច្ច (គឺកិរិយាទទួលអារម្មណ៍) ឲ្យសម្រេចកើតឡើងហើយរលត់ទៅ, អំពីនោះ **វិបាកាហេតុកមនោវិញ្ញាណធាតុ** សម្រេចសន្តីរណកិច្ច (គឺកិរិយាពិចារណា) ឲ្យសម្រេចកើតឡើងហើយរលត់ទៅ, អំពីនោះ កិរិយាហេតុកមនោវិញ្ញាណ-

ធាតុ សម្រេចវោដ្ឋព្វនកិច្ច (គឺកិរិយាកំណត់នូវអារម្មណ៍) ឲ្យសម្រេច កើតឡើងហើយរលត់ទៅ, ក្នុងលំដាប់នោះ **ជវន** ក៏ស្ទុះទៅ ។ ការសង្រួមក្តី ការមិនសង្រួមក្តី ឈ្មោះថា មិនមានក្នុងសម័យនោះ គឺក្នុងភវង្គសម័យ ឬក្នុងសម័យណាមួយ មានអាវជ្ជនសម័យ ជាដើម ។ **ក៏ក្នុងខណៈនៃជវន** ប្រសិនបើភាពជាអ្នកទ្រុស្តសីលក្តី ភាពជាអ្នកភ្លេចស្មារតីក្តី ការមិនដឹងក្តី ការមិនអត់ធ្មត់ក្តី សេចក្តីខ្ជិលក្តី រមែងកើតឡើង ការមិនសង្រួមក៏មានពិត ។ ឯការមិនសង្រួមនោះ កាលមានយ៉ាងនេះ លោកហៅថា មិនសង្រួម ក្នុងចក្ខុន្ទ្រិយ ។

ព្រោះហេតុអ្វី ? ព្រោះកាលបើការមិនសង្រួមមានហើយ ទ្វារក្តី ភវង្គក្តី វិថីចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាដើមក្តី ជាកិរិយាមិនបានគ្រប់គ្រងហើយ ។ ដូចជាអ្វី ? ដូចជាទ្វារទាំង ៤ ក្នុងនគរមិនបិទហើយ ទីទាំងឡាយមានទ្វារខាងក្នុងផ្ទះ និងល្វែង និងបន្ទប់ជាដើម ជាទីដែលបិទល្អហើយ ក៏មែនពិតហើយ សូម្បីដូច្នោះ ទ្រព្យទាំងអស់ខាងក្នុងនគរ ឈ្មោះថា មិនរក្សា មិនគ្រប់គ្រងដែរ, ព្រោះពួកចោរចូលទៅតាមទ្វារនគរ ប្រាថ្នាអំពើណា គប្បីធ្វើអំពើនោះ យ៉ាងនោះឯង **ក្នុងជវន** កាលបើភាពទ្រុស្តសីលជាដើមកើតឡើងហើយ ការមិនសង្រួមនោះមាន, ទ្វារក្តី ភវង្គក្តី វិថីចិត្តទាំងឡាយ មានអាវជ្ជនជាដើមក្តី ឈ្មោះថា មិនបានគ្រប់គ្រងហើយ ។

ឯសេចក្តីល្អ មានសីលជាដើម កើតឡើងហើយ ក្នុងជវន នោះ ទ្វារក្តី ភវង្គក្តី វិថីចិត្តទាំងឡាយ មានអាវជ្ជនចិត្តជាដើមក្តី ឈ្មោះថា បានគ្រប់គ្រងហើយ ។ ដូចជាអ្វី ? ដូចជាទ្វារនគរ ដែលបិទល្អហើយ ទីទាំងឡាយមានទីខាងក្នុងផ្ទះជាដើម ឈ្មោះថា មិនបានបិទ ក៏មែនពិតហើយ សូម្បីដូច្នោះ ទ្រព្យទាំងអស់ខាងក្នុង នគរ ឈ្មោះថា រក្សាគ្រប់គ្រងល្អហើយដែរ, ព្រោះថា ទ្វារនគរ ដែលបិទហើយ ការចូលទៅនៃពួកចោរមិនមាន យ៉ាងនេះឯង **ក្នុងជវន** កាលបើគុណទាំងឡាយមានសីលជាដើមកើតឡើងហើយ ទ្វារក្តី ភវង្គក្តី វិថីចិត្តទាំងឡាយមានអាវជ្ជនជាដើមក្តី ឈ្មោះថា បានគ្រប់គ្រងហើយ ព្រោះថា ហេតុនោះសំវរៈ គឺការសង្រួម សូម្បីកើតឡើងក្នុងខណៈនៃជវនៈ លោកហៅថា សង្រួមក្នុងចក្ខុ-ន្ទ្រិយ ។ សូម្បីក្នុងពាក្យជាដើមថា ឮសំឡេងដោយត្រចៀក ក៏មានន័យដូចន័យនេះដែរ ។

សីលនេះ មានកិរិយាវៀរចាកការប្រកាន់នូវនិមិត្តជាដើម ដែលកិលេសតាមព័ទ្ធព័ទ្ធក្នុងអារម្មណ៍ទាំងឡាយ មានរូបជាដើម ជាលក្ខណៈ បណ្ឌិតគប្បីជ្រាបថា **ឥន្ទ្រិយសំវរសីល** យ៉ាងនេះ ដោយសង្ខេប ។ (ចាកវិសុទ្ធិមគ្គ សីលនិទ្ទេស)

<u>ក្នុងដីកា</u>បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖

ក៏ក្នុងអធិការនេះ កាលរូបារម្មណ៍ប្រាកដផ្លូវចក្ខុទ្វារ កាលកុសលជវនៈនិងអកុសលជវនៈកើតឡើង ៧ ដង ជាប់ដោយហេតុមានធម្មជាតិដែលកំណត់ទុកជាដើម ហើយឈានចុះកាន់ភវង្គ កាលជវនៈផ្លូវមនោទ្វារកើតឡើង ៧ ដង ដូចគ្នាក្នុងអារម្មណ៍នោះនុ៎ះឯងតាមគួរដល់ជវនៈផ្លូវចក្ខុទ្វារ ហើយឈានចុះកាន់ភវង្គ ជវនៈអាស្រ័យអារម្មណ៍នោះឯង ផ្លូវទ្វារនោះឯងទៀត កំណត់ដោយន័យជាដើមថា "ស្ត្រី បុរស" កន្លងទៅ ៧ គ្រា ដោយអំណាចសេចក្ដីជ្រះថ្លា ឬសេចក្ដីកំណត់ជាដើម ។ លោកអាចារ្យសំដៅយកជវនៈដែលប្រព្រឹត្តទៅយ៉ាងនេះ ទើបពោលពាក្យមានជាដើមថា "កាលភាពជាអ្នកទ្រុស្តសីលជាដើមកើតឡើងក្នុងជវនចិត្ត កាលសេចក្ដីមិនសង្រួមនោះមាន សូម្បីទ្វារ ក៏ឈ្មោះថា ជាការមិនបានគ្រប់គ្រង" ដូច្នេះ ។

ក៏ តស្មឹ ប្រកប ជវនេ ប្រែថា ក្នុងជវនៈនោះ ។

ពាក្យថា **កាលសំវរៈមានសីលជាដើម** សេចក្ដីថា កាលសីលសំវរៈ សតិសំវរៈ ញាណសំវរៈ ខន្តិសំវរៈ និងវីរិយសំវរៈ កើតឡើងហើយ ។ ដូចយ៉ាងថា កាលបុគ្គលមិនចូលទៅតាំងធម៌សម្រាប់ឃុំគ្រង គឺសតិទុកមុន ក៏គប្បីជ្រាបថា សេចក្ដីទ្រុស្តសីល

ជាដើមកើតឡើងបាន យ៉ាងណា កាលចូលទៅតាំងធម៌សម្រាប់ចូលទៅគ្រប់គ្រង គឺសតិទុកមុន ក៏គប្បីជ្រាបថា សីលជាដើមកើតឡើងបាន ដូច្នោះ ។ សូម្បីក្នុងអារម្មណ៍ មានសំឡេងជាដើម ក៏គប្បីជ្រាបនិមិត្ត និងអនុព្យញ្ជនៈតាមគួរ ។

ក៏បុគ្គលស្តាប់សំឡេងដោយសោតវិញ្ញាណហើយ មិនកាន់យកនិមិត្តថា "សំឡេងស្រី សំឡេងប្រុស" ឬនិមិត្តដែលគួរប្រាថ្នា និងមិនគួរប្រាថ្នា ដែលជាទីតាំងនៃកិលេស រមែងបញ្ឈប់នៅក្នុងសំឡេង ត្រឹមតែថា ដែលខ្លួនបានឮហើយប៉ុណ្ណោះ ។ និងទាំងមិនកាន់យកអាការនៃសំឡេងចំរៀងជាដើម ដែលផ្សេងដោយសេចក្តីផ្សេងមានសំឡេងដែលកើតចាកឋានទាំង ៦ (សំឡេងសត្វក្ងោក) ជាដើម ដែលកំណត់ដោយជាសំឡេងទាបជាង (សំឡេងគ្រលរជាដើម ដែលបានវោហារថា "អនុព្យញ្ជនៈ" ព្រោះញ៉ាំងកិលេសឲ្យប្រាកដ ។ សូម្បីអារម្មណ៍មានក្លិនជាដើម ក៏គប្បីពោលតាមគួរយ៉ាងនេះ ។

ចំណែកផ្លូវមនោទ្វារ កវគ្គដែលមានអាវជ្ជនៈ ឈ្មោះថាមនោទ្វារ បណ្ឌិតគប្បីប្រកបដោយន័យមានជាដើមថា កាលធម្មា-រម្មណ៍ ប្រាកដផ្លូវទ្វារនោះហើយ ក៏ដឹង គឺជ្រាបអារម្មណ៍ដោយជវនចិត្តនោះពិត ដូច្នេះ ។ កិលេសទាំងឡាយ ដែលជាប់តាមមានដល់ការកាន់យកនិមិត្តជាដើមនេះ ហេតុនោះ ការកាន់យក

និមិត្តជាដើមនោះនុ៎ះឯង ឈ្មោះថា **កិលេសានុពន្ធោ** ប្រែថា មានកិលេសជាប់តាម, **ឥន្ទ្រិយសំវរសីល** មានការវៀរចាកការកាន់យកនិមិត្តជាដើម ដែលមានកិលេសជាប់តាមនោះ ជាលក្ខណៈ ទើបឈ្មោះថា **កិលេសានុពន្ធនិមិត្តាទិគាហបរិវជ្ជនលក្ខណំ** ប្រែថា មានការវៀរចាកការកាន់យកនិមិត្តជាដើម ដែលមានកិលេសជាប់-តាមជាលក្ខណៈ ។ ដោយអាទិសព្ទ លោកអាចារ្យរមែងរួមយកអនុព្យញ្ជនៈផង ។

## អធិប្បាយអាជីវបារិសុទ្ធិសីល

ឥឡូវនេះ គប្បីជ្រាបក្នុង**អាជីវបារិសុទ្ធិសីល** ដែលលោកពោលហើយ ជាលំដាប់អំពីឥន្ទ្រិយសំវរសីល ។

ពាក្យថា **នៃសិក្ខាបទទាំង ៦ ដែលព្រះអង្គបញ្ញត្តហើយព្រោះហេតុនៃអាជីវៈ ព្រោះដំណើរនៃអាជីវៈ** បានសេចក្តីថា សិក្ខាបទទាំង ៦ នោះហ្នឹងឯង ដែលព្រះអង្គបញ្ញត្តហើយយ៉ាងនេះថា "ភិក្ខុមានសេចក្តីប្រាថ្នាអាក្រក់ លុះក្នុងអំណាចសេចក្តីប្រាថ្នា ពោលអួតឧត្តរិមនុស្សធម្ម ដែលមិនមាន (ក្នុងខ្លួន) ដែលមិនពិត ព្រោះហេតុតែអាជីវៈ ព្រោះដំណើរនៃអាជីវៈ ត្រូវអាបត្តិបារាជិក, ភិក្ខុប្រព្រឹត្តនិយាយជីកនាំបុរសឲ្យស្ត្រី ជីកនាំស្ត្រីឲ្យបុរស ព្រោះ

ហេតុតែអាជីវៈ ព្រោះដំណើរនៃអាជីវៈ ត្រូវអាបត្តិសង្ឃាទិសេស, ភិក្ខុពោលថា ភិក្ខុណានៅក្នុងវិហាររបស់អ្នក ភិក្ខុនោះឯងជាព្រះ-អរហន្ត ព្រោះហេតុតែអាជីវៈ ព្រោះដំណើរនៃអាជីវៈ កាលកំពុងប្តេជ្ញា ត្រូវអាបត្តិថុល្លច្ច័យ, ភិក្ខុមិនឈឺ សូមបណីតភោជនទាំងឡាយ ដើម្បីប្រយោជន៍ដល់ខ្លួនមកបរិភោគ ព្រោះហេតុតែអាជីវៈ ព្រោះដំណើរនៃអាជីវៈ ត្រូវអាបត្តិបាចិត្តិយ, ភិក្ខុនីមិនឈឺ សូមបណីតភោជនទាំងឡាយ ដើម្បីប្រយោជន៍ដល់ខ្លួនមកបរិភោគ ព្រោះហេតុតែអាជីវៈ ព្រោះដំណើរនៃអាជីវៈ ត្រូវអាបត្តិបាដិទេស-នីយៈ, ភិក្ខុដែលមិនមានជម្ងឺ សូមសម្ល៍ត្តិ បាយក្តី ដើម្បីប្រយោជន៍ដល់ខ្លួនយកមកបរិភោគ ព្រោះហេតុតែអាជីវៈ ព្រោះដំណើរអាជីវៈ ត្រូវអាបត្តិទុក្កដ, នេះសិក្ខាបទទាំង ៦ ។

(ចាក វិសុទ្ធិមគ្គ សីលនិទ្ទេស)

ពាក្យថា **ព្រោះហេតុតែអាជីវៈ** បានដល់ ព្រោះការស្វែងរកចិញ្ចឹមជីវិតជាហេតុ បានដល់ សេចក្តីប្រាថ្នាថា “ដោយអាការយ៉ាងនេះ យើងនឹងស្វែងរកចិញ្ចឹមជីវិត មិនលំបាកដោយបច្ច័យទាំងឡាយ” ។

ពាក្យថា **ព្រោះដំណើរនៃអាជីវៈ** ជាវេវចនៈរបស់ពាក្យថា ព្រោះហេតុតែអាជីវៈនោះនុ៎ះឯង ។ ពាក្យថា **មានសេចក្តីប្រាថ្នា**

*លាមក សេចក្ដីថា ប្រកបដោយសេចក្ដីប្រាថ្នាក្នុងការលើកសរសើរ ដោយគុណដែលមិនមានរបស់មនុស្សលាមក ។ល។*

*ពីរបទថា សញ្ញត្តិំ សមាបជ្ជិ សេចក្ដីថា រមែងដល់សេចក្ដីជាការដឹកនាំ អធិប្បាយថា ប្រាប់សេចក្ដីប្រាថ្នារបស់បុរសដល់ស្ត្រី ឬសេចក្ដីប្រាថ្នារបស់ស្ត្រីដល់បុរស ។ ភ្ជាប់សេចក្ដីថា "ដោយអំណាចការប្រព្រឹត្តិកន្លងសិក្ខាបទទាំង ៦ នោះ" ខ្ញុំបានសម្ដែងទុកក្នុងខាងដើមហើយ ។*

*(ចាកបរមត្ថមញ្ជុសា ភាគ១)*

## បាបធម៌ ៥ យ៉ាង

១–កុហនា : *ការតាំងទុក ឬការតម្កល់ទុក ឬការរៀបចំនូវឥរិយាបថក្ដី ការសម្ដែងទឹកមុខក្ដី ភាពនៃបុគ្គលអ្នកសម្ដែងទឹកមុខក្ដី ការកុហកដោយឫកក្ដី លំនាំនៃការកុហកក្ដី ភាពនៃការកុហកក្ដី ដោយមារយាទពោលគឺការសេពនូវបច្ច័យ ឬដោយការខ្សឹបខ្សៀវក្នុងទីជិតនៃភិក្ខុដែលមានសេចក្ដីប្រាថ្នាលាមក ច្រើនដោយសេចក្ដីប្រាថ្នា ដែលអាស្រ័យលាភសក្ការៈ និងសេចក្ដីសរសើរ នេះហៅថា* **កុហនា** *។*

២-លបនា : *ការពោលរាក់ទាក់មុន ការនិយាយរកមុន ការលលួង ការនិយាយបញ្ជោរ ការនិយាយបញ្ជោរហួសពេក ការពោលទាក់ ការពោលទាក់ហួសពេក ការលើកខ្លួន ការលើក-តម្កើងខ្លួន ភាពនៃបុគ្គលពោលពាក្យជាទីស្រឡាញ់ ភាពជាអ្នកបន្ទាបខ្លួន ភាពជាអ្នកមានសម្តីដូចសម្លសំណ្ដក ភាពជាអ្នកប្រព្រឹត្តបីពនូវកុមារតូចៗ របស់ជនទាំងឡាយដទៃ នៃភិក្ខុដែលមានសេចក្តីប្រាថ្នាលាមក ច្រើនដោយសេចក្តីប្រាថ្នាដែលអាស្រ័យលាភសក្ការៈ និងសេចក្តីសរសើរ នេះហៅថា* **លបនា** ។

៣-នេមិត្តិកតា : *ការធ្វើនិមិត្ត និមិត្តកម្ម ឱភាស ឱភាសកម្ម ការខ្សឹប ការនិយាយបរិកថាដល់បុគ្គលដទៃ នៃភិក្ខុដែលមានសេចក្តីប្រាថ្នាលាមក ច្រើនដោយសេចក្តីប្រាថ្នា ដែលអាស្រ័យលាភសក្ការៈ និងសេចក្តីសរសើរ នេះហៅថា* **នេមិត្តិកតា**។

៤-និប្បេសិកតា : *ការជេរ ការនិយាយសង្កត់សង្កិន ការតិះដៀល ការលើកទោស ការថ្កោលទោស ការនិយាយបញ្ចើច ការនិយាយបញ្ចើចបញ្ចើ ការនិយាយបន្ថោក ការនិយាយបន្ថោក-បន្ទាប ការនិយាយបង្អាច់ ការនិយាយដាក់កំហុស ថ្កោលទោស កំបាំងមុខឲ្យបុគ្គលដទៃ នៃភិក្ខុដែលមានសេចក្តីប្រាថ្នាលាមក ច្រើន*

ដោយសេចក្តីប្រាថ្នា ដែលអាស្រ័យលាភសក្ការៈ និងសេចក្តីសរសើរ នេះហៅថា **និប្បេសិកតា** ។

៥-លាភេន លាភំ និជិគីសនតា : ភិក្ខុអាស្រ័យលាភសក្ការៈ និងសេចក្តីសរសើរ មានសេចក្តីប្រាថ្នាលាមក ច្រើនដោយសេចក្តីប្រាថ្នា នាំយកអាមិសដែលខ្លួនបានអំពីទីនេះ ទៅក្នុងទីឯណោះ ឬថា នាំយកអាមិសដែលខ្លួនបានក្នុងទីឯណោះ មកក្នុងទីនេះវិញ ការស្វែង ការស្វែងរក ការស្វះស្វែងរក ការចង់បាន ការខ្វល់ខ្វាយ ការចរប្របរកនូវអាមិសដោយអាមិស មានសភាពយ៉ាងនេះ នេះហៅថា **លាភេន លាភំ និជិគីសនតា** (ការយកលាភទាក់លាភ) ។ (ចាកគម្ពីរវិសុទ្ធិមគ្គ)

ដីកា : ភិក្ខុរមែងស្វែងរក គឺប្រាថ្នាដើម្បីនឹងនាំទៅ ឬទទួលយកទៅនូវលាភមានចំនួនច្រើនអំពីបុគ្គលដទៃ ដោយការឲ្យលាភ (មានចំនួនតិច) ដែលខ្លួនបានមក ព្រោះមានសេចក្តីប្រាថ្នាលាមក ដោយហេតុនោះ ទើបឈ្មោះថា ជាអ្នកស្វែងរកលាភដោយលាភ, ភាវៈរបស់ភិក្ខុជាអ្នកស្វែងរកលាភដោយលាភ ឈ្មោះថា ការទាក់លាភដោយលាភ (**លាភេន លាភំ និជិគីសនតា**) ។

(សារត្ថបកាសិនី ចូឡដីកា)

ពាក្យថា **អាស្រ័យលាភសក្ការៈ និងសេចក្តីសរសើរ**

បានសេចក្តីថា អាស្រ័យ គឺប្រាថ្នាលាភសក្ការៈ និងកិត្តិស័ព្ទ ។ ពាក្យថា **មានសេចក្តីប្រាថ្នាលាមក** បានសេចក្តីថា ត្រូវការសម្តែងគុណដែលមិនមាន ។ ពាក្យថា **ច្រើនដោយសេចក្តីប្រាថ្នា** បានសេចក្តីថា សេចក្តីប្រាថ្នាគ្របសង្កត់ហើយ គឺសេចក្តីប្រាថ្នាចូលទៅប្រទូស្តហើយ ។ (ចាកគម្ពីរវិសុទ្ធិមគ្គ)

ក្នុងពាក្យថា សន្និស្សិតស្ស **(អាស្រ័យ)** នេះ លោកប្រាថ្នាយកទីអាស្រ័យគឺតណ្ហា ព្រោះដូច្នោះ លោកទើបពោលថា “**បត្ថយន្តស្ស** : មានសេចក្តីប្រាថ្នា” ដូច្នេះ ។ ក្នុងពាក្យថា **ប្រាថ្នាគុណដែលមិនមាន** មានសេចក្តីថា ជាអ្នកប្រាថ្នាដើម្បីឲ្យគេសរសើរក្នុងកាលគុណមានសទ្ធាជាដើមមិនមាន គឺមិនប្រាជកក្នុងខ្លួន ។ មែនពិត សេចក្តីប្រាថ្នាលាមក មានលក្ខណៈសរសើរគុណដែលមិនមាន, និងមានលក្ខណៈមិនដឹងប្រមាណក្នុងការទទួល ។ ពាក្យថា **ត្រូវសេចក្តីប្រាថ្នាគ្របសង្កត់** សេចក្តីថា ឈ្មោះថាសេចក្តីប្រាថ្នាគ្របសង្កត់ ព្រោះអត្ថថា ដែលសេចក្តីប្រាថ្នាដ៏លាមកធ្វើឲ្យប្រាសចាកសម្មាអាជីវៈ ។ លោកពោលថា “គឺសេចក្តីប្រាថ្នាចូលទៅប្រទូស្តហើយ” ព្រោះអធិប្បាយថា ក៏បុគ្គលបែបនោះជាអ្នកត្រូវអន្តរាយ គឺអាជីវៈបៀតបៀនហើយ ។

(ចាកគម្ពីរវិសុទ្ធិមគ្គមហាដីកា)

## កុហនវត្ថុ ៣ យ៉ាង

*កុហនវត្ថុ ខាងការសេពបច្ច័យ ១ កុហនវត្ថុ ខាងឥរិយាបថ ១ កុហនវត្ថុ ខាងការខ្សឹបជិត ១ ។*

*កុហនវត្ថុ ខាងការសេពបច្ច័យ តើដូចម្ដេច ? ។ល។*

*(ចាកសុត្តន្ត. មហានិទ្ទេស ៦៥ , ៨០)*

## អធិប្បាយបាបធម៌

*ឥឡូវនេះ នឹងអធិប្បាយក្នុងពាក្យថា បាបធម៌ទាំងឡាយមានយ៉ាងនេះជាដើម គប្បីជ្រាបការកាន់យកបាបធម៌ដ៏ច្រើន ដែលទ្រង់សម្ដែងក្នុងព្រហ្មជាលសូត្រ ដោយន័យជាដើមថា "ម្នាលលោកដ៏ចម្រើន ម្យ៉ាងទៀត ដូចសមណព្រាហ្មណ៍ពួកខ្លះ បរិភោគភោជនដែលគេឲ្យដោយសទ្ធា ពួកលោកចិញ្ចឹមជីវិតដោយមិច្ឆាជីពគឺតិរច្ឆានវិជ្ជាបែបនេះ ដូចជាអ្វី ? ដូចជាតម្រាទាយអវយវៈ ទាយនិមិត្ត ទាយឧបត្តិហេតុ (ដែលកើតឡើង) ទាយយល់សប្តិ ទាយលក្ខណៈ ទាយកណ្ដុរកាត់សំពត់ តម្រាបូជាភ្លើង តម្រាបូជាវែក" ។ មិច្ឆាជីពនេះហ្នឹងឯង ដូចពោលមកនេះ ប្រព្រឹត្តទៅដោយអំណាចការប្រព្រឹត្តិកន្លងសិក្ខាបទ ៦ ដែលទ្រង់បញ្ញត្ត ព្រោះហេតុតែអាជីវៈអម្បាលនេះ និងដោយអំណាចបាបធម៌ទាំងឡាយ មានយ៉ាងនេះជាដើម គឺកុហកដោយឫក ការពោលរួសរាយ ការធ្វើ*

និមិត្ត ការពោលកៀស ការស្វែងរកដោយលាភ អម្បាលនេះ ព្រោះហេតុនោះឯង ការវៀរចាកមិច្ឆាជីវៈគ្រប់ប្រការ នេះឈ្មោះថា **អាជីវបារិសុទ្ធិសីល** ។

## ពាក្យថា អាជីវបារិសុទ្ធិ

ពួកភិក្ខុអាស្រ័យនូវសភាវៈនេះ រស់នៅ ព្រោះហេតុនោះ សភាវៈនោះ ឈ្មោះថា **អាជីវៈ** ។ ចុះអាជីវៈនោះ ដូចម្តេច ? សភាវៈនោះ បានដល់ សេចក្តីព្យាយាមដើម្បីស្វែងរកនូវបច្ច័យ ។ ពាក្យថា **បារិសុទ្ធិ** បានសេចក្តីថា ភាពនៃសេចក្តីបរិសុទ្ធ ។ សេចក្តីបរិសុទ្ធនៃអាជីវៈ ឈ្មោះថា **អាជីវបារិសុទ្ធិ** ។

<u>ដីកា</u> បរមត្ថមញ្ជុសា ភាគ១ ថា ៖

ព្រោះអាជីវបារិសុទ្ធិសីល មានសេចក្តីព្យាយាមជាគ្រឿងឲ្យសម្រេច លោកទើបពោលថា "សេចក្តីព្យាយាមក្នុងការស្វែងរកបច្ច័យ" ដូច្នេះ សេចក្តីបរិសុទ្ធនៃអាជីវៈនោះ ជាសេចក្តីព្យាយាមដែលមិនមានទោស ដែលជាហេតុមានការបានបច្ច័យដោយធម៌ដ៏ស្មើ ។ ព្រោះអ្នកខ្ជិលច្រអូស រមែងមិនអាចស្វែងរកបច្ច័យដោយត្រឹមត្រូវបានឡើយ ។ (ភាគ១ ទំព័រ២២៨)

## អធិប្បាយបច្ចយសន្និស្សិតសីល

ចំណែកក្នុងបច្ចយសន្និស្សិតសីលនេះ ដែលពោលក្នុងលំដាប់នៃអាជីវបារិសុទ្ធិសីលនោះ យ៉ាងណា, គប្បីជ្រាបវិនិច្ឆ័យក្នុងបច្ចយសន្និស្សិតសីលនោះ ៖

ពាក្យថា បដិសង្ខា យោនិសោ **(ពិចារណាដោយឧបាយ)** បានដល់ ត្រួតត្រាហើយ គឺដឹងដោយឧបាយ គឺគន្ធ អធិប្បាយថា ពិចារណា ។ ម្យ៉ាងទៀត ការពិចារណាហ្នឹងឯង ដែលលោកពោលហើយ ដោយន័យទាំងនោះ មានន័យថា "ដើម្បីការពារត្រជាក់"ជាដើម គប្បីជ្រាបថា **ការពិចារណាដោយឧបាយ** ។

<u>ដីកា បរមត្ថមញ្ជុសា</u> ពន្យល់ថា ៖

លោកអាចារ្យកាលនឹងសម្តែងថា ក៏**យោនិសោ**ស័ព្ទ ក្នុងពាក្យថា **យោនិសោ** នេះ មានអត្ថថា **ឧបាយ** ទើបពោលថា ដោយឧបាយ គឺដោយត្រូវផ្លូវ ។ លោកអាចារ្យពោលថា ពិចារណាហើយ គឺដឹងហើយ ដូច្នេះហើយទើបពោលថា "សេចក្តីថាពិចារណាហើយ" ដូច្នេះជាដើម ក៏ដើម្បីសម្តែងថា ការពិចារណានេះនោះ បានដល់ **បច្ចវេក្ខណញាណ** ។

ដូចយ៉ាងថា ពាក្យថា **បច្ចវេក្ខិត្វា** សេចក្ដីថា ឃើញចំពោះៗ ប្រយោជន៍នោះៗ មានការពារត្រជាក់ជាដើម, អធិប្បាយថា ឃើញដោយញាណយ៉ាងណា, ពាក្យថា **បដិសង្ខាយ** ក៏ដូច្នោះ សេចក្ដីថា ពិចារណាចំពោះៗ ហើយ នូវប្រយោជន៍នោះៗឯង អធិប្បាយថា ដឹងហើយ ។ មែនពិត **សង្ខា**ស័ព្ទក្នុងពាក្យនេះ ជាបរិយាយនៃញាណ ។ តែក្នុងពាក្យនេះ អាចារ្យមួយពួកទៀត ពោលទុកថា ពាក្យថា **បដិសង្ខា យោនិសោ** ជាដើម លោកពោលដោយកាលដែលបរិភោគបច្ច័យដោយពិត, សូម្បីយ៉ាងនោះ បច្ចយសន្និស្សិត-សីលនឹងបរិសុទ្ធបាន ក៏ដោយការពិចារណា ជាប់ដោយសេចក្ដីជាធាតុ ឬជាប់ដោយរបស់បដិកូល។ អាចារ្យពួកខ្លះពោលថា បច្ចយ-សន្និស្សិតសីល រមែងបែកធ្លាយ ។ តែអាចារ្យពួកមួយ ពោលថា កំណាត់ទុកមុនតែម្ដង, បណ្ឌិតគប្បីពិចារណាហើយកាន់យក ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ ៖

ក្នុងពាក្យទាំងនោះ ពាក្យថា ចីវរំ ***(ចីវរ)*** បានដល់ សំពត់ផ្ទាំងណាមួយ បណ្ដាសំពត់ទាំងឡាយមានស្បង់ជាដើម ។

ពាក្យថា បដិសេវតិ ***(សេព)*** បានដល់ ប្រើប្រាស់ គឺស្លៀក ឬដណ្ដប់ ។ ពាក្យថា យាវទេវ ***(ត្រឹមតែ)*** ជាពាក្យ**និយម**កំណាត់ដែននៃប្រយោជន៍ ។

ឯត្តកាមេវ ហិ យោគិនោ ចីវរបដិសេវនេ បយោជនំ យទិទំ សីតស្ស បដិឃាតាយាតិអាទិ, ន ឥតោ ភិយ្យោ។ *មែនពិត ប្រយោជន៍ក្នុងការសេពនូវចីវរនៃព្រះយោគី ត្រឹមតែប៉ុណ្ណោះឯង គឺត្រឹមតែដើម្បីការពារនូវត្រជាក់ជាដើម, មិនប្រសើរក្រៃលែងជាងនេះទៀតទេ ។*

*__ដីកា__ : លោកអាចារ្យពោលថា "**បានដល់ សំពត់ប្រភេទណាមួយ បណ្តាសំពត់អន្តរវាសកៈជាដើម**" ដោយប្រាថ្នាយកថា ពាក្យថា "**ចីវរំ**" ជាឯកវចនៈ ប្រាប់ត្រឹមតែម្យ៉ាង, ក៏ពាក្យថា **ចីវរំ** ក្នុងបាលី ជាឯកវចនៈ ព្រោះពាក្យនោះ ជាស័ព្ទពោលដល់ជាតិ ព្រោះដូច្នោះ ទើបអាចជ្រាបបានថា ព្រះយោគីអ្នករក្សាចីវរបានមានប្រមាណប៉ុនណា, ទ្រង់កាន់យកចីវរមានប្រមាណប៉ុណ្ណោះនោះទាំងអស់នោះទុកជាមួយគ្នា, ម្យ៉ាងទៀត ពាក្យថា **ប្រភេទណាមួយ** នេះ ជាការកំណត់កាន់យកដោយមិនមានសេសសល់, មិនមែនជាពាក្យមិនទៀង ។ ចំណែកការកំណត់ថា "ស្លៀក ឬដណ្តប់" ដូច្នេះ ជាការសម្តែងដល់ការចែកការប្រើប្រាស់ ដែលជាបរិយាយនៃការសេពចំពោះ (នូវចីវរ) គប្បីឃើញថា លោកបញ្ញត្តដល់ការបរិភោគនោះ ដោយប្រការដូច្នេះ ហើយទើបសង្គ្រោះដល់ការប្រើ-*

ប្រាស់ សូម្បីជាប់ដោយការធ្វើឲ្យជាទីដេក ទីអង្គុយ និងធ្វើជាចីវរកុដិករណៈ (ធ្វើជាសំពត់ដំបូល) ជាដើមផង ។

ខេត្តនៃប្រយោជន៍ទាំងឡាយ ឈ្មោះថា **បយោជនាវធិ**, សេចក្តីកំណត់ដោយការកំណត់ខេត្តដែននៃប្រយោជន៍នោះ យ៉ាងណា, ការពោលដល់សេចក្តីកំណត់យ៉ាងនោះ ឈ្មោះថា ជាពាក្យកំណត់ខេត្តដែននៃប្រយោជន៍ ។ (ចាកបរមត្ថមញ្ជុសា មហាដីកា)

## អធិប្បាយបច្ចវេក្ខណៈវិធី

វិធីដែលត្រូវពិចារណានូវបច្ច័យទាំង ៤ មានបែបដែលលោករៀងទុកក្នុងពេលមុនៗ មកគ្រប់គ្រាន់ហើយ ឯក្នុងទីនេះសូមអធិប្បាយសេចក្តីណាដែលប្លែក ឬលើសអំពីនោះប៉ុណ្ណោះ ដើម្បីពង្រីកប្រាជ្ញារបស់លោកអ្នកសិក្សា ឲ្យកាន់តែទូលាយឡើងទៀត។

ក៏ឯបច្ចវេក្ខណវិធី គឺវិធីដែលសម្រាប់ពិចារណាក្នុងបច្ច័យមួយៗ នោះ មានបួនៗ គឺក្នុងចីវរប្បច្ច័យ ៤ បិណ្ឌបាតប្បច្ច័យ ៤ សេនាសនប្បច្ច័យ ៤ គិលានប្បច្ច័យ ៤ ហើយមានឈ្មោះថា **ធាតុប្បច្ចវេក្ខណៈ បដិកូលប្បច្ចវេក្ខណៈ តំខណិកប្បច្ចវេក្ខណៈ អតីតប្បច្ចវេក្ខណៈ** ដូចគ្នា រួមទាំងអស់ត្រូវជាបច្ចវេក្ខណៈ ១៦ ។

**បច្ចវេក្ខណកាល** គឺកាលដែលត្រូវពិចារណាក្នុងបច្ច័យមួយៗ នោះ មានបីៗ ហើយមានឈ្មោះថា បដិលាភកាល (កាលដែល

កំពុងបាន ឬកំពុងទទួលនូវបច្ច័យ) ១ បរិភោគកាល (កាលដែលកំពុងបរិភោគនូវបច្ច័យ) ១ អតីតកាល (កាលដែលបរិភោគប្រើប្រាស់កន្លងហើយ) ១ ដូចគ្នាគ្រប់បច្ច័យទាំង ៤ រួមទាំងអស់ត្រូវជាកាល ១២ ។

បណ្តាកាលទាំង ៣ នោះ ក្នុង**បដិលាភកាល** ត្រូវពិចារណាដោយធាតុប្បច្ចវេក្ខណៈក៏បាន បដិកូលប្បច្ចវេក្ខណៈ ក៏បាន, ក្នុងបរិភោគកាល ត្រូវពិចារណាដោយតំខណិកប្បច្ចវេក្ខណៈ, ក្នុងអតីតកាល ត្រូវពិចារណាដោយអតីតប្បច្ចវេក្ខណៈ ។

**ធាតុប្បច្ចវេក្ខណៈ** ត្រូវពិចារណាផ្អែកមកជាមួយនឹងកាយរបស់ខ្លួន ឲ្យឃើញថា គ្រាន់តែជាធាតុ ដើម្បីនឹងលះបង់សេចក្តីប្រកាន់ថា ជាខ្លួន និងរបស់ខ្លួន រាប់បញ្ចូលក្នុងធាតុមនសិការ-កម្មដ្ឋាន ឬចតុធាតុវវដ្ឋានកម្មដ្ឋាន ។

**បដិកូលប្បច្ចវេក្ខណៈ** ត្រូវពិចារណាផ្អែកមកជាមួយនឹងកាយរបស់ខ្លួន ឲ្យឃើញថា ជារបស់មិនស្អាត គួរខ្ពើមរអើម ដើម្បីលះបង់សេចក្តីសម្គាល់ខុស រាប់បញ្ចូលក្នុងអាហារប្បដិកូល-សញ្ញាកម្មដ្ឋាន ឯក្នុងបច្ច័យឯទៀត រាប់បញ្ចូលក្នុងបដិកូលមន-សិការកម្មដ្ឋាន ។

*តំខណិកប្បច្ចវេក្ខណៈ* និង *អតីតប្បច្ចវេក្ខណៈ* ត្រូវពិចារណា ឲ្យដឹងនូវផលរបស់ប្រយោជន៍ ក្នុងការបរិភោគប្រើប្រាស់នូវបច្ច័យ ៤ ដូចគ្នា មិនឲ្យសម្គាល់ប្រយោជន៍ហួសកម្រិត, តែតំខណិកប្បច្ចវេក្ខណៈ ត្រូវពិចារណាក្នុងកាលដែលកំពុងបរិភោគប្រើប្រាស់, ឯអតីតប្បច្ចវេក្ខណៈ ត្រូវពិចារណាបន្ថែមក្នុងបរិភោគប្រើប្រាស់រួចហើយក្នុងថ្ងៃដដែល ការពារក្រែងភ្លេចស្មារតី ក្នុងកាលដែលកំពុងបរិភោគប្រើប្រាស់នោះ, ដើម្បីនឹងបិទនូវក្រសែរបស់តណ្ហា មិនឲ្យមានសេចក្ដីប្រាថ្នាជាប់ចិត្តក្នុងបច្ច័យទាំងនោះ និងប្រហារនូវឧបនិស្ស័យរបស់រាគៈ ទោសៈ មោហៈ និងមានៈជាដើម មិនឲ្យកើតឡើង មានតែនាំមកនូវសេចក្ដីទុក្ខក្នុងអបាយមកប្រគល់ឲ្យដោយពិត, តួយ៉ាង ដូចមានពុទ្ធភាសិតដែលព្រះមានព្រះភាគ ត្រាស់សម្ដែងក្នុងគម្ពីរខុទ្ទកនិកាយ ធម្មបទគាថា មលវគ្គ ទី ១៨ នោះទ្រង់ត្រាស់ថា ៖

អយសាវ មលំ សមុដ្ឋាយ តទុដ្ឋាយ តមេវ ខាទតិ
ឯវំ អតិធោនចារិនំ សានិ កម្មានិ នយន្តិ ទុគ្គតឹ ។

ច្រេះកើតអំពីដែក លុះកើតអំពីដែកនោះហើយ តែងស៊ីដែកនោះវិញ យ៉ាងណាមិញ កម្មទាំងឡាយរបស់ខ្លួន តែងនាំបុគ្គលអ្នកប្រព្រឹត្តកន្លងបញ្ញាជាគ្រឿងជម្រះចិត្ត (ពិចារណា

*នូវបច្ច័យហើយបរិភោគ) ឲ្យទៅកាន់ទុគ្គតិ ក៏យ៉ាងនោះដែរ ។*

## ផែនរបស់ប្រយោជន៍ក្នុងការបរិភោគបច្ច័យ

*តំខណិកប្បច្ចវេក្ខណៈ និងអតីតប្បច្ចវេក្ខណៈ ត្រូវពិចារណាឲ្យដឹងនូវផែនរបស់ប្រយោជន៍ ក្នុងការបរិភោគប្រើប្រាស់នូវបច្ច័យ ៤ មិនឲ្យសម្គាល់ប្រយោជន៍ហួសកម្រិត, ក្នុងបច្ចវេក្ខណៈទាំងពីរនោះ នឹងអធិប្បាយតែ* ***តំខណិកប្បច្ចវេក្ខណៈ*** *១ ប៉ុណ្ណោះ ទុកជាតួយ៉ាង ឯអតីតប្បច្ចវេក្ខណៈ មិនចាំបាច់អធិប្បាយឡើយ ព្រោះសេចក្ដីដូចគ្នា ខុសគ្នាតែត្រង់កាលប៉ុណ្ណោះ ។ ហើយតំខណិកប្បច្ចវេក្ខណៈនោះសោត នឹងសូមអធិប្បាយក្នុងចីវរប្បច្ច័យជាមុន ឯក្នុងបច្ច័យដទៃទៀត នឹងអធិប្បាយរៀងលំដាប់គ្នាតទៅ ។*

## ចីវរប្បច្ច័យ

*ក្នុងចីវរប្បច្ច័យកំណត់ផែនរបស់ប្រយោជន៍ ៤ យ៉ាង គឺ*

១-សីតស្ស បដិឃាតាយ *ដើម្បីការពារនូវត្រជាក់,*

២-ឧណ្ហស្ស បដិឃាតាយ *ដើម្បីការពារនូវកំដៅ,*

៣–ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃា–តាយ *ដើម្បីការពារនូវសម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ ពស់តូចនិងពស់ធំទាំងឡាយ,*

៤–ហិរិកោបិនប្បដិច្ឆាទនត្ថំ *ដើម្បីបិទបាំងនូវអវយវៈ ដែលធ្វើនូវសេចក្តីខ្មាសឲ្យកម្រើក ។*

*ក្នុងគម្ពីរវិសុទ្ធិមគ្គ ៖*

*ពាក្យថា* សីតស្ស *(**ត្រជាក់**) បានដល់ ត្រជាក់ឯណាមួយ ដែលកើតឡើងហើយ ដោយអំណាចធាតុខាងក្នុងកម្រើក ឬរដូវខាងក្រៅប្រែប្រួល ។ ពាក្យថា* បដិឃាតាយ *(**ដើម្បីការពារ**) បានសេចក្តីថា ដើម្បីកិរិយាកំចាត់បង់ ។ ភិក្ខុប្រើប្រាស់ចីវរ មិនឲ្យអាពាធកើតឡើងក្នុងសរីរៈ យ៉ាងណា ដើម្បីបន្ទោបង់អាពាធយ៉ាងនោះឯង ។ ដ្បិតថា សរីរៈត្រូវត្រជាក់បៀតបៀនហើយ ភិក្ខុមានចិត្តរវើរវាយ មិនអាចតម្កល់ទុកដោយឧបាយបាន ព្រោះហេតុនោះ ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតហើយថា គប្បីប្រើប្រាស់ចីវរ ដើម្បីការពារត្រជាក់ ។ ក្នុងន័យទាំងពួង គប្បីជ្រាបដូចន័យនេះ ។ល។*

## បិណ្ឌបាតប្បច្ច័យ

*ក្នុងបិណ្ឌបាតប្បច្ច័យ ចាត់ជាអង្គដែលត្រូវហាមឃាត់ ៤ ដែលជាដែនរបស់ប្រយោជន៍ ៨ រួមទាំងអស់ ត្រូវជា ១២ គឺ*

១–នេវ ទវាយ *មិនមែនដើម្បីលេងដូចក្មេងអ្នកស្រុក*

២–ន មទាយ *មិនមែនឲ្យកើតបុរិសមានះស្រវឹង ដូចអ្នកប្រដាល់,*

៣–ន មណ្ឌនាយ *មិនមែនដើម្បីប្រដាប់តាក់តែង រាងកាយដូចស្ត្រីក្នុងបុរី,*

៤–ន វិភូសនាយ *មិនដើម្បីស្អិតស្អាងរាងកាយ ឲ្យផូរផង់ពណ៌សម្បុរ ដូចអ្នកលេងរបាំ ។*

*ទាំង ៤ នេះ ជាអង្គដែលត្រូវហាមឃាត់ មិនមែនជាដែនរបស់ប្រយោជន៍ទេ ។*

៥–ឥមស្ស កាយស្ស ឋិតិយា *ដើម្បីទ្រទ្រង់ឲ្យតាំងនៅនៃកាយនេះ,*

៦–យាបនាយ *ដើម្បីញ៉ាំងជីវិតិន្ទ្រិយឲ្យប្រព្រឹត្តទៅ,*

៧–វិហឹសុបរតិយា *ដើម្បីបំបាត់បង់នូវសេចក្ដីលំបាក,*

៨–ព្រហ្មចរិយានុគ្គហាយ *ដើម្បីអនុគ្រោះដល់មគ្គ-*

*ព្រហ្មចរិយៈ និងសាសនព្រហ្មចរិយៈ,*

៩-ឥតិ បុរាណញ្ច វេទនំ បដិហង្ខាមិ *ដូច្នេះ អញនឹងកម្ចាត់បង់នូវវេទនាចាស់ គឺសេចក្ដីឃ្លានដែលមានហើយផង;*

១០-នវញ្ច វេទនំ ន ឧប្បាទេស្សាមិ *អញនឹងញ៉ាំងវេទនាថ្មី គឺឆ្អែតហួសប្រមាណ មិនឲ្យកើតឡើងបានផង;*

១១-យាត្រា ច មេ ភវិស្សតិ *កិរិយាប្រព្រឹត្តទៅនៃឥរិយាបថទាំង ៤ នឹងមានដល់អញផង;*

១២-អនវជ្ជតា ច *សេចក្ដីមិនមានទោស មានមិនប្រមូសកាយ មិនប្រមូសចិត្តជាដើម (នឹងមានដល់អញ) ផង;*

*អង្គទាំង ៨ នេះ ជាដែនរបស់ប្រយោជន៍, នៅសល់អង្គ ១ ទៀតគឺ* ផាសុវិហារោ ច *"ការនៅសប្បាយក្នុងឥរិយាបថទាំង ៤ (នឹងមានដល់អញ) ផង", តែអង្គនេះ លោកមិនបានរាប់ញូលមកផងទេ ព្រោះលោកចាត់ជាអានិសង្សរបស់ភោជន ។*

*បណ្ដាអង្គទាំង ១២ នេះ អង្គដែលត្រូវឃាត់ ៤ ខាងដើម សម្រាប់ប្រហារនូវឧបនិស្ស័យរបស់កិលេស គឺអង្គទី ១ សម្រាប់ប្រហារនូវឧបនិស្ស័យរបស់មោហៈ, អង្គទី ២ សម្រាប់ប្រហារនូវឧបនិស្ស័យរបស់ទោសៈ, អង្គទី ៣ និងទី ៤ សម្រាប់ប្រហារនូវ*

ឧបនិស្ស័យរបស់រាគៈ, ឯអន្តក្រៅអំពីនេះ សម្រាប់កំណត់ដែនរបស់ប្រយោជន៍ប៉ុណ្ណោះ ។

ពាក្យថា បិណ្ឌបាតំ **(បិណ្ឌបាត)** បានដល់ អាហារឯណានីមួយ ។ មែនពិត អាហារណាមួយ ឈ្មោះថា បិណ្ឌបាត ព្រោះធ្លាក់ចុះក្នុងបាត្រភិក្ខុ ដោយភាពជាដុំបាយ ។ ម្យ៉ាងទៀត ការធ្លាក់ចុះនៃដុំបាយ ឈ្មោះថា **បិណ្ឌបាត** ។ លោកពោលសេចក្តីថា កិរិយាប្រជុំចុះព្រមនៃភិក្ខា ដែលភិក្ខុបានហើយក្នុងទីនោះៗ ។ល។

ដីកា បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖

ពាក្យថា **អាហារឯណានីមួយ** សេចក្តីថា វត្ថុដែលបុគ្គលគប្បីទំពាយ៉ាងណាមួយ ដែលផ្សេងដោយខាទនីយៈ និងភោជនីយៈជាដើម ។

ពាក្យថា **មិនមែនដើម្បីលេង ដើម្បីស្រវឹង ដើម្បីប្រដាប់តាក់តែង និងឲ្យមានសម្បុរផូរផង់ទេ** នេះ ជាពាក្យសម្តែងអត្ថបដិសេធ ដោយអវធារណៈថា "យាវទេវ" (ត្រឹមតែដើម្បី...ប៉ុណ្ណោះ) ។ ឈ្មោះថា **ឋិតិ** ព្រោះអត្ថថា ជាហេតុតាំងនៅនៃឧបាទិន្នធម៌ បានដល់ **អាយុ** ព្រោះដូច្នោះ លោកទើបពោលថា "ពាក្យថា ឋិតិនេះ ជាឈ្មោះរបស់ជីវិតិន្ទ្រិយ" ដូច្នេះ ។ ពិត

*យ៉ាងនោះ អាយុនោះ លោកសម្តែងថា ឈ្មោះថា “**ឋិតិ**”, ពាក្យថា* ឋិតិយា យាបនាយ *សេចក្តីថា ដើម្បីឲ្យជីវិតិន្ទ្រិយដែលបាន* *វោហារថា “**ឋិតិ**” ព្រោះជាហេតុតាំងនៅនៃកាយឲ្យប្រព្រឹត្តទៅ ។* *ព្រោះហេតុនោះ លោកទើបពោលថា “ដើម្បីញុំាងជីវិតិន្ទ្រិយ៍ឲ្យ* *ប្រព្រឹត្តទៅ” ។*

*ពាក្យថា* អាពាធនដ្ឋេន *សេចក្តីថា ព្រោះអត្ថថា បៀត-បៀន, ឬព្រោះអត្ថថា ចាក់ដោត ។ មែនពិត សេចក្តីឃ្លានជារោគ* *យ៉ាងក្រៃលែង ។ បទថា* ឧបរមត្ថំ *សេចក្តីថា ដើម្បីរម្ងាប់ ។* *ដូចមនុស្សឈឺដំបៅ ក៏ត្រូវលាបថ្នាំរក្សាដំបៅ ។ ភ្ជាប់សេចក្តីថា* *ដូចមនុស្សឈឺ កាលសេចក្តីក្តៅនិងសេចក្តីត្រជាក់ជាដើម គ្រប* *សង្កត់ ក៏សេពចំពោះនូវថ្នាំត្រជាក់និងថ្នាំក្តៅ ដែលជាគ្រឿងកែ* *ភាពត្រជាក់ និងក្តៅនោះ ។*

*ក្នុងគម្ពីរវិសុទ្ធិមគ្គ ថា ៖*

**ព្រហ្មចរិយានុគ្គហាយា**តិ សកលសាសនព្រហ្មចរិយស្ស ច មគ្គព្រហ្មចរិយស្ស ច អនុគ្គហត្ថំ ។ អយញ្ហិ បិណ្ឌ-បាតបដិសេវនបច្ចយា កាយពលំ និស្សាយ សិក្ខត្តយា-នុយោគវសេន ភវកន្តារនិត្ថរណត្ថំ បដិបជ្ជន្តោ ព្រហ្មចរិយា-នុគ្គហាយ បដិសេវតិ, កន្តារនិត្ថរណត្ថិកា បុត្តមំសំ

វិយ, នទីនិត្ថរណត្ថិកា កុល្លំ វិយ, សមុទ្ទនិត្ថរណត្ថិកា នាវមិវ ច ។

*ពាក្យថា ព្រហ្មចរិយានុគ្គហាយ (ដើម្បីអនុគ្រោះដល់ព្រហ្មចរិយៈ) បានដល់ ដើម្បីអនុគ្រោះដល់សាសនព្រហ្មចរិយៈទាំងអស់ និងមគ្គព្រហ្មចរិយៈ ។ សេចក្ដីពិតថា ភិក្ខុនេះ អាស្រ័យកម្លាំងកាយ ព្រោះឆាន់បិណ្ឌបាតជាបច្ច័យ ហើយបដិបត្តិដើម្បីផុតឆ្ងាយគឺភព ដោយអំណាចនៃកិរិយាប្រកបរឿយៗ ក្នុងសិក្ខា ៣ យ៉ាង ឈ្មោះថា ឆាន់ដើម្បីអនុគ្រោះព្រហ្មចរិយៈ, ដូចពួកជនអ្នកត្រូវការឆ្លងផុតឆ្ងាយ ត្រូវស៊ីសាច់កូន, និងដូចពួកជនអ្នកត្រូវការឆ្លងស្ទឹង ត្រូវអាស្រ័យក្បូន, និងដូចពួកជនអ្នកត្រូវការឆ្លងសមុទ្រត្រូវអាស្រ័យនាវា ។*

***<u>ដីកា</u> បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖***

មគ្គព្រហ្មចរិយំ ឋបេត្វា សិក្ខត្តយសង្គហា សាសនាវចរិតព្វា អនុសាសនី សាសនព្រហ្មចរិយន្តិ អាហ "**សកលសាសនព្រហ្មចរិយស្ស ច មគ្គព្រហ្មចរិយស្ស** ចា"តិ ។ *អនុសាសនី គឺពាក្យទូន្មាននោះឯង ដែលបុគ្គលគប្បីប្រព្រឹត្ត ដែលសង្គ្រោះដោយសិក្ខា ៣ វៀរមគ្គព្រហ្មចរិយៈ ជាសាសនព្រហ្ម-*

ចរិយៈ ដូច្នោះ លោកទើបពោលថា “**ដើម្បីអនុគ្រោះដល់សាសន-ព្រហ្មចរិយៈទាំងអស់ និងមគ្គព្រហ្មចរិយៈ**” ដូច្នេះ ។

**អនុគ្គហាណត្ថន្តិ** អនុ អនុ គណ្ហានត្ថំ សម្បាទនត្ថំ។

បទថា **អនុគ្គហាណត្ថំ** ប្រែថា ដើម្បីអនុគ្រោះ គឺដើម្បីឲ្យដល់ព្រម ។

ពាក្យថា **កាយពលំ និស្សាយ** (អាស្រ័យកម្លាំងកាយ) សេចក្ដីថា អាស្រ័យកម្លាំងកាយដែលជាហេតុឲ្យគុណវិសេសបរិបូរណ៍ តាមដែលបានប្រារព្ធទុក ។ ព្រោះដូច្នោះ លោកទើបពោលថា “**ដោយអំណាចនៃកិរិយាប្រកបរឿយៗ ក្នុងសិក្ខា ៣**” ជាដើម ។ មានការប្រៀបធៀបដោយឧបមាថា កិរិយានិងស្វាមីត្រូវការឆ្លងផ្លូវកន្តារ និងមនុស្សត្រូវការឆ្លងស្ទឹង និងសមុទ្រសំឡឹងដល់ការសម្រេចប្រយោជន៍នោះៗ តែម្យ៉ាងប៉ុណ្ណោះ ជាអ្នកមិនមានសេចក្ដីត្រេកអរ សេចក្ដីពេញចិត្ត បរិភោគនូវសាច់បុត្តជាដើមទេ (បន្ទំចិត្តបរិភោគ) ក៏ព្រោះ(បើ)វៀរសាច់បុត្តជាដើមនោះ ក៏នឹងមិនសម្រេច (ការឆ្លងផ្លូវកន្តារ) សេចក្ដីនេះយ៉ាងណា, សូម្បីយោគីនេះ ក៏ត្រូវការនឹងឆ្លងផ្លូវកន្តារគឺភពតែម្យ៉ាងក៏ដូច្នោះ ជាអ្នកមិនមានសេចក្ដីប្រាថ្នា មិនមានសេចក្ដីពេញចិត្ត ក៏ចាំបាច់ត្រូវសេព

ចំពោះនូវបិណ្ឌបាត ព្រោះវៀរចាកបិណ្ឌបាតនោះ ការឆ្លងផ្លូវកន្តារគឺភព ក៏នឹងមិនសម្រេច ។

នៅក្នុងគម្ពីរបរមត្ថមញ្ជូសា អធិប្បាយថា ៖

អន្តរាយដែលចូលមកកាត់ផ្តាច់ជីវិតិន្ទ្រិយ ឬទម្លាយឥរិយាបថ គប្បីមានបាន ក៏ព្រោះប្រកបដោយការបរិភោគអាហារដែលមិនសប្បាយ និងការបរិភោគលើសប្រមាណ តែអន្តរាយនោះនឹងមិនមាន ក៏ព្រោះប្រកបដោយការបរិភោគអាហារដែលជាទីសប្បាយ និងការបរិភោគល្មមប្រមាណ ។ លោកអាចារ្យ កាលនឹងសម្តែងសេចក្តីនេះថា កាលជាយ៉ាងនេះ ការធ្វើដំណើរទៅ គឺការប្រព្រឹត្តិទៅនៃសរីរៈ ពោលគឺសេចក្តីប្រព្រឹត្តទៅបានអស់កាលយូរនឹងមានបាន ទើបពោលថា "ដោយការបរិភោគល្មមប្រមាណការប្រព្រឹត្តិទៅ គឺការធ្វើដំណើរទៅអស់កាលយូរ ព្រោះមិនមានអន្តរាយដែលនឹងចូលមកកាត់ជីវិតិន្ទ្រិយ ឬនឹងទម្លាយឥរិយាបថនឹងមានដល់យើង" ដូច្នេះ ។ រោគណា មិនជារោគដែលកែបាន និងដែលកែមិនបាន រោគនោះ ឈ្មោះថា **រោគពុំរៃ** រោគនោះមានដល់បុគ្គលនេះ បុគ្គលនេះ ឈ្មោះថា **រោគពុំរៃ** ។

ក៏មនុស្សអ្នកមានរោគពុំរៃនោះ រមែងប្រើថ្នាំរក្សាអស់កាលជានិច្ច សូម្បីកិក្ខុនេះ ក៏ត្រូវសេពដូច្នោះឯង ។ សួរថា បើថា

ការធ្វើដំណើរទៅ គឺការសម្រេចអត្តភាពឲ្យប្រព្រឹត្តទៅសោត ពាក្យដែលលោកពោលទុកក្នុងបទមុនថា "ដើម្បីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ"ក្តី ក្នុងរឿងនេះ មានសេចក្តីបែកផ្សេងគ្នាយ៉ាងណា ? ឆ្លើយថា ការញ៉ាំងជីវិតិន្ទ្រីយ៍ឲ្យប្រព្រឹត្តទៅ ទ្រង់ប្រាថ្នាយកថា "យាបនា (ដើម្បីញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅ)" ក្នុងបទមុន, តែក្នុងបទនេះ ទ្រង់ប្រាថ្នាយកការប្រព្រឹត្តិទៅ គឺការធ្វើដំណើរទៅ ពោលគឺសេចក្តីមិនដាច់ខ្សែនៃឥរិយាបថទាំង ៤ ដូច្នោះក្នុងរឿងនេះ មានសេចក្តីដូចពោលមកនេះ ។

ការស្វែងរកបច្ច័យដោយមិច្ឆាជីវៈ ដែលព្រះពុទ្ធជាម្ចាស់ទ្រង់វៀរសហើយ ឈ្មោះថា **ការស្វែងរកមិនប្រពៃ** ។ ការមិនដឹងប្រមាណក្នុងទេយ្យធម៌របស់ទាយក, និងរបស់ខ្លួន ហើយទទួល, ឬការទទួលដើម្បីនឹងញ៉ាំងសទ្ធាទេយ្យឲ្យធ្លាក់ចុះ ឈ្មោះថា ការទទួលដែលមិនប្រពៃ ឬបានដល់ ការទទួលដែលជាហេតុត្រូវអាបត្តិ ។ ការមិនពិចារណាហើយបរិភោគ ឈ្មោះថា ការបរិភោគដែលមិនប្រពៃ ។ ការវៀរការស្វែងរក ការទទួល និងការបរិភោគដែលមិនប្រពៃទាំងនោះ គប្បីជ្រាបដោយអំណាចការធ្វើបច្ច័យឲ្យកើតឡើងជាដើម ដោយធម៌ដ៏ស្មើ ។ មែនពិត ការស្វែងរកបច្ច័យ

ដោយធម៌ ទទួលមកដោយធម៌ ពិចារណាហើយ ទើបបរិភោគ ឈ្មោះថា ជាអ្នកមិនមានទោស ។ល។

**ក្នុងគម្ពីរវិសុទ្ធិមគ្គ ថា ៖**

ចត្តារោ បញ្ច អាលោបេ អភុត្វា ឧទកំ បិវេ

អលំ ផាសុវិហារាយ បហិតត្តស្ស ភិក្ខុនោ ។

ភិក្ខុគប្បីឈប់បរិភោគ (អាហារ) ៤-៥ ពុំនូតទៀត (ទឹងឆ្អែត) ហើយផាន់ទឹក នេះក៏ល្មមហើយ ដើម្បីការនៅជាសុខនៃភិក្ខុអ្នកបំពេញសេចក្តីព្យាយាម ។

ដោយហេតុមានប្រមាណប៉ុណ្ណេះ ការកំណត់នូវប្រយោជន៍ នឹងការបដិបត្តិជាកណ្តាល គប្បីជ្រាបថា ទ្រង់សម្តែងហើយ ។

## សេនាសនប្បច្ច័យ

ក្នុងសេនាសនប្បច្ច័យ កំណត់ដែនរបស់ប្រយោជន៍៥ យ៉ាងគឺ

១-សីតស្ស បដិឃាតាយ ដើម្បីការពារនូវត្រជាក់;

២-ឧណ្ហស្ស បដិឃាតាយ ដើម្បីការពារនូវកំដៅ;

៣-ឌំសមកសវាតាតបសិរីសបសម្ផស្សានំ បដិឃាតាយ ដើម្បីការពារនូវសម្ផស្សនៃរបោម មូស ខ្យល់ កំដៅថ្ងៃ

ពស់តូច និងពស់ធំទាំងឡាយ;

៤–ឧតុបរិស្សយវិនោទនំ ដើម្បីបន្ទោបង់នូវក្រវល់ក្រវាយ ដែលកើតអំពីរដូវ ;

៥–បដិសល្លានារាមត្ថំ ដើម្បីប្រមូលចិត្តអំពីអារម្មណ៍ផ្សេងៗ ហើយអភិរម្យសម្ងំនៅក្នុងកម្មដ្ឋាន ។

ពាក្យថា **សេនាសនៈ** បានសេចក្តីថា ទាំងទីដេកទីអង្គុយ ។ សេចក្តីពិត ភិក្ខុដេកក្នុងទីណាៗ ទីនោះៗ ទោះក្នុងវិហារក្តី ទោះក្នុងទីមានបង្អាជាដើមក្តី ឈ្មោះថា **សេនៈ**, ភិក្ខុអង្គុយនៅក្នុទីណាៗ ទីនោះៗ ឈ្មោះថា **អាសនៈ**, រួមទីនោះជាមួយគ្នា ហៅថា **សេនាសនៈ** ។

ពាក្យថា **ដើម្បីបន្ទោបង់សេចក្តីអន្តរាយគឺរដូវ** និងដើម្បីសេចក្តីចៀសចេញចាកអារម្មណ៍ ហើយសម្ងំនៅ បានសេចក្តីថា រដូវហ្នឹងឯង ឈ្មោះថា អន្តរាយគឺរដូវ ដោយអត្ថថា ជាសត្រូវដើម្បីបន្ទោបង់សេចក្តីអន្តរាយគឺរដូវ និងដើម្បីសេចក្តីត្រេកអរក្នុងការចៀសចេញចាកអារម្មណ៍ ហើយសម្ងំនៅ ។

រដូវមិនជាទីសប្បាយណា ធ្វើការបៀតបៀនដល់សរីរៈ និងធ្វើចិត្តឲ្យរាយមាយ ជារដូវគឺភិក្ខុគប្បីបន្ទោបង់ដោយការប្រើប្រាស់

សេនាសនៈ លោកពោលសេចក្ដីថា ដើម្បីបន្ទោបង់នូវរដូវនោះ និងដើម្បីសេចក្ដីសុខ ដល់ភាពនៃបុគ្គលម្នាក់ឯង ។

កិរិយាបន្ទោបង់នូវសេចក្ដីអន្តរាយ គឺរដូវលោកពោលហើយ ដោយន័យថា ដើម្បីការពារត្រជាក់ជាដើម ក៏ពិតមែនហើយ, តែលោកពោលសេចក្ដីថា ការបិទបាំងកេរ្តិ៍ខ្មាស ជាប្រយោជន៍ដ៏ទៀង ក្នុងការប្រើប្រាស់ចីវរ, ប្រយោជន៍ក្រៅនេះ គង់មានក្នុងកាលម្ដងៗ យ៉ាងណា សូម្បីក្នុងទីនេះ គប្បីជ្រាបពាក្យថា ដើម្បីបន្ទោបង់សេចក្ដីអន្តរាយ គឺរដូវ និងសេចក្ដីត្រេកអរក្នុងការចៀសចេញចាកអារម្មណ៍ ហើយសម្ងំនៅនេះ ជាពាក្យដែលលោកពោលហើយ សំដៅដល់កិរិយាបន្ទោបង់សេចក្ដីអន្តរាយ គឺរដូវដ៏ទៀងយ៉ាងនោះដែរ ។ ម្យ៉ាងទៀត រដូវមានបការៈដូចពោលហើយនេះបានដល់ រដូវហ្នឹងឯង ។

ឯសេចក្ដីអន្តរាយមាន ២ យ៉ាង គឺ **អន្តរាយដែលប្រាកដ** ១ **ដែលកំបាំង** ១ ។ ក្នុង ២ យ៉ាងនោះ ពួកសត្វមានរាជសីហ៍ និងខ្លាជាដើម ឈ្មោះថា **អន្តរាយប្រាកដ** ។ កិលេសទាំងឡាយ មានរាគៈ និងទោសៈជាដើម ឈ្មោះថា **អន្តរាយដ៏កំបាំង** ។

# គិលានប្បច្ច័យ

ក្នុងគិលានប្បច្ច័យ ដែនរបស់ប្រយោជន៍កំណត់ត្រឹមតែ ១ គឺ ឧប្បន្នានំ វេយ្យាពាធិកានំ វេទនានំ បដិឃាតាយ អព្យាបជ្ឈបរមតាយ : ដើម្បីការពារនូវទុក្ខវេទនាទាំងឡាយ ដែលបៀតបៀនផ្សេងៗ ដែលកើតឡើងហើយ ដរាបទៅដល់ត្រឹមប្រាសចាកសេចក្ដីទុក្ខ ។

វិនិច្ឆ័យក្នុងពាក្យថា គិលានបច្ចយភេសជ្ជបរិក្ខារំ នេះ **ថ្នាំ** ឈ្មោះថា **បច្ច័យ** ដោយសេចក្ដីសំដៅថា ជាសត្រូវ, សេចក្ដីថា ដោយអត្ថថា ដល់ភាពជាសត្រូវចំពោះរោគ ។ ពាក្យថា **បច្ច័យ** នេះ ជាឈ្មោះនៃវត្ថុជាទីសប្បាយណាមួយ ។ ការងារនៃគ្រូពេទ្យ ព្រោះភាពនៃថ្នាំដែលគ្រូពេទ្យនោះ អនុញ្ញាតហើយ ព្រោះហេតុនោះ ឈ្មោះថា **ភេសជ្ជៈ** ។ ថ្នាំជាបច្ច័យនៃអ្នកជម្ងឺហ្នឹងឯង ឈ្មោះថា **គិលានប្បច្ចយភេសជ្ជៈ** ។ ការងារគ្រូពេទ្យណាមួយ ជាទីសប្បាយដល់អ្នកជម្ងឺ លោកពោលសេចក្ដីថា ប្រេង ទឹកឃ្មុំ និងស្ករអំពៅ ជាដើម ។ ឯគ្រឿងព័ទ្ធព័ទ្ធ ដែលលោកពោលក្នុងប្រយោគទាំងឡាយថា នគរដែលគេបិទល្អហើយ ដោយកំពែងនៃនគរបរិក្ខារ ៧ ជាន់ជាដើម ឈ្មោះថា **បរិក្ខារ** ។ គ្រឿងអលង្ការដែលលោកពោលក្នុងប្រយោគទាំងឡាយថា **រថ** (គឺអរិយមគ្គ) មានសីលជា

បរិក្ខារ មានឈានជាក្ងៅ មានសេចក្តីព្យាយាមជាកង់ជាដើម ។ សម្ភារៈដែលលោកពោលទុកក្នុងប្រយោគទាំងឡាយថា បរិក្ខារនៃជីវិតនេះហ្នឹងឯង គឺបព្វជិតគប្បីផ្គត់ផ្គង់ជាដើម ។ ក៏ឯគ្រឿងផ្សំក្តី គ្រឿងព័ទ្ធព័ទ្ធក្តី រមែងគួរក្នុងបទនេះ ។ សេចក្តីពិត ថ្នាំជាបច្ច័យនៃជម្ងឺនោះ ឈ្មោះថា គ្រឿងការពារជីវិត ព្រោះមិនឲ្យចន្លោះដល់កិរិយាកើតឡើងនៃអាពាធ គ្រឿងសម្រេចជីវិតឲ្យវិនាសហើយរក្សាខ្លះ ឈ្មោះថា ជាគ្រឿងគាំទ្រ ព្រោះជាហេតុឲ្យជីវិតនោះ ប្រព្រឹត្តទៅអស់កាលយូរខ្លះ ព្រោះហេតុនោះ ទើបលោកពោលថា **បរិក្ខារ** ។ ដោយអាការយ៉ាងនេះ ថ្នាំជាបច្ច័យនៃជម្ងឺនោះ ជាបរិក្ខារនៃជីវិត ព្រោះហេតុនោះ ឈ្មោះថា **គិលានបច្ចយ-ភេសជ្ជបរិក្ខារ** ។ នូវថ្នាំជាបច្ច័យនៃជម្ងឺ ជាគ្រឿងគាំទ្រនោះ ។ វត្ថុណាមួយជាទីសប្បាយដល់អ្នកជម្ងឺ ដែលគ្រូពេទ្យអនុញ្ញាតហើយ លោកពោលសេចក្តីថា គ្រឿងគាំទ្រជីវិត មានប្រេង ទឹកឃ្មុំ និងស្ករអំពៅជាដើម ។

ពាក្យថា **កើតឡើងហើយ** បានសេចក្តីថា កើតមានស្រេចហើយ ។ ក្នុងពាក្យថា **នៃអាពាធផ្សេងៗ** នេះ បានសេចក្តីថា ការកម្រើកធាតុ ឈ្មោះថា ការបៀតបៀន និងរោគឃ្លង់ បូសនិងកមជាដើម ដែលមានការកម្រើកធាតុនោះ ជាសមុដ្ឋាន ឈ្មោះថា ការបៀតបៀនផ្សេងៗ ។ ព្រោះកើតអំពីព្យាពាធ ។ ពាក្យថា

*សោយ* បានសេចក្ដីថា សោយទុក្ខ បានដល់ សោយផលនៃអកុសល ។ (ដើម្បីឃាត់) ការសោយអាពាធផ្សេងៗនោះ ។ ពាក្យថា **ដើម្បីមិនបៀតបៀនយ៉ាងក្រៃលែង** បានសេចក្ដីថា ដើម្បីសេចក្ដីមិនមានទុក្ខយ៉ាងក្រៃលែង ។ (អធិប្បាយថា) ពេលណាភិក្ខុឆាន់ថ្នាំ ពេលនោះ ទុក្ខទាំងអស់ គឺភិក្ខុលះបង់ហើយ ។

នៅក្នុងគម្ពីរបរមត្ថមញ្ជុសា **ភាគ១ ពន្យល់ថា ៖**

ភាពជាបដិបក្ខចំពោះរោគ ដែលមានការកម្រើកនៃធាតុជាលក្ខណៈ, ឬថា មានទុក្ខវេទនាដែលមានការកម្រើកនៃធាតុនោះជាហេតុ ជាលក្ខណៈ ឈ្មោះថា អត្ថថា ជាហេតុប្រឆាំ ។ ដោយហេតុនោះ លោកអាចារ្យទើបពោលថា "សេចក្ដីថា ដោយអត្ថថា ដល់ភាពជាសត្រូវ (ចំពោះរោគ)" ដូច្នេះ, មានអធិប្បាយថា ដោយអត្ថថា ស្ងប់រម្ងាប់ (រោគ)បាន ។

ពាក្យថា **(វត្ថុដែលជាទីសប្បាយ) យ៉ាងណាមួយ** បានដល់ (វត្ថុដែលជាទីសប្បាយ) យ៉ាងណាមួយ បណ្ដាវត្ថុមានទឹកដោះថ្លាជាដើម ។ មែនពិត មានអធិប្បាយថា វត្ថុសប្បាយ ព្រោះវត្ថុនោះស្ងប់សេចក្ដីវិការបាន ។ ឈ្មោះថា ជាវត្ថុដែលពេទ្យផ្ញើ ព្រោះជាវត្ថុដែលពេទ្យនោះ គប្បីចាត់ចែង ។ ព្រោះហេតុនោះ លោកទើបពោលថា "ព្រោះសេចក្ដីដែលពេទ្យនោះអនុញ្ញាត" ដូច្នេះ ។

ពាក្យថា **ដោយបរិក្ខារនៃនគរ** គឺដោយវត្ថុឡោមព័ទ្ធរក្សាព្រះនគរ ។ អាចារ្យទាំងឡាយពោលដល់វត្ថុ ៧ យ៉ាង ថា "បរិក្ខារនៃនគរ" ដូច្នេះក៏មាន ។

ពាក្យថា **មានសីលជាបរិក្ខារ** គឺមានសីលដែលបរិសុទ្ធល្អជាគ្រឿងប្រដាប់ ។ ក៏ក្នុងសូត្រនេះ **អរិយមគ្គ** ទ្រង់ប្រាថ្នាយកថា "រថ" និងត្រាស់ដល់ធម៌ទាំងឡាយ មានសម្មាវាចាជាដើមថាជា "បរិក្ខារ" ដោយអត្ថថា ជាគ្រឿងប្រដាប់នៃអរិយមគ្គនោះ ។

ពាក្យថា **បរិក្ខារនៃជីវិត** បានដល់ ហេតុនៃការប្រព្រឹត្តិទៅនៃជីវិត ។ បទថា សមុទានេតព្វា (គប្បីនាំមកដោយប្រពៃ) គឺគប្បីនាំមក បានដល់ គប្បីស្វែងរកតៗទៅដោយប្រពៃ ។ គេសជ្ជៈដែលជាបច្ច័យសម្រាប់មនុស្សឈឺនោះ រមែងជាបរិក្ខារ (នៃជីវិត) ព្រោះការពារអន្តរាយទាំងឡាយបានដោយប្រពៃ ។ ព្រោះហេតុនោះ លោកទើបពោលថា "ព្រោះរក្សាទុក ។ល។ ដែលធ្វើជីវិតឲ្យវិនាស" ដូច្នេះ ។

ក្នុងពាក្យទាំងឡាយនោះ បទថា អន្តរំ ប្រែថា ចន្លោះ សំដៅសេចក្តីថា **ឱកាស** ។ សេចក្តីថា ព្រោះរក្សាទុក បីដូចពួកសេវកៈអ្នកបម្រើ ឈរឡោមព័ទ្ធរក្សាម្ចាស់របស់ខ្លួន មិនឲ្យឱកាសដល់ពួកសត្រូវ ។

*បទថា អស្ស ប្រកប ជីវិតស្ស ប្រែថា នៃជីវិតនោះ ។ ពាក្យថា **ព្រោះភាពជាហេតុ** គឺព្រោះភាពជាហេតុនៃការប្រព្រឹត្តិទៅបានអស់កាលយូរ ។ មែនពិត ភេសជ្ជៈដែលជា**សាតនៈ** គឺដែលមានក្នុងផ្លូវបញ្ជូនអាហារ (**សាយនៈ** ប្រែថា សរសៃនាំរសក៏បាន) រមែងញ៉ាំងជីវិតឲ្យប្រព្រឹត្តទៅអស់កាលសូម្បីយូរពិត ។ ភិក្ខុរមែងកំចាត់ទុក្ខវេទនាដែលនៅមិនទាន់កើតឡើងនៅឡើយ ដោយការបរិភោគភេសជ្ជៈ មិនមែនកំចាត់ទុក្ខវេទនាដែលកើតឡើងហើយទេ ព្រោះទុក្ខវេទនាដែលកើតឡើងហើយទាំងនោះ មានការបែកធ្លាយទៅតាមសភាវៈរបស់ខ្លួននោះឯងក៏ពិត ។ សូម្បីដូច្នោះ លោកក៏ហៅទុក្ខវេទនាដែលនៅមិនទាន់កើតឡើង ដែលដូចនឹងទុក្ខ-វេទនាដែលកើតឡើងហើយថា "កើតឡើងហើយ" ។ មែនពិត វោហារថា កើតឡើងហើយនោះ រមែងមានបានក្នុងធម៌ទាំងឡាយដែលដូចជាធម៌ដែលកើតឡើងហើយនោះ, ដូចពាក្យថា* សា ឯវ តិត្តិរិ *(សត្វទានោះឯង)*, តានិយេវ ឱសធានិ *(ឱសថ ក៏គឺនោះៗ ឯង) ដូច្នេះឯង ។ ព្រោះដូច្នោះ លោកទើបពោលថា បទថា "*ឧប្បន្នានំ *ប្រែថា កើតឡើងហើយ គឺមានហើយ បង្កើតហើយ" ដូច្នេះ ។*

*ការកម្រើកនៃធាតុនោះ ចាប់ផ្តើមអំពីការកកើតខ្លួន ក៏ជាសមុដ្ឋាននៃរោគទាំងនេះ ព្រោះហេតុនោះ រោគទាំងនេះ ទើបឈ្មោះថា មានការកម្រើកនៃធាតុនោះជាសមុដ្ឋាន ។ លោកអាចារ្យពោលទុកថា “**ទុក្ខវេទនា**” ដូច្នេះ ហើយពោលថា “ទុក្ខវេទនាដែលជាអកុសលវិបាក” ដើម្បីធ្វើឲ្យផ្សេងអំពីទុក្ខវេទនានោះ ព្រោះទុក្ខ-វេទនានោះ សូម្បីមានសភាពជាអកុសលក៏មាន ។ ការកម្រើកនៃធាតុ ឈ្មោះថា **ព្យាពាធ** ព្រោះអត្ថថា ធ្វើឲ្យលំបាកទៅផ្សេងៗ ព្យាពាធនោះឯង ជា **ព្យាបជ្ឈ** ព្រោះអត្ថថា ជាទីមិនមានព្យាបជ្ឈ បានដល់ សេចក្តីមិនមានទុក្ខ ។ ព្រោះហេតុនោះ លោកអាចារ្យពោលថា បទថា “**អព្យាបជ្ឈបរមតាយ**” ប្រែថា ដើម្បីសេចក្តីមិនមានទុក្ខជាយ៉ាងក្រៃលែង ដូច្នេះ ។*

*ពាក្យថា **ទុក្ខនោះ** បានដល់ ទុក្ខដែលមានរោគជាហេតុ ។*

*<u>ក្នុងគម្ពីរវិសុទ្ធិមគ្គ</u> ថា ៖*

ឯវមិទំ សង្ខេបតោ បដិសង្ខា យោនិសោ បច្ចយ-បរិភោគលក្ខណំ បច្ចយសន្និស្សិតសីលំ វេទិតព្វំ ។ *សីលដែលមានកិរិយាពិចារណាដោយឧបាយនៃបញ្ញា ហើយបរិភោគនូវបច្ច័យជាលក្ខណៈនេះ គប្បីជ្រាបថា ឈ្មោះថា **បច្ចយសន្និ-ស្សិតសីល** ដោយសង្ខេបយ៉ាងនេះឯង ។*

*ឯវចនត្ថៈនៃពាក្យនុ៎ះ ដូចតទៅ ៖*

ចីវរាទយោ ហិ យស្មា តេ បដិច្ច និស្សាយ បរិភុញ្ជមានា ចាណិនោ អយន្តិ បវត្តន្តិ, តស្មា បច្ចយាតិ វុច្ចន្តិ ។ តេ បច្ចយេ សន្និស្សិតន្តិ បច្ចយសន្និស្សិតំ ។

*មែនពិត សត្វទាំងឡាយពឹង អាស្រ័យនូវចីវរជាដើមនោះ ហើយប្រើប្រាស់ ទើបទៅបាន គឺដំណើរទៅបាន ព្រោះហេតុនុ៎ះឯង លោកទើបហៅថា* ***បច្ច័យ*** *។ សីលដែលអាស្រ័យនូវបច្ច័យទាំងឡាយនោះ ឈ្មោះថា* ***បច្ចយសន្និស្សិតសីល*** *។*

# ចតុបារិសុទ្ធិសម្បាទនវិធិ

## ១-បាតិមោក្ខសំវរសីល

ឯវមេតស្មិំ ចតុព្វិធេ សីលេ សទ្ធាយ **ចាតិមោក្ខ-សំវរោ** សម្បាទេតព្វោ ។ *បណ្ដាសីលទាំង ៤ យ៉ាងនុ៎ះ* ***បាតិមោក្ខសំវរៈ*** *ភិក្ខុគប្បីឲ្យសម្រេចដោយសទ្ធា ។*

*សេចក្ដីពិត បាតិមោក្ខសំវរៈនោះ មានកិរិយាសម្រេចដោយសទ្ធា ព្រោះការបញ្ញត្តសិក្ខាបទកន្លងនិស្ស័យនៃសាវក ។ ក៏ការត្រាស់ហាមឃាត់ការទូលសូមឲ្យទ្រង់បញ្ញត្តិសិក្ខាបទ ជានិទស្សនៈ*

ក្នុងបាតិមោក្ខសំវរៈនុ៎ះ ។ ព្រោះហេតុនោះ ភិក្ខុសមាទានទូវសិក្ខា-បទ តាមដែលព្រះអង្គបញ្ញត្ត មិនឲ្យសេសសល់ដោយសទ្ធា មិនធ្វើនូវសេចក្តីអាឡោះអាល័យសូម្បីក្នុងជីវិត គប្បីឲ្យសម្រេចដោយប្រពៃ ។ សមដូចទ្រង់សម្តែងពាក្យនេះថា ៖

កិកីវ អណ្ឌំ ចមរីវ វាលធឹ
បិយំវ បុត្តំ នយនំវ ឯកកំ
តថេវ សីលំ អនុរក្ខមានកា
សុបេសលា ហោថ សទា សគារវា ។

**បក្សីត្រដេវវិច** រក្សាពងយ៉ាងណា **ម្រឹគទ្រាយសត្វចាមរី** រក្សារោមកន្ទុយយ៉ាងណា **មាតា** រក្សាកូនជាទីស្រឡាញ់ យ៉ាងណា **បុរសមានភ្នែកម្ខាង** រក្សាភ្នែកយ៉ាងណា, អ្នកទាំងឡាយកាលរក្សាសីល ចូរជាអ្នកមានសីលជាទីស្រឡាញ់ ប្រកបដោយសេចក្តីគោរពគ្រប់កាល យ៉ាងនោះចុះ ។

<u>ក្នុងដីកា</u> បរមត្ថមញ្ជុសា លោកពន្យល់ថា ៖

លោកអាចារ្យប្រាថ្នានឹងសម្តែងសីល ដែលបានសម្តែងទុកដោយសេចក្តីផ្សេងគ្នានៃសីល មានបាតិមោក្ខសំវរជាដើម តាមប្រការដែលពោលហើយ ដោយការចែកហេតុឲ្យសម្រេចទៀត ទើបផ្តើមពាក្យថា “**ឯវមេតស្មឹ**” ដូច្នេះជាដើម ។ ក្នុងបទទាំងនោះ

ឈ្មោះថា **សាធនៈ** ព្រោះអត្ថថា ជាហេតុឲ្យសម្រេច គឺឲ្យដល់ព្រម បាតិមោក្ខសំវរ ឈ្មោះថា **សទ្ធាសាធនៈ** ព្រោះអត្ថថា មានសទ្ធា ជាហេតុឲ្យសម្រេច ។

ក៏បើថា សូម្បីវៀរវីរិយៈ សតិ និងបញ្ញាចេញ បាតិមោក្ខ-សំវរសីល ក៏សម្រេចមិនបាន មិនមែនឬ ?

លោកអាចារ្យកាលសម្តែងថា ពិតមែន សម្រេចមិនបានទេ តែដែលពោលយ៉ាងនេះ សំដៅយកការៈដែលសទ្ធាជាហេតុវិសេស ដូច្នេះ ទើបពោលថា "ព្រោះសេចក្តីដែលការទ្រង់បញ្ញត្តិសិក្ខាបទ ផុតវិស័យរបស់សាវក" ដូច្នេះ ។ល។

ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ក្នុងសីល ៤ នោះ គប្បីជ្រាបសាធនៈដូច្នេះ ឈ្មោះថា **សាធនៈ** ដោយអត្ថថា ជាគ្រឿងសម្រេច គឺជាគ្រឿងឲ្យដល់សេចក្តីសម្រេច, សាធនៈ គឺសទ្ធារបស់ភិក្ខុនេះ ហេតុនោះ ភិក្ខុនេះឈ្មោះថា អ្នកញ៉ាំងសទ្ធាឲ្យសម្រេច ។ កាលដែលព្រះសាវកទាំងឡាយ កន្លងវិស័យរបស់ខ្លួន គប្បីឲ្យដល់ព្រមគឺសទ្ធា ហេតុនោះ លោក ទើបពោលថា **ព្រោះកន្លងវិស័យរបស់សាវក** ។

ក្នុងសេចក្តីនេះ ពាក្យថា **ជានិទស្សនៈ** នេះ ឲ្យសម្រេចក្នុង សេចក្តីមិនមែនជាវិស័យ ។ ពាក្យថា **ព្រោះហេតុនោះ** សេចក្តីថា

ព្រោះញុំាងសទ្ធាឲ្យសម្រេច ។ មានវាចាប្រកបសេចក្ដីថា ភិក្ខុសមាទានសិក្ខាបទ សូម្បីខ្លួននៅមិនដឹងដល់ប្រយោជន៍ ឲ្យដល់ព្រមដោយសទ្ធាក្នុងព្រះមានព្រះភាគប៉ុណ្ណោះ ។

ក្នុងដីកា បរមត្ថមញ្ជុសា ពន្យល់ទៀតថា ៖

**សទ្ធាយា**តិ សទ្ធាគហណេន សត្ថរិ ធម្មេ ច សទ្ធាយ បច្ចុបដ្ឋាបនេន ។ ជីវិតេបិ បគេវ ជីវិតបរិក្ខារេតិ អធិប្បាយោ ។ ពាក្យថា **ដោយសទ្ធា** គឺដោយការកាន់យកដោយសទ្ធា បានដល់ ដោយការធ្វើឲ្យតាំងឡើង ព្រោះដោយសទ្ធាក្នុងព្រះសាស្ដា និងក្នុងព្រះធម៌ ។ អធិប្បាយថា សូម្បីក្នុងជីវិត (ក៏មិនធ្វើសេចក្ដីអាល័យ) និងបាច់ពោលទៅថ្វីក្នុងបរិក្ខារនៃជីវិតសោត ។

ពាក្យថា **ដូចបក្សីត្រដេវវិចរក្សាស៊ុត** សេចក្ដីថា ដូចបក្សីឈ្មោះត្រដេវវិច រក្សាស៊ុត (ពង) របស់ខ្លួន ។ បានឮមកថា សត្វត្រដេវវិចនោះ រមែងលះបង់ជីវិត រក្សាស៊ុតទុកប៉ុណ្ណោះ ។ ពាក្យថា **ដូចចាមរីរក្សារោម** បានដល់ ដូចម្រឹគឈ្មោះចាមរី រក្សានូវរោមកន្ទុយរបស់ខ្លួន ។ បានឮមកថា កាលចាមរីដែលត្រូវនាយព្រានធ្វើឲ្យដួល រមែងលះបង់សូម្បីជីវិត រក្សាទុកតែរោមកន្ទុយរបស់ខ្លួន ដែលជាប់នៅក្នុងបន្ទាជាដើមនោះឯង ។ គប្បីធ្វើបីបទថា បិយំវ បុត្តំ ឯកកាំ មកសម្ពន្ធគ្នា ។ ជាពាក្យឧបមាដែលអាចារ្យ

ពោលទុកដោយអំណាចការរងចាំ ព្រួយបារម្ភណ៍ថា ដូចយ៉ាងថា កុដុម្ពិកៈអ្នកមានបុត្តត្រឹមតែម្នាក់ រមែងរក្សាបុត្តម្នាក់នោះយ៉ាងល្អបំផុត, មួយ៉ាងទៀត មនុស្សមានភ្នែកតែម្ខាង រមែងរក្សាភ្នែកម្ខាងនោះ ដោយយកចិត្តទុកដាក់យ៉ាងល្អបំផុត យ៉ាងណា ។ ភិក្ខុអ្នករក្សាសីលក៏ដូច្នោះ ពិតដូច្នេះ ។

បទថា សុបេសលា ប្រែថា មានសីលជាទីស្រឡាញ់ដោយល្អ ។ បទថា **សទា** (គ្រប់កាល) គឺក្នុងកាលជាភិក្ខុកំលោះ ជាភិក្ខុកណ្តាល និងជាព្រះថេរៈ រហូតអស់កាលទាំងពួង ។ ភិក្ខុឈ្មោះថា មានសេចក្តីគោរព ក៏ដោយអំណាចគារវធម៌ទាំង ៦ សេចក្តីថា ជាអ្នកមានការធ្វើឲ្យប្រាកដប្រជា ។

<u>ដីកា</u> សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ពាក្យថា **ដូចមេត្រដេវវិច** សេចក្តីថា ដូចបក្សីត្រដេវវិច, ក៏សព្ទថា **ឥវ** ក្នុងទីនេះចុះក្នុងអត្ថនៃសព្ទថា ដូច ។ គប្បីនាំសេចក្តីមកភ្ជាប់ថា ដូចបិតារក្សាបុត្រដែលជាទីស្រឡាញ់តែម្នាក់ ។ ដូចជនមានភ្នែកតែម្ខាង រក្សាភ្នែកម្ខាងដូច្នោះ ។ ពាក្យថា **តាមរក្សា** សេចក្តីថា កអក្សរចុះក្នុងអត្ថថា បីបាច់ត្រកង ។ ពាក្យថា **ជាអ្នកមានសីលជាទីស្រឡាញ់** សេចក្តីថា ជាអ្នកមានសីលជាទីស្រឡាញ់ដោយល្អ ឬថា ចូរជាអ្នកអាចដោយល្អក្នុងការរក្សាសីល ។

<u>ក្នុងគម្ពីរវិសុទ្ធិមគ្គ</u> ៖

*សូម្បីពាក្យដទៃទៀត ទ្រង់ត្រាស់ថា ។ មហាសមុទ្រ ស្ថិតនៅជាធម្មតា មិនដែលកន្លងហួសពីមាត់ច្រាំងទេ យ៉ាងណា ម្នាលបហារាទៈ សិក្ខាបទណា ដែលតថាគតបញ្ញត្តហើយដល់ពួកសាវក ពួកសាវករបស់តថាគត មិនប្រព្រឹត្តកន្លងនូវសិក្ខាបទនោះ សូម្បីព្រោះហេតុជីវិត ក៏យ៉ាងនោះដែរ ។ ក៏ក្នុងសេចក្តីនេះ គប្បីជ្រាបរឿងព្រះថេរៈទាំងឡាយដែលពួកចោរចងក្នុងដងព្រៃ ។*

ចាតិមោក្ខំ វិសោធេន្តោ អប្បេវ ជីវិតំ ជហេ
បញ្ញត្តំ លោកនាថេន ន ភិន្ទេ សីលសំវរំ ។

*កុលបុត្តអ្នកមានសទ្ធា កាលជម្រះនូវបាតិមោក្ខសំវរសីល គប្បីលះបង់នូវជីវិត ដែលមានប្រមាណតិចចេញ មិនទម្លាយនូវសីលសំវរៈ ដែលព្រះបរមលោកនាថ ទ្រង់ត្រាស់បញ្ញត្តហើយទេ ។*

<u>ក្នុងដីកា</u> *បរមត្ថមញ្ជូសា ពន្យល់ទៀតថា ៖*

*ពាក្យថា **ក៏យ៉ាងនោះដែរ** សេចក្តីថា មហាសមុទ្រស្ថិតនៅជាធម្មតា មិនដែលកន្លងហួសពីមាត់ច្រាំងទេ យ៉ាងណា, ពួកសាវករបស់តថាគត(មិនប្រព្រឹត្តកន្លងនូវសិក្ខាបទនោះ) ក៏យ៉ាងនោះដែរ។ ពាក្យថា **ពួកសាវករបស់តថាគត** ត្រាស់សំដៅយកព្រះអរិយ-*

*សាវកទាំងឡាយ, ព្រោះថា ព្រះអរិយៈទាំនោះ ជាអ្នកមានសីលមាំមួន ។ ពាក្យថា* ***ក្នុងសេចក្តីនេះ*** *គឺក្នុងរឿងការមិនប្រព្រឹត្តិកន្លងសីល សូម្បីព្រោះហេតុនៃជីវិត ។*

*ពាក្យថា* សមសីសី *បានដល់* ***ជីវិតសមសីសី*** *។ ក៏អរហត្តមគ្គ របស់ព្រះអរិយបុគ្គលណា ធ្វើអវិជ្ជាដែលជាក្បាលរបស់កិលេសឲ្យអស់ទៅបានតាមលំដាប់មគ្គ, អំពីនោះទៅ កាលមានការតាំងមាំក្នុងបច្ចវេក្ខណញ្ញាណ ១៩ ហើយឈានចុះកាន់ភវង្គ ចុតិក៏ធ្វើជីវិតិន្ទ្រិយដែលជាក្បាលរបស់ខន្ធដែលប្រព្រឹត្តទៅឲ្យអស់ទៅ, ព្រះអរិយបុគ្គលនោះ លោកហៅថា "ជីវិតសមសីសី" ព្រោះការដែលមានវារៈព្រមគ្នាតែយ៉ាងនេះ ។*

## ២. ឥន្ទ្រិយសំវរសីល

យថា ច ចាតិមោក្ខសំវរោ សទ្ធាយ, ឯវំ សតិយា **ឥន្ទ្រិយសំវរោ** សម្បាទេតព្វោ ។ *ក៏បាតិមោក្ខសំវរៈ គប្បីឲ្យសម្រេចដោយសទ្ធា យ៉ាងណា* ***ឥន្ទ្រិយសំវរៈ*** *គប្បីឲ្យសម្រេចដោយ**សតិ** យ៉ាងនោះ ។*

*ដ្បិតឥន្ទ្រិយសំវរៈនោះ ឈ្មោះថា សម្រេចដោយសតិ ព្រោះឥន្ទ្រិយទាំងឡាយ តាំងនៅហើយដោយសតិ គឺទោសមានអភិជ្ឈា*

ជាដើមតាមគ្រប់សង្កត់មិនបាន ។ ព្រោះហេតុនោះ ឥន្ទ្រិយ-សំវរៈនោះ ដែលភិក្ខុលើកហើយនូវអាទិត្តបរិយាយ ដោយន័យជាដើមថា "ម្នាលភិក្ខុទាំងឡាយ ចក្ខុន្ទ្រិយដែលភិក្ខុអារហើយដោយបន្ទះដែកដ៏ក្តៅ ដែលឆេះសព្វហើយ សន្ធោសន្ធៅហើយប្រាលឆ្អៅហើយ ប្រសើរជាងការកាន់យកនិមិត្ត ដោយអនុព្យញ្ជនៈក្នុងរូបទាំងឡាយ ដែលគប្បីដឹងដោយភ្នែក មិនប្រសើរឡើយ" ការឃាត់នូវការកាន់យកអារម្មណ៍មាននិមិត្តជាដើម ដែលអភិជ្ឈាជាដើមគប្បីគ្របសង្កត់នូវវិញ្ញាណដែលប្រព្រឹត្តទៅ ក្នុងទ្វារមានចក្ខុទ្វារជាដើម ក្នុងអារម្មណ៍ទាំងឡាយមានរូបជាដើម ដោយសតិដែលមិនភ្លេចហើយ គប្បីឲ្យសម្រេចដោយប្រពៃ ។ មែនពិត កាលឥន្ទ្រិយសំវរៈនេះ ភិក្ខុមិនឲ្យសម្រេចហើយយ៉ាងនេះ សូម្បីបាតិ-មោក្ខសីល ក៏ជាសីលមិនខ្ជាប់ខ្ជួន ជាសីលមិនតាំងនៅយូរ ដូចសន្ទូងដែលបុគ្គលពុំទាន់យកមែកឈើ ចាត់ចែងព័ន្ធព័ទ្ធឲ្យល្អហើយ ។ ឯភិក្ខុនេះ ចោរគឺកិលេសទាំងឡាយតែងបៀតបៀនបាន ដូចស្រុកដែលមានទ្វារបើកហើយ ពួកចោរមែងបើកបាន ។ រាគៈតែងគ្របសង្កត់ចិត្តរបស់ភិក្ខុនោះ ដូចភ្លៀងលេចស្រោចផ្ទះដែលគេប្រក់មិនល្អ ។ ដូចជាពាក្យនេះ ដែលទ្រង់ត្រាស់ថា ៖

រូបេសុ សទ្ទេសុ អថោ រសេសុ

គន្ធេសុ ជសេ្វសុ ច រក្ខតិន្ទ្រិយំ
ឯតេ ហិ ទ្វារា វិវដា អរក្ខិតា
ហានន្តិ គាមំវ បរស្ស ហារិនោ ។
យថា អគារំ ទុច្ឆន្នំ វុដ្ឋី សមតិវិជ្ឈតិ
ឯវំ អភាវិតំ ចិត្តំ រាគោ សមតិវិជ្ឈតិ។

*ភិក្ខុត្រូវរក្សាឥន្ទ្រិយក្នុងរូប សំឡេង ក្លិន រស និង សម្ផស្ស ព្រោះថា ទ្វារទាំងនោះ ដែលបើកហើយ មិនរក្សាហើយ កិលេស រមែងបៀតបៀនបាន ដូចស្រុកដែលបើកទ្វារចំហ ពួកចោរ រមែងលួចបាន ។ ភ្លៀងលេចស្រោចផ្ទះ ដែលគេប្រក់មិនល្អហើយ យ៉ាងណា រាគៈតែងគ្របសង្កត់ចិត្ត ដែលគេមិនអប់រំហើយ យ៉ាងនោះ ។*

*តែឥន្ទ្រិយសំវរៈនោះ ភិក្ខុឲ្យសម្រេចហើយ សូម្បីបាតិមោក្ខ-សំវរសីល ក៏ជាសីលខ្ជាប់ខ្ជួន តាំងនៅអស់កាលយូរ ដូចសន្ទង ដែលគេយកមែកឈើព័ន្ធព័ទ្ធល្អហើយ ។ ឯភិក្ខុនោះ ពួកចោរគឺកិលេស រមែងបៀតបៀនមិនបាន ដូចស្រុកមានទ្វារបិទជិតល្អហើយ ចោរលួចមិនបាន ។ម្យ៉ាងទៀត រាគៈមិនគ្របសង្កត់ចិត្តភិក្ខុនោះ ដូចភ្លៀងមិនលេចស្រោចផ្ទះ ដែលគេប្រក់ល្អហើយ ។ ដូចជាពាក្យនេះ ដែលទ្រង់ត្រាស់ថា ៖*

រូបេសុ សទ្ទេសុ អថោ រសេសុ
គន្ធេសុ ផស្សេសុ ច រក្ខតិន្ទ្រិយំ
ឯតេ ហិ ទ្វារា បិទហិតា សុសំវុតា
ន ហានន្តិ គាមំវ បរស្ស ហារិនោ ។
យថា អគារំ សុច្ឆន្នំ វុដ្ឋី ន សមតិវិជ្ឈតិ
ឯវំ សុភាវិតំ ចិត្តំ រាគោ ន សមតិវិជ្ឈតិ។

ភិក្ខុរក្សាឥន្ទ្រិយ ក្នុងរូប សំឡេង រស ក្លិន និងសម្ផស្ស ព្រោះថា ទ្វារទាំងនោះ ដែលភិក្ខុបិទ សង្រួមល្អហើយ ចោរ គឺកិលេសបៀតបៀនមិនបាន ដូចស្រុកមានទ្វារបិទល្អហើយ ពួកចោរលួចមិនបាន ។ ភ្លៀងមិនលេចស្រោចផ្ទះ ដែលគេ ប្រក់ល្អហើយ យ៉ាងណា រាគៈ មិនគ្របសង្កត់ចិត្តដែលគេ ចម្រើនល្អហើយយ៉ាងនោះ ។

នេះជាទេសនាឧក្រិដ្ឋយ៉ាងក្រៃលែង ។

ធម្មតាចិត្តនេះ ប្រព្រឹត្តទៅរហ័ស ព្រោះហេតុនោះ ភិក្ខុគប្បី បន្ទោបង់រាគៈដែលកើតឡើងហើយ ដោយការធ្វើទុកក្នុងចិត្តថា មិនល្អ បំពេញឥន្ទ្រិយសំវរៈឲ្យសម្រេច ដូចព្រះថេរៈឈ្មោះវង្គីស បួសថ្មី ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ លោកបានលើករឿងព្រះវង្គីសត្ថេរ និងព្រះថេរៈចិត្តគុត្តត្ថេរ ហើយពោលយ៉ាងនេះទៀតថា ៖

ព្រោះហេតុនោះ សូមក្លីកុលបុត្រ ដែលប្រាថ្នាប្រយោជន៍ឯទៀតៗ

មក្កដោវ អរញ្ញម្ហិ វនេ ភន្តោ មិគោ វិយ
ពាលោ វិយ ច ឧត្រស្តោ ន ភវេ លោលលោចនោ
អធោ ខិបេយ្យ ចក្ខូនិ យុគមត្តទស្សោ សិយា
វនមក្កដលោលស្ស ន ចិត្តស្ស វសំ វជេ ។

មិនជាអ្នកមានភ្នែករវ្វេមរវ្វាម ដូចស្វាក្នុងព្រៃ ដូចម្រឹគផ្លាងក្នុងព្រៃ ដូចទារកតូចដែលតក់ស្លុតហើយទេ គប្បីដាក់ភ្នែកចុះក្រោម គប្បីជាអ្នកមានកិរិយាឃើញត្រឹមមួយជួរនឹម មិនត្រូវលុះក្នុងអំណាចចិត្ត ដូចស្វាក្នុងព្រៃ ។

ក្នុងដីកា បរមត្ថមញ្ជូសា លោកពោលទុកថា ៖

ពាក្យថា (ឥន្ទ្រិយទាំងឡាយ) ដែលសតិតាំងមាំហើយ គឺឥន្ទ្រិយទាំងឡាយដែលសតិចូលទៅតាំងទុកមុននោះពិត តាំងមាំហើយដោយអំណាចការរក្សាទុក ។ ពាក្យថា ព្រោះធម៌ទាំងឡាយមានអភិជ្ឈាជាដើម នឹងគប្បីហូរទៅតាមមិនបាន សេចក្តីថា ព្រោះ

ធម៌ទាំងឡាយមានអភិជ្ឈាជាដើម និងមិនគប្បីជាប់តាម ដោយភាពជាទ្វារ ។

ពាក្យថា **ក្នុងរូបទាំងឡាយ** គឺក្នុងរូបារម្មណ៍ទាំងឡាយ ។ ពាក្យថា **ការកាន់យកនូវនិមិត្តដោយអនុព្យញ្ជនៈ** គឺការកាន់យកនូវនិមិត្ត មានសុភនិមិត្តជាដើម ដោយអំណាចការធ្វើកិលេសទាំងឡាយឲ្យជាក់ច្បាស់រឿយៗ គឺដោយអំណាចការធ្វើឲ្យប្រាកដ ដោយការធ្វើឲ្យកើតឡើង; ម្យ៉ាងទៀត ពាក្យថា **ដោយអនុព្យញ្ជនៈ** បានដល់ ដោយចំណែកតូចៗ មានដៃនិងជើងជាដើម, ពាក្យថា **ការកាន់យកនូវនិមិត្ត** បានដល់ ការកាន់យកនូវនិមិត្ត មានឥត្ថីនិមិត្ត បុរិសនិមិត្ត និងសុភនិមិត្ត ជាដើម ។

ពាក្យថា **ព្រោះសេចក្តីប្រែប្រួលនៃសញ្ញា** គឺព្រោះហេតុនៃសេចក្តីសម្គាល់ខុសនៃសញ្ញា ដែលប្រព្រឹត្តទៅថា "ល្អក្នុងវត្ថុដែលមិនល្អ" គឺព្រោះសញ្ញាវិបរិតជាហេតុ ។ សួរថា សូមលោកចូរវៀរសុភនិមិត្ត ដូចម្តេច ? ឆ្លើយថា ចូរវៀរ គឺចូរមិនធ្វើទុកក្នុងចិត្តនូវសុភនិមិត្តដែលប្រកបដោយរាគៈ គឺដែលជាហេតុកើតឡើងនៃរាគៈ មិនមែនជាអ្នកមិនធ្វើទុកក្នុងចិត្ត ដល់សុភនិមិត្តតែម្យ៉ាងប៉ុណ្ណោះទេ តែថា ចូរចម្រើនចិត្តរបស់ខ្លួនដោយអសុភភាវនាផង ។

សួរថា ចូរចម្រើនយ៉ាងណា ?

ឆ្លើយថា ចូរចម្រើននូវចិត្តឲ្យមានអារម្មណ៍តែមួយ តាំងមាំល្អ គឺចូរចម្រើនដោយបការៈដែលចិត្តនោះ មានអារម្មណ៍តែមួយ ព្រោះមិនមានសេចក្តីគ្រវែងទៅមក និងជាធម្មជាតិតាំងមាំល្អ ព្រោះមានសេចក្តីពិតប្រាកដយ៉ាងល្អ ក្នុងអារម្មណ៍ដែលមិនល្អ ដូច្នេះចុះ ។

ព្រះអានន្ទត្ថេរ កាលសម្តែងការសង្កត់សង្កិននូវកាមរាគៈដោយ សមថការនាយ៉ាងនេះហើយ ឥឡូវនេះ ប្រាថ្នានឹងសម្តែងវិធីកាត់ផ្តាច់ ទើបពោលថា "**សង្ខារេ**" ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ពាក្យថា **ចូរពិចារណាឃើញសង្ខារទាំងឡាយ ដោយភាពជារបស់ដទៃ** បានដល់ ចូរពិចារណាឃើញសង្ខារទាំងឡាយសូម្បីទាំងអស់ថា "ជារបស់ដទៃ" ព្រោះសេចក្តីថា មិនស្តាប់បង្គាប់ ។

ក៏ដោយភាវៈជាទុក្ខ ព្រោះត្រូវការកើតឡើងនិងការរលត់ទៅបៀតបៀន ព្រោះហេតុជារបស់មិនទៀង និងចូរពិចារណាឃើញដោយភាវៈជាសភាពមិនមែនតួខ្លួន ព្រោះមិនមែនតួខ្លួនជាសភាវៈនិងព្រោះវៀរចាកតួខ្លួន ។ កាលលោកលើកសង្ខារទាំងឡាយឡើងកាន់ត្រៃលក្ខណ៍ ចម្រើនវិបស្សនាយ៉ាងនេះ ក៏នឹងញ៉ាំងរាគៈដ៏ធំឲ្យរលត់បាន ដោយប្រការទាំងពួង ដោយមគ្គទី ៤ តាមលំដាប់មគ្គ គឺនឹងចូលទៅស្ងប់រាគៈដ៏ធំ ព្រោះសេចក្តីដែលមានអារម្មណ៍ច្រើនដោយការគ្របសង្កត់ធម៌ដែលប្រព្រឹត្តទៅក្នុងភូមិ ៣ បាន ។

ព្រះអានន្ទត្ថេរ ទូន្មានព្រះវង្គីសត្ថេរ ឲ្យប្រកបក្នុងការបន្ទោបង់កាម-រាគៈ ឲ្យរឹងប៉ឹងឡើងទៅទៀតថា **កុំជាអ្នកមានសេចក្តីក្តៅក្រហាយរឿយៗ ដូចក្នុងឥឡូវនេះឡើយ** ដូច្នេះ ។

លោកអាចារ្យ កាលធ្វើវិធីក្នុងការធ្វើឥន្ទ្រិយសំវរឲ្យដល់ព្រមយ៉ាងនេះហើយ ប្រាថ្នាសម្តែងន័យថា ឥន្ទ្រិយសំវរនោះ និងជាការធ្វើឲ្យដល់ព្រមបានល្អ ក៏ដោយអាការៈយ៉ាងនេះ ដូច្នេះ ទើបសម្តែងដល់ព្រះថេរៈទាំងឡាយ អ្នកធ្វើឲ្យបរិបូរណ៍ក្នុងឥន្ទ្រិយ-សំវរសីលនោះទុក ដោយពាក្យថា "**អបិច**" ដូច្នេះ ជាដើម ។

ពាក្យថា **ទម្លាយឥន្ទ្រិយទាំងឡាយ** គឺទម្លាយឥន្ទ្រិយសំវរ-សីល ។ មែនពិត កាលឥន្ទ្រិយសំវរសីលទាំងនោះបែកធ្លាយហើយ សូម្បីឥន្ទ្រិយទាំងឡាយ ក៏ពោលបានថាបែកធ្លាយហើយដែរ ព្រោះមិនមានការរក្សាទុក,ម្យ៉ាងទៀត ឥន្ទ្រិយទាំងឡាយដែលជាទ្វារនៃការកាន់យកនូវនិមិត្ត និងអនុព្យញ្ជនៈនោះឯង ឈ្មោះថា ជាការបែកធ្លាយ ព្រោះជាហេតុកើតសេចក្តីវិនាស ដល់បុគ្គលអ្នកព្រមព្រៀងដោយឥន្ទ្រិយនោះ, គប្បីជ្រាបថា មិនជាការបែកធ្លាយ ក៏ដោយបរិយាយផ្ទុយ ។ អាចារ្យមួយពួកទៀត ពោលថា ម្យ៉ាងទៀត ការបង្អោនឥន្ទ្រិយទាំងឡាយចូលទៅ (កាន់អារម្មណ៍) ដោយមិនត្រូវទំនង ឈ្មោះថា ជាការធ្វើឲ្យបែកធ្លាយ, កាលបង្អោនចូលទៅត្រូវទំនង ឈ្មោះថា ជាការមិនធ្វើឲ្យបែកធ្លាយ ដូច្នេះ ។

# ៣_អាជីវបារិសុទ្ធិសីល

*ក្នុងគម្ពីរវិសុទ្ធិមគ្គ ភាគ១ ទំព័រ៧៦ ថា* **:** យថា បន ឥន្ទ្រិយសំវរោ សតិយា, តថា វីរិយេន **អាជីវបារិសុទ្ធិ** សម្បាទេតព្វា ។ *ឯឥន្ទ្រិយសំវរៈ គប្បីឲ្យសម្រេចដោយ**សតិ** យ៉ាងណា **អាជីវបារិសុទ្ធិ** គប្បីឲ្យសម្រេចដោយ**វីរិយៈ**យ៉ាងនោះ ។*

*សេចក្ដីពិត អាជីវបារិសុទ្ធិនោះ សម្រេចដោយសេចក្ដី**ព្យាយាម** ព្រោះភិក្ខុមានព្យាយាមប្រារព្ធហើយដោយប្រពៃ ជាគ្រឿងកើតព្រមនូវការលះបង់មិច្ឆាជីវៈ ។ ព្រោះហេតុនោះ ភិក្ខុគប្បីលះការស្វែងរកមិនសមគួរ និងកម្មមិនគួរហើយ បំពេញអាជីវ-បារិសុទ្ធិឲ្យពេញលេញទុំ៉ះ ដោយសេចក្ដីព្យាយាម គឺដោយការស្វែងរកដ៏ប្រពៃ មានត្រាច់បិណ្ឌបាតជាដើម ការសេពបច្ច័យទាំងឡាយដែលកើតឡើងដ៏បរិសុទ្ធ ព្រោះភាពជាអ្នកវៀរបច្ច័យទាំងឡាយដែលកើតឡើងមិនបរិសុទ្ធ ដូចគេវៀរពស់ពិស ។*

*<u>ក្នុងដីកា</u> បរមត្ថមញ្ជូសា **ភាគ១** ពន្យល់ថា* ៖

*បទថា* តថា វីរិយេន *(**ដោយវីរិយដូច្នោះ**) សេចក្ដីថា លោកធ្វើវីរិយៈឲ្យប្រែកទៅដោយតថាសព្ទ ។ សតិ ដែលមានលក្ខណៈរកទោសមិនបាននោះឯង ជាហេតុឲ្យសម្រេចឥន្ទ្រិយ-*

សំវរសីល យ៉ាងណា វីរិយៈដែលមានលក្ខណៈរកទោសមិនបាន ក៏ជាហេតុឲ្យសម្រេចអាជីវបារិសុទ្ធិសីលដូច្នោះ ដូច្នេះឯង ។ គប្បីឃើញការសម្ដែងដល់វីរិយៈនោះឯង ថាជាសេចក្ដីដែលលោកធ្វើឲ្យប្លែកទៅ ។ ព្រោះហេតុនោះនុ៎ះឯង លោកទើបពោលថា "សេចក្ដីព្យាយាមដែលភិក្ខុប្រារព្ធហើយដោយប្រពៃ" ដូច្នេះ ។

ការស្វែងរកដែលមិនត្រឹមត្រូវ ឈ្មោះថា **អនេសនា** សង្គ្រោះយកមិច្ឆាជីវៈតាមដែលពោលហើយ ។ **អនេសនា**នោះនុ៎ះឯង ឈ្មោះថា **អប្បដិរូបា** ព្រោះអត្ថថា មិនសមគួរដល់ពាក្យប្រៀនប្រដៅរបស់ព្រះសាស្ដា បានដល់ (លះបង់) ការស្វែងរកដែលមិនត្រឹមត្រូវ មិនសមគួរនោះ ។

ន័យមួយទៀត ការស្វែងរកដែលជាសត្រូវចំពោះសេចក្ដីសមគួរ ឈ្មោះថា ការស្វែងរកដែលមិនសមគួរ សម្រាប់ភិក្ខុអ្នកកាន់ធុតង្គ បានដល់ ការស្វែងរកខុស និងខកំណត់របស់ធុតង្គជាការបដិបត្តិរបស់ភិក្ខុរូបណាមួយ ដែលញ៉ាំងសល្លេខធម៌ (ធម៌ជាគ្រឿងជុះខាត់កិលេស) ឲ្យកម្រើក ។ **ច** ស័ព្ទ ក្នុងចំណោកនេះ លោកសម្ដែងថា **ត្រូវដកទៅ** សេចក្ដីថា លះបង់ការស្វែងរកដែលមិនត្រឹមត្រូវ និងការស្វែងរកដែលមិនសមគួរ ។

ក្នុងសេចក្ដីថា បដិសេវមានេន បរិវជ្ជនតា សម្បា–

ខេត្តា ប្រែថា (អាជីវបារិសុទ្ធិសីលនេះ) ភិក្ខុអ្នកសេព វៀរស្រឡះហើយ គប្បីឲ្យដល់ព្រម ។ ដោយពាក្យថា "ដែលមានការកើតឡើងដោយបរិសុទ្ធ" នេះនុ៎ះពិត ជាការដែលលោកអាចារ្យសម្ដែងការៈដែលគុណទាំងឡាយ មានធម្មទេសនាជាដើម មានអធ្យាស្រ័យដ៏បរិសុទ្ធ ជាសមុដ្ឋាន ព្រោះហេតុនោះ ទើបពោលថា "**ក៏របស់ពួកគ្រហស្ថ អ្នកជ្រះថ្លាដោយគុណទាំងឡាយ មានធម្ម-ទេសនាជាដើមរបស់លោក**" ដូច្នេះ ។ ដោយអាទិសព្ទ គប្បីជ្រាបដល់ការកាន់យកគុណទាំងឡាយ មានភាពជាអ្នកបានស្ដាប់ច្រើន ការបរិបូរណ៍នៃវត្ត ការដល់ព្រមនៃឥរិយាបថជាដើម ។ សូម្បីក្នុងពាក្យនេះថា ក៏អ្នកជ្រះថ្លាក្នុងធុតង្គគុណរបស់លោក ក៏មានន័យនេះឯង ។ ដោយអាទិសព្ទថា បិណ្ឌចាតចរិយាទីហិ ដែលប្រែថា ដោយវត្តមានការត្រាច់ទៅបិណ្ឌបាតជាដើម គប្បីឃើញថា សង្គ្រោះយកសេចក្ដីប្រព្រឹត្តិ មានការគប់មិត្តល្អ សម្លាញ់ល្អ និងការទ្រទ្រង់សំពត់បំសុកូលជាដើម ។

<u>ក្នុងគម្ពីរវិសុទ្ធិមគ្គ</u> ថា ៖

បណ្ដាបច្ច័យទាំងឡាយពីរយ៉ាងនោះ បច្ច័យដែលកើតឡើងអំពីសង្ឃ ឬគណៈរបស់ភិក្ខុដែលមិនកាន់ធុតង្គទេ និងដែលកើតឡើងអំពីសំណាក់ពួកគ្រហស្ថដែលជ្រះថ្លាហើយ ដោយគុណទាំង

ឡាយមានធម្មទេសនាជាដើមរបស់ភិក្ខុនោះ ឈ្មោះថា កើតឡើង ដោយបរិសុទ្ធ, ឯបច្ច័យដែលកើតឡើងដោយត្រាច់បិណ្ឌបាតជាដើម ឈ្មោះថា **កើតឡើងដ៏បរិសុទ្ធក្រៃលែង** ។ បច្ច័យដែលកើតឡើង ដោយត្រាច់បិណ្ឌបាតជាដើមរបស់ភិក្ខុអ្នកកាន់ធុតង្គក្តី អំពីសំណាក់ ពួកគ្រហស្ថដែលជ្រះថ្លាក្នុងធុតង្គគុណរបស់ភិក្ខុនោះក្តី ដោយ អនុលោមតាមទំនៀមនៃធុតង្គ ឈ្មោះថា កើតឡើងដ៏បរិសុទ្ធ ។

ម្យ៉ាងទៀត កាលថ្នាំស្រម៉ត្រាំដោយទឹកមូត្រស្អុយ និងមធុ- រស ៤ យ៉ាង កើតឡើងដល់ភិក្ខុនោះ ដើម្បីរម្ងាប់ជម្ងឺម្យ៉ាង, កាលសមាទានធុតង្គនៃភិក្ខុ កាលគិតថា "ពួកសព្រហ្មចារីឯទៀត នឹងបរិភោគមធុរស ៤ យ៉ាង" ហើយ(ខ្លួនឯង)បរិភោគចំណិតផ្លែ- ស្រម៉ តែម្យ៉ាង រមែងសមគួរ ។ ឯភិក្ខុនោះ លោកហៅថា ភិក្ខុ ប្រកបដោយ**អរិយវង្សដ៏ឧត្តម** ។

<u>ក្នុងដីកា</u> បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

ពាក្យថា **ដោយអនុលោមចំពោះការកំណត់របស់ធុតង្គ** គឺ ដោយអំណាចអនុលោមចំពោះការបដិបត្តិដែលកំណត់ទុក ក្នុងធុតង្គ នោះៗ សេចក្តីថា ដោយអំណាចការមិនធ្វើឲ្យកម្រើក ។ អ្នក ប្រាថ្នាច្រើនប៉ុណ្ណោះ មានការចិញ្ចឹមជីវិតដោយមិច្ឆាជីវៈ មិនមែន អ្នកប្រាថ្នាតិចទេ ។ លោកអាចារ្យពោលថា "ដើម្បីប្រយោជន៍ដល់

ការរម្ងាប់សេចក្ដីមិនស្រួលខ្លួន ប្រើប្រាស់តែម្យ៉ាង” ដូច្នេះជាដើម ដើម្បីសម្ដែងថា មិច្ឆាជីវៈកើតឡើងមិនបានឡើយ កាលសេចក្ដីប្រាថ្នាតិច ដល់ការៈខ្ពង់ខ្ពស់នោះឯង ។

ក្នុងបទទាំងនោះ បទថា **បូតិហារីជកី** បានដល់ ស្រម៉ដែលត្រាំដោយទឹកមូត្រស្អុយ ឬដែលគេចោលហើយ ព្រោះភាពជារបស់ស្អុយ ។ ភិក្ខុឈ្មោះថា **អរិយវង្សិកៈ** ព្រោះអត្ថថា មានអរិយវង្ស ឬប្រកបក្នុងអរិយវង្ស, ភិក្ខុឈ្មោះថា អ្នកខ្ពង់ខ្ពស់បំផុត ព្រោះសេចក្ដីដែលដកចេញពីសេចក្ដីប្រាថ្នាក្នុងបច្ច័យ ឲ្យនៅក្នុងទីឆ្ងាយបានហើយផង ភិក្ខុនោះជាអរិយវង្សិកៈផង ព្រោះហេតុនោះ ទើបឈ្មោះថា **ឧត្តមអរិយវង្សិកៈ** ។

<u>ក្នុងគម្ពីរវិសុទ្ធិមគ្គ</u> ថា ៖

យេ បនេតេ ចីវរាទយោ បច្ចយា, តេសុ យស្ស កស្សចិ ភិក្ខុនោ អាជីវំ បរិសោធេន្តស្ស ចីវរេ ច បិណ្ឌបាតេ ច និមិត្តោភាសបរិកថាវិញ្ញត្តិយោ ន វដ្ដន្តិ ។ សេនាសនេ បន អបរិគ្គហិតធុតង្គស្ស និមិត្តោភាសបរិកថា វដ្ដន្តិ ។

ម្យ៉ាងទៀត បច្ច័យទាំងឡាយមានចីវរជាដើមនេះណា បច្ច័យអម្បាលនោះ ការធ្វើនិមិត្ត ឱភាស (ការបំភ្លឺ) បរិកថា និងវិញ្ញត្តិ (ការសូម) ក្នុងចីវរក្ដី បិណ្ឌបាតក្ដី **មិនគួរដល់ភិក្ខុណាមួយ** ដែល

កំពុងជម្រះនូវអាជីវៈ ។ តែថា ការធ្វើនិមិត្ត ឱភាស និងបរិកថា ក្នុងសេនាសនៈ រមែងគួរដល់ភិក្ខុមិនកាន់ធុតង្គ ។

ក្នុងដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

ពាក្យថា **(មិនគួរ) ដល់ភិក្ខុរូបណាមួយ** គឺដល់ភិក្ខុរូប-ណាមួយ បណ្ដាភិក្ខុអ្នកកាន់ធុតង្គ និងមិនបានកាន់ធុតង្គ ។

**ក្នុងគម្ពីរវិសុទ្ធិមគ្គ** ថា ៖

បណ្ដានិមិត្តទាំងនោះ កាលភិក្ខុកំពុងធ្វើបរិកម្មផែនដីជាដើម ដើម្បីសេនាសនៈ កាលពួកគ្រហស្ថសួរថា បពិត្រលោកម្ចាស់ ធ្វើអ្វី នរណាឲ្យធ្វើ ? ពោលតបថា ពុំមាននរណាមួយឲ្យធ្វើទេ, ឬក៏និមិត្តកម្មបែបនេះឯទៀតណាក្ដី ឈ្មោះថា **និមិត្ត** ។

ការពោលថា ម្នាលឧបាសក ពួកអ្នកនៅក្នុងទីណា ? បពិត្រលោកម្ចាស់ នៅក្នុងប្រាសាទ, “**ភិក្ខូនំ បន ឧបាសកា បាសាទោ ន វដ្ដតិ** : ម្នាលឧបាសក ចុះប្រាសាទ មិនគួរដល់ពួកភិក្ខុទេឬ ? ឬក៏ឱភាសកម្មបែបនេះ សូម្បីឯទៀតក៏ដោយ ឈ្មោះថា **ឱភាសៈ** ។

ការពោលថា “**ភិក្ខុសង្ឃស្ស សេនាសនំ សម្ពាធំ** : សេនាសនៈរបស់ភិក្ខុសង្ឃចង្អៀត”, ឬការនិយាយអមបែបនេះ សូម្បីឯទៀតក៏ដោយ ឈ្មោះថា **បរិកថា** ។ គ្រប់ពាក្យទាំងអស់

គួរក្នុងភេសជ្ជៈ ។ តែភេសជ្ជៈដែលកើតឡើងដោយបការៈដូច្នោះ កាលរោគស្ងប់រម្ងាប់ហើយ បរិភោគ មិនគួរ ។

ក្នុងសេចក្តីនោះ ពួកវិន័យធរ ពោលថា គួរ ព្រោះទ្វារព្រះមានព្រះភាគ ប្រទានហើយ ។ ចំណែកពួកភិក្ខុអ្នកទ្រទ្រង់ព្រះសូត្រ ពោលយ៉ាងនេះថា អាបត្តិមិនមានក៏ពិតមែនហើយ ប៉ុន្តែឈ្មោះថា ញុំាងអាជីវៈឲ្យកម្រើក ព្រោះហេតុនោះ ទើបមិនគួរ ។

ភិក្ខុណាមួយមិនធ្វើនិមិត្ត ឱភាសៈ បរិកថា និងវិញ្ញត្តិ សូម្បីព្រះមានព្រះភាគ អនុញ្ញាតហើយ អាស្រ័យគុណមានប្រាថ្នាតិចជាដើមប៉ុណ្ណោះ សូម្បីអស់ទៅនៃជីវិត កើតឡើងចំពោះមុខ ក៏បរិភោគបច្ច័យដទៃ វៀរចាកឱភាសកម្មជាដើម ភិក្ខុនុ៎ះលោកហៅថា អ្នកប្រព្រឹត្តជុសខាត់យ៉ាងក្រៃលែង ឧបមាដូចព្រះថេរៈ ឈ្មោះ **សារីបុត្ត** ។

<u>ក្នុងដីកា</u> បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

ការចំពោះបច្ច័យទាំងឡាយ ហើយធ្វើនិមិត្ត ដោយប្រការដែលអ្នកដទៃដឹងសេចក្តីប្រាថ្នាបាន ឈ្មោះថា **និមិត្ត** ។ ការមិនពោលត្រង់ៗ តែម្តង ពោលបញ្ជិតបញ្ចៀងដោយប្រការដែលសេចក្តីប្រាថ្នា (របស់ខ្លួន) ជាការជាក់ច្បាស់ (ដល់អ្នកដទៃ) បានឈ្មោះថា **ឱភាស** ។ ការពោលដោយបរិយាយ (ពោលអមៗ)

*ឈ្មោះថា **បរិកថា** ។ ពាក្យថា (តែកេសជ្ជៈ) **ដែលកើតឡើងដោយបការៈដូច្នោះ** គឺដែលកើតឡើងហើយ ដោយអំណាចអាការមាននិមិត្តជាដើម ។*

## ៤-បច្ចយសន្និស្សិតសីល

*ក្នុងគម្ពីរវិសុទ្ធិមគ្គ ថា ៖* យថា ច វីរិយេន អាជីវ-ចារិសុទ្ធិ, តថា **បច្ចយសន្និស្សិតសីលំ** បញ្ញាយ សម្បា-ទេតព្វំ ។ *ឯអាជីវបារិសុទ្ធិ សម្រេចដោយវីរិយៈ យ៉ាងណា, **បច្ចយសន្និស្សិតសីល** គប្បីឲ្យសម្រេចដោយបញ្ញា យ៉ាងនោះ ។*

*ព្រោះថា បច្ចយសន្និស្សិតសីលនោះ សម្រេចដោយបញ្ញា ព្រោះអ្នកមានបញ្ញា អាចឃើញទោស និងអានិសង្សក្នុងបច្ច័យទាំងឡាយ ។ ព្រោះហេតុនោះ ភិក្ខុកាលលះបង់នូវសេចក្តីត្រេកអរក្នុងបច្ច័យ ហើយពិចារណាដោយបញ្ញា មានវិធីដូចពោលហើយ បរិភោគចំពោះបច្ច័យដែលកើតឡើងដោយធម៌ដ៏ស្មើ ហើយគប្បីញុំាងបច្ចយសន្និស្សិតសីលនោះឲ្យសម្រេច ។*

*ដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖*

*ការឃើញទោសគឺអាបត្តិ ព្រោះការបរិភោគ ដូចជំពាក់បំណុល ក្នុងការបរិភោគបច្ច័យមិនបានពិចារណា, និងអានិសង្ស*

ក្នុងការបរិភោគបច្ច័យដែលបានពិចារណា ដោយបរិយាយផ្ទុយគ្នានឹងការបរិភោគបច្ច័យដែលមិនបានពិចារណានោះ ឈ្មោះថា ការឃើញទោស និងអានិសង្ស ។ ក៏ព្រោះការឃើញទោស និងអានិសង្សនោះ មានបច្ច័យជាអធិការ (អ្នកចាត់ចែង) លោកទើបពោលថា "ក្នុងព្រោះបច្ច័យទាំងឡាយ" ដូច្នេះ ។ មែនពិត ធម្មជាតិទាំងដែលជាហេតុ និងមិនមែនហេតុ បុគ្គលរមែងពោលដល់ដោយភាវៈជាហេតុបាន ដូចពាក្យថា "ភត្តសម្រេចហើយ ព្រោះស្មៅទាំងឡាយ" ដូច្នេះជាដើម ។ ដើម្បីសម្តែងថា ឈ្មោះថា ការបរិភោគបច្ច័យដែលមិនបានពិចារណា នឹងគប្បីមានដល់ភិក្ខុបានដោយប្រការ គឺហេតុណា, ការវៀរចាកប្រការគឺហេតុនោះចេញ បច្ចយសន្និស្សិតសីល ក៏រមែងសម្រេចនិងបរិសុទ្ធបានដូច្នេះ លោកអាចារ្យទើបពោលថា "ព្រោះហេតុនោះ" ដូច្នេះជាដើម ។

<u>ដីកា</u> សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ការឃើញទោស ដោយអំណាចធាតុមនសិការជាដើម ក្នុងវេលាទទួល និងអានិសង្ស ដោយអំណាចភាពជាហេតុតាំងនៅនៃកាយនេះជាដើម ក្នុងបច្ច័យទាំងឡាយដែលបរិភោគ ឈ្មោះថា ឃើញទោស និងអានិសង្សក្នុងបច្ច័យទាំងឡាយ ។ ពាក្យថា **ព្រោះហេតុនោះ** សេចក្តីថា ព្រោះសីលនេះសម្រេចបានដោយបញ្ញា

ព្រោះដូច្នោះ ។ ភ្ជាប់សេចក្ដីថា ពិចារណាដោយបញ្ញា លះសេចក្ដីជាប់ចិត្តក្នុងបច្ច័យ ហើយបរិភោគបច្ច័យ គប្បីឲ្យបច្ចយសន្និស្សិត-សីលនោះដល់ព្រម ។

តត្ថ **ធម្មេន សមេន ឧប្បន្នេ**តិ ឯតេន បច្ចយ-សន្និស្សិតសីលស្ស អាជីវចារិសុទ្ធិ និស្សាយេវ បវត្តិ ទស្សេតិ ។ បណ្ដាពាក្យទាំងនោះ ដោយពាក្យថា **បច្ច័យដែលកើតឡើងដោយធម៌ដ៏ស្មើ** នេះ លោកសម្ដែងថា បច្ចយសន្និស្សិត-សីល អាស្រ័យអាជីវបារិសុទ្ធិប៉ុណ្ណោះប្រព្រឹត្តទៅ ។

## អធិប្បាយបច្ចវេក្ខណៈ

ក្នុងគម្ពីរវិសុទ្ធិមគ្គ ថា ៖

ការពិចារណា ក្នុងបច្ចយសន្និស្សិតសីលនោះ មានពីរយ៉ាង គឺ **បដិលាភកាល** (ក្នុងកាលបានបច្ច័យ) ១ **បរិភោគកាល** (ក្នុងកាលបរិភោគបច្ច័យ) ១ ។ មែនពិត ការបរិភោគរបស់ភិក្ខុអ្នកបរិភោគបច្ច័យមានចីវរជាដើម ដែលពិចារណាដោយអំណាចជាធាតុ ឬដោយអំណាចជារបស់បដិកូល សូម្បីក្នុងបដិលាភកាលដែលខ្លួនតាំងទុកហើយ បរិភោគឲ្យលើសអំពីបដិលាភកាលនោះទៅ មិនមានទោសឡើយ សូម្បីក្នុងបរិភោគកាល ។

*ក្នុងដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖*

**ធាតុវសេន វា**តិ "យថាបច្ចយំ វត្តមានំ ធាតុមត្ត-មេវេតំ យទិទំ ចីវរាទិ តទុបភុញ្ជកោ ច បុគ្គលោ"តិ ឯវំ ធាតុមនសិការវសេន វា ។

*ពាក្យថា **ធាតុវសេន វា** បានដល់ ជាប់ដោយអំណាចនៃមនសិការៈថាជាធាតុ យ៉ាងនេះថា "បច្ច័យមានចីវរជាដើម និងបុគ្គលអ្នកប្រើប្រាស់បច្ច័យមានចីវរជាដើម នេះណា, នេះត្រឹមតែជាធាតុ ដែលប្រព្រឹត្តទៅតាមបច្ច័យប៉ុណ្ណោះ" ដូច្នេះក្តី ។*

*<u>ដីកា</u> សារត្ថទីបនី ភាគ១ ពន្យល់ថា ៖*

*ពាក្យថា **ធាតុវសេន វា** សេចក្តីថា គប្បីឃើញសេចក្តីយ៉ាងនេះថា នេះត្រឹមតែជាធាតុ មានបឋវីធាតុជាដើម មិនមែនសត្វ មិនមែនជីវៈ គឺចីវរជាដើម និងបុគ្គលអ្នកបរិភោគចីវរជាដើមនោះ រួមសេចក្តីថា មិនមានទោសឡើយ ដល់ភិក្ខុអ្នកបរិភោគចីវរជាដើម ដែលពិចារណា តាំងទុកដោយធាតុមនសិការៈ ។*

*<u>ក្នុងដីកា</u> បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖*

**បដិក្កូលវសេន វា**តិ បិណ្ឌបាតេ តាវ អាហារេ បដិក្កូលសញ្ញាវសេន, "សព្វានិ បន ឥមានិ ចីវរាទីនិ

អជិគុច្ឆនីយានិ, ឥមំ បូតិកាយំ បត្វា អតិវិយ ជិគុច្ឆ-
នីយានិ ជាយន្តិ"តិ ឯវំ បដិក្កូលមនសិការវសេន វា ។

*ពាក្យថា* **បដិក្កូលវសេន វា** *បានដល់ ជាប់ដោយ
អំណាចនៃសេចក្តីសម្គាល់ថា ជារបស់បដិកូល ក្នុងបិណ្ឌបាត គឺ
ក្នុងអាហារប៉ុណ្ណោះ, ម្យ៉ាងទៀត ជាប់ដោយអំណាចនៃមនសិការៈ
ថាជាបដិកូលយ៉ាងនេះថា "ក៏បច្ច័យមានចីវរជាដើមទាំងអស់ពួក
នេះ មិនទាន់គួរខ្ពើមរអើមទេ, លុះមកប៉ះត្រូវកាយស្អុយនេះហើយ
ក៏កើតជារបស់គួរខ្ពើមរអើមក្រៃពេក" ដូច្នេះ ។*

*ពាក្យថា* **តតោ ឧទ្ធំ** ***(បរិភោគឲ្យលើសអំពីបដិលាភ-
កាលតទៅ)*** *គឺក្នុងកាលតទៅអំពីកាលដែលបានមក ។ ដែល
ឈ្មោះថា* **អនវជ្ជោវ បរិភោគោ** ***(ការបរិភោគមិនមានទោស
ឡើយ)*** *ក៏ព្រោះភាពដែលភិក្ខុធ្វើឲ្យហ្មត់ចត់ហើយដោយបញ្ញា តាំង
ពីដើម ដូចការប្រើប្រាស់បាត្រនិងចីវរ ដែលបានអធិដ្ឋានហើយ
រក្សាទុក ដូច្នោះ ។ ខដែលពោលមកនេះ នេះជាខមួយ ដែល
សម្តែងសេចក្តីបរិសុទ្ធក្នុងខាងដើម ព្រោះការពិចារណា, មិនមែន
ជាខមួយដែលបដិសេធការពិចារណា ក្នុងវេលាដែលបរិភោគទេ ។
ព្រោះហេតុនោះ លោកទើបពោលថា "សូម្បីក្នុងវេលាដែល
បរិភោគ" ជាដើម ។ (គឺក្នុងវេលាបរិភោគ សូម្បីភ្លេចពិចារណា*

ក៏មិនមានទោសទេ បើថា បានពិចារណាដោយអំណាចជាធាតុ ឬជារបស់បដិកូល តាំងពីបដិលាភកាលមកហើយ) ។ បទថា **តត្រ** ប្រែថា ក្នុងការពិចារណា ក្នុងវេលាដែលបរិភោគនោះ ។

<u>ក្នុងដីកា</u> **សង្ខេបត្ថជោតនី** ភាគ១ ពន្យល់ថា ៖

ម្យ៉ាងទៀត ពាក្យថា **អនវជ្ជោវ** សេចក្តីថា មិនមានទោសឡើយ បានដល់ ប្រសើរពិត ។ មានអធិប្បាយថា កាលភិក្ខុពិចារណាក្នុងវេលាបរិភោគនោះឯង ការបរិភោគត្រឹមតែមិនមានទោស, កាលភិក្ខុពិចារណាទាំងក្នុងវេលាបានមក (បដិលាភកាល) សូម្បីក្នុងវេលាបរិភោគ (បរិភោគកាល) ក៏ពិចារណាទៀត ការបរិភោគ ឈ្មោះថា មិនមានទោសជាង ។

ពាក្យថា **បរិភោគកាលេបិ** (សូម្បីក្នុងវេលាបរិភោគ) នេះ គប្បីនាំមកភ្ជាប់ជាមួយបទទាំងឡាយ ដែលពោលទុកមុនហើយថា កាលភិក្ខុពិចារណាហើយដោយបញ្ញា បរិភោគតាមវិធីដែលពោលហើយ ការបរិភោគបច្ច័យ ឈ្មោះថា មិនមានទោសឡើយ ។

## ការបរិភោគមាន ៤ យ៉ាង

១-ថេយ្យបរិភោគ បរិភោគដោយអាការៈជាចោរ

២-ឥណបរិភោគ បរិភោគដោយអាការៈជាបំណុល

៣-ទាយជ្ជបរិភោគ បរិភោគដោយភាពជាអ្នកទទួលមត៌ក

៤-សាមិបរិភោគ បរិភោគដោយភាពជាម្ចាស់ ។

## អធិប្បាយបរិភោគ ៤ យ៉ាង

ក្នុង ៤ យ៉ាងនោះ ការបរិភោគនៃភិក្ខុទ្រុស្តសីល អន្តុយបរិភោគ សូម្បីកណ្ដាលជំនុំសង្ឃ ឈ្មោះថា **ថេយ្យបរិភោគ** ។

កាលដែលភិក្ខុមានសីល បរិភោគដោយមិនពិចារណា ឈ្មោះថា **ឥណបរិភោគ** ។ ព្រោះហេតុនោះ ចីវរ ត្រូវពិចារណារាល់ៗ ពេលបរិភោគ បិណ្ឌបាត ត្រូវពិចារណាគ្រប់ៗពំនូត កាលមិនអាចពិចារណា ដូច្នោះទេ ត្រូវពិចារណាមុនភត្ត ក្រោយ-ភត្ត យាមខាងដើម យាមកណ្ដាល និងយាមខាងចុង ។ បើភិក្ខុមិនពិចារណាសោះ អរុណរះឡើង ឈ្មោះថា តាំងនៅក្នុងទីជាឥណបរិភោគ ។ សូម្បីសេនាសនៈ ភិក្ខុត្រូវពិចារណាគ្រប់ៗខណៈប្រើប្រាស់ ។ ក្នុងការទទួលក្តី ក្នុងការបរិភោគក្តី នូវភេសជ្ជៈ គួរជាអ្នកមានសតិជាគ្រឿងគាំទ្រ ។ សូម្បីកាលជាយ៉ាងនេះ ភិក្ខុធ្វើស្មារតីក្នុងពេលទទួល មិនធ្វើក្នុងពេលបរិភោគ ក៏ត្រូវអាបត្តិ តែបើមិនធ្វើស្មារតីក្នុងពេលទទួល ហើយធ្វើក្នុងពេលបរិភោគ មិនត្រូវអាបត្តិទេ ។

ក្នុងដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

ការបរិភោគ របស់បុគ្គលដែលមិនសមគួរបរិភោគ ឈ្មោះថា **ថេយ្យបរិភោគ** ។ អធិប្បាយថា ទាំងព្រះមានព្រះភាគ ទ្រង់អនុញ្ញាតបច្ច័យទាំងឡាយទុក ក៏សម្រាប់ភិក្ខុអ្នកមានសីលក្នុងសាសនារបស់ព្រះអង្គ មិនមែនសម្រាប់បុគ្គលទ្រុស្តសីលទេ ។ ទាំងពួកទាយក មានការបរិច្ចាគយ៉ាងនេះ ក៏សម្រាប់ភិក្ខុអ្នកមានសីល មិនមែនសម្រាប់បុគ្គលទ្រុស្តសីលទេ ។ ព្រោះគេសង្ឃឹមការតបស្នងដល់ការៈនៃការធ្វើរបស់ខ្លួន នឹងមានផលច្រើន ។ ព្រោះព្រះ-សាស្តាទ្រង់មិនអនុញ្ញាត និងព្រោះពួកទាយក មិនបានបរិច្ចាគឲ្យដូចពោលមកនេះ ការបរិភោគរបស់ភិក្ខុអ្នកទ្រុស្តសីល ទើបជាការបរិភោគ ដោយភាពជាចោរ ឈ្មោះថា **ថេយ្យបរិភោគ** ។

ការបរិភោគ ដោយអំណាចជំពាក់បំណុល សេចក្តីថា ដូចជាទទួលជំពាក់បំណុលបរិភោគ ព្រោះមិនមានទក្ខិណាវិសុទ្ធិ អំពីបដិគ្គាហកៈ ឈ្មោះថា **ឥណបរិភោគ** ។

ពាក្យថា **ព្រោះហេតុនោះ** លោកដកយកសេចក្តីដែលបានពោលហើយ ដោយពាក្យថា “**សីលវតោ**” ជាដើមនោះឯង ដោយការៈជាហេតុ ។ ភ្ជាប់សេចក្តីថា ភិក្ខុដោះចីវរចេញចាកកាយហើយគប្បីពិចារណាក្នុងវេលាដែលប្រើប្រាស់គ្រប់គ្រា ក្នុងវេលាមុនកត្ត ។ល។ ក្នុងយាមចុងបំផុត ដូច្នេះ ។ កាលមិនអាចយ៉ាងនោះ គឺដោយ

*អំណាចកាលដែលផ្សេងគ្នាតាមដែលពោលហើយ ក៏គប្បីពិចារណាក្នុងមួយថ្ងៃ ៤ ដងខ្លះ ៣ ដងខ្លះ ២ ដងខ្លះ មួយដងប៉ុណ្ណោះខ្លះ ។ ប្រសិនបើថា (លោកមិនពិចារណាសោះ) អរុណរះឡើង រមែងតាំងនៅក្នុងឥណបរិភោគ ។*

ហិយ្យោ យំ មយា ចីវរំ បរិភុត្តំ, តំ យាវទេវ សីតស្ស បដិឃាតាយ ។បេ។ ហិរិកោបីនបដិច្ឆាទនត្ថំ ។ ហិយ្យោ យោ មយា បិណ្ឌបាតោ បរិភុត្តោ, សោ "នេវ ទវាយា"តិអាទិនា សចេ អតីតបរិភោគបច្ចវេក្ខណំ ន ករេយ្យាតិ វទន្តិ, តំ វីមំសិតព្វំ ។

*អាចារ្យទាំងឡាយលោកពោលថា បើមិនធ្វើការពិចារណាទៅក្នុងអតីត: ដោយន័យថា "សំពត់ចីវរណា ដែលយើងមិនបានពិចារណាហើយ ប្រើប្រាស់ហើយក្នុងថ្ងៃម្សិល សំពត់ចីវរនោះ យើងប្រើប្រាស់កំណត់ទុកដើម្បីការពារត្រជាក់ ។ល។ ដើម្បីបិទបាំងអវយវៈដែលធ្វើនូវសេចក្តីខ្មាសឲ្យកម្រើកប៉ុណ្ណោះ" ។ បិណ្ឌបាតណា ដែលយើងបរិភោគហើយក្នុងថ្ងៃម្សិល បិណ្ឌបាតនោះ យើងបានបរិភោគហើយ "មិនមែនដើម្បីលេង" ដូចនេះជាដើម ដូច្នេះ, ពាក្យដែលអាចារ្យទាំងឡាយពោលនោះ បណ្ឌិតគប្បីពិចារណាចុះ។*

**សេនាសនម្បិ បរិភោគេ បរិភោគេតិ** បវេសេ បវេសេ។ ពាក្យថា ***សូម្បីសេនាសនៈ ក៏គប្បីពិចារណាក្នុងវេលាដែលប្រើ-ប្រាស់គ្រប់គ្រា*** *គឺគប្បីពិចារណាក្នុងវេលាដែលចូលទៅគ្រប់គ្រា ។*

**សតិបច្ចយតា**តិ សតិយា បច្ចយភាវោ បដិគ្គហណស្ស, បរិភោគស្ស ច បច្ចវេក្ខណសតិយា បច្ចយភាវោ យុជ្ជតិ, បច្ចវេក្ខិត្វាវ បដិគ្គហេតព្វំ, បរិភុញ្ជិតព្វញ្ចាតិ អត្ថោ ។ តេនេវាហ ***"សតី កត្វា"***តិអាទិ ។

*បទថា សតិបច្ចយតា បានដល់ ការមានសតិជាបច្ច័យគួរដល់ការទទួល និងការមានសតិក្នុងការពិចារណាជាបច្ច័យ គួរដល់ការបរិភោគ, អធិប្បាយថា គប្បីពិចារណាដូចគ្នាហើយ ទើបទទួល និងបរិភោគ ។ ព្រោះហេតុនោះ លោកទើបពោលថា* ***"សតី កត្វា : ធ្វើសតិ"*** *ដូច្នេះជាដើម ។*

*ពាក្យថា* ***សូម្បីកាលជាយ៉ាងនេះ*** *សេចក្តីថា សូម្បីបើថា ការពិចារណាសូម្បីក្នុងកាលទាំងពីរ (គឺក្នុងកាលទទួល ក្នុងកាលបរិភោគ) ជាការប្រពៃសោត, សូម្បីកាលជាយ៉ាងនេះ ។ អាចារ្យមួយពួកទៀតពោលថា បទថា សតិបច្ចយតា គឺកាលសេចក្តីដែលការបរិភោគភេសជ្ជៈ ជាបច្ច័យមាន, សេចក្តីថា កាលបច្ច័យមាន ។*

បទថា ឯវំ សន្តេបិ គឺសូម្បីកាលបច្ច័យមានដូច្នេះ ។ ពាក្យនោះ ត្រឹមតែជាមតិរបស់អាចារ្យប៉ុណ្ណោះ ។

តថា ហិ បច្ចយសន្និស្សិតសីលំ បច្ចវេក្ខណាយ វិសុជ្ឈតិ, ន បច្ចយស្ស ភាវមត្តេន ។ ពិតយ៉ាងនោះ បច្ចយសន្និស្សិតសីល រមែងបរិសុទ្ធបាន ព្រោះការពិចារណា មិនមែនបរិសុទ្ធបាន ព្រោះតែមានបច្ច័យទេ ។

<u>ដីកា</u> សារត្ថទីបនី ភាគ១ ពន្យល់ថា ៖

ពាក្យថា សតិបច្ចយតា សេចក្តីថា ភាពជាបច្ច័យគឺការ មានសតិក្នុងការពិចារណាជាបច្ច័យ រមែងគួរ, បានដល់ ភាពជាអ្នក ញ៉ាំងការពិចារណាដោយសតិ ឲ្យសម្រេច ដោយអំណាចសម្ប-ជញ្ញៈដែលមានប្រយោជន៍ (សាត្ថកសម្បជញ្ញវសេន) ទាំងក្នុងការ ទទួលនិងការបរិភោគ គួរពិត ។ម្យ៉ាងទៀត សតិនោះឯង ជាបច្ច័យដែលជាគ្រឿងពិចារណា នៃការទទួលនិងការបរិភោគទាំង នេះមាន ហេតុនោះ ការទទួលនិងការបរិភោគទាំងនេះ ឈ្មោះថា មានសតិជាបច្ច័យ ។ ភាវៈនៃការទទួល និងការបរិភោគដែល មានសតិជាបច្ច័យទាំងនោះ ឈ្មោះថា **ការមានសតិជាបច្ច័យ** ។ សេចក្តីថា ការដែលភិក្ខុទាំងនោះមានសតិជាបច្ច័យណា ការដែល

ភិក្ខុទាំងនោះមានសតិជាបច្ច័យនោះ រមែងគួរ ទាំងក្នុងការទទួល ទាំងក្នុងការបរិភោគ ។

ម្យ៉ាងទៀត គប្បីជ្រាប**អលុត្តសមាស**ថា បច្ច័យក្នុងការទទួលបច្ច័យ គប្បីឃើញដោយការលុបបទក្រោយចេញ, កាលមានសតិជាបច្ច័យនោះឯង ការប្រព្រឹត្តទៅក្នុងការទទួលបច្ច័យ គឺក្នុងកាលទទួលវត្ថុដែលជាប្រយោជន៍ ឈ្មោះថា ភាពជាអ្នកមានសតិជាបច្ច័យ គប្បីឃើញការលុបស័ព្ទថា **ប្រព្រឹត្តទៅ** ។ ក៏ក្នុងស័ព្ទថា **ប្រព្រឹត្តទៅ** នេះ លោកប្រាថ្នាយកភាពជារបស់គួរទទួល និងគួរបរិភោគ ក្នុងកាលមានការទទួលរបស់ដែលជាប្រយោជន៍ប៉ុណ្ណោះ ។ នេះជាការសម្តែងខែសេចក្តីជាបច្ច័យ ដោយការលុប **យ** អក្សរ ។ អធិប្បាយថា កាលមានស័ព្ទថា ការដែលគេសង្ហះជាបច្ច័យក្នុងការរម្ងាប់រោគ ។ សូម្បីក្នុងទីនេះ គប្បីឃើញការលុបស័ព្ទថា **គហណ** ចេញ ។

ពាក្យថា **ឯវំ សន្តេបិ** (សូម្បីកាលជាយ៉ាងនេះ) សេចក្តីថា សូម្បីកាលបច្ច័យជារបស់គួរពិចារណាទាំង ២ កាល ។ អធិប្បាយថា កាលភិក្ខុមិនធ្វើសតិពិចារណាក្នុងការទទួល ធ្វើសតិក្នុងខណៈបរិភោគ សីលនោះរមែងបរិសុទ្ធ ដោយស័ព្ទថា **មិនជាអាបត្តិ (អនាបត្តិ)** ។

## សុទ្ធិមាន ៤ យ៉ាង

*សេចក្តីពិត សុទ្ធិមាន ៤ យ៉ាង គឺ*

*១-ទេសនាសុទ្ធិ បរិសុទ្ធិដោយការសម្តែង*

*២-សំវរសុទ្ធិ បរិសុទ្ធិដោយការសង្រួម*

*៣-បរិយេដ្ឋិសុទ្ធិ បរិសុទ្ធិដោយការស្វែងរក*

*៤-បច្ចវេក្ខណសុទ្ធិ បរិសុទ្ធិដោយការពិចារណា ។*

*ក្នុង ៤ យ៉ាងនោះ* ***បាតិមោក្ខសំវរសីល*** *ឈ្មោះថា ទេសនាសុទ្ធិ ។ ព្រោះបាតិមោក្ខសំវរសីលនោះ លោកហៅថា ទេសនាសុទ្ធិ ព្រោះបរិសុទ្ធិដោយការសម្តែង ។*

***ឥន្ទ្រិយសំវរសីល*** *ឈ្មោះថា សំវរសុទ្ធិ ។ ព្រោះថា ឥន្ទ្រិយ-សំវរសីលនោះ លោកហៅថា សំវរសុទ្ធិ ព្រោះបរិសុទ្ធដោយការសង្រួម គឺអធិដ្ឋានចិត្តនោះថា យើងនឹងមិនធ្វើយ៉ាងនេះទៀត ។*

***អាជីវបារិសុទ្ធិ*** *ឈ្មោះថា បរិយេដ្ឋិសុទ្ធិ ។ ព្រោះអាជីវ-បារិសុទ្ធិសីលនោះ លោកហៅថា បរិយេដ្ឋិសុទ្ធិ ព្រោះភាពនៃអាជីវៈ-ស្អាតដោយការស្វែងរក នៃកិក្ខុកាលលះបង់នូវការស្វែងរកមិនគួរ ហើយញុំាងបច្ច័យទាំងឡាយឲ្យកើតឡើងដោយធម៌ដ៏ស្មើ ។*

***បច្ចយសន្និស្សិតសីល*** *ឈ្មោះថា បច្ចវេក្ខណសុទ្ធិ ។ ព្រោះ បរិសុទ្ធដោយការពិចារណា ដោយមានបការៈដូចដែលលោកបាន*

ពោលហើយ ។ ព្រោះហេតុនោះ ពាក្យដែលលោកពោលថា កាលភិក្ខុមិនធ្វើស្មារតីក្នុងពេលទទួល ហើយធ្វើសតិក្នុងពេលបរិភោគ មិនត្រូវអាបត្តិទេ ។

<u>ក្នុងដីកា</u> បរមត្ថមញ្ជុសា ភាគ១ ពន្យល់ថា ៖

លោកអាចារ្យ កាលសម្ដែងគ្រឿងបរិសុទ្ធនៃបច្ចយសន្និស្សិតសីល យ៉ាងនេះហើយ ដើម្បីសម្ដែងគ្រឿងបរិសុទ្ធិសូម្បីទាំងអស់ ដោយបំណងនោះនុ៎ះឯង ទើបពោលថា "ក៏សុទ្ធិ មាន ៤ យ៉ាង" ដូច្នេះជាដើម ។ ក្នុងពាក្យទាំងនោះ ធម្មជាតិឈ្មោះថា **សុទ្ធិ** ព្រោះអត្ថថា ជាគ្រឿងបរិសុទ្ធិ ។ សុទ្ធិគឺការសម្ដែងតាមការសមគួរដល់ធម៌ ឈ្មោះថា **ទេសនាសុទ្ធិ** ។

ក៏ក្នុងអធិការនេះ គប្បីឃើញថា សូម្បីការចេញ (ចាកអាបត្តិ ដោយការនៅបរិវាស) ក៏មានការសង្គ្រោះចូលក្នុងទេសនានោះឯង ។ ចំណែកសម្រាប់ភិក្ខុទាំងឡាយ អ្នកមានមូលាអាបត្តិដាច់ហើយ (បារាជិក ៤) ការប្ដេជ្ញាថា ខ្លួនមិនមែនជាភិក្ខុទេនោះឯង ជាទេសនា ។

*សុទ្ធិ* គឺសំវរៈដែលពិសេសដោយការតាំងចិត្ត (ថានឹងមិនធ្វើយ៉ាងនេះទៀត) ឈ្មោះថា សំវរសុទ្ធិ ។

*សុទ្ធិ* គឺការស្វែងរកបច្ច័យទាំងឡាយដោយស្មើតាមធម៌ នោះឯង ឈ្មោះថា បរិយេដ្ឋិសុទ្ធិ ។

*សុទ្ធិ* គឺការពិចារណាដោយវិធីតាមដែលពោលហើយក្នុងបច្ច័យសូម្បីទាំង ៤ ឈ្មោះថា បច្ចវេក្ខណសុទ្ធិ ។

វចនត្ថៈនេះ ជាន័យនៃពាក្យសមាស ក្នុងសុទ្ធិទាំងឡាយមុន ។ ចំណែកវចនត្ថៈក្នុងសីល មានសុទ្ធិទាំងឡាយ មានបាតិ-មោក្ខសំវរសីល ឈ្មោះថា ទេសនាសុទ្ធិ ព្រោះអត្ថថា មានការសម្តែងជាគ្រឿងបរិសុទ្ធិ ។ សូម្បីក្នុងសីលដ៏សេស ក៏មានន័យនេះដូចគ្នា ។ ចំណែកសព្ទថា **សុទ្ធិ** ក៏មានន័យដូចខ្ញុំបានពោលហើយនោះឯង ។ ពាក្យថា **(នឹងមិនធ្វើ) យ៉ាងនេះ** លោកអាចារ្យពោលសំដៅយកប្រភេទនៃសំវរ ។ ពាក្យថា **លះបង់** គឺការវៀរថាមិនធ្វើ ។

ក្នុង<u>គម្ពីរវិសុទ្ធិមគ្គ</u> លោកពោលទៀត ថា ៖

ការបរិភោគប្រើប្រាស់បច្ច័យរបស់សេក្ខបុគ្គល ៧ ពួក ឈ្មោះថា **ទាយជ្ជបរិភោគ** ។ ព្រោះជាបុត្ររបស់ព្រះមានព្រះភាគ លោកមានសភាពជាអ្នកទទួលបច្ច័យទាំងឡាយ ជារបស់នៃបិតា ហើយបរិភោគនូវបច្ច័យនោះ ។ សួរថា ចុះសេក្ខបុគ្គលទាំងនោះ បរិភោគនូវបច្ច័យទាំងឡាយរបស់ព្រះមានព្រះភាគឬ ឬបរិភោគនូវបច្ច័យទាំងឡាយរបស់គ្រហស្ថ ? ឆ្លើយថា បច្ច័យទាំងនោះ ទុកជា

ពួកគ្រហស្ថប្រគេនហើយក៏ដោយ គង់ជាបច្ច័យរបស់ព្រះមានព្រះ-ភាគពិត ព្រោះភាពនៃបច្ច័យទាំងនោះ ព្រះមានព្រះភាគ អនុញ្ញាតហើយ ព្រោះហេតុនោះ គប្បីជ្រាបថា ព្រះសេក្ខទាំងនោះ បរិភោគបច្ច័យព្រះមានព្រះភាគ ។ ឯក្នុងការបរិភោគបច្ច័យនោះ មានធម្មទាយាទសូត្រជាបន្ទាល់ ។

ការបរិភោគរបស់ពួកព្រះខីណាស្រព ឈ្មោះថា **សាមិបរិ-ភោគ** ។ ព្រោះពួកលោកមានសភាពជាម្ចាស់ បរិភោគបាន ព្រោះពួកលោកជាអ្នកកន្លងហើយនូវភាពនៃខ្លួនជាខ្ញុំតណ្ហា ។

បណ្តាបរិភោគទាំងនេះ សាមិបរិភោគ និងទាយជ្ជបរិភោគ គួរដល់ភិក្ខុគ្រប់រូបទាំងអស់ ។ ឯឥណបរិភោគ មិនគួរទេ ។ ការពោលក្នុងថេយ្យបរិភោគ ក៏មិនមាន ។

ក៏ការបរិភោគរបស់ភិក្ខុមានសីល ពិចារណាហើយនុ៎ះហ្នឹងឯង ឈ្មោះថា ការបរិភោគដោយភាពមិនជាបំណុល ព្រោះជាសត្រូវដល់ឥណបរិភោគ ឬដល់នូវការរួបរួមក្នុងទាយជ្ជបរិភោគដែរ ។ មែនហើយ ភិក្ខុមានសីល លោកពោលថា សេក្ខដែរ ព្រោះលោកប្រកបព្រមដោយសិក្ខានេះ ។ ក៏ក្នុងការបរិភោគទាំងនេះ សាមិបរិភោគជាកំពូល ព្រោះហេតុនោះឯង ភិក្ខុកាលប្រាថ្នានូវសាមិបរិភោគនោះ ពិចារណាដោយបច្ចវេក្ខណៈ មានបការៈ

ដែលយើងពោលហើយ បរិភោគហើយ គប្បីញុំាងបច្ចយសន្និស្សិតសីលឲ្យសម្រេច ។

ក៏កាលធ្វើយ៉ាងនេះ ឈ្មោះថា ជាអ្នកធ្វើកិច្ច ។ សមដូចពាក្យនេះ ដែលលោកពោលថា ៖

សាវកមានបញ្ញាដ៏ប្រសើរ បានស្តាប់ធម៌ដែលព្រះសុគតសម្តែងហើយ គប្បីពិចារណាហើយសេពដុំបាយ វិហារជាទីដេក ទីអង្គុយ និងទឹកសម្រាប់លាងធូលីក្នុងសង្ឃាដិ ព្រោះហេតុនោះ ភិក្ខុមិនជាប់ក្នុងធម៌ទាំងនេះ គឺក្នុងដុំបាយ ទីដេក ទីអង្គុយ និងទឹកសម្រាប់លាងធូលីក្នុងសង្ឃាដិ ដូចជាដំណក់ទឹកលើស្លឹកឈូក លោកបានហើយតាមកាលគួរ ដោយសេចក្តីអនុគ្រោះអំពីបុគ្គលដទៃ ឧស្សាហ៍តាំងស្មារតីស្គាល់ប្រមាណក្នុងបង្អែម ចង្អាប និងគ្រឿងស្រស់ស្រូបទាំងឡាយ ដូចគ្រូពេទ្យស្គាល់ប្រមាណក្នុងភេសជ្ជៈ គ្រឿងធ្វើនូវដំបៅឲ្យដុះសាច់ បុរសស៊ីសាច់កូនក្នុងផ្លូវដាច់ស្រយាល យ៉ាងណា អ្នករទេះសេពខ្លាញ់សម្រាប់លាបភ្លៅរទេះ យ៉ាងណា ភិក្ខុមិនជាប់ក្នុងរសអាហារហើយឆាន់អាហារ ដើម្បីញុំាងអត្តភាពឲ្យប្រព្រឹត្តទៅ យ៉ាងនោះ ។

ក្នុងដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

បច្ច័យ ៤ ឈ្មោះថា **ទាយៈ** (មត៌ក) ព្រោះអត្ថថា ដែលបុគ្គលគប្បីឲ្យ, ទាយៈនោះ ដែលបុគ្គលណា រមែងកាន់យកព្រោះហេតុនោះ បុគ្គលនោះឈ្មោះថា **ទាយាទ** ។ បច្ច័យដែលភិក្ខុគប្បីបរិភោគទាំងឡាយ ឈ្មោះថា ជារបស់ព្រះមានព្រះភាគ ព្រោះទ្រង់មិនអនុញ្ញាតទុក ក៏មិនមានការបរិភោគបានឡើយដោយប្រការទាំងពួង និងព្រោះកាលទ្រង់អនុញ្ញាតទុកនោះឯង ទើបមានការបរិភោគបាន ។ ក៏ធម្មទាយាទសូត្រ (មជ្ឈិមនិកាយ មូលបណ្ណាសក បិដកលេខ២០ ទំព័រ៤៣) ដែលប្រព្រឹត្តទៅយ៉ាងនេះថា "តស្មាតិហ មេ ភិក្ខវេ ធម្មទាយាទា ភវថ មា អាមិសទាយាទា អត្ថិ មេ តុម្ហេសុ អនុកម្បា កិន្តិ មេ សាវកា ធម្មទាយាទា ភវេយ្យុំ នោ អាមិសទាយាទាតិ : ម្នាលភិក្ខុទាំងឡាយ ព្រោះហេតុនោះ ក្នុងធម្មវិន័យនេះ អ្នកទាំងឡាយចូរយកធម៌របស់តថាគតជាមត៌ក កុំយកអាមិសជាមត៌កឡើយ, តថាគត មានសេចក្តីអនុគ្រោះចំពោះអ្នកទាំងឡាយ ដូច្នេះថា ធ្វើម្តេចហ្ន៎ ពួកសាវករបស់តថាគត គួរជាអ្នកយកធម៌ជាមត៌ក កុំយកអាមិសជាមត៌កឡើយ" ដូច្នេះ ជាសាធកក្នុងរឿងនេះ គឺក្នុងសេចក្តីនេះ ។

*សម្រាប់បុគ្គល ដែលនៅមិនទាន់ប្រាសចាករាគៈទាំងឡាយ រមែងមិនមានភាពជាម្ចាស់ក្នុងការបរិភោគបច្ច័យ ព្រោះភាពជាទាសៈរបស់តណ្ហា សម្រាប់អ្នកប្រាសចាករាគៈទាំងឡាយហើយ ឈ្មោះថា មានភាពជាម្ចាស់ក្នុងការបរិភោគបច្ច័យនោះ ព្រោះមានការបរិភោគបានតាមសេចក្ដីពេញចិត្ត ដោយមិនមានភាពជាទាសៈរបស់តណ្ហានោះ ។ ពិតយ៉ាងនោះ លោកទាំងនោះ រមែងបរិភោគបច្ច័យទាំងឡាយ ដោយអាការដែលធ្វើវត្ថុបដិកូល ឲ្យជាវត្ថុមិន-បដិកូល ក៏បាន ដោយអាការធ្វើវត្ថុមិនបដិកូល ឲ្យជាវត្ថុបដិកូល ក៏បាន ដោយអាការព្រងើយ វៀរអាការទាំងពីរនោះចេញ ក៏បាន ទាំងញុំាងសេចក្ដីសង្ឃឹមរបស់ពួកទាយកឲ្យពេញបានផង ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា "ពិតមែន ព្រះខីណាស្រព ទាំងនោះបរិភោគ ចាត់ជា**សាមិបរិភោគ** ព្រោះភាពដែលលោកទាំងនោះកន្លងភាពជាទាសៈរបស់តណ្ហាបានហើយ" ដូច្នេះ ។*

*ពាក្យថា (គួរ) **ដល់ភិក្ខុទាំងឡាយទាំងពួង** គឺដល់ភិក្ខុទាំងឡាយ ជាព្រះអរិយៈ និង បុថុជ្ជន ។*

*សួរថា សាមិបរិភោគ និងទាយជ្ជបរិភោគទាំងនេះ មានដល់បុថុជ្ជនទាំងឡាយបានយ៉ាងណា ?*

*ឆ្លើយថា មានបានដោយអំណាចការប្រៀបធៀប ។ ក៏កាលចិត្តដែលមិនជាប់ជំពាក់ក្នុងបច្ច័យនោះៗ ព្រោះលះបង់សេចក្ដីប្រាថ្នា*

ក្នុងបច្ច័យនៃភិក្ខុសូម្បីជាបុថុជ្ជន អ្នកតាំងនៅក្នុងសល្លេខបដិបត្តិយ៉ាងណា ការបរិភោគនោះ រមែងដូចជាសាមិបរិភោគ ។ ចំណែកការបរិភោគបច្ច័យដែលបានពិចារណាហើយ នៃភិក្ខុអ្នកមានសីល រមែងដូចទាយជ្ជបរិភោគ, ព្រោះការមិនធ្វើមនោរថរបស់ពួកទាយកឲ្យវិនាសទៅ ។ ពាក្យនេះ សមដូចពាក្យលោកអាចារ្យបានពោលទុកថា "ដល់ការសង្គ្រោះចូលក្នុងទាយជ្ជបរិភោគនោះឯងក៏បាន" ដូច្នេះ ។ ក្នុងការបរិភោគរបស់ភិក្ខុអ្នកជាកល្យាណបុថុជ្ជន មិនមានពាក្យដែលត្រូវពោលដល់ឡើយ ព្រោះកល្យាណបុថុជ្ជនទាំងឡាយនោះ មានការសង្គ្រោះចូលក្នុងព្រះសេក្ខបាន ។ ក៏សេក្ខសូត្រជាសាធកនៃសេចក្តីនេះបាន ។ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា "ព្រោះថា សូម្បីលោកអ្នកមានសីល" ដូច្នេះជាដើម ។

**បច្ចនីកត្ថា**តិ យថា ឥណាយិកោ អត្តនោ រុចិយា ឥច្ឆិតទេសំ គន្តុំ ន លភតិ, ឯវំ ឥណបរិភោគយុត្តោ លោកតោ និស្សរិតុំ ន លភតីតិ តប្បដិបក្ខត្តា សីលវតោ បច្ចវេក្ខិតបរិភោគោ អាណណ្យបរិភោគោតិ អាហ "**អាណណ្យបរិភោគោ វា**"តិ ។

ពាក្យថា ***ព្រោះភាពជាសត្រូវ*** សេចក្តីថា ប្រៀបដូចបុគ្គលអ្នកជំពាក់បំណុល រមែងមិនបានដើម្បីទៅកាន់ទីកន្លែងដែលប្រាថ្នា

*តាមសេចក្តីពេញចិត្តរបស់ខ្លួន យ៉ាងណា, ភិក្ខុប្រកបដោយការបរិភោគដូចជំពាក់បំណុល រមែងមិនបានដើម្បីចេញចាកលោកបានដូច្នេះ យ៉ាងនេះ ។ ការបរិភោគបច្ច័យដែលបានពិចារណាហើយនៃភិក្ខុអ្នកមានសីល ឈ្មោះថា ការបរិភោគដោយការមិនជាបំណុល ព្រោះជាបដិបក្ខចំពោះការបរិភោគដោយភាពជាបំណុលនោះ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា "ចាត់ជាការបរិភោគមិនជាបំណុល ក៏បាន" ដូច្នេះ ។*

ឯតេន និប្បរិយាយតោ ចតុបរិភោគវិនិមុត្តោ វិសុំ-យេវាយំ បរិភោគោតិ ទស្សេតិ ។ *ដោយពាក្យនេះ លោកអាចារ្យសម្តែងថា ការបរិភោគដោយសេចក្តីមិនជាបំណុលនេះ ជាការបរិភោគម្យ៉ាងដោយឡែក ដែលផុតចាកការបរិភោគ ៤ យ៉ាង ដោយនិប្បរិយាយ ។*

**ឥមាយ សិក្ខាយា**តិ សីលសង្ខាតាយ សិក្ខាយ ។ **កិច្ចការី**តិ បដិញ្ញានុរូបំ បដិបជ្ជនតោ យុត្តបត្តការី ។

*ពាក្យថា **ដោយសិក្ខានេះ** គឺដោយសិក្ខាពោលគឺ សីល ។ ពាក្យថា កិច្ចការី បានដល់ ជាអ្នកមានប្រក្រតីធ្វើឲ្យដល់ភាពត្រឹមត្រូវ ព្រោះបដិបត្តិបានសមគួរដល់បដិញ្ញា ។*

# អធិប្បាយសីលពួក ៥ ក្រុមទី១

ក្នុងសីលពួក៥ នៃក្រុមទី១ គប្បីជ្រាបវិនិច្ឆ័យដូច្នេះ ៖

គប្បីជ្រាបសេចក្ដីដោយអំណាច នៃអនុបសម្បន្នសីលជាដើម ។ សមដូចពាក្យនេះ ដែលព្រះសារីបុត្ត ពោលហើយក្នុងគម្ពីរបដិសម្ភិទាមគ្គ (បិដក លេខ៦៩ ទំព័រ៩៦) ថា

***បរិយន្តបារិសុទ្ធិសីល*** *តើដូចម្ដេច ? សីលរបស់អនុបសម្បន្នទាំងឡាយ ដែលមានសិក្ខាបទមានទីបំផុត នេះឈ្មោះថា* ***បរិយន្តបារិសុទ្ធិសីល*** *។*

***អបរិយន្តបារិសុទ្ធិសីល*** *តើដូចម្ដេច ? សីលរបស់ឧបសម្បន្នទាំងឡាយ ដែលមានសិក្ខាបទមិនមានទីបំផុត នេះឈ្មោះថា* ***អបរិយន្តបារិសុទ្ធិសីល*** *។*

***បរិបុណ្ណបារិសុទ្ធិសីល*** *តើដូចម្ដេច ? សីលរបស់កល្យាណបុថុជ្ជនទាំងឡាយ ដែលប្រកបក្នុងកុសលធម៌ អ្នកបំពេញក្នុងអសេក្ខបរិយន្តសីល មិនស្ដាយកាយនិងជីវិត ជាអ្នកមានជីវិតលះបង់ហើយ នេះឈ្មោះថា* ***បរិបុណ្ណបារិសុទ្ធិសីល*** *។*

***អបរាមដ្ឋបារិសុទ្ធិសីល*** *តើដូចម្ដេច ? សីលរបស់សេក្ខៈបុគ្គល ៧ ពួក នេះឈ្មោះថា* ***អបរាមដ្ឋបារិសុទ្ធិសីល*** *។*

***បដិបស្សទ្ធិបារិសុទ្ធិសីល*** *តើដូចម្ដេច ? សីលរបស់ព្រះ-*

ទីណាស្រេច ជាសាវកនៃព្រះតថាគត របស់ព្រះបច្ចេកពុទ្ធ របស់ព្រះតថាគតជាអរហន្តសម្មាសម្ពុទ្ធ នេះឈ្មោះថា **បដិបស្សទ្ធិ-បារិសុទ្ធិសីល** ដូច្នេះ ។

ក្នុងសីល ៥ យ៉ាងនោះ សីលរបស់អនុបសម្បន្នទាំងឡាយ គប្បីជ្រាបថា **បរិយន្តបារិសុទ្ធិសីល** ព្រោះជាសីលមានទីបំផុតដោយអំណាចនៃការរាប់ ។ **សីលរបស់ឧបសម្បន្ន** សូម្បីមានទីបំផុតដោយអំណាចនៃការរាប់យ៉ាងនេះ គឺ ៖

"នវ កោដិសហស្សានិ អសីតិសតកោដិយោ
បញ្ញាសសតសហស្សានិ ឆត្តឹសា ច បុនាបរេ ។
ឯតេ សំវរវិនយា សម្ពុទ្ធេន បកាសិតា
បេយ្យាលមុខេន និទ្ទិដ្ឋា សិក្ខា វិនយសំវរេ"តិ ។

"សិក្ខាបទដែលជាសំវរវិន័យ មានចំនួនប្រាំបួនពាន់កោដិ និងមួយរយប៉ែតសិបកោដិ និងផ្សេងទៀតហាសិបសែន និងសាម-សិបប្រាំមួយសែនផ្សេងៗទៀត សិក្ខាបទទាំងនេះ ។ ដែលព្រះ-សម្មាសម្ពុទ្ធ ទ្រង់ប្រកាសទុកហើយ ជាសិក្ខាបទដែលទ្រង់សម្តែងទុកក្នុងវិនយបិដកដោយបំព្រួញ គឺបេយ្យាល" ដូច្នេះ ។

ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

អសីតិ សតកោដិយោតិ អសីតិអធិកេន សតេន

គណិតា កោដិយោ ៨ ។

*ពាក្យថា* អសីតិ សតកោដិយោ *សេចក្តីថា និងកោដិទាំងឡាយដែលរាប់ដោយមួយរយក្រៃលែងដោយ ៨០ ។ ក៏ក្នុងទីនេះ ច អក្សរ ប្រកបទុកក្នុងអដ្ឋានៈ, អធិប្បាយថា និងមួយរយលើសទៅ ៨០ នៃកោដិទាំងឡាយ ។ មែនពិត ការរាប់សីលនេះគប្បីជ្រាបថា បុព្វាចារ្យទាំងឡាយ រួបរួមតាំងទុកដោយអំណាចផ្នែកអាបត្តិ ប្រកបបេយ្យាល ជាប្រភេទអាបត្តិវារៈមកហើយក្នុងសុត្តវិភង្គជាដើម ក្នុងវិនយបិដក ។ ព្រោះហេតុនោះ លោកពោលពាក្យមានជាដើមថា "សំវរវិន័យទាំងនេះ" ។ មានវាចាប្រកបសេចក្តីថា ព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រកាសសំវរវិន័យទាំងនេះ ពោលគឺសិក្ខា ដែលលោកសម្តែងទុកដោយមុខបេយ្យាលក្នុងវិនយបិដក ដែលជាវិនយសំវរៈ ព្រោះទូន្មាននិងសង្រួមកាយនិងវាចា ក្នុងសុត្តវិភង្គជាដើមនោះ ។*

*ក្នុងគម្ពីរវិសុទ្ធិមគ្គ លោកពោលទៀតថា ៖*

*គប្បីជ្រាបថា ឈ្មោះថា* ***អបរិយន្តបារិសុទ្ធិសីល*** *ព្រោះសំដៅយកនូវភាពនៃការសមាទាន ដោយមិនមានសេសសល់ និងភាពនៃសីលមានទីបំផុតដែលខ្លួនមិនឃើញហើយ ដោយអំណាចនៃលាភ យស ញាតិ អង្គ និងជីវិត ដូចសីលរបស់ព្រះមហា-*

*តិស្សត្ថេរ ឆាន់ផ្លែស្វាយ មានកិរិយានៅក្នុងចិរគុម្ពៈ ដូច្នោះ ។ ពិតយ៉ាងនោះ លោកមានអាយុនោះ កាលមិនលះអនុស្សតិរបស់សប្បុរសនេះថា ៖*

"ធនំ ចជេ អង្គវរស្ស ហេតុ
អង្គំ ចជេ ជីវិតំ រក្ខមានោ
អង្គំ ធនំ ជីវិតញ្ចាបិ សព្វំ
ចជេ នរោ ធម្មមនុស្សរន្តោ"តិ ។

*"នរៈ គប្បីលះបង់ទ្រព្យ ព្រោះតែហេតុនៃអវយវៈដ៏ប្រសើរ កាលរក្សានូវជីវិត គប្បីលះបង់នូវអវយវៈ, កាលរលឹកឃើញធម៌ គប្បីលះបង់នូវអវយវៈ ទ្រព្យ និងសូម្បីជីវិតទាំងអស់" ដូច្នេះ,*

*មិនប្រព្រឹត្តកន្លងសិក្ខាបទ សូម្បីក្នុងវេលាសង្ស័យនូវជីវិត អាស្រ័យនូវ**អបរិយន្តបារិសុទ្ធិសីល**នោះ នៅលើខ្នងឧបាសក បានសម្រេចហើយនូវព្រះអរហត្ត ។*

*ឯសីលរបស់ពួកព្រះសេក្ខៈ គប្បីជ្រាបថា **អបរាមដ្ឋបារិសុទ្ធិ** ព្រោះមិនពាល់ត្រូវដោយអំណាចនៃទិដ្ឋិ, ចំណែកឯសីលដែលមិនពាល់ត្រូវដោយអំណាចកតរបស់ពួកបុថុជ្ជន គប្បីជ្រាបថា អបរា-មដ្ឋបារិសុទ្ធិដែរ ដូចសីលរបស់កុដុម្ពិយបុត្តតិស្សត្ថេរ ។*

ឯសីលរបស់ពួកព្រះអរហន្តជាដើម គប្បីជ្រាបថា **បដិប្បស្សទ្ធិបារិសុទ្ធិ** ព្រោះការៈនៃសីលនោះ បរិសុទ្ធដោយស្ងប់ចាកសេចក្តីក្រវល់ក្រវាយទាំងពួង ។

## អធិប្បាយសីលពួក ៥ ក្រុមទី២

គប្បីជ្រាបសេចក្តីអធិប្បាយ ដូចតទៅ ៖

គប្បីជ្រាបសេចក្តីដោយអំណាចធម៌មានជាដើមថា ការលះបង់នូវបាណាតិបាតជាដើម ។ សមដូចពាក្យនេះ ដែលលោកពោលហើយ ក្នុងគម្ពីរបដិសម្ភិទាមគ្គ (បិដកលេខ៦៩ ទំព័រ១០៦) ថា "សីល ៥ គឺ ការលះបង់បាណាតិបាត ឈ្មោះថា សីល, ការវៀរ ឈ្មោះថា សីល, ចេតនា ឈ្មោះថា សីល, សេចក្តីសង្រួម ឈ្មោះថា សីល, ការមិនប្រព្រឹត្តកន្លង ឈ្មោះថា សីល, ការលះបង់អទិន្នាទាន កាមេសុមិច្ឆាចារ មុសាវាទ បិសុណាវាចា ផរុសវាចា សម្ផប្បលាបៈ អភិជ្ឈា ព្យាបាទ មិច្ឆាទិដ្ឋិ លះនូវកាមច្ឆន្ទៈ ដោយនេក្ខម្មៈ, នូវព្យាបាទ ដោយអព្យាបាទ, នូវថីនមិទ្ធៈ ដោយអាលោកសញ្ញា, នូវឧទ្ធច្ចៈ ដោយអវិក្ខេបៈ (ការមិនរាយមាយ), នូវវិចិកិច្ឆា ដោយការកំណត់នូវធម៌ (ធម្មវវត្ថាន), នូវអវិជ្ជា ដោយញាណ, នូវអរតិ ដោយបាមោជ្ជៈ, នូវនីវរៈទាំងឡាយ ដោយ

បឋមជ្ឈាន, វិតក្កៈ វិចារៈ ដោយទុតិយជ្ឈាន, នូវបីតិ តតិយជ្ឈាន, នូវសុខនិងទុក្ខ ដោយចតុត្ថជ្ឈាន, នូវរូបសញ្ញា បដិឃសញ្ញា និង នានត្តសញ្ញា ដោយអាកាសានញ្ចាយតនសមាបត្តិ, នូវអាកាសា-នញ្ចាយតនសញ្ញា ដោយវិញ្ញាណញ្ចាយតនសមាបត្តិ, នូវសេចក្តី សំគាល់ក្នុងវិញ្ញាណញ្ចាយតនៈ ដោយអាកិញ្ចញ្ញាយតនសមាបត្តិ, នូវសេចក្តីសំគាល់ក្នុងអាកិញ្ចញ្ញាយតនៈ ដោយនេវសញ្ញានាសញ្ញា-យតនសមាបត្តិ, នូវសេចក្តីសំគាល់ថាទៀង ដោយការពិចារណា ឃើញថាមិនទៀង (អនិច្ចានុបស្សនា), នូវសេចក្តីសំគាល់ថាសុខ ដោយការពិចារណាឃើញថាទុក្ខ (ទុក្ខានុបស្សនា), នូវសេចក្តី សំគាល់ថាខ្លួន (អត្តសញ្ញា) ដោយការពិចារណាឃើញថា មិនមែន ខ្លួន (អនត្តានុបស្សនា), នូវសេចក្តីត្រេកត្រអាល (នន្ទិ) ដោយការ ពិចារណាឃើញថា គួរនឿយណាយ (និព្វិទានុបស្សនា), នូវរាគៈ ដោយការពិចារណាឃើញថា ប្រាសចាករាគៈ (វិរាគានុបស្សនា), នូវការកើតឡើង ដោយការពិចារណាឃើញថា រលត់ទៅ (និរោធា-នុបស្សនា), នូវសេចក្តីប្រកាន់ ដោយការពិចារណាឃើញថា គួររលាស់ចោល (បដិនិស្សគ្គានុបស្សនា), នូវសេចក្តីសំគាល់ថា រឹងប៉ឹង ដោយការពិចារណាឃើញថា អស់ទៅ (ខយានុបស្សនា), នូវការប្រមូលមក ដោយការពិចារណាឃើញថា សូន្យទៅ (វយា-នុបស្សនា), នូវសេចក្តីសំគាល់ថាឋិតថេរ (ធុវ) ដោយការពិចារណា

ឃើញថា ប្រែប្រួល (វិបរិណាមានុបស្សនា), នូវគ្រឿងចំណាំ ដោយការពិចារណាឃើញថា មិនមានគ្រឿងចំណាំ (អនិមិត្តា-នុបស្សនា), នូវសេចក្ដីប្រាថ្នា ដោយការពិចារណាឃើញថា មិនគួរប្រាថ្នា (អប្បណិហិតានុបស្សនា), នូវការប្រកាន់មាំ ដោយការពិចារណាឃើញថា សូន្យ (សុញ្ញតានុបស្សនា), នូវសេចក្ដីប្រកាន់មាំ និងសេចក្ដីប្រកាន់ស្អិតថាខ្លឹមសារ ដោយអធិប្បញ្ញា និងធម្មវិបស្សនា, នូវសេចក្ដីប្រកាន់មាំ ព្រោះសេចក្ដីវង្វេងខ្លាំង ដោយយថាភូតញាណទស្សនៈ, នូវសេចក្ដីប្រកាន់មាំ ព្រោះអាល័យ ដោយការពិចារណាឃើញថា ជាទោស (អាទីនវានុបស្សនា), នូវការមិនពិចារណា ដោយការឃើញដោយការពិចារណា (បដិសង្ខា-នុបស្សនា), នូវសេចក្ដីប្រកាន់មាំ ព្រោះកិលេសជាគ្រឿងប្រកបទុក ដោយការពិចារណាឃើញនូវធម៌ជាគ្រឿងបើក (គោត្រភូញាណ), នូវពួកកិលេសដែលតាំងនៅក្នុងទីតែមួយជាមួយនឹងទិដ្ឋិ ដោយសោតាបត្តិមគ្គ, នូវកិលេសដ៏គ្រោតគ្រាត ដោយសកទាគាមិមគ្គ, នូវពួកកិលេសដ៏ល្អិត ដោយអនាគាមិមគ្គ, នូវកិលេសទាំងអស់ ដោយអរហត្តមគ្គ ឈ្មោះថា សីល ១, ការវៀរចេញ ឈ្មោះថា សីល ១, ចេតនា ឈ្មោះថា សីល ១, ការសង្រួម ឈ្មោះថា សីល ១, ការមិនប្រព្រឹត្តកន្លង ឈ្មោះថា សីល ១ ។ សីលមានសភាពយ៉ាងនេះ ប្រព្រឹត្តទៅដើម្បីការមិនក្ដៅក្រហាយចិត្ត, ប្រព្រឹត្តទៅ

*ដើម្បីបាមោជ្ជៈ ប្រព្រឹត្តទៅដើម្បីបីតិ ប្រព្រឹត្តទៅដើម្បីបស្សទ្ធិ ប្រព្រឹត្តទៅដើម្បីសោមនស្ស ប្រព្រឹត្តទៅដើម្បីអាសេវនៈ ប្រព្រឹត្តទៅដើម្បីភាវនា ប្រព្រឹត្តទៅដើម្បីធ្វើឲ្យច្រើន (ពហុលីកម្ម) ប្រព្រឹត្តទៅដើម្បីគ្រឿងអលង្ការ ប្រព្រឹត្តទៅដើម្បីគ្រឿងបរិក្ខារ ប្រព្រឹត្តទៅដើម្បីបរិវារ ប្រព្រឹត្តទៅដើម្បីការបំពេញ (បារិបូរិយ) ប្រព្រឹត្តទៅដើម្បីសេចក្តីនឿយណាយដោយចំណែកមួយ (ឯកន្តនិព្វិទា) ដើម្បីប្រាសចាករាគៈ ដើម្បីនិរោធ ដើម្បីសេចក្តីស្ងប់ស្ងាត់ (ឧបសមា) ដើម្បីអភិញ្ញា ដើម្បីត្រាស់ដឹង (សម្ពោធាយ) ដើម្បីនិព្វាន" ដូច្នេះ ។*

ឯត្ថ ច បហានន្តិ កោចិ ធម្មោ នាម នត្ថិ អញ្ញត្រ វុត្តប្បការានំ បាណាតិបាតាទីនំ អនុប្បាទមត្តតោ ។ យស្មា បន តំ តំ បហានំ តស្ស តស្ស កុសលធម្មស្ស បតិដ្ឋានដ្ឋេន ឧបធារណំ ហោតិ, វិកម្បាភាវករណេន ច សមាធានំ ។ តស្មា បុព្វេ វុត្តេនេវ ឧបធារណសមាធាន-សង្ខាតេន សីលនដ្ឋេន សីលន្តិ វុត្តំ ។

*ក៏ក្នុងពាក្យទាំងនោះ ពាក្យថា* បហានំ ***(ការលះ)*** *បានសេចក្តីថា ធម៌ណាមួយ វៀរចាកហេតុត្រឹមតែកិរិយាមិនកើតឡើងនៃបាណាតិបាតជាដើម មានបការៈដែលពោលហើយមិនមាន ។ ឯការលះនោះៗ ឈ្មោះថា ជាគ្រឿងទ្រទ្រង់ទុក ដោយអត្ថថា*

ប្រតិស្ឋានទុកនូវកុសលធម៌នោះៗផង ឈ្មោះថា ជាគ្រឿងរួបរួម ដោយកិរិយាធ្វើនូវភាពនៃកុសលធម៌ មិនឲ្យរោយរាយទៅផង ព្រោះហេតុនោះឯង ទើបលោកពោលថា សីល ដោយអត្ថថា ប្រក្រតី ពោលគឺកិរិយាទ្រទ្រង់ទុក (ឧបធារណ) និងកិរិយារួបរួមទុក (សមាធាន) ដែលពោលហើយក្នុងកាលមុនឯងណោះ ។

ឥតរេ ចត្តារោ ធម្មា តតោ តតោ វេរមណិវសេន, តស្ស តស្ស សំវរវសេន, តទុភយសម្បយុត្តចេតនាវសេន, តំ តំ អវីតិក្កមន្តស្ស អវីតិក្កមនវសេន ច ចេតសោ បវត្តិសព្ភាវំ សន្ធាយ វុត្តា ។

ធម៌ទាំង ៤ យ៉ាងក្រៅនេះ លោកពោលសំដៅយកការប្រព្រឹត្តទៅ និងសភាពនៃចិត្ត ដោយអំណាចនៃកិរិយាវៀរចាកទោសនោះៗ, ដោយអំណាចនៃកិរិយារវាំងទោសនោះៗ, ដោយអំណាចនៃចេតនាដែលសម្បយុត្តដោយធម៌ទាំងពីរនោះ, និងដោយអំណាចនៃកិរិយាមិនប្រព្រឹត្តកន្លង នៃភិក្ខុកាលមិនប្រព្រឹត្តកន្លងនូវទោសនោះៗ ។

## វិសុទ្ធិនាបញ្ហាកម្ម ទី៦ (សំកិលេសនៃសីល)

៦-កោ ចស្ស សំកិលេសោ ?

*ចុះអ្វីជាគ្រឿងសៅហ្មងនៃសីល ?*

ខណ្ឌាទិភាវោ សីលស្ស សំកិលេសោ, អខណ្ឌាទិភាវោ វោទានំ ។ សោ បន ខណ្ឌាទិភាវោ លាភយសាទិហេតុកេន ភេទេន ច សត្តវិធមេថុនសំយោគេន ច សង្គហិតោ ។

*ភាពមានការដាច់ជាដើម ឈ្មោះថា គ្រឿងសៅហ្មងនៃសីល ។ ភាពមានការមិនដាច់ជាដើម ឈ្មោះថា ជាគ្រឿងផូរផង់ ។ ក៏ភាពមានការដាច់ជាដើមនោះ លោកសង្គ្រោះហើយដោយប្រភេទប្រកបដោយហេតុ មានលាភនិងយសជាដើម និងដោយមេថុនសំយោគ ៧ យ៉ាង ។*

*ពិតយ៉ាងនោះ បណ្តាអាបត្តិទាំង ៧ កង សិក្ខាបទនៃភិក្ខុណា ជាសិក្ខាបទដាច់ហើយក្នុងខាងដើម ឬខាងចុង សីលរបស់ភិក្ខុនោះ ឈ្មោះថា **ដាច់** ដូចសាដកដាច់ហើយត្រង់ជាយ ដូច្នោះ ។ ចំណែកសិក្ខាបទរបស់ភិក្ខុរូបណា បែកធ្លាយហើយត្រង់កណ្តាល សីលរបស់ភិក្ខុនោះ ឈ្មោះថា **ធ្លុះហើយ** ដូចសាដកធ្លុះហើយត្រង់កណ្តាល ដូច្នោះ ។ សិក្ខាបទរបស់ភិក្ខុរូបណា បែកធ្លាយហើយ*

២-៣ តាមលំដាប់ សីលរបស់ភិក្ខុរូបនោះ ឈ្មោះថា **ពពាល** ដូចមេគោមានពណ៌នៃសរីរៈខ្មៅខ្លះ ក្រហមខ្លះ ជាដើមណាមួយ ដោយពណ៌មានចំណែកមិនស្មើគ្នា ដែលតាំងឡើងត្រង់ខ្នងខ្លះ ត្រង់ពោះខ្លះ ដូច្នោះ ។ សិក្ខាបទរបស់ភិក្ខុរូបណា បែកធ្លាយក្នុងចន្លោះៗ សីលរបស់ភិក្ខុរូបនោះ ឈ្មោះថា **ពព្រុះ** ដូចមេគោដែលលាយចម្រុះ ដោយចំណុចនៃពណ៌មិនស្មើគ្នា ក្នុងចន្លោះៗ ដូច្នោះ ។

ភាពមានការដាច់ជាដើម ឈ្មោះថា គ្រឿងសៅហ្មងនៃសីល ។ ភាពមានការមិនដាច់ជាដើម ឈ្មោះថា ជាគ្រឿងផូរផង់ ។

ភាពដែលសីលដាច់ជាដើម ព្រោះការបែកធ្លាយ ដែលមានលាភជាដើម ជាហេតុ មានបការៈយ៉ាងនេះមុន ។

ភាពនៃសីលដាច់ជាដើម ដោយអំណាចមេថុនសំយោគ ៧ យ៉ាងនេះ ។ សមពិតដូចព្រះមានព្រះភាគ ត្រាស់ទុក (ក្នុងមេថុនសំយោគនោះ) ថា ៖

## មេថុនសំយោគ ៧

ជាណុស្សោណិព្រាហ្មណ៍ ក្រាបបង្គំទូលព្រះដ៏មានព្រះភាគដូច្នេះថា បពិត្រព្រះគោតមដ៏ចម្រើន ចុះការដាច់ក្តី ធ្លុះក្តី ពពាលក្តី ពព្រុសក្តី នៃព្រហ្មចរិយធម៌ តើដូចម្តេច ?

ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា ៖

១-ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាសមណៈ ឬព្រាហ្មណ៍ ប្តេជ្ញាថា ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរដោយប្រពៃ មិនបានប៉ះពាល់នូវការប៉ះពាល់ដោយបុគ្គលពីរៗ មួយអន្លើដោយមាតុគ្រាម (សេពមេថុន) តែថា រមែងត្រេកអរនឹងការដុសខាត់ នួត ងូត ច្របាច់ របស់មាតុគ្រាម ។ បុគ្គលនោះ រមែងត្រេកអរនឹងការដុសខាត់នោះ រីករាយនឹងការដុសខាត់នោះ ដល់នូវសេចក្តីត្រេកអរដោយការដុសខាត់នោះ ។ ម្នាលព្រាហ្មណ៍ នេះឯងហៅថា ដាច់ផង ធ្លុះផង ពពាលផង ពព្រុសផង នៃព្រហ្មចរិយធម៌ ម្នាលព្រាហ្មណ៍ នេះហៅថា បុគ្គលប្រព្រឹត្តព្រហ្មចរិយធម៌មិនបរិសុទ្ធ ជាអ្នកប្រកបដោយមេថុនសំយោគ រមែងមិនផុតចាកជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស ឧបាយាសៈ តថាគតហៅថា រមែងមិនរួចចាកវដ្តទុក្ខឡើយ ។

២- ម្នាលព្រាហ្មណ៍ បុគ្គលខ្លះក្នុងលោកនេះ ជាសមណៈ ឬព្រាហ្មណ៍ប្តេជ្ញាថា ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរដោយប្រពៃ រមែងមិនប៉ះពាល់ចំពោះការប៉ះពាល់ដោយបុគ្គលពីរៗ មួយអន្លើដោយមាតុគ្រាម ទាំងមិនត្រេកអរនឹងការដុសខាត់ នួត ងូត ច្របាច់របស់មាតុគ្រាមទេ តែថា រមែងចំអកឡកឡឺយ សើចក្អាកក្អាយជាមួយនឹងមាតុគ្រាម ។បេ។

៣-បើមិនចំអកឡកឡឺយ សើចក្អាកក្អាយជាមួយនឹងមាតុ-គ្រាមទេ រមែងនៅមៀងក្អែកដោយក្អែក ដៀងចំពោះមាតុគ្រាម ។

៤-បើមិនបានមៀងក្អែកដោយក្អែក ដៀងចំពោះមាតុគ្រាមទេ រមែងស្តាប់សំឡេងនៃមាតុគ្រាម កាលសើចក្តី កាលនិយាយក្តី ច្រៀងក្តី យំក្តី ខាងក្រៅជញ្ជាំង ឬខាងក្រៅកំពែង ។

៥-បើមិនស្តាប់សំឡេងនៃមាតុគ្រាម កាលសើចក្តី និយាយក្តី ច្រៀងក្តី យំក្តី ខាងក្រៅជញ្ជាំង ឬខាងក្រៅកំពែងទេ តែថា រលឹករឿយៗ នូវហេតុដែលធ្លាប់សើច ធ្លាប់និយាយ ធ្លាប់លេង ជាមួយនឹងមាតុគ្រាម ក្នុងកាលពីដើម ។

៦-បើមិនរលឹករឿយៗ នូវហេតុដែលធ្លាប់សើច ធ្លាប់និយាយ ធ្លាប់លេងជាមួយនឹងមាតុគ្រាម ក្នុងកាលពីដើមទេ តែថា រមែង ឃើញនូវគហបតិ ឬគហបតិបុត្រ ដែលស្កប់ស្កល់ មូលមិត្ត បម្រើដោយកាមគុណទាំង ៥ ។

៧-បើមិនបានឃើញនូវគហបតី ឬគហបតិបុត្រ ដែលស្កប់-ស្កល់មូលមិត្ត បម្រើដោយកាមគុណទាំង ៥ ទេ តែថា ប្រព្រឹត្ត ព្រហ្មចរិយធម៌ ដើម្បីប្រាថ្នានូវទេពនិកាយណាមួយថា អញសុំឲ្យ បានជាទេវតា ទោះជាទេវតាណាមួយ ដោយសីលនេះផង ដោយ វត្តនេះផង ដោយតបធម៌នេះផង ដោយព្រហ្មចរិយធម៌ផង ។

បុគ្គលនោះ រមែងត្រេកអរនឹងធម៌នោះ រីករាយនឹងធម៌នោះ ដល់នូវសេចក្តីត្រេកអរចំពោះធម៌នោះ ។

ម្នាលព្រាហ្មណ៍ នេះឈ្មោះថា ដាច់ផង ធ្លុះផង ពពាលផង ពព្រុសផង នៃព្រហ្មចរិយធម៌ ម្នាលព្រាហ្មណ៍ បុគ្គលនេះ ហៅថា ប្រព្រឹត្តព្រហ្មចរិយធម៌មិនបរិសុទ្ធ ជាអ្នកប្រកបដោយមេថុនសំយោគ រមែងមិនរួចចាកជាតិ ជរា មរណៈ សោកៈ បរិទេវៈ ទុក្ខៈ ទោមនស្ស ឧបាយាសៈ តថាគតហៅថា មិនរួចចាកវដ្តទុក្ខឡើយ ។ (ចាកសុត្តន្តបិដក ភាគ៤៧ ទំព័រ១០១)

ភាពនៃសីលមានដាច់ជាដើម បណ្ឌិតគប្បីជ្រាបថា លោកសង្គ្រោះហើយ ដោយប្រភេទដែលប្រកបដោយហេតុ មានលាភជាដើមផង ដោយមេថុនសំយោគ ៧ ផង យ៉ាងនេះ ។

## វិស្សជ្ជនាបញ្ហាកម្ម ទី៧ (វោទាននៃសីល)

៧-កឹ វោទានន្តិ? *អ្វីជាគ្រឿងផូរផង់នៃសីល ?*

អខណ្ឌាទិភាវោ បន សព្វសោ សិក្ខាបទានំ អភេទេន, ភិន្នានញ្ច សប្បដិកម្មានំ បដិកម្មករណេន, សត្តវិធមេថុនសំយោគាភាវេន ច, អបរាយ ច "កោធោ ឧបនាហោ មក្ខោ បឡាសោ ឥស្សា មច្ឆរិយំ មាយា សាឋេយ្យំ ថម្ភោ សារម្ភោ មានោ អតិមានោ មទោ បមាទោ"តិអាទីនំ បាបធម្មានំ អនុប្បត្តិយា, អប្បិច្ឆតា-សន្តុដ្ឋិតាសល្លេខតាទីនញ្ច គុណានំ ឧប្បត្តិយា សង្គហិតោ។

*ឯភាពនៃសីលមិនដាច់ជាដើម លោកសង្គ្រោះហើយដោយកិរិយាមិនបែកធ្លាយនៃសិក្ខាបទទាំងឡាយ ដោយអាការៈទាំងពួង ១ ដោយកិរិយាធ្វើតបនូវសិក្ខាបទទាំងឡាយ ដែលបែកធ្លាយហើយ តែជាសិក្ខាបទមានការធ្វើតបបាន ១ ដោយការមិនមាននៃមេថុន-សំយោគ ៧ ផង ១ ដោយការមិនកើតឡើងដទៃទៀតនៃបាបធម៌ទាំងឡាយ មានដូច្នេះជាដើមគឺ* កោធៈ *(សេចក្តីក្រោធ)* ឧបនាហៈ *(ចូលទៅចងសេចក្តីក្រោធទុក)* មក្ខៈ *(លប់គុណគេ)* បឡាសៈ *(វាយឫកស្មើ)* ឥស្សា *(ប្រណែន)* មច្ឆរិយៈ *(កំណាញ់)* មាយា

*(បិទបាំងទោសខ្លួន) សាឋេយ្យៈ (អួតអាង) ថម្ភៈ (រឹងប្អឹង) សារម្ភៈ (ប្រណាំងប្រជែង) មានៈ (មានះ) អតិមានៈ (មើលងាយគេ) មទៈ (ស្រវឹង) បមាទៈ (ប្រហែសធ្វេស)ផង ១, ដោយកិរិយាកើតឡើងនៃគុណទាំងឡាយ មានភាពជាអ្នកប្រាថ្នាតិច និងភាពជាអ្នកមានសេចក្តីសន្តោស និងភាពជាអ្នកជុសខាត់នូវកិលេសជាដើមផង ១ ។*

*មែនពិត សីលទាំងឡាយណា មិនបែកធ្លាយហើយ ដើម្បីប្រយោជន៍ សូម្បីដល់លាកជាដើមក្តី សូម្បីបែកធ្លាយហើយព្រោះសេចក្តីប្រមាទជាទោស ត្រឡប់ធ្វើឡើងវិញក្តី ដែលមេថុនសំយោគទាំងឡាយ ឬថា ដែលបាបធម៌ទាំងឡាយ មានកោធៈនិងឧបនាហៈជាដើម បៀតបៀនមិនបានហើយក្តី សីលទាំងឡាយនោះលោកពោលថា មិនដាច់ មិនធ្លុះ មិនពពាល មិនពព្រុះដោយប្រការទាំងពួង ។ ម្យ៉ាងទៀត សីលទាំងឡាយនោះ ឈ្មោះថា* ***សីលអ្នកជា*** *ព្រោះកិរិយាធ្វើនូវភាពជាអ្នកជាផង ឈ្មោះថា ជាសីលដែលអ្នកប្រាជ្ញសរសើរហើយ ព្រោះវិញ្ញូជនទាំងឡាយសរសើរហើយផង ឈ្មោះថា ជា**សីលមិនប៉ះពាល់ហើយព្រោះតណ្ហា និងទិដ្ឋិទាំងឡាយ** មិនប៉ះពាល់ហើយផង ឈ្មោះថា* ***សីលប្រព្រឹត្តទៅហើយដើម្បីសមាធិ*** *ព្រោះញុំាងឧបចារសមាធិ ឬអប្បនាសមាធិ*

ឲ្យប្រព្រឹត្តទៅផង ។ ព្រោះហេតុនោះ គប្បីជ្រាបថា “ភាពនៃសីលមិនដាច់ជាដើមនេះ ឈ្មោះថាជាហេតុផូរផង់” របស់សីលទាំងនោះ។

<u>ដីកា</u> បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

ពាក្យថា ភុជិស្សភាវករណំ **(ធ្វើនូវភាពជាអ្នកជាផង)** ព្រោះដោះចាកភាពជាទាសៈរបស់តណ្ហា ដោយភាពជាឧបនិស្ស័យនៃវិវដ្ដៈ ។ លោកអាចារ្យពោលថា “**វិញ្ញូហិ បសត្ថត្តា**” ដូច្នេះ ព្រោះអរិយជនទាំងឡាយមិនជាប្រមាណ ។ សីលឈ្មោះថា **សមាធិ-សំវត្តនិកៈ** ព្រោះអត្ថថា មានការប្រព្រឹត្តិទៅព្រមដើម្បីសមាធិជាប្រយោជន៍, ឬប្រកបក្នុងការប្រព្រឹត្តទៅព្រមដើម្បីសមាធិ ។

ក្នុងគម្ពីរវិសុទ្ធិមគ្គ ៖

តំ បនេតំ ប៉ោធានំ ទ្វីហាការេហិ សម្បជ្ជតិ សីលវិបត្តិយា ច អាទីនវទស្សនេន, សីលសម្បត្តិយា ច អានិសំសទស្សនេន ។

ម្យ៉ាងទៀត សេចក្ដីផូរផង់នុ៎ះហ្នឹងឯង តែងសម្រេចដោយអាការៈពីរយ៉ាង គឺដោយការឃើញទោសក្នុងសីលវិបត្តិ ១ ដោយការឃើញអានិសង្សក្នុងសីលសម្បត្តិ ១ ។

*<u>ដីកា</u> បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖*

និប្ផាទេន សស្សសម្បត្តិ វិយ បដិបក្ខវិគមេន សីលសម្បទា, សា ច តត្ថ សតិ ទោសទស្សនេតិ អាហ "**សីលវិបត្តិយា ច អាទីនវទស្សនេន**"តិ ។

***សីលសម្បទា** រមែងមានបានព្រោះការប្រាសចាកទៅនៃធម៌ដែលជាបដិបក្ខៈ ដូចការដល់ព្រមនៃសំទូង រមែងមានបាន ព្រោះមិនមានពូជដែលធ្វើអន្តរាយ ដូច្នោះ, ក៏សីលសម្បទានោះ រមែងសម្រេចបាន កាលមានការឃើញទោសក្នុងសីលវិបត្តិនោះ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា "**សីលវិបត្តិយា ច អាទីនវទស្សនេន**" ដូច្នេះ ។*

និសម្មការីនំ បយោជនគរុកតាយ ទិដ្ឋគុណោយេវ សម្មាបដិបត្តីតិ វុត្តំ "**សីលសម្បត្តិយា ច អានិសំសទស្សនេន**"តិ ។

***សម្មាបដិបត្តិ** រមែងមានបាន ព្រោះបានឃើញគុណហើយប៉ុណ្ណោះ ព្រោះបុគ្គលអ្នកមានប្រក្រតីពិចារណាមុនហើយទើបធ្វើជាអ្នកធ្ងន់ក្នុងប្រយោជន៍ ព្រោះហេតុនោះ លោកអាចារ្យទើបពោលថា "**សីលសម្បត្តិយា ច អានិសំសទស្សនេន**" ដូច្នេះ ។*

## ទោសនៃសីលវិបត្តិ

*ក្នុងពីរយ៉ាងនោះ ឯទោសនៃសីលវិបត្តិ គប្បីជ្រាបតាមន័យនៃព្រះសូត្រមានពីរយ៉ាងនេះជាដើមថា ម្នាលភិក្ខុទាំងឡាយ ទោស ៥ ប្រការនេះ នៃសីលវិបត្តិ របស់បុគ្គលទ្រុស្តសីល ។ ម្យ៉ាងទៀត បុគ្គលទ្រុស្តសីល ព្រោះហេតុជាអ្នកទ្រុស្តសីល ទើបមិនជាទីស្រឡាញ់នៃទេវតា និងមនុស្សទាំងឡាយ ជាអ្នកមិនគួរដល់កិរិយាប្រៀនប្រដៅនៃសព្រហ្មចារីទាំងឡាយ ជាអ្នកដល់ហើយនូវសេចក្តីទុក្ខ ព្រោះកិរិយាតិះដៀលនូវភាពនៃខ្លួន ជាអ្នកទ្រុស្តសីលទាំងឡាយ ជាអ្នកក្តៅក្រហាយព្រោះសេចក្តីសរសើរ បុគ្គលអ្នកមានសីលទាំងឡាយ, ម្យ៉ាងទៀត ជាអ្នកមានសម្បុរអាក្រក់ ដូចជាសាជកដែលបុគ្គលត្បាញហើយដោយសំបកធ្មៃ ព្រោះភាពនៃខ្លួនជាអ្នកទ្រុស្តសីលនោះ,*

*ម្យ៉ាងទៀត ជនទាំងឡាយណាដល់នូវទិដ្ឋានុគតិ កាន់តាមបែបរបស់បុគ្គលទ្រុស្តសីលនោះ ជនទាំងនោះនឹងប្រសព្វទុក្ខ ព្រោះកិរិយានាំមកនូវទុក្ខក្នុងអបាយអស់កាលដ៏យូរ ជាបុគ្គលឥតតម្លៃ ព្រោះបុគ្គលនោះ បើទទួលនូវទេយ្យធម៌របស់ជនទាំងឡាយណា មិនធ្វើនូវទេយ្យធម៌របស់ជនទាំងនោះ ឲ្យមានផលច្រើន ជាបុគ្គលដែលគេជម្រះបានដោយក្រ ដូចជារណ្តៅលាមក ដែលរាប់មកយូរ*

ឆ្នាំណាស់ទៅហើយ, ជាអ្នកឋិតនៅខាងក្រៅស្មោះ ចាកហេតុទាំងពីរ ដូចជាកំណាត់ឧសដែលដុតនូវសាកសព, សូម្បីកាលបេ្តជ្ញានូវភាព នៃខ្លួនជាភិក្ខុ ក៏នៅតែមិនមែនភិក្ខុដដែល, ដូចលាដែលជាប់តាម ហ្វូងគោ ជាអ្នកមានសេចក្តីតក់ស្លុតជានិច្ច ដូចជាបុរសអ្នកមាន ពៀរទើងគ្នាសព្វកាល ជាអ្នកមិនគួរដល់ការនៅរួមគ្នា ដូចជាសាកសព ដែលស្លាប់ហើយ សូម្បីប្រកបហើយដោយគុណមានសុតៈជាដើម ក៏ជាអ្នកមិនគួរដល់ការបូជារបស់សព្រហ្មចារីទាំងឡាយ ដូចជាភ្លើង ក្នុងព្រៃស្មសាន ដែលមិនគួរដល់កិរិយាបូជានៃព្រាហ្មណ៍ទាំងឡាយ ជាអ្នកអភ័ព្វក្នុងការត្រាស់ដឹងនូវគុណវិសេស, ដូចជាមនុស្សខ្វាក់ ជាអ្នកអភ័ព្វក្នុងការឃើញរូប, ជាអ្នកអស់សង្ឃឹមក្នុងព្រះសទ្ធម្ម ដូចជាចណ្ឌាលកុមារ ដែលអស់សង្ឃឹមក្នុងរាជ្យសម្បត្តិ, សូម្បី សម្គាល់ថា អញបានសេចក្តីសុខហើយ ដូច្នេះ ក៏នៅតែទុក្ខពិតៗ ព្រោះភាពនៃខ្លួនមានចំណែកនៃសេចក្តីទុក្ខ ដែលទ្រង់សម្តែងហើយ ក្នុងអគ្គិក្ខន្ធបរិយាយសូត្រ ។

បណ្ឌិតគប្បីជ្រាបការឃើញទោស ក្នុងសីលវិបត្តិ ដោយការ ពិចារណា មានយ៉ាងនេះជាដើមថា ៖

អគ្គិក្ខន្ធាលិង្គនទុក្ខាធិកទុក្ខកដុកដលំ

អវិជហតោ កាមសុខំ សុខំ កុតោ ភិន្នសីលស្ស ។

សេចក្ដីសុខនឹងមានមកពីណា ដល់អ្នកដែលមានសីលបែក-ធ្លាយហើយ កាលមិនលះបង់នូវសេចក្ដីសុខក្នុងកាម មានផលក្ដៅផ្សា នាំមកនូវសេចក្ដីទុក្ខយ៉ាងក្រៃលែងជាងសេចក្ដីទុក្ខដែលកើតអំពីការប្រកៀកគំនរភ្លើង ។

អភិវាទនសាទិយនេ កឹ នាម សុខំ វិបន្នសីលស្ស
ទឡ្ហវាឡរជ្ជុឃំសនទុក្ខាធិកទុក្ខភាគិស្ស ។

សេចក្ដីសុខរបស់អ្នកមានសីលវិបត្តិហើយ មានចំណែកនៃសេចក្ដីទុក្ខដ៏ក្រៃលែងជាងសេចក្ដីទុក្ខ ដែលកើតអំពីការក្ដួតដោយខ្សែរោមទ្រាយដ៏មាំ ដូចម្ដេចនឹងមានក្នុងកិរិយាត្រេកអរចំពោះការថ្វាយបង្គំ ។

សទ្ធានមញ្ជលិកម្មសាទិយនេ កឹ សុខំ អសីលស្ស
សត្តិប្បហារទុក្ខាធិមត្តទុក្ខស្ស យំហេតុ ។

អ្នកមិនមានសីល ជាហេតុនៃសេចក្ដីទុក្ខ មាត្រាថា ក្រៃលែងជាងសេចក្ដីទុក្ខដែលកើតអំពីការប្រហារដោយលំពែង ដូចម្ដេចហ្ន៎ នឹងមានសេចក្ដីសុខក្នុងកិរិយាត្រេកអរចំពោះអញ្ជលីកម្មនៃអ្នកមានសទ្ធា ។

ចីវរបរិភោគសុខំ កឹ នាម អសំយតស្ស
យេន ចិរំ អនុភវិតព្វោ និរយេ ជលិតអយោបដ្ដសម្ផស្សោ។

អ្នកមិនសង្រួមហើយ គប្បីសោយការពាល់ត្រូវដែលកើតអំពីបន្ទះដែក ដែលឆេះហើយក្នុងនរកអស់កាលដ៏យូរ ដូចម្តេចនឹងមានសេចក្តីសុខអំពីការប្រើប្រាស់ចីវរ ។

មធុរោបិ បិណ្ឌចារោ ហលាហលវិសូបមោ អសីលស្ស
អាទិត្តា គិលិតព្វា អយោគុឡា យេន ចិររត្តំ ។

បិណ្ឌបាតដ៏ឆ្ងាញ់ ក៏ទុកដូចជាថ្នាំពិសដ៏ខ្លាំងក្លាដល់អ្នកមិនមានសីល ព្រោះដូចជាអ្នកគប្បីលេបដុំដែកដ៏ក្រហមអស់កាលដ៏យូរ ។

សុខសម្មតោបិ ទុក្ខោ អសីលិនោ មញ្ចបីឋបរិភោគោ
យំ ពាធិស្សន្តិ ចិរំ ជលិតអយោមញ្ចបីឋានិ ។

ការប្រើប្រាស់គ្រែនិងតាំង ដែលគេសន្មតថាជាសុខ ក៏ជាទុក្ខដល់អ្នកមិនមានសីល ព្រោះគេនឹងត្រូវទុក្ខ គឺគ្រែដែក និងតាំងដែកដែលភ្លើងឆេះហើយ បៀតបៀនអស់កាលដ៏យូរ ។

ទុស្សីលស្ស វិហារេ សទ្ធាទេយ្យម្ហិ កា និវាស រតិ
ជលិតេសុ និវសិតព្វំ យេន អយោកុម្ភិមជ្ឈេសុ ។

សេចក្តីត្រេកអរក្នុងការនៅក្នុងវិហារ ដែលគេឲ្យដោយសទ្ធា ដូចម្តេចនឹងមានដល់អ្នកទ្រុស្តសីល ព្រោះគេគប្បីនៅក្នុងពាក់កណ្តាលខ្ទះដែកដែលភ្លើងឆេះហើយ ។

សង្កស្សរសមាចារោ កសម្ពុជាតោ អវស្សុតោ ចាបោ

អន្ធោប្ចតីតិ ច យំ និន្ទន្តោ អាហ លោកគរុ ។
ធី ជីវិតំ អសញ្ញតស្ស តស្ស សមណជនវេសធារិស្ស
អស្សមណស្ស ឧបហតំ ខតមត្តានំ វហន្តស្ស ។

ព្រះពុទ្ធជាទីគោរពនៃលោក ទ្រង់តិះដៀលនូវបុគ្គលទ្រុស្តសីលណាថា អ្នកមានសមាចារប្រកបដោយសេចក្តីរង្កៀស អ្នកមានជាតិដ៏ស្មោកគ្រោកដូចជាសម្រាម អ្នកមានចិត្តទទឹកជោគដោយរាគៈ អ្នកមានចិត្តដ៏លាមក អ្នកស្អុយក្នុង ។ គួរតិះដៀលជីវិតរបស់បុគ្គលទ្រុស្តសីលនោះ អ្នកមិនមានប្រាជ្ញា អ្នកទ្រទ្រង់នូវភេទជាសមណៈ ក៏មិនជាសមណៈ អ្នកនាំខ្លួនដែលកិលេសជីកកំចាត់គុណឲ្យអស់ទៅ ។

គូថំ វិយ កុណបំ វិយ មណ្ឌនកាមា វិវជ្ជយន្តីធ
យំ នាម សីលវន្តោ សន្តោ កឹ ជីវិតំ តស្ស ។
សព្វភយេហិ អមុត្តោ មុត្តោ សព្វេហិ អធិគមសុខេហិ
សុបិហិតសគ្គទ្វារោ អបាយមគ្គំ សមារុឡ្ហោ ។

សប្បុរសទាំងឡាយ មានសីលក្នុងលោកនេះ តែងវៀរនូវបុគ្គលទ្រុស្តសីលណា ដូចអ្នកប្រាថ្នាដើម្បីស្អិតស្អាង វៀរស្រឡះនូវលាមក នូវសាកសព ជីវិតរបស់បុគ្គលទ្រុស្តសីលនោះ នឹងមានប្រយោជន៍អ្វី, ព្រោះមិនផុតចាកភ័យទាំងពួង តែងផុតហើយចាក

អធិគមសុខទាំងអស់ បិទទ្វារស្ថានសួគ៌ជិតស្និតហើយ មានតែចុះកាន់ផ្លូវអបាយ ។

ការុណាយ វត្ថុភូតោ ការុណិកជនស្ស ឆាម កោ អញ្ញោ ទុស្សីលសមោ ទុស្សី លតាយ ឥតិ ពហុវិធា ទោសាតិ ។ មនុស្សដទៃណា ដែលជាទីតាំងនៃសេចក្ដីករុណារបស់ជនអ្នកប្រកបដោយសេចក្ដីអាណិត ស្មើដោយបុគ្គលទ្រុស្តសីល ទោសនៃភាពជាអ្នកទ្រុស្តសីល មានច្រើនយ៉ាងដូច្នេះ ។

## អានិសង្សនៃសីលសម្បត្តិ

គប្បីជ្រាបការសម្ដែងអានិសង្សក្នុងសីលសម្បត្តិ ព្រោះផ្ទុយគ្នាពីបការៈដែលពោលហើយ ។

តស្ស ចាសាទិកំ ហោតិ បត្តចីវរធារណំ

បព្វជ្ជា សផលា តស្ស យស្ស សីលំ សុនិម្មលំ ។

ម្យ៉ាងទៀត សីលនៃភិក្ខុណា មានមន្ទិលអស់រលីងហើយ បរិសុទ្ធស្អាត ការទ្រទ្រង់បាត្រនិងចីវរនៃភិក្ខុនោះ រមែងនាំមកនូវសេចក្ដីជ្រះថ្លា បព្វជ្ជារបស់លោកក៏មានផលច្រើន ។

អត្តានុវាទាទិភយំ សុទ្ធសីលស្ស ភិក្ខុនោ

អន្ធការំ វិយ រវី ហទយំ នាវគាហតិ ។

*ភ័យមានអត្តានុវាទភ័យជាដើម តែងមិនធ្លាក់ចុះកាន់ហឫទ័យរបស់ភិក្ខុដែលមានសីលបរិសុទ្ធ ដូចជាព្រះអាទិត្យដែលមិនធ្លាក់ចុះកាន់ទីងងឹត ។*

សីលសម្បត្តិយា ភិក្ខុ សោភមានោ តបោវនេ
បភាសម្បត្តិយា ចន្ទោ គគនេ វិយ សោភតិ ។

*ភិក្ខុល្អក្នុងព្រៃគឺតបៈ ព្រោះបរិបូរណ៍ដោយសីល ដូចជាព្រះ-ចន្ទដែលល្អ ក្នុងស្រទាប់នៃមេឃ ព្រោះដល់ព្រមដោយរស្មី ។*

កាយគន្ធោបិ បាមោជ្ជំ សីលវន្តស្ស ភិក្ខុនោ
ករោតិ អបិ ទេវានំ សីលគន្ធេ កថាវ កា ។

*សូម្បីក្លិនកាយរបស់ភិក្ខុមានសីល តែងធ្វើសេចក្តីរីករាយដល់ទេវតាទាំងឡាយ នឹងពោលទៅថ្វីក្នុងក្លិននៃសីល ។*

សព្វេសំ គន្ធជាតានំ សម្បត្តឹ អភិភុយ្យតិ
អវិឃាតី ទិសា សព្វា សីលគន្ធោ បវាយតិ ។

*ក្លិនរបស់សីល តែងគ្របទូវសម្បត្តិនៃគន្ធជាតិទាំងឡាយទាំងពួងបាន តែងផ្សាយទៅកាន់ទិសទាំង ១០ ឥតទើសទាល់ ។*

អប្បកាបិ កតា ការា សីលវន្តេ មហប្ផលា
ហោន្តីតិ សីលវា ហោតិ បូជាសក្ការភាជនំ ។

សក្ការៈ ដែលទាយកធ្វើហើយ ក្នុងអ្នកមានសីល ឈ្មោះថា សូម្បីប្រមាណតិច ក៏មានផលច្រើន ព្រោះអ្នកមានសីល ជាភាជនៈសម្រាប់ទទួលគ្រឿងសក្ការៈបូជា ។

សីលវន្តំ ន ពាធន្តិ អាសវា ទិដ្ឋធម្មិកា
សម្បរាយិកទុក្ខានំ មូលំ ឧនតិ សីលវា ។

អាសវៈទាំងឡាយ ប្រព្រឹត្តទៅក្នុងបច្ចុប្បន្ន បៀតបៀនបុគ្គលមានសីលមិនបាន បុគ្គលមានសីលតែងជីករំលើងនូវឫសគល់នៃសេចក្ដីទុក្ខទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខ ។

យា មនុស្សេសុ សម្បត្តិ យា ច ទេវេសុ សម្បទា
ន សា សម្បន្នសីលស្ស ឥច្ឆតោ ហោតិ ទុល្លភា ។

សម្បត្តិណា ក្នុងមនុស្សលោក និងសម្បត្តិណាក្នុងទេវលោក សម្បត្តិនោះ កាលអ្នកមានសីលបរិបូរណ៍ប្រាថ្នាហើយ មិនជារបស់បានដោយក្រទេ ។

អច្ចន្តសន្តា បន យា អយំ និព្វានសម្បទា
មនោ សម្បន្នសីលស្ស តមេវ អនុធាវតិ ។

និព្វាននេះហ្នឹងឯង ដែលមានសេចក្ដីស្ងប់ក្នុងទីបំផុតក្រៃពេក ចិត្តរបស់អ្នកមានសីលបរិបូរណ៍ហើយ តែងស្ទុះទៅកាន់និព្វាន-សម្បត្តិនោះឯង ។

សព្ពសម្បត្តិមូលម្ហិ សីលម្ហិ ឥតិ បណ្ឌិតោ
អនេកាការវោការំ អានិសំសំ វិភាវយេតិ ។

*បណ្ឌិតគប្បីសម្តែងឲ្យច្បាស់នូវអានិសង្ស មានអាការៈ និងវោហារដ៏ច្រើនក្នុងសីល ជាឫសគល់នៃសម្បត្តិទាំងពួង ដូចពណ៌នាមកនេះ ។*

*ដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖*

**សម្បរាយិកទុក្ខានំ មូលំ** នាម ទុស្សីល្យំ ។

*ពាក្យថា* ***ឫសគល់នៃសេចក្តីទុក្ខទាំងឡាយ ដែលប្រព្រឹត្តទៅក្នុងលោកខាងមុខ*** *បានដល់ ភាពជាអ្នកទ្រុស្តសីល ។*

អត្តមតិក្កន្តំ អច្ចន្តំ, អច្ចន្តំ សន្តា **អច្ចន្តសន្តា** កិលេសបរិឡាហសង្ខាតទរថានំ អភាវេន សព្ពទា សន្តា ។

*មានទីបំផុតដែលកន្លងបានហើយ ឈ្មោះថា* ***អច្ចន្ត*** *(ទីបំផុត), ឈ្មោះថា* ***សន្តា*** *(ស្ងប់) គឺស្ងប់គ្រប់កាល ព្រោះមិនមានសេចក្តីខ្វល់ខ្វាយ ពោលគឺ* ***កិលេសបរិឡាហៈ*** *(សេចក្តីក្តៅក្រហាយគឺកិលេស) ។*

*ក្នុងគម្ពីរវិសុទ្ធិមគ្គ ៖*

ឯវញ្ហិ វិភាវយតោ សីលវិបត្តិតោ ឧព្វិជ្ជិត្វា សីលសម្បត្តិនិន្នំ មានសំ ហោតិ ។ តស្មា យថាវុត្តំ ឥមំ

សីលវិបត្តិយា អាទីនវំ ឥមញ្ច សីលសម្បត្តិយា អានិសំសំ ឱស្វា សព្វាទរេន សីលំ វោទាបេតព្វន្តិ ។

ព្រោះថា កាលចម្រើននូវសីលយ៉ាងនេះហើយ ចិត្តរមែងភ័យខ្លាចអំពីសីលវិបត្តិ, ហើយបង្អោនចូលទៅកាន់សីលសម្បត្តិ ។ ព្រោះហេតុនោះ បណ្ឌិតឃើញនូវទោសក្នុងសីលវិបត្តិនេះ និងក្នុងអានិសង្សក្នុងសីលសម្បត្តិនេះ ដែលពោលហើយ គប្បីញ៉ាំងសីលឲ្យផូរផង់ដោយអំពើសព្វគ្រប់ចុះ ។

<u>ដីកា</u> បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

**ឧព្វិជ្ជិត្វា**តិ ញាណុត្រាសេន ឧត្តសិត្វា ។

ពាក្យថា **ភ័យខ្លាច** គឺភិតភ័យ ដោយការភិតភ័យគឺញាណ ។

**វោទាបេតព្វន្តិ** វិសោធេតព្វំ ។

ពាក្យថា **គប្បីញ៉ាំងសីលឲ្យផូរផង់** គឺគប្បីធ្វើឲ្យបរិសុទ្ធ ។

បរិច្ឆេទទី ១ ឈ្មោះសីលនិទ្ទេស ចប់ ។

# ២-ធុតង្គនិទ្ទេស

ឥទានិ យេហិ អប្បិច្ឆតាសន្តុដ្ឋិតាទីហិ គុណេហិ វុត្តប្បការស្ស សីលស្ស វោទានំ ហោតិ, តេ គុណេ សម្បាទេតុំ យស្មា សមាទិន្នសីលេន យោគិនា ធុតង្គ-សមាទានំ កាតព្វំ ។ ឯវញ្ហិស្ស អប្បិច្ឆតាសន្តុដ្ឋិតា-សល្លេខបវិវេកាបចយវីរិយារម្ភសុភរតាទិគុណសលិលវិក្ខា-លិតមលំ សីលញ្ចេវ សុបរិសុទ្ធំ ភវិស្សតិ, វតានិ ច សម្បជ្ជិស្សន្តិ ។ ឥតិ អនវជ្ជសីលព្វតគុណបរិសុទ្ធសព្វ-សមាចារោ ចោរាណេ អរិយវំសត្តយេ បតិដ្ឋាយ ចតុត្ថ-ស្ស ភាវនារាមតាសង្ខាតស្ស អរិយវំសស្ស អធិគមារហោ ភវិស្សតិ ។ តស្មា ធុតង្គកថំ អារភិស្សាម ។

*សេចក្ដីផូរផង់នៃសីល មានបការៈដូចដែលយើងបានពោលហើយ រមែងមានដោយគុណទាំងឡាយ មានសេចក្ដីប្រាថ្នាតិច និងសេចក្ដីសន្ដោសជាដើមណា, ការសមាទានធុតង្គ ព្រះយោគីដែលសមាទានសីលហើយ ត្រូវតែធ្វើ ដើម្បីញ៉ាំងគុណទាំងនោះឲ្យសម្រេច, ព្រោះថា កាលបើយ៉ាងនេះ មានមន្ទិលលាងចេញហើយ*

ដោយទឹកគឺគុណ មានសេចក្តីប្រាថ្នាតិច និងសេចក្តីសន្តោស ភាពជាអ្នកជុះខាត់នូវកិលេស ការសន្សំសេចក្តីស្ងប់ស្ងាត់ ប្រារព្ធសេចក្តីព្យាយាម និងភាពជាអ្នកចិញ្ចឹមងាយជាដើម នឹងជាសីលបរិសុទ្ធស្អាតផង វត្តទាំងឡាយសម្រេចបានផង, អ្នកមានមារយាទទាំងពួងបរិសុទ្ធ ដោយគុណមានសីលនិងវត្ត មិនមានទោសដូច្នេះឯង តែងតាំងនៅហើយក្នុងប្រជុំបីនៃអរិយវង្ស ដែលមានមកហើយពីកាលមុនជាអ្នកគួរបាននូវអរិយវង្ស ពោលគឺភាពនៃសេចក្តីត្រេកអរក្នុងភាវនាជាគម្រប់ ៤, ព្រោះហេតុនោះឯង យើងនឹងប្រារព្ធនូវធុតង្គ-កថា ក្នុងកាលឥឡូវនេះ ។

## ធុតង្គ ១៣

សេចក្តីពិតធុតង្គទាំង ១៣ ព្រះមានព្រះភាគអនុញ្ញាតហើយដល់កុលបុត្រទាំងឡាយ ដែលមានអាមិស គឺកាមគុណក្នុងលោក លះបង់ស្រឡះ មិនអាឡោះអាល័យក្នុងកាយនិងជីវិត មានប្រាថ្នាដើម្បីញ៉ាំងសេចក្តីបដិបត្តិដ៏សមគួរឲ្យសម្រេច ។ ធុតង្គទាំង ១៣ នោះ គឺ

**១-បំសុកូលិកង្គៈ** អង្គនៃភិក្ខុអ្នកទ្រទ្រង់សំពត់បំសុកូលជាប្រក្រតី

២-តេចីវរិកង្គៈ អង្គនៃភិក្ខុអ្នកមានចីវរបីជាប្រក្រតី

៣-បិណ្ឌបាតិកង្គៈ អង្គនៃភិក្ខុអ្នកកាន់បិណ្ឌបាតជាប្រក្រតី

៤-សបទានចារិកង្គៈ អង្គនៃភិក្ខុអ្នកត្រាច់ទៅតាមលំដាប់ផ្ទះ ជាប្រក្រតី

៥-ឯកាសនិកង្គៈ អង្គនៃភិក្ខុអ្នកឆាន់លើអាសនៈមួយ ជាប្រក្រតី

៦-បត្តបិណ្ឌិកង្គៈ អង្គនៃភិក្ខុអ្នកឆាន់ក្នុងបាត្រជាប្រក្រតី

៧-ខលុបច្ឆាភត្តិកង្គៈ អង្គនៃភិក្ខុអ្នកមិនឆាន់ភត្តមក ខាងក្រោយជាប្រក្រតី

៨-អារញ្ញិកង្គៈ អង្គនៃភិក្ខុអ្នកនៅក្នុងព្រៃជាប្រក្រតី

៩-រុក្ខមូលិកង្គៈ អង្គនៃភិក្ខុអ្នកនៅទៀបគល់ឈើជាប្រក្រតី

១០-អព្ភោកាសិកង្គៈ អង្គនៃភិក្ខុអ្នកនៅក្នុងទីវាលជាប្រក្រតី

១១-សោសានិកង្គៈ អង្គនៃភិក្ខុអ្នកនៅក្នុងព្រៃស្មសាន ជាប្រក្រតី

១២-យថាសន្ថតិកង្គៈ អង្គនៃភិក្ខុអ្នកនៅលើអាសនៈ ដែលសង្ឃក្រាលហើយជាប្រក្រតី

*១៣-នេសជ្ជិកង្គ: អង្គនៃភិក្ខុអ្នកនៅដោយកិរិយាអង្គុយជាប្រក្រតី ។*

# ធុតង្គវិនិច្ឆ័យ

**អត្ថតោ លក្ខណាទីហិ សមាទានវិធានតោ**
**បភេទតោ ភេទតោ ច តស្ស តស្សានិសំសតោ ។**
**កុសលត្តិកតោ ចេវ ធុតាទីនំ វិភាគតោ**
**សមាសព្យាសតោ ចាបិ វិញ្ញាតព្វោ វិនិច្ឆយោ ។**

*សេចក្តីវិនិច្ឆ័យក្នុងធុតង្គទាំងនោះ គប្បីជ្រាបតាមសេចក្តីអធិប្បាយ តាមលក្ខណៈជាដើម តាមវិធីសមាទាន តាមប្រភេទ តាមសេចក្តីបែកធ្លាយ តាមអានិសង្សនៃធុតង្គនោះៗ តាមប្រមាណបីនៃកុសល តាមកិរិយាញែកនូវធម៌ជាគ្រឿងកំចាត់បង់នូវកិលេសជាដើម និងតាមសេចក្តីបំប្រួញ និងពិស្តារ ។*

# ១ វិនិច្ឆ័យតាមអត្ថ

## វិនិច្ឆ័យបំសុកូលិកង្គតាមអត្ថ

ក្នុងខនោះ គប្បីជ្រាបវិនិច្ឆ័យតាមសេចក្ដីមុន សំពត់ណា ដូចជាប្រឡាក់ហើយដោយអាចម៍ដី ដោយអត្ថថា ជាសំពត់ផ្សព្វផ្សាយទៅហើយក្រៃពេក ក្នុងទីទាំងឡាយនោះៗ ព្រោះភាពនៃសំពត់នោះ ស្ថិតនៅហើយលើអាចម៍ដីទាំងឡាយ បណ្ដាទីទាំងឡាយ មានផ្លូវនៃរថព្រៃស្មសាន និងគំនរសម្រាមជាដើម ទីណាមួយ ព្រោះហេតុដូច្នោះ ឈ្មោះថា **បំសុកូល** ។ ម្យ៉ាងទៀត សំពត់ណាដល់នូវភាពគួរខ្ពើម ដូចអាចម៍ដី ព្រោះហេតុដូច្នោះ សំពត់នោះ ឈ្មោះថា **បំសុកូល** ។ លោកពោលសេចក្ដីថា ដល់នូវភាពជាវត្ថុដែលគេគួរខ្ពើម ។ ការទ្រទ្រង់នូវសំពត់បំសុកូល មានអត្ថវិគ្រោះបានហើយយ៉ាងនេះ ឈ្មោះថា **បំសុកូល** ។ ការទ្រទ្រង់នូវសំពត់បំសុកូលជាប្រក្រតីនៃភិក្ខុនោះ ព្រោះហេតុដូច្នោះ ភិក្ខុនោះ ឈ្មោះថា **បំសុកូលិកោ** ។ អង្គនៃភិក្ខុអ្នកទ្រទ្រង់សំពត់បំសុកូលជាប្រក្រតីនោះ ដោយសមាទានណា រមែងមានពាក្យថា បំសុកូលិកង្គៈនេះ គប្បីជ្រាបថា ជាឈ្មោះនៃកិរិយាសមាទាននោះ ។

## វិនិច្ឆ័យតេចីវរិកង្គតាមអត្ថ

*តាមន័យនេះ ត្រៃចីវរ ពោលគឺសង្ឃាដិ ចីពរ និងស្បង់នៃភិក្ខុនោះជាប្រក្រតី ព្រោះហេតុដូច្នោះ ភិក្ខុនោះ ឈ្មោះថា អ្នកមានត្រៃចីវរជាប្រក្រតី ។ អង្គនៃភិក្ខុមានចីវរបីជាប្រក្រតី ឈ្មោះថា* ***តេចីវរិកង្គៈ*** *។*

## វិនិច្ឆ័យបិណ្ឌបាតិកង្គតាមអត្ថ

*ក៏ការធ្លាក់ចុះនៃដុំអាមិសទាំងឡាយ ពោលគឺចង្ហាន់ ហេតុដូច្នោះ ឈ្មោះថា* ***បិណ្ឌបាតៈ*** *។ អធិប្បាយថា កិរិយាធ្លាក់ចុះក្នុងបាត្រនៃបិណ្ឌៈទាំងឡាយ ដែលអ្នកដទៃឲ្យហើយ ។ ភិក្ខុឯណាស្វែងរកបិណ្ឌបាតនោះ កាលចូលទៅកាន់ត្រកូលនោះៗ ស្វែងរក ហេតុដូច្នោះ ភិក្ខុនោះ ឈ្មោះថា បិណ្ឌបាតិកៈ (អ្នកកាន់បិណ្ឌ-បាត) ។ មយ៉ាងទៀត កិរិយាត្រាច់ទៅដើម្បីដុំបាយជាវត្តនៃភិក្ខុនោះ ហេតុដូច្នោះ លោកឈ្មោះថា* ***បិណ្ឌបាតី*** *(អ្នកត្រាច់ទៅដើម្បីដុំបាយជាវត្ត) ។ ពាក្យថា* ***បតិតុំ*** *បានសេចក្ដីថា ត្រាច់ទៅ ។ បិណ្ឌបាតី ហ្នឹងឯង ឈ្មោះថា* ***បិណ្ឌបាតិកៈ*** *។ អង្គនៃភិក្ខុអ្នកកាន់បិណ្ឌបាត ឈ្មោះថា* ***បិណ្ឌបាតិកង្គៈ*** *។*

## វិនិច្ឆ័យសបទានចារិកង្គតាមអត្ថ

*កិរិយាដាច់ លោកហៅថា* ***ទានៈ*** *។ កិរិយាទៅប្រាសចាកកិរិយាដាច់ ឈ្មោះថា* ***អបទានៈ*** *(មិនដាច់) ។ អធិប្បាយថា កិរិយាមិនដាច់ ។ មួយអន្ទើដោយកិរិយាមិនដាច់ ឈ្មោះថា* ***សបទានៈ*** *ដាច់រឿយៗ ។ លោកពោលសេចក្តីថា លំដាប់ផ្ទះប្រាសហើយចាកការដាច់ (គឺផ្ទះជាប់តគ្នា) ។ ការត្រាច់ទៅតាមលំដាប់ផ្ទះជាប្រក្រតីនៃភិក្ខុនោះ ព្រោះហេតុនោះ លោកឈ្មោះថា* ***សបទានចារី*** *(អ្នកមានកិរិយាត្រាច់ទៅតាមលំដាប់ផ្ទះជាប្រក្រតី)។ ភិក្ខុអ្នកត្រាច់ទៅតាមលំដាប់ផ្ទះជាប្រក្រតីហ្នឹងឯង ឈ្មោះថា* ***សបទានចារិកៈ*** *។ អង្គនៃភិក្ខុអ្នកត្រាច់ទៅតាមលំដាប់ផ្ទះជាប្រក្រតីនោះ ឈ្មោះថា* ***សបទានចារិកង្គៈ*** *។*

## វិនិច្ឆ័យឯកាសនិកង្គតាមអត្ថ

*កិរិយាបរិភោគលើអាសនៈតែមួយ ឈ្មោះថា* ***ឯកាសនៈ*** *។ កិរិយាបរិភោគលើអាសនៈតែមួយជាប្រក្រតីនៃភិក្ខុនោះ ហេតុដូច្នោះ លោកឈ្មោះថា ឯកាសនិកៈ (កិរិយាបរិភោគលើអាសនៈ*

តែមួយនៃភិក្ខុ) ។ អង្គនៃកិរិយាបរិភោគលើអាសនៈមួយ ជាប្រក្រតីនៃភិក្ខុនោះ ឈ្មោះថា **ឯកាសនិកង្គៈ** ។

## វិនិច្ឆ័យបត្តបិណ្ឌិកង្គតាមអត្ថ

ដុំអាមិសក្នុងបាត្រតែមួយប៉ុណ្ណោះ ព្រោះហេតុ លោកឃាត់កាជនៈទីពីរ ឈ្មោះថា **បត្តបិណ្ឌ** (ដុំអាមិសក្នុងបាត្រតែមួយ) ។ ការទទួលដុំអាមិសក្នុងបាត្រ ដោយធ្វើសេចក្ដីសម្គាល់ថា ជាដុំអាមិសក្នុងបាត្រ ក្នុងវេលាទទួលដុំអាមិសក្នុងបាត្រ ក្នុងកាលឥឡូវនេះ ជាប្រក្រតីនៃភិក្ខុនោះ ព្រោះហេតុនោះ ភិក្ខុនោះ ឈ្មោះថា **បត្តបិណ្ឌិកៈ** (អ្នកធ្វើសេចក្ដីសម្គាល់ដុំអាមិសក្នុងបាត្រជាប្រក្រតី) ។ អង្គនៃបត្តបិណ្ឌិកភិក្ខុនោះ ឈ្មោះថា **បត្តបិណ្ឌិកង្គៈ** ។

## វិនិច្ឆ័យខលុបច្ឆាភត្តិកង្គតាមអត្ថ

សព្ទថា **ខលុ** ជានិបាតប្រើក្នុងសេចក្ដីបដិសេធន៍ ។ ភត្តដែលភិក្ខុហាមឃាត់ហើយទើបបានជាខាងក្រោយ ឈ្មោះថា **បច្ឆា-ភត្ត** ។ ការបរិភោគបច្ឆាភត្តនោះ ឈ្មោះថា **បច្ឆាភត្តភោជន** ។ ការបរិភោគបច្ឆាភត្តដោយធ្វើសេចក្ដីសម្គាល់ថាជាបច្ឆាភត្ត ក្នុងកិរិយា

*បរិភោគបច្ឆាភត្តនោះជាប្រក្រតីនៃភិក្ខុនោះ ព្រោះហេតុដូច្នោះ ភិក្ខុនោះ ឈ្មោះថា **បច្ឆាភត្តិក** ។ ភិក្ខុមិនជាអ្នកបរិភោគបច្ឆាភត្តជាប្រក្រតី ឈ្មោះថា **ខលុបច្ឆាភត្តិកៈ** ។ ពាក្យនេះ ជាឈ្មោះភោជនជាសំណល់ដែលទ្រង់ហាមឃាត់ហើយ ដោយអំណាចនៃការសមាទាន ។ តែក្នុងអដ្ឋកថាពោលថា សត្វបក្សីមួយបែប ឈ្មោះថា **ខលុ** សត្វបក្សីនោះ ពាំនូវផ្លែឈើដោយចំពុះ កាលបើផ្លែឈើនោះ របូតជ្រុះហើយ វាមិនស៊ីនូវផ្លែឈើដទៃទៀតឡើយ ភិក្ខុនេះក៏មានដំណើរប្រហែលនឹងសត្វបក្សីនោះដែរ ហេតុដូច្នោះ ភិក្ខុនោះ ឈ្មោះថា **ខលុបច្ឆាភត្តិកៈ** ។ អង្គនៃភិក្ខុនោះ ឈ្មោះថា **ខលុបច្ឆាភត្តិកង្គៈ** ។*

## វិនិច្ឆ័យអារញ្ញិកង្គតាមអត្ថ

*កិរិយានៅក្នុងព្រៃ ឈ្មោះថា **អារញ្ញិកៈ** ។ កិរិយានៅក្នុងព្រៃជាប្រក្រតីនៃភិក្ខុនោះ ហេតុដូច្នោះ ភិក្ខុនោះ ឈ្មោះថា **អារញ្ញិកៈ** ។ អង្គនៃភិក្ខុនោះ ឈ្មោះថា **អារញ្ញិកង្គៈ** ។*

## វិនិច្ឆ័យរុក្ខមូលិកង្គតាមអត្ថ

*ការនៅទៀបគល់ឈើ ឈ្មោះថា **រុក្ខមូលៈ** ។ ការនៅទៀបគល់ឈើនោះ ជាប្រក្រតីនៃភិក្ខុនោះ ហេតុដូច្នោះ ភិក្ខុនោះ ឈ្មោះថា **រុក្ខមូលិកៈ** ។ អង្គនៃរុក្ខមូលិកភិក្ខុ ឈ្មោះថា **រុក្ខមូលិកង្គៈ** ។*

*សូម្បីក្នុងអង្គនៃអព្ភោកាសិកៈ និងសោសានិកៈ ក៏មានន័យដូចនេះដែរ ។*

## វិនិច្ឆ័យយថាសន្ថតិកង្គតាមអត្ថ

*សេនាសនៈ ដែលគេក្រាលហើយយ៉ាងណា ឈ្មោះថា **យថាសន្ថតៈ** ។ ពាក្យនេះ ជាឈ្មោះនៃសេនាសនៈ ដែលភិក្ខុអ្នកចែកសេនាសនៈសម្តែងឲ្យជាដំបូង យ៉ាងនេះថា សេនាសនៈនេះត្រូវបានដល់អ្នក ។ កិរិយានៅលើសេនាសនៈដែលសង្ឃចាត់ហើយយ៉ាងណានោះ ជាប្រក្រតីនៃភិក្ខុនោះ ហេតុដូច្នោះ ភិក្ខុនោះ ឈ្មោះថា **យថាសន្ថតិកៈ** ។ អង្គនៃភិក្ខុនោះ ឈ្មោះថា **យថា-សន្ថតិកង្គៈ** ។*

## វិនិច្ឆ័យនេសជ្ជិកង្គតាមអត្ថ

កិរិយាហាមឃាត់ការដេក ហើយនៅដោយកិរិយាអង្គុយជាប្រក្រតីនៃភិក្ខុនោះ ហេតុដូច្នោះ ភិក្ខុនោះ ឈ្មោះថា **នេសជ្ជិកៈ** ។ អង្គនៃភិក្ខុនោះ ឈ្មោះថា **នេសជ្ជិកង្គៈ** ។

ក៏ហេតុអម្បាលនេះទាំងអស់ ឈ្មោះថា ជាអង្គនៃភិក្ខុអ្នកកំចាត់ ព្រោះលោកកំចាត់កិលេសចេញបាន ដោយការសមាទាននោះៗ និងឈ្មោះថា **ធុតង្គៈ** ព្រោះអង្គនៃគុណជាតិទាំងនោះ មានញាណដែលបានវោហារថា **ធុតៈ**, ព្រោះកំចាត់កិលេសចេញបាន។ម្យ៉ាងទៀត ក៏គុណជាតិអម្បាលនោះ ឈ្មោះថា ធុតៈ ព្រោះកំចាត់កិលេសជាសត្រូវ និងឈ្មោះថា ជាអង្គនៃខបដិបត្តិ ហេតុដូច្នោះ គុណជាតិទាំងនោះ ឈ្មោះថា ធុតង្គៈ ។ គប្បីជ្រាបវិនិច្ឆ័យតាមអត្ថក្នុងធុតង្គទាំងនោះ ត្រឹមប៉ុណ្ណេះចុះ ។

## ២ វិនិច្ឆ័យធុតង្គដោយលក្ខណៈជាដើម

សព្វានេវ បនេតានិ សមាទានចេតនាលក្ខណានិ ។ ក៏ធុតង្គទាំងអស់នេះឯង មានសមាទានចេតនាជាលក្ខណៈ ។ សមដូចពាក្យដែលព្រះអដ្ឋកថាពោលហើយថា ជនណាសមាទាន

ជននោះ ឈ្មោះថា បុគ្គល, បុគ្គលសមាទានដោយធម៌ណា ធម៌នោះគឺចិត្តនិងចេតសិក, ចេតនាជាហេតុសមាទានណា ចេតនានោះ ឈ្មោះថា **ធុតង្គ**, ហាមឃាត់នូវកិច្ចណា កិច្ចនោះ ឈ្មោះថា **វត្ថុ** ។

ដីកា សារត្ថទីបនី ភាគ១ ពន្យល់ថា ៖

បណ្តាបទទាំងនោះ ពាក្យថា **ដោយការសមាទាន** សេចក្តីថា ដោយចេតនាជាគ្រឿងសមាទាន បង្សុកូលិកង្គធុតង្គជាដើម ។ ភិក្ខុជាអ្នកកំចាត់កិលេស មានការជាប់ចិត្តក្នុងបច្ច័យជាដើម គឺឲ្យកម្រើក បានដល់ កំចាត់ដោយតទង្គប្បហាន នោះឈ្មោះថា អ្នកកំចាត់កិលេសហើយ ។ ភាវៈរបស់ភិក្ខុនោះ ឈ្មោះថា **ភាពនៃភិក្ខុកំចាត់កិលេសហើយ** ។ ព្រោះហេតុនោះ ភិក្ខុណា ឈ្មោះថាជា **អ្នកមានធុតៈ** ដោយអត្ថថា កំចាត់កិលេសទាំងឡាយដោយការសមាទានទាំងឡាយ ការសមាទានទាំងនោះរបស់ភិក្ខុនោះ ជាអង្គនៃការកំចាត់កិលេស ហេតុនោះ លោកពោលថា "អង្គរបស់ភិក្ខុអ្នកឈ្មោះថាកំចាត់" ។

ចេតនាជាហេតុសមាទាន, ចេតនាកម្មនោះ ជាលក្ខណៈរបស់ធុតង្គទាំងនេះ ហេតុនោះ ធុតង្គទាំងនេះ ឈ្មោះថា មានសមាទាន-

ចេតនាជាលក្ខណៈ, ឬធុតង្គទាំងនេះ គប្បីកំណត់ដោយអំណាចនៃសមាទានចេតនា ។ ក៏ធម៌ទាំងឡាយ សូម្បីប្រកបជាមួយចេតនា និងឈ្មោះថា ចេតនាជាគ្រឿងបរិហារ ព្រោះមានសម្បយុត្តធម៌ជាមូល ចាត់ជាធុតង្គនោះឯង ។ ដោយពាក្យមានជាដើមថា **អ្នកសមាទាននោះ បានដល់ បុគ្គល** លោកសម្តែងដល់អ្នកធ្វើ និងការធ្វើក្នុងការសមាទានធុតង្គ និងកិរិយាកម្ម និងការឲ្យប្រព្រឹត្តដោយភាពជាបទអាចសមាទានធុតង្គ ។ អ្នកធ្វើនិងការធ្វើក្នុងការសមាទានធុតង្គនោះ ដឹងបានងាយ ។ តែពោលដោយសេចក្តីព្រោះលោកពោលថា **ធម៌ជាគ្រឿងសមាទាន**ទើបសម្រេច សូម្បីកិរិយាសមាទានគឺកាយបយោគនិងវចីបយោគ ដែលប្រព្រឹត្តទៅដោយន័យមានជាដើមថា "ខ្ញុំព្រះករុណាហាមឃាត់គហបតីចីវរ" ។

ដោយពាក្យថា **សមាទានចេតនាជាធុតង្គ** នេះលោកសម្តែងកម្មដែលគប្បីសមាទាន ។ ក៏សូម្បីចេតនាក្នុងការប្រជុំនៃធម៌គឺចិត្តនិងចេតសិក ដែលត្រាស់ថា "ធម៌ជាគ្រឿងសមាទាន" សម្រេចហើយមិនមែនឬ ។ ចេតនានោះឯង គប្បីជាការធ្វើដោយអត្ថថា គប្បីសមាទានបានយ៉ាងដូចម្តេចហ្ន៎ ។ វាទៈនេះមិនខុសទេ ។

ក៏ដោយពាក្យថា **ធុតង្គ** នេះ កាលពោលដោយសាមញ្ញក្នុងទីនេះ ព្រះមានព្រះភាគ ទ្រង់បំណាងដល់ចេតនាដែលមានការសមាទានសន្តោសក្នុងបច្ច័យជាសភាវៈ ដោយពាក្យជាដើមថា "ជារបស់ចាស់ជាវង្សរបស់ព្រះអរិយទាំងឡាយ មានព្រះពុទ្ធជាម្ចាស់ ព្រះនាមថាអនាទិជាដើម" ព្រោះហេតុដូច្នោះ លោកទើបពោលថា ធុតង្គដែលមិនសម្រេចក្នុងខាងដើម កិច្ចកាន់យកដោយភាពដូចគ្នា ដោយភាពជាធុតង្គដែលគួរសមាទានហើយ សមាទានចេតនាដែលប្រព្រឹត្តទៅក្នុងសន្តានរបស់ខ្លួន ។ ក៏ចេតនាជាហេតុសូម្បីនេះណា និងចេតនាជាគ្រឿងបរិហារ មានចេតនាដែលជាហេតុនោះជាមូល ចាត់ជាធុតង្គរបស់ព្រះយោគាវចរទាំងនោះ ។ ពិតមែន ចេតនាសូម្បីឈ្មោះថាជាអរិយវង្សចាស់ ព្រោះចូលទៅដល់ភាពស្មើគ្នាជាមួយអរិយវង្សរមែងសម្រេចថាជាហេតុធ្វើ ព្រោះបំណាងដល់ភាពវិសេសនៃបុគ្គលនោះៗ ព្រោះហេតុនោះ សេចក្តីប្រាថ្នាត្រាច់ប្រព្រឹត្តទៅហើយ ព្រោះមិនមានវោហារថា សត្វអ្នកធ្វើ និងភាពស្មើគ្នា ដែលផុតចាកគុណវិសេស ។

ដោយពាក្យថា **ហាមឃាត់កិច្ចណា កិច្ចនោះ ឈ្មោះថា វត្ថុ** នេះ លោកសំដែងដល់ការដែលគហបតីទានចីវរជាដើម ប្រព្រឹត្តទៅក្នុងធុតង្គ ។ ក៏របស់ដែលហាមនោះ លោកហៅថា "វត្ថុ" ព្រោះជាការណ៍ប្រព្រឹត្តទៅក្នុងធុតង្គ ឬព្រោះជាអារម្មណ៍នៃតណ្ហា ។ ក៏ដោយពាក្យនេះ លោកសំដែងថា "ប្រយោជន៍គឺការហាមគហបតីទានចីវរដែលហាមនោះឯងជាធុតង្គ ប្រយោជន៍គឺការសេពវត្ថុដែលអនុញ្ញាតមិនមែនជាធុតង្គឡើយ" ។

ក្នុង<u>គម្ពីរ</u>វិសុទ្ធិមគ្គ :

សព្វានេវ ច លោលុប្បវិទ្ធំសនរសានិ, និល្លោលុប្បភាវបច្ចុបដ្ឋានានិ អប្បិច្ឆតាទិអរិយធម្មបទដ្ឋានានិ ។ ម្យ៉ាងទៀត ធុតង្គទាំងអស់នោះឯង មានកិរិយាកំចាត់បង់នូវសេចក្តីល្មោភជាកិច្ច មានភាវៈនៃសេចក្តីមិនល្មោភជាផល មានធម៌ដ៏ប្រសើរ មានភាពនៃបុគ្គលមានសេចក្តីប្រាថ្នាតិចជាដើមជាទីតាំង។

វិនិច្ឆ័យក្នុងធុតង្គទាំងនោះ គប្បីជ្រាបដោយកិច្ចទាំងឡាយមានលក្ខណជាដើមដូចពោលមកនេះ ។

<u>ដីកា</u> សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

កិត្តិរមែងល្មោភយ៉ាងក្រៃលែង គឺរមែងចាប់ប្រកាន់នូវរូបជា-

ដើម ដោយអំណាចតណ្ហាជាហេតុ ភិក្ខុនោះឈ្មោះថា អ្នកល្មោភ ។ ភាវៈរបស់ភិក្ខុអ្នកល្មោភនោះ ឈ្មោះថា **ភាពជាអ្នកល្មោភ** គឺការត្រាច់ទៅនៃតណ្ហា ។ ធុតង្គទាំងឡាយមានការកំចាត់សេចក្ដីល្មោភនោះជាកិច្ច ។ ព្រោះហេតុនោះឯង ប្រយោជន៍គឺការហាមសេចក្ដីល្មោភនោះ រមែងញុំាងធុតង្គនោះឲ្យប្រាកដតាមសភាព ដល់អ្នកប្រាថ្នាតិចជាដើម ពោលគឺមិនមានសេចក្ដីល្មោភ ។ ធម៌មានសេចក្ដីប្រាថ្នាតិចជាដើម ដែលជារបស់ប្រសើរ ជាបទដ្ឋាននៃធុតង្គទាំងនេះ ដោយភាពជាអារម្មណ៍ដែលគួរសមាទាន ហេតុនោះ ធុតង្គទាំងនេះ **មានអរិយធម៌ មានសេចក្ដីប្រាថ្នាតិចជាដើម ជាបទដ្ឋាន ។**

## ៣ វិធីសមាទានធុតង្គ

ក៏វិនិច្ឆ័យក្នុងអាការៈ ៥ យ៉ាង មានវិធីសមាទានជាដើម គប្បីជ្រាបដូចតទៅ ។ ធុតង្គទាំងអស់ កាលព្រះមានព្រះភាគទ្រង់គង់ធរមាននៅ គប្បីសមាទានក្នុងសំណាក់នៃព្រះមានព្រះ-ភាគពិត, កាលព្រះអង្គទ្រង់បរិនិព្វានហើយ គប្បីសមាទានក្នុងសំណាក់នៃព្រះមហាសាវក, កាលព្រះមហាសាវកនោះមិនមានទេ

គប្បីសមាទានក្នុងសំណាក់នៃព្រះខីណាស្រេព, កាលព្រះខីណា-ស្រេពមិនមានទេ គប្បីសមាទានក្នុងសំណាក់នៃព្រះអនាគាមិ, កាលព្រះអនាគាមិមិនមានទេ គប្បីសមាទានក្នុងសំណាក់នៃព្រះ-សកទាគាមិ, កាលព្រះសកទាគាមិមិនមានទេ គប្បីសមាទានក្នុងសំណាក់នៃព្រះសោតាបន្នៈ, កាលព្រះសោតាបន្នៈមិនមានទេ គប្បីសមាទានក្នុងសំណាក់នៃភិក្ខុអ្នកទ្រទ្រង់បិដកបី, កាលភិក្ខុអ្នកទ្រទ្រង់បិដកបីមិនមានទេ គប្បីសមាទានក្នុងសំណាក់នៃភិក្ខុអ្នកទ្រទ្រង់បិដកពីរ, កាលភិក្ខុទ្រទ្រង់បិដកពីរមិនមានទេ គប្បីសមា-ទានក្នុងសំណាក់នៃភិក្ខុអ្នកទ្រទ្រង់នូវបិដកមួយ, កាលភិក្ខុអ្នកទ្រទ្រង់បិដកមួយមិនមានទេ គប្បីសមាទានក្នុងសំណាក់នៃភិក្ខុអ្នកទ្រទ្រង់សង្គីតិកៈមួយ, កាលភិក្ខុអ្នកទ្រទ្រង់សង្គីតិកៈមួយមិនមានទេ គប្បីសមាទានក្នុងសំណាក់នៃព្រះអដ្ឋកថាចារ្យ, កាលព្រះអដ្ឋ-កថាចារ្យមិនមានទេ គប្បីសមាទានក្នុងសំណាក់នៃភិក្ខុអ្នកទ្រទ្រង់នូវធុតង្គ, កាលបើភិក្ខុអ្នកទ្រទ្រង់នូវធុតង្គនោះមិនមានទេ គប្បីបោសនូវលាននៃព្រះចេតិយ ហើយអង្គុយច្រហោង សមាទានហាក់ដូចជាកាលពោលក្នុងសំណាក់នៃព្រះសម្មាសម្ពុទ្ធចុះ ។

មួយទៀត សូម្បីកិរិយាសមាទានដោយខ្លួនឯងក៏គួរដែរ ។ ក៏ក្នុងកិរិយាសមាទានដោយខ្លួនឯងនេះ គប្បីសម្តែងរឿងព្រះថេរៈពីររូបជាបងប្អូន ក្នុងចេតិយបព៌ត ព្រះថេរៈជាបង លោកមានសេចក្តីប្រាថ្នាតិច ព្រោះរក្សាធុតង្គ នេះជារឿងសាធារណៈពិត ។

ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ពាក្យមានជាដើមថា "ក្នុងសំណាក់ព្រះមានព្រះភាគ" លោកពោលទុក ព្រោះធុតង្គទាំងឡាយសូម្បីដែលសមាទានក្នុងសំណាក់របស់ព្រះសម្ពុទ្ធ ប្រកាសការបែកខ្ញែកនៃអកុសលធម៌ ការសៅហ្មងតាមសភាវៈជាដើម មិនមានការកម្រើក ។ ពាក្យថា **ភិក្ខុអ្នកទ្រទ្រង់សង្គីតិកៈមួយ** សេចក្តីថា របស់ភិក្ខុអ្នកបួសទ្រទ្រង់និកាយមួយ ។ ពាក្យថា **ព្រះអដ្ឋកថាចារ្យ** សេចក្តីថា របស់ភិក្ខុអ្នកបួសដល់ភាពជាព្រះអដ្ឋកថាចារ្យ ដោយភាពជាអ្នកស្ទាត់ជំនាញព្រមដោយគុណវិសេសនោះ ។ សូម្បីខ្លួនឯង ក៏គួរនឹងសមាទាន ដោយភាពជាអ្នកប្រាថ្នាតិចក្នុងធុតង្គ ទាំងដែលនឹងបានព្រះថេរៈតាមដែលពោល ។

ពាក្យថា **កំឯក្នុងការសមាទានដោយខ្លួនឯង** នេះ សេចក្តីថា សូម្បីកាលព្រះថេរៈមានព្រះទីណាស្រេចជាដើម មានទូវក្នុងការបំពេញបន្ថែមនៃការសមាទានធុតង្គរបស់ខ្លួនឯង ។

ដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

ពាក្យថា **រឿងភាពជាអ្នកប្រាថ្នាតិចក្នុងធុតង្គរបស់ព្រះថេរៈជាបង** បានដល់ រឿងដែលមកហើយយ៉ាងនេះថា មានរឿងព្រះ-ថេរៈនោះជានេសជ្ជិកៈ, អ្នកណាៗ ក៏មិនដឹងភាពដែលលោកនោះជានេសជ្ជិកៈនោះ ។ ក្នុងថ្ងៃមួយជាខាងក្រោយមក ក្នុងពេលកណ្តាលយប់ ព្រះថេរៈប្អូនក្រៅនេះ ឃើញលោកអង្គុយលើគ្រែសិង ដោយពន្លឺផ្លេកបន្ទោរ ទើបសួរថា "នេះអ្វីលោកម្ចាស់ដ៏ចម្រើន លោកម្ចាស់ជានេសជ្ជិកៈឬ"។ ព្រះថេរៈ(ជាបង) ព្រោះភាពជាអ្នកប្រាថ្នាតិចក្នុងធុតង្គ ទើបសិងចុះក្នុងទីនោះភ្លាមតែម្តង ហើយសមាទាន (ថ្មី) ក្នុងខាងក្រោយ ដូច្នេះ ។

ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ពាក្យថា **រឿង** សេចក្តីថា រឿងការសិងភ្លាមៗ ដើម្បីបិទបាំងធុតង្គ ហើយសមាទានដោយខ្លួនឯងជាខាងក្រោយ របស់ព្រះថេរៈ ១ រូប អ្នកកាន់នេសជ្ជិកង្គធុតង្គជាដើម ដែលទ្រង់អនុញ្ញាតទុក សម្រាប់

*ភិក្ខុដទៃ ព្រោះសេចក្តីប្រាថ្នាតិចក្នុងធុតង្គ ត្រូវព្រះថេរៈប្អូនឃើញលោកអង្គុយនៅលើទីសិង ដោយពន្លឺផ្ទេកបន្ទោរ ក្នុងពេលកណ្តាលរាត្រី សួរថា "លោកម្ចាស់ កាន់នេសជ្ជិកង្គធុតង្គឬហ្ន៎" ។*

*គម្ពីរវិសុទ្ធិមគ្គ ពណ៌នាវិធីសមាទានជាដើមទៀតថា ៖*

*ឥឡូវនេះ យើងនឹងពណ៌នានូវវិធីសមាទាន ប្រភេទការបែកធ្លាយ និងអានិសង្សទាំងឡាយនៃធុតង្គមួយៗ ។*

## ៣.១_ពោលដោយបង្សុកូលិកង្គៈ

*បង្សុកូលិកង្គៈ មានពាក្យសមាទានថា* **"គហបតិទានចីវរំ បដិក្ខិបាមិ** *: ខ្ញុំឃាត់ចីវរដែលគហបតីប្រគេនហើយ",* **"បំសុកូលិកង្គំ សមាទិយាមិ** *: ខ្ញុំសមាទាននូវបំសុកូលិកង្គៈ", ពាក្យទាំងពីរនេះ ព្រះយោគីសមាទានតាមពាក្យណាមួយក៏បាន ។ នេះជាការសមា-ទាន ក្នុងបំសុកូលិកង្គៈនេះពិត ។*

*ក៏ព្រះយោគីនោះ មានធុតង្គសមាទានហើយយ៉ាងនេះ គប្បីកាន់យកចីវរណាមួយ ក្នុងចីវរទាំងនោះ គឺ*

សំពត់ដែលធ្លាក់ក្នុងព្រៃស្មសាន ១ សំពត់ដែលធ្លាក់ចុះក្បែរពានផ្សារ ១ សំពត់ដែលចោលក្បែរពោងរថ ១ សំពត់ដែលចោលលើគំនរសម្រាម ១ សំពត់ដែលជូតមន្ទិលគភ៌ ១ សំពត់ជូតទឹកអ្នកជម្ងឺហើយចោល ១ សំពត់ដែលចោលក្បែរកំពង់ទឹក ១ សំពត់ដែលគេទៅមិនត្រឡប់វិញ ១ សំពត់ដែលភ្លើងឆេះ ១ សំពត់ដែលគោទំពា ១ សំពត់ដែលកណ្ដៀរកោ ១ សំពត់ដែលកណ្ដុរកាត់ ១ សំពត់ដែលធ្លុះចំកណ្ដាល ១ សំពត់ដែលរេចជាយ ១ សំពត់នាំមកចាកទង់ ១ សំពត់រុំជុំបូក ១ សំពត់ជារបស់សមណៈ ១ សំពត់ធ្លាក់ក្នុងទឹកអភិសេក ១ សំពត់ដែលសម្រេចដោយឫទ្ធិ ១ សំពត់ធ្លាក់ក្បែរផ្លូវ ១ សំពត់ដែលខ្យល់ក្ដួចមក ១ សំពត់ដែលទេវតាឲ្យ ១ សំពត់ដែលរលកទឹកសមុទ្របន្សាត់ទៅលើគោក ១, ហើយហែកចោលកន្លែងដែលទុព្វល បោកលាងកន្លែងដែលមាំមួន ធ្វើឲ្យជាចីវរ ផ្លាស់គហបតីចីវរចាស់ចេញ ហើយប្រើប្រាស់ចុះ ។

## អធិប្បាយបង្សុកូលចីវរ

*ក្នុងសំពត់ទាំងនោះ ពាក្យថា **សោសានិកៈ** បានសេចក្ដីថា សំពត់ធ្លាក់ចុះក្នុងព្រៃស្មសាន ។ ពាក្យថា **បាបណិកៈ** បានសេចក្ដីថា សំពត់ដែលធ្លាក់ចុះក្បែរទ្វារនៃរានផ្សារ ។ ពាក្យថា **រថិយចោឡៈ** បានសេចក្ដីថា សំពត់ដែលបុគ្គលអ្នកត្រូវការដោយបុណ្យ បោលតាមចន្លោះបង្អួចទៅត្រង់ផ្លូវរថ ។ ពាក្យថា **សង្ការចោឡៈ** បានសេចក្ដីថា សំពត់ដែលគេបោលក្នុងទីនៃគំនរសម្រាម ។ ពាក្យថា **សោត្ថិយៈ** បានសេចក្ដីថា សំពត់ដែលគេជូតមន្ទិលគភ៌ហើយបោល ។ បានឮថា មាតានៃតិស្សៈអាមាត្យប្រើគេឲ្យជូតនូវមន្ទិលគភ៌ ដោយសំពត់មានតម្លៃមួយសែនហើយឲ្យបោលទៀបផ្លូវជាទីទៅកាន់វិហារឈ្មោះតាលវេឡិ ដោយគំនិតថា ភិក្ខុអ្នកប្រព្រឹត្តបំសុកូលនឹងកាន់យក ។ ភិក្ខុទាំងឡាយកាន់យកដើម្បីប៉ះសំពត់ចាស់ ។ ជនទាំងឡាយ ដែលពេទ្យចាប់ខ្មោចទាំងឡាយឲ្យងូតទឹកព្រមទាំងក្បាល ហើយបោលទៅ ដោយសម្គាល់ថា សំពត់កាឡកណ្ណីដូច្នេះ ដោយចីវរណា ចីវរនោះឈ្មោះថា **នហានចោឡៈ** ។ កំណាត់សំពត់ដែលគេបោលហើយ*

ត្រង់កំពង់ទឹកសម្រាប់ផ្ងូតឈ្មោះតិត្ថចោឡៈ ។ មនុស្សទាំងឡាយទៅកាន់ព្រៃស្មសានហើយត្រឡប់មកវិញ ផ្ងូតទឹកហើយបោលទៅនូវសំពត់ណា សំពត់នោះ ឈ្មោះថា **គតប្បច្ចាគតៈ** ។ ពាក្យថា **អគ្គិទឌ្ឍៈ** បានសេចក្ដីថា សំពត់មានកន្លែងដែលភ្លើងឆេះហើយ ។ ព្រោះថា មនុស្សទាំងឡាយ តែងបោលនូវសំពត់នោះ ។ សំពត់ទាំងឡាយដែលគោទំពាជាដើម ជាសំពត់ប្រាកដដែរ ។ មែនពិត មនុស្សទាំងឡាយកាលឡើងកាន់នាវា តែងចងទង់ហើយទើបចុះទៅ ។ កាលពួកគេមិនឃើញហើយកាន់យកនូវសំពត់នោះ ទើបគួរ ។ សូម្បីសំពត់ណា ដែលគេចងទុកហើយក្នុងទីចម្បាំង កាលសេនាទាំងពីរពួកទៅហើយ កាន់យកសំពត់នោះ ក៏គួរ ។ ពាក្យថា **ថូបចីវរ** បានសេចក្ដីថា សំពត់ដែលគេរុំព័ទ្ធដំបូក ហើយធ្វើនូវពលីកម្ម ។ ចីវររបស់ភិក្ខុ ឈ្មោះថា **សមណចីវរ** ។ ចីវរដែលគេបោលនៅកន្លែងអភិសេកនៃស្ដេច ឈ្មោះថា **អភិសេកៈ** ។ ចីវររបស់ឯហិភិក្ខុ ឈ្មោះថា **ឥទ្ធិមយៈ** ។ ពាក្យថា **បន្ថិកៈ** បានសេចក្ដីថា សំពត់ដែលជ្រុះដោយភ្លេចស្មារតី សំពត់នោះគប្បីរក្សាទុកបន្តិចសិនហើយសឹមកាន់យក ។ ពាក្យថា **វាតាហដៈ** បានសេចក្ដីថា សំពត់ដែលខ្យល់បោកបក់ឲ្យធ្លាក់ចុះ

ក្នុងទីឆ្ងាយ ។ ក៏កិរិយាដែលភិក្ខុកាលមិនឃើញនូវជនជាម្ចាស់ទាំងឡាយហើយ កាន់យកនូវសំពត់នោះរមែងគួរ ។ ពាក្យថា **ទេវទត្តិយៈ** បានសេចក្តីថា សំពត់ដែលទេវតាទាំងឡាយឲ្យហើយ ដូចដែលប្រគេនដល់ព្រះអនុរុទ្ធត្ថេរ ។ ពាក្យថា **សាមុទ្ទិយៈ** បានសេចក្តីថា សំពត់ដែលរលកសមុទ្រផាត់ទៅលើគោក ។

## ប្រភេទនៃបង្សុកូលចីវរ

ក៏សំពត់ណា ដែលទាយកប្រគេនហើយដោយពាក្យថា យើងប្រគេនសង្ឃ ឬត្រាច់ទៅដើម្បីសូមកំណាត់សំពត់ ហើយបាន សំពត់នោះមិនមែនជាបំសុកូលទេ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងភិក្ខុទត្តិយៈតទៅ ។ ចីវរណា ដែលភិក្ខុអ្នកចែកចីវរ ឲ្យកាន់យកតាមលំដាប់វស្សា ឬចីវរសម្រាប់សេនាសនៈ ចីវរនោះ មិនឈ្មោះថា បំសុកូលទេ, ចីវរដែលភិក្ខុអ្នកចែកចីវរ មិនឲ្យហើយកាន់យក ទើបឈ្មោះថា បំសុកូល ។ សូម្បីសំពត់ទាំងឡាយនោះ សំពត់ណាដែលទាយកទាំងឡាយប្រគេនទៀបជើងនៃភិក្ខុ រួចហើយភិក្ខុនោះ ប្រគេនក្នុងដៃនៃភិក្ខុអ្នកទ្រទ្រង់សំពត់បង្សុកូល សំពត់នោះ ឈ្មោះថា បរិសុទ្ធដោយ

ចំណែកមួយ ។ សំពត់ណា ដែលទាយកតម្កល់ទៀបជើងនៃភិក្ខុ, សូម្បីភិក្ខុនោះ ប្រគេនដូចយ៉ាងនោះ សំពត់នោះ ឈ្មោះថា បរិសុទ្ធទាំងពីរចំណែក ។ សំពត់ណាដែលភិក្ខុបាន ព្រោះទាយក ប្រគេនតម្កល់ទុកក្នុងដៃហើយ លោកក៏ដាក់ទុកក្នុងដៃដែរ សំពត់ នោះ មិនឈ្មោះថា ចីវរដ៏ឧក្រិដ្ឋទេ ។ ចីវរដែលភិក្ខុបង្សុកូល ចូលចិត្តនូវចំណែកនៃសំពត់បង្សុកូលនេះដូច្នេះ គប្បីប្រើប្រាស់ ចុះ ។ នេះជាវិធានក្នុងបំសុកូលិកង្គៈនោះ ។

## ប្រភេទនៃបង្សុកូលិកង្គធុតង្គ

ក៏គប្បីជ្រាបប្រភេទ ដូចតទៅនេះ ។ ភិក្ខុអ្នកប្រព្រឹត្ត បង្សុកូល មាន ៣ ពួក គឺ បង្សុកូលដ៏ឧក្រិដ្ឋ ១ បង្សុកូល យ៉ាងកណ្តាល ១ បង្សុកូលយ៉ាងមុទុ (ទន់ខ្សោយ) ១ ។ ក្នុង ៣ ពួកនោះ ភិក្ខុដែលកាន់យកសំពត់ដែលធ្លាក់ចុះក្នុងព្រៃស្មសាន តែម្យ៉ាង ឈ្មោះថា អ្នកប្រព្រឹត្តឧក្រិដ្ឋ ។ ភិក្ខុកាន់យកសំពត់ដែល ទាយកតម្កល់ទុក ដោយគិតថា បព្វជិតនឹងកាន់យកដូច្នេះ ឈ្មោះ ថាប្រព្រឹត្តយ៉ាងកណ្តាល ។ ភិក្ខុកាន់យកសំពត់ដែលទាយក តម្កល់ទុកប្រគេនទៀបជើង ឈ្មោះថា ប្រព្រឹត្តយ៉ាងទន់ខ្សោយ ។

## ការបែកធ្លាយនៃបង្សុកូលិកង្គធុតង្គៈ

*ក្នុងខណៈដែលភិក្ខុអ្នកកាន់ធុតង្គ ៣ ពួកនោះ ពួកណាមួយ ត្រេកអរចំពោះសំពត់ដែលគ្រហស្ថទាំងឡាយ ប្រគេនហើយ ដោយសេចក្ដីពេញចិត្ត ដោយបំណងរបស់ខ្លួន ធុតង្គរមែង បែកធ្លាយ ។ នេះជាសេចក្ដីបែកធ្លាយក្នុងបង្សុកូលិកង្គៈនោះ ។*

## អានិសង្សនៃបង្សុកូលិកង្គធុតង្គ

*ក៏អានិសង្សមានយ៉ាងនេះ គឺភាពនៃសេចក្ដីបដិបត្តិដ៏សមគួរ ដល់និស្ស័យ ព្រោះបាលីថា អ្នកបួសត្រូវអាស្រ័យបង្សុកូលចីវរ ១ កិរិយាប្រតិស្ឋានក្នុងអរិយវង្សជាដំបូង ១ មិនមានសេចក្ដី លំបាក ព្រោះកិរិយារក្សា ១ ភាពនៃកិរិយាប្រព្រឹត្តមិនជាប់ដោយ បុគ្គលដទៃ ១ ភាពជាអ្នកមិនខ្លាចដោយចោរភ័យ ១ មិនមាន តណ្ហាក្នុងគ្រឿងប្រើប្រាស់ ១ ភាពជាអ្នកមានបរិក្ខារដ៏សមគួរដល់ សមណៈ ១ ភាពជាអ្នកមានបច្ច័យដែលព្រះមានព្រះភាគ ទ្រង់ សរសើរថា សំពត់ទាំងតិចផង រកបានដោយងាយផង មិនមាន ទោសផង ១ ភាពជាអ្នកគួរជ្រះថ្លា ១ កិរិយាបង្កើនទូវសេចក្ដី*

*បដិបត្តិដោយប្រពៃ ១ ឲ្យជាគំរូ ទិដ្ឋានុគតិដល់ជនជំនាន់ក្រោយ ១ ។*

*ព្រះយោគីអ្នកទ្រទ្រង់បង្សុកូលចីវរ ដើម្បីកំចាត់បង់នូវមារនិងសេនានៃមារ រមែងល្អដូចជាក្សត្រមានគ្រឿងក្រោះប្រដាប់ហើយ រមែងល្អក្នុងទីចម្បាំង, ព្រះពុទ្ធជាគ្រូនៃសត្វលោក ទ្រង់លះបង់នូវសំពត់ដ៏ប្រសើរទាំងឡាយ មានសំពត់ដែលបានមកអំពីដែនកាសីជាដើម ហើយទ្រទ្រង់នូវចីវរណា ភិក្ខុអង្គណានឹងមិនគប្បីទ្រទ្រង់នូវចីវរបង្សុកូលនោះ, ព្រោះហេតុនោះ ភិក្ខុកាលរលឹកឃើញនូវសេចក្តីប្តេជ្ញារបស់ខ្លួន គប្បីត្រេកអរតែក្នុងចីវរបង្សុកូលដ៏សមគួរដល់កិរិយាប្រព្រឹត្តនូវសេចក្តីព្យាយាម ដូច្នេះ ។*

## ៣.២_ពោលដោយតេចីវរិកង្គៈ

*តេចីវរិកង្គៈ គប្បីសមាទានដោយពាក្យនេះថា* **“ចតុត្ថកចីវរំ បដិក្ខិបាមិ** *: ខ្ញុំហាមឃាត់នូវចីវរជាគំរប់ ៤”,* **“តេចីវរិកង្គំ សមាទិយាមិ** *: ខ្ញុំសូមសមាទាននូវតេចីវរិកង្គៈ” ដូច្នេះ ពាក្យណាមួយក៏បាន ។ ឯភិក្ខុអ្នកទ្រទ្រង់ត្រៃចីវរនោះ បានសំពត់ដើម្បី*

ចីវរហើយ តែមិនអាចដើម្បីធ្វើកើត ព្រោះភាពជាអ្នកមិនសប្បាយជាដើម វត្ថុណាមួយមិនសម្រេចក្តី ដរាបណា ត្រូវទុកដាក់បានដរាបនោះ ។ ទោសព្រោះកិរិយាទុកដាក់ជាបច្ច័យមិនមានទេ។ តែថា កិរិយាដែលភិក្ខុទុកតាំងអំពីកាលដែលខ្លួនជ្រលក់ហើយមិនគួរទេ ។ ឈ្មោះថា ធុតង្គចោរ តែងតែមាន ។ នេះជាវិធាន (បែប) នៃតេចីវរិកង្គៈនោះ ។

ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ពាក្យថា **នូវចីវរជាគំរប់ ៤** នេះ លោកពោលសំដៅដល់សំពត់ចីវរគួរដល់ការស្លៀកដណ្តប់ ដល់ភាពជាសំពត់អធិដ្ឋាន ។ ព្រោះហេតុនោះ រមែងជាការដែលលោកសម្តែងថា សំពត់និសីទនៈដែលជាសំពត់ទី ៤ ជាដើម ដែលគួរដល់ការស្លៀកនិងដណ្តប់ដែលគ្រហស្ថនាំមកក្រៅពីរដូវភ្លៀងមិនគួរហាម ។

## ប្រភេទនៃតេចីវរិកង្គៈ

បើតាមប្រភេទតេចីវរិកង្គៈនេះ ក៏មាន ៣ ពួក ។ ក្នុង ៣ ពួកនោះ អ្នកកាន់យ៉ាងឧក្រិដ្ឋ ក្នុងការជ្រលក់ គប្បីជ្រលក់ស្បង់ ឬចីពរនោះ រួចសឹមជ្រលក់ចីពរដទៃ ។ លោកឃុំចីវរដែល

*ជ្រលក់ហើយនោះ ហើយគប្បីជ្រលក់សង្ឃាដិ ។ តែបើស្មៀកសង្ឃាដិមិនគួរទេ ។ នេះជាវត្តក្នុងសេនាសនៈ ដែលតាំងនៅក្នុងទីបំផុតនៃស្រុក របស់ភិក្ខុអ្នកទ្រទ្រង់នូវត្រៃចីវរ ។ ឯកិរិយាដែលភិក្ខុអ្នកនៅក្នុងព្រៃ បោកហើយជ្រលក់ម្តងពីរក៏មាន ។ តែគប្បីអង្គុយក្នុងទីជិតល្មមឃើញបុគ្គលណាមួយ ហើយអាចដើម្បីទាញសំពត់កាសាវៈមកដណ្តប់បាន ។ ចំណែកអ្នកកាន់ថ្នាក់កណ្តាលសំពត់កាសាវៈ សម្រាប់ប្រើក្នុងរោងសម្រាប់ជ្រលក់មានជាធម្មតា ការស្មៀក ឬដណ្តប់សំពត់នោះ ហើយធ្វើការជ្រលក់ក៏គួរ ។ ឯអ្នកកាន់ជួរថយ ស្មៀក ឬដណ្តប់ចីវរទាំងឡាយរបស់ភិក្ខុអ្នកមានចំណែកស្មើៗគ្នាក្នុងចន្លោះ និងចន្លោះ មិនគួរទេ ។*

**ធុតង្គតេចីវរិកស្ស បន ចតុត្ថំ វត្តមានំ អំសកាសាវំមេវ វដ្ដតិ ។ តញ្ច ខោ វិត្ថារតោ វិទត្ថិ, ទីឃតោ តិហត្ថមេវ វដ្ដតិ ។**
*បើមានសំពត់អង្សៈជាគំរប់ ៤ ក៏គួរដល់ធុតង្គតេចីវរិកភិក្ខុដែរ ។ តែសំពត់នោះឯង ត្រូវមានទទឹង ១ ចំអាម បណ្តោយ ៣ ហត្ថប៉ុណ្ណោះទើបគួរ ។*

*<u>ដីកា</u> សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖*

*ពាក្យថា* **ចតុត្ថំ** *(ចីវរជាគំរប់ ៤) បានដល់ សំពត់ដែល*

*គួរដល់ការស្ងៀកនិងដណ្តប់ ។ ព្រោះហេតុនោះ លោកពោលថា “សំពត់អន្តរៈ” ។ អធិប្បាយថា សំពត់ដែលគ្របលើ ស្បា ដើម្បីកំបាត់វត្ថុដែលជាប់ គឺមន្ទិលមានញើសជាដើមក្នុងចីវរដែលដណ្តប់ ។ ពាក្យថា* **វិត្ថារតោ វិទត្ថិ** *(មានទទឹង ១ ចំអាម) មានសេចក្តីថា មានការសម្តែងដល់ប្រមាណផ្នែកទទឹងមិនល្មមដល់ការអធិដ្ឋាន ។ ព្រោះហេតុនោះ រមែងជាការឲ្យដឹងថា សំពត់ដែលតូចជាងផ្នែកទទឹងមិនល្មមដល់ការអធិដ្ឋាន រមែងគួរ ។ តែពាក្យថា* ***បណ្តាយ ៣ ហត្ថប៉ុណ្ណោះ*** *នេះ ជាការសម្តែងត្រឹមប្រមាណក្នុងការប្រើ ។ ព្រោះហេតុនោះ អំពីនោះសំពត់ណាមួយ រមែងមិនខុស ព្រោះសូម្បីសំពត់ធំល្មមដល់ការអធិដ្ឋាន ។*

## ការបែកធ្លាយនៃតេចីវរិកង្គៈ

*ក៏ធុតង្គនៃភិក្ខុទាំង ៣ ពួកនេះ តែងបែកធ្លាយក្នុងខណៈដែលត្រេកអរហើយនូវចីវរជាគំរប់ ៤ ។ នេះជាការបែកធ្លាយក្នុងតេចីវរិកង្គៈនោះ ។*

## អានិសង្សនៃតេចីវរិកង្គៈ

ក៏អានិសង្ស មានយ៉ាងនេះគឺ ភិក្ខុអ្នកទ្រទ្រង់នូវត្រៃចីវរ ជាអ្នកសន្តោសដោយចីវរជាគ្រឿងរក្សានូវកាយ ព្រោះសន្តុដ្ឋភាពនោះ លោកនឹងកាន់យកនូវត្រៃចីវរទៅបាន ដូចជាសត្វស្លាប ១ ភាពជាអ្នកមានវល់តិច ១ ការវៀរចាកកិរិយាសន្សំសំពត់ ១ ភាពជាអ្នកប្រព្រឹត្តស្រាលរហ័ស ១ កិរិយាលះបង់សេចក្តីល្មោភក្នុងចីវរដ៏លើស ១ ភាពជាអ្នកស្គាល់ប្រមាណក្នុងវត្ថុដែលគួរ ១ ភាពជាអ្នកប្រព្រឹត្តជុសខាត់កិលេស ១ ផលនៃអប្បិច្ឆតាគុណជាដើមនឹងសម្រេច ១ គុណមានយ៉ាងនេះជាដើម រមែងសម្រេចដោយប្រការដូច្នេះ ។

ព្រះយោគីអ្នកមានបញ្ញា លះបង់នូវសេចក្តីប្រាថ្នាក្នុង
សំពត់ដ៏លើស វៀរស្រឡះចាកការសន្សំ ដឹងនូវរសនៃ
សេចក្តីសុខដែលកើតអំពីសេចក្តីសន្តោស អ្នកទ្រទ្រង់នូវ
ចីវរបី, ព្រោះហេតុនោះ អ្នកប្រាថ្នាដើម្បីត្រាច់ទៅដោយ
ស្រួលដូចជាបក្សីមានស្លាបជាគ្រឿងត្រាច់ទៅ គប្បីធ្វើ
សេចក្តីត្រេកអរក្នុងចីវរដែលកំណត់ទុកចុះ ។

## ៣.៣~ពោលដោយបិណ្ឌបាតិកង្គៈ

*បិណ្ឌបាតិកង្គៈ សមាទានដោយពាក្យ ២ យ៉ាង ពាក្យណាមួយក៏បាន ថា* **"អតិរេកលាភំ បដិក្ខិបាមិៈ** *ខ្ញុំហាមឃាត់អតិរេកលាភ",* **"បិណ្ឌបាតិកង្គំ សមាទិយាមិៈ** *ខ្ញុំសមាទាននូវបិណ្ឌបាតិកង្គៈ" ។*

*ក៏ភិក្ខុអ្នកកាន់បិណ្ឌបាតជាវត្តនោះ មិនត្រូវត្រេកអរភត្ត ១៤ យ៉ាងនេះទេគឺ សង្ឃភត្ត ១ ឧទ្ទេសភត្ត ១ និមន្តនភត្ត ១ សលាកភត្ត ១ បក្ខិកភត្ត ១ ឧបោសថិកភត្ត ១ បាដិបទិកភត្ត (ភត្តដែលគេប្រគេនក្នុងថ្ងៃ ១ កើត ១ រោច) ១ អាគន្តុកភត្ត ១ គមិកភត្ត ១ គិលានភត្ត ១ គិលានុបដ្ឋាកភត្ត ១ វិហារភត្ត (ភត្តដែលគេប្រគេនឧទ្ទិសវិហារ ឬភត្តដែលកើតឡើងក្នុងវិហារនោះ) ១ ធុរភត្ត (និច្ចភត្ត : ភត្តដែលទាយកថ្វាយជាប្រចាំ) ១ វារកភត្ត (ភត្តដែលគេផ្លាស់វារៈគ្នាទំនុកបម្រុង) ១ ។*

*ប្រសិនបើទាយកមិនពោលដោយន័យជាដើមថា* **"សង្ឃភត្តំ គណ្ហថ** *: ព្រះករុណាទាំងឡាយ សូមទទួលនូវសង្ឃភត្ត" ហើយទូលថា* **"អម្ហាកំ គេហេ សង្ឃោ ភិក្ខំ គណ្ហាតុ, តុម្ហេបិ ភិក្ខំ**

**គណ្ឋថ** : ព្រះសង្ឃសូមទទួលនូវកិក្ខាក្នុងផ្ទះរបស់ខ្ញុំព្រះករុណាទាំងឡាយ, សូមឱ្យព្រះករុណាទាំងឡាយ ក៏សូមទទួលកិក្ខា” ដូច្នេះហើយ ប្រគេនហើយ នឹងត្រេកអរភត្តទាំងនោះ ក៏គួរ ។ ស្លាកប្រាសចាកអាមិស(កើតឡើង)អំពីសំណាក់សង្ឃក្តី ភត្តដែលគេចំអិនហើយក្នុងវិហារក្តី គួរពិត ។

ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ក៏ភត្តទាំងអស់នេះ លោកពោលថា **មិនគួរត្រេកអរ** ព្រោះគេថ្វាយឧទ្ទិសសង្ឃ ។ ចំណែកភត្តដែលគេថ្វាយដោយអំណាចបុគ្គល វៀរសង្ឃភត្តនិងសលាកភត្តចេញ រមែងគួរដល់កិក្ខុអ្នកកាន់បិណ្ឌបាតជាវត្ត ។ ព្រោះពាក្យថា **នឹងត្រេកអរភត្តទាំងនោះក៏គួរ** នេះ ជាពាក្យដែលលោកពោលដោយបរិយាយថាភិក្ខា ។ ស្លាកដែលទាក់ទងដោយភេសជ្ជៈនិងចីវរជាដើម ឈ្មោះថា **ស្លាកប្រាសចាកអាមិស** ។ ពាក្យថា **សូមឱ្យភត្តដែលគេចំអិនហើយក្នុងវិហារ** សេចក្តីថា ភត្តដែលទាយកទាំងឡាយ ចំអិនក្នុងវិហារដើម្បីប្រយោជន៍ដល់សង្ឃ រមែងគួរ ព្រោះជាកិក្ខាដែលទាយកនាំមក ។

## ប្រភេទនៃបិណ្ឌបាតិកង្គៈ

*បើពោលតាមប្រភេទបិណ្ឌបាតិកង្គៈនេះ មាន ៣ យ៉ាង ។ ក្នុង ៣ យ៉ាងនោះ ភិក្ខុអ្នកកាន់ឧក្រិដ្ឋ រមែងទទួលភិក្ខាដែលគេនាំមកទាំងខាងមុខ ទាំងខាងក្រោយបាន, លោកកំពុងឈរទៀបទ្វារផ្ទះមួយ ឲ្យបាត្រដល់ទាយកដែលមកទទួលយកទៅ ក៏បាន, ទទួលនូវភិក្ខាដែលគេនាំមកប្រគេន ក្នុងកាលត្រឡប់វិញ ក៏បាន, តែថា ក្នុងថ្ងៃនោះបើអង្គុយហើយ មិនត្រូវទទួលចង្ហាន់ទៀតទេ ។ ភិក្ខុអ្នកកាន់ថ្នាក់កណ្ដាល ក្នុងថ្ងៃនោះ សូម្បីអង្គុយហើយក៏ទទួលបាន តែមិនត្រូវទទួលទុកដើម្បីថ្ងៃស្អែក និងថ្ងៃតទៅទេ ។ ភិក្ខុអ្នកកាន់ធូរថយ រមែងទទួលភិក្ខាដើម្បីថ្ងៃស្អែក និងថ្ងៃតទៅក៏បាន ។ ទាំងពីរពួកនោះ មិនបានសេចក្ដីសុខ ក្នុងកិរិយានៅតាមទំនើងចិត្តទេ ។ ភិក្ខុអ្នកកាន់ឧក្រិដ្ឋប៉ុណ្ណោះ ទើបបាន ។*

*<u>ដីកា</u> សារត្ថទីបនី ភាគ១ ពន្យល់ថា ៖*

*ពាក្យថា **ទៀបទ្វារផ្ទះមួយ** សេចក្ដីថា ឈរចំពោះមុខទ្វារផ្ទះ ។ ដោយពាក្យនេះ លោកសម្ដែងថា ឈរក្នុងវិហារជាដើម មកទទួលយកបាត្រ ឲ្យទៅ មិនគួរ ។ ពាក្យថា **កាលត្រឡប់វិញ***

សេចក្ដីថា ឈ្មោះថា កាលត្រឡប់ ដោយអត្ថថា ជាវេលាដែលភិក្ខុទាំងឡាយត្រាច់ទៅបិណ្ឌបាតក្នុងស្រុកត្រឡប់មកវិញ ត្រឡប់ចេញមកអំពីស្រុកនោះ ដើម្បីត្រូវការឆាន់ ។ ក៏ពាក្យនេះ ជាទុតិយាវិភត្ត ចុះក្នុងអត្ថថាក្នុង ។ អធិប្បាយថា ភិក្ខុកាន់បិណ្ឌបាតជាវត្ត អង្គុយក្នុងរោងឆាន់ដើម្បីត្រូវការឆាន់ ទទួលសូម្បីភត្តដែលគេនាំមកប្រគេនបាន ។

## រឿងភិក្ខុបបួលគ្នាទៅស្ដាប់ធម៌

បានឮថា អរិយវង្ស មានក្នុងស្រុកមួយ ។ ភិក្ខុអ្នកកាន់ឧក្រិដ្ឋ បបួលភិក្ខុក្រៅនេះថា ម្នាលអាវុសោ មកយើងទៅស្ដាប់ធម៌ ។ ក្នុងភិក្ខុពីររូបនោះ ភិក្ខុមួយរូប ពោលថា បពិត្រលោកដ៏ចម្រើន ខ្ញុំមានមនុស្សម្នាក់ គេឲ្យអង្គុយចាំគេសិន ។ ភិក្ខុមួយរូបទៀត ពោលថា បពិត្រលោកដ៏ចម្រើន សូម្បីខ្ញុំក៏ទទួលភិក្ខារបស់មនុស្សម្នាក់ ដើម្បីថ្ងៃស្អែកទៅហើយ ។ ទាំងពីររូបនោះសាបសូន្យយ៉ាងនេះឯង ។ ភិក្ខុអ្នកកាន់ឧក្រិដ្ឋក្រៅនេះ ត្រាច់ទៅដើម្បីបិណ្ឌបាតអំពីព្រឹកហើយ បានដោយរសនៃធម៌ ។

## ការបែកធ្លាយនៃបិណ្ឌបាតិកង្គៈ

*ក៏ធុតង្គនៃភិក្ខុទាំង ៣ ពួកនេះ តែងបែកធ្លាយក្នុងខណៈ ដែលត្រេកអរចំពោះអតិរេកលាភ មានសង្ឃភត្តជាដើម ។ នេះជាការបែកធ្លាយក្នុងបិណ្ឌបាតិកង្គៈនោះ ។*

## អានិសង្សក្នុងបិណ្ឌបាតិកង្គៈ

*ក៏អានិសង្សមានយ៉ាងនោះគឺ ភាពនៃសេចក្ដីបដិបត្តិដ៏សមគួរដល់និស្ស័យ ព្រោះបាលីថា អ្នកបួសត្រូវអាស្រ័យភោជនគឺដុំបាយដែលនឹងគប្បីបាន ១ កិរិយាតាំងនៅស៊ប់ក្នុងអរិយវង្សជាគំរប់ពីរ ១ ភាពនៃកិរិយាប្រព្រឹត្តមិនជាប់ដោយបុគ្គលដទៃ ១ ភាពជាអ្នកមានបច្ច័យដែលព្រះមានព្រះភាគ ទ្រង់សរសើរថា ភោជនទាំងនោះតិចផង បានដោយងាយផង មិនមានទោសផង ១ មានការញាំញីសេចក្ដីខ្ជិលច្រអូស ១ មានការចិញ្ចឹមជីវិតបរិសុទ្ធ ១ កិរិយាបំពេញសេខិយបដិបត្តិ ១ ភាពជាអ្នកចិញ្ចឹមខ្លួនដោយមិនត្រូវអាស្រ័យអ្នកដទៃ ១* **កិរិយាអនុគ្រោះបុគ្គលដទៃ** *១ កិរិយាលះបង់នូវមានៈ ១ កិរិយាហាមឃាត់នូវចំណង់ក្នុងរស ១ ភាពមិនមានអាបត្តិ ព្រោះគណភោជន បរម្បរភោជន និងចារិត្ត-*

សិក្ខាបទទាំងឡាយ ១ ភាពជាអ្នកប្រព្រឹត្តសមគួរដល់អបច្ចិច្ចតា-គុណជាដើម ១ កិរិយាបង្កើនសេចក្តីបដិបត្តិដោយប្រពៃ ១ ការអនុគ្រោះពួកជនជំនាន់ក្រោយ ១ ។

ព្រះយោគីអ្នកមានសេចក្តីសន្តោសក្នុងជុំបាយ ដែលនឹងគប្បីបាន អ្នកមានកិរិយារស់នៅមិនជាប់ដោយបុគ្គលដទៃ អ្នកមានសេចក្តីល្មោភក្នុងអាហារលះបង់ហើយ អ្នកមានក្នុងទិសទាំង ៤ រមែងបន្ទោបង់សេចក្តីខ្ជិលច្រអូស អាជីវៈរបស់លោក រមែងបរិសុទ្ធ, ព្រោះហេតុនោះ អ្នកមានបញ្ញាល្អ មិនគប្បីមើលងាយភិក្ខាចារ ។ សេចក្តីពិតភិក្ខុអ្នកកាន់បិណ្ឌបាតយ៉ាងនេះ អ្នកចិញ្ចឹមខ្លួន មិនត្រូវឲ្យគេចិញ្ចឹម ទាំងជាអ្នកមិនអាស្រ័យលាភ និងសេចក្តីសរសើរ, ទេវតាទាំងឡាយ តែងស្រឡាញ់លោកអ្នកប្រាកដដូច្នោះ ។

ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ពាក្យថា **បរានុគ្គហកិរិយា** (កិរិយាអនុគ្រោះបុគ្គលដទៃ) ព្រោះទៅទទួលភិក្ខាតាមលំដាប់ផ្ទះ របស់ពួកជនអ្នកមិនអាចទៅប្រគេនខ្លួនឯងបាន ។

## ៣.៤-ពោលដោយសបទានចារិកង្គ

*សបទានចារិកង្គ: មានកិរិយាសមាទានថា* **“លោលុប្បចារំ បដិក្ខិបាមិ** *: ខ្ញុំហាមឃាត់នូវការប្រព្រឹត្តិល្មោភ”,* **សបទានចារិកង្គំ សមាទិយាមិ** *: ខ្ញុំសមាទាននូវសបទានចារិកង្គ:” ដូច្នេះ ពាក្យណាមួយក៏បាន ។*

*ក៏ភិក្ខុអ្នកកាន់សបទានចារិក:នោះ ឈរទៀបទ្វារស្រុកហើយ គប្បីកំណត់ការមិនមានសេចក្ដីអន្តរាយ ។ ក្នុងប្រក ឬក្នុងស្រុកណា មានអន្តរាយ គប្បីលះទីនោះ ហើយត្រាច់ទៅក្នុងទីដទៃ រមែងគួរ ។ លោកមិនបានវត្ថុណាមួយទៀបទ្វារនៃផ្ទះ ឬក្នុងប្រក ឬក្នុងស្រុកណា គប្បីធ្វើសេចក្ដីសម្គាល់ទីនោះថាមិនមែនស្រុក ហើយទៅក្នុងទីដទៃ ។ ក្នុងទីណាបានវត្ថុណាមួយ លះទីនោះហើយទៅ មិនគួរទេ ។ ឯភិក្ខុនេះ គប្បីចូលទៅពីព្រលឹម, ព្រោះថា កាលបើហេតុយ៉ាងនេះមាន នឹងអាចដើម្បីលះបង់ទីមិនសប្បាយ ហើយទៅក្នុងទីដទៃបាន ។ ប្រសិនបើមនុស្សទាំងឡាយ ឲ្យទានក្នុងវិហាររបស់លោក ឬមកទទួលបាត្រក្នុងចន្លោះផ្លូវ ហើយប្រគេនបិណ្ឌបាត ក៏គួរ ។ មួយទៀត ភិក្ខុនេះ*

សូម្បីត្រាច់ទៅកាន់ផ្លូវ មិនត្រូវវិលផងស្រុក ដែលខ្លួនជួបហើយក្នុងវេលាភិក្ខាចារ ហើយត្រាច់ទៅទេ ។ ភិក្ខុមិនបានក្នុងទីនោះ ឬបានវត្ថុមានប្រមាណតិច គប្បីត្រាច់ទៅតាមលំដាប់ស្រុក ។ នេះជាវិធីនៃសបទានចារិកង្គៈនោះ ។

ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ពាក្យថា **ក្នុងទីដទៃ** សេចក្ដីថា ក្នុងស្រុក ឬក្នុងច្រកដទៃ ។ ដោយពាក្យនេះ លោកសម្ដែងថា សបទានចារិកភិក្ខុ នឹងលះសូម្បីលំដាប់ស្រុក ឬថ្នល់ ដូចលំដាប់ផ្ទះ មិនគួរទេ ។ ពាក្យថា **ទីមិនសប្បាយ** សេចក្ដីថា ស្ថានទីមិនសប្បាយ ព្រោះមានអន្តរាយ ឬព្រោះមិនមានលាភ ។

ក្នុងអដ្ឋកថា តតិយបារាជិក មានពន្យល់មួយកន្លែង ពីភិក្ខុមិនគួរទទួលបិណ្ឌបាត អំពីត្រកូលមិច្ឆាទិដ្ឋិ ថា ៖

ពីរបទថា **តេ ភិក្ខូ** (ភិក្ខុទាំងនោះ) បានដល់ ភិក្ខុដែលឆាន់បិណ្ឌបាតតាំងពីដើមអាសនៈព្រះថេរៈទាំងនោះចុះមក ។ បានឮថា ភិក្ខុទាំងនោះ បានមរណភាពគ្រប់រូបទាំងអស់ ។ ពាក្យដ៏សេសក្នុងរឿងនេះ ច្បាស់លាស់ទាំងនោះ ។ កាលភិក្ខុ-បានបិណ្ឌបាតដ៏ប្រណីត ដោយគោរពក្នុងត្រកូលពួកមិច្ឆាទិដ្ឋិ

*អ្នកមិនមានសទ្ធា មិនទាន់បានពិចារណា ខ្លួនឯងមិនគួរឆាន់ផង ទាំងមិនគួរប្រគេនដល់ភិក្ខុពួកដទៃផង ។ ភិក្ខុបានកត្តាហារ ឬរបស់គួរទំពាឆាន់សូម្បីវត្ថុណា ដែលជារបស់បានមកពីត្រកូល-មិច្ឆាទិដ្ឋិនោះ, កត្តាហារជាដើមសូម្បីនោះ មិនគួរឆាន់ ។ ព្រោះថាត្រកូលទាំងនោះ រមែងប្រគេនសូម្បីវត្ថុដែលគេមិនបានយកអ្វីគ្របទុក ដែលមានពស់ ក្អែប និងខ្លួយជាដើម ចូលដេកសម្ងំជារបស់ដែលត្រូវចោលជាធម្មតា ។ ភិក្ខុមិនគួរទទួលបិណ្ឌបាតសូម្បីដែលប្រឡាក់ដោយវត្ថុ មានរបស់ក្រអូប និងល្មៀតជាដើមអំពីត្រកូលមិច្ឆាទិដ្ឋិនោះ ។ ពិតមែន ត្រកូលមិច្ឆាទិដ្ឋិទាំងនោះរមែងសម្គាល់នូវកត្តាហារដែលខ្លួនយកមកជូតសំអាត ដែលមានរោគក្នុងរាងកាយ ហើយរក្សាទុកថា "ជារបស់គួរប្រគេន" នោះឯង ។*

## ប្រភេទនៃសបទានចារិកង្គ:

*បើតាមប្រភេទធុតង្គនេះ មាន ៣ យ៉ាង ។ ក្នុង ៣ យ៉ាងនោះ ភិក្ខុអ្នកកាន់យ៉ាងឧក្រិដ្ឋ រមែងមិនទទួលភិក្ខាដែលគេនាំមកអំពីខាងមុខក្ដី ភិក្ខាដែលគេនាំមកអំពីក្រោយក្ដី ដែលគេនាំមក*

ប្រគេនវេលាត្រឡប់វិញក្ដី, ប៉ុន្តែ រមែងលះបាត្រទៀបទ្វារផ្ទះបុគ្គលដទៃ ។ ក៏ក្នុងធុតង្គនេះ ភិក្ខុស្មើដោយព្រះមហាកស្សបត្ថេរមិនមាន ។ សូម្បីកន្លែងលះបាត្ររបស់ព្រះមហាកស្សបត្ថេរនោះរមែងប្រាកដ ។ ភិក្ខុអ្នកកាន់យ៉ាងកណ្ដាល រមែងទទួលភិក្ខាដែលគេនាំមកអំពីមុខ ឬអំពីក្រោយខ្លះ ដែលគេនាំមកក្នុងពេលត្រឡប់វិញខ្លះ រមែងលះបាត្រទៀបទ្វារផ្ទះរបស់បុគ្គលដទៃខ្លះ ។ ប៉ុន្តែលោកមិនអង្គុយរង់ចាំភិក្ខាទេ ។ ភិក្ខុអ្នកកាន់យ៉ាងកណ្ដាល យ៉ាងនេះ អនុលោមដល់ភិក្ខុអ្នកកាន់បិណ្ឌបាតិកង្គៈឧក្រិដ្ឋ ។ ភិក្ខុអ្នកកាន់យ៉ាងធូរថយ អង្គុយរង់ចាំអស់ថ្ងៃនោះ ។

<u>ដីកា</u> សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ពាក្យថា **ខាងមុខ** សេចក្ដីថា ខាងមុខរបស់ភិក្ខុនោះអ្នកដើរទៅតាមផ្លូវ ។ អធិប្បាយថា អ្នកឈរនៅទៀបទ្វារផ្ទះប៉ុណ្ណោះទទួលភត្តដែលទាយកនាំមកថ្វាយ ។ ពាក្យថា **កន្លែងលោកលះបាត្រ** នេះ លោកពោលសំដៅដល់ទីដាក់បាត្រទៀបទ្វារផ្ទះរបស់ស្ដេចសក្កទេវរាជ ដែលក្លែងភេទជាជាងតម្បាញប្រថាប់ឈរ ។ ពាក្យថា **នោះ** បានដល់ ភិក្ខុអ្នកកាន់យ៉ាងកណ្ដាល ។

## ការបែកធ្លាយនៃសបទានចារិកង្គៈ

ក៏ធុតង្គនៃភិក្ខុទាំង ៣ ពួកនេះ រមែងបែកធ្លាយត្រឹមតែកិរិយាប្រព្រឹត្តល្មោភកើតឡើង ។ នេះជាការបែកធ្លាយក្នុងសបទានចារិកង្គៈនោះ ។

## អានិសង្សនៃសបទានចារិកង្គៈ

ក៏អានិសង្សមានយ៉ាងនេះគឺ ភាពជាអ្នកថ្មីជានិច្ច ក្នុងត្រកូលទាំងឡាយ ១ ភាពជាអ្នកដូចព្រះចន្ទ្រ ១ កិរិយាលះបង់សេចក្តីកំណាញ់ត្រកូល ១ ភាពជាអ្នកមានសេចក្តីអនុគ្រោះដ៏ស្មើ ១ មិនមានទោសព្រោះចូលទៅកាន់ត្រកូល ១ មិនត្រេកអរដោយការនិមន្ត ១ ភាពជាអ្នកមិនត្រូវការដោយចង្ហាន់ដែលគេនាំមកចំពោះ ១ ភាពជាអ្នកប្រព្រឹត្តសមគួរដល់អប្បិច្ឆតាគុណជាដើម ១ ។

ភិក្ខុអ្នកប្រព្រឹត្តទៅតាមលំដាប់ច្រកជាប្រក្រតី ក្នុងសាសនា
នេះ អ្នកមានឧបមាដូចព្រះចន្ទ្រ អ្នកថ្មីជានិច្ចក្នុងត្រកូល
ទាំងឡាយ អ្នកមិនកំណាញ់ អ្នកមានសេចក្តីអនុគ្រោះ
ក៏ស្មើដល់ជនទាំងពួង អ្នកផុតស្រឡះហើយចាកទោស

ព្រោះកិរិយាចូលទៅជិតកាន់ត្រកូល ព្រោះហេតុនោះ អ្នកប្រាថ្នាលះបង់សេចក្ដីប្រព្រឹត្តល្មោភហើយ អ្នកមានចក្ខុដាក់ចុះ មានការឃើញត្រឹមមួយជួរនឹម ការប្រាថ្នាការត្រាច់ទៅដោយសេរីលើផែនដី គប្បីប្រព្រឹត្តការត្រាច់ទៅតាមលំដាប់ច្រក ។

## ៣.៥ ពោលដោយឯកាសនិកង្គ

ឯកាសនិកង្គៈ មានកិរិយាសមាទានដោយពាក្យទាំងនេះថា **"នានាសនភោជនំ បដិក្ខិបាមិ** : ខ្ញុំហាមឃាត់នូវភោជន ក្នុងអាសនផ្សេងៗ", **"ឯកាសនិកង្គំ សមាទិយាមិ** : ខ្ញុំសមាទាននូវឯកាសនិកង្គៈ" ដូច្នេះ ពាក្យណាមួយក៏បាន ។

ក៏ភិក្ខុអ្នកប្រព្រឹត្តនៅក្នុងអាសនៈតែមួយជាវត្តនោះ កាលអង្គុយក្នុងសាលាឆាន់ ក៏មិនអង្គុយលើអាសនៈនៃព្រះថេរៈ គប្បីកំណត់នូវអាសនៈដ៏សមគួរថា "អាសនៈនេះ ត្រូវបានដល់យើង" ហើយអង្គុយចុះ ថាបើលោកពុំទាន់លែងឆាន់ អាចារ្យ ឬឧបជ្ឈាយ៍មក ក្រោកឡើងធ្វើវត្ត ក៏គួរ ។ ឯព្រះថេរៈឈ្មោះ

ចូឡាភ័យ អ្នកទ្រទ្រង់ព្រះត្រៃបិដក ពោលថា គួររក្សាអាសនៈ ឬភោជនទុក ដោយហេតុថា ភិក្ខុនេះ កំពុងឆាន់នៅឡើយ ព្រោះហេតុនោះ ចូរធ្វើវត្តចុះ គឺថាកុំឆាន់នៅឡើយ ព្រោះហេតុនោះ ចូរធ្វើវត្តចុះ គឺថាកុំបរិភោគភោជនឡើយ ។ នេះជាវិធីនៃឯកាសនិកង្គៈនោះ ។

ដីកា បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖

ពាក្យថា **ក្រោកឡើងធ្វើវត្ត ក៏គួរ** គឺកាលដែលលោកនឹងធ្វើវត្ត រមែងគួរ ។ ឈ្មោះថាវត្ត ក៏បានដល់កិច្ចដែលគប្បីធ្វើក្នុងបុគ្គលដែលតាំងនៅក្នុងឋានៈគួរគោរពនោះឯង ។ ក៏ដើម្បីសម្តែងវិធីបដិបត្តិក្នុងវត្តនោះ លោកអាចារ្យទើបពោលដល់វាទៈរបស់ព្រះថេរៈដែលថា "គួររក្សាអាសនៈ ឬភោជនទុក" ដូច្នេះជាដើម។

វាទៈរបស់ព្រះថេរៈនោះ មានសេចក្តីសំដៅថា ការអង្គុយនឹងគប្បីរក្សា ឯកាសនិកភិក្ខុអ្នកឆាន់, ក៏មានការពោលអធិប្បាយបានថា មិនគួរក្រោកឡើងដរាបដល់ទីបំផុតការឆាន់ ព្រោះធុតង្គមានការបែកធ្លាយបាន ។ ឬភោជននឹងគប្បីរក្សាភិក្ខុដែលនៅមិនទាន់បានឆាន់ទុកអំពីការបែកធ្លាយនៃធុតង្គ, ក៏មានសេចក្តី

សំដៅថា គួរក្រោកឡើងដរាបដែលនៅមិនទាន់បានឆ្អែត ។ អធិប្បាយថា តែព្រោះហេតុទី ២ នេះប៉ុណ្ណោះមិនមានក្នុងវារៈនេះ, ព្រោះដូច្នោះ ទើបត្រូវរក្សាការធ្វើវត្ត កុំរក្សាធុតង្គ ដូច្នេះ ។ ព្រោះហេតុនោះ លោកទើបពោលថា “តែថាភិក្ខុរូបនេះ” ដូច្នេះជាដើម។

## ប្រភេទនៃឯកាសនិកង្គ:

បើតាមប្រភេទធុតង្គៈនេះ មាន ៣ យ៉ាង ។ ក្នុង ៣ យ៉ាងនោះ ភិក្ខុអ្នកកាន់យ៉ាងឧក្រិដ្ឋ, វត្តុតិចក្តី ច្រើនក្តី ចូលលើកទុក, បើលូកដៃក្នុងភោជនណា ចាប់យកភោជនដទៃអំពីនោះ មិនបានទេ ។ ថាបើមនុស្សទាំងឡាយគិតថា ព្រះថេរៈមិនមានអ្វីឆាន់ហើយនាំយកសប្បិជាដើមមក វត្ថុនេះគួរ **ដើម្បីជាភេសជ្ជៈតែម្យ៉ាង**, មិនគួរដើម្បីជាអាហារទេ ។ ភិក្ខុអ្នកកាន់យ៉ាងកណ្តាលរមែងបានដើម្បីទទួលវត្ថុដទៃ ដរាបកត្តក្នុងបាត្រមិនទាន់អស់ ។ ព្រោះថា អ្នកកាន់យ៉ាងកណ្តាលនេះ ឈ្មោះថា ជាអ្នកមានភោជនជាទីបំផុត ។ ភិក្ខុអ្នកកាន់យ៉ាងធូរថយ រមែងបានដើម្បីបរិភោគដរាបមិនទាន់ក្រោកចាកអាសនៈ ។ ដ្បិតភិក្ខុអ្នកកាន់យ៉ាងធូរថយនោះ ឈ្មោះថាជាអ្នកមានទឹកក្នុងទីបំផុត ព្រោះមិនទាន់កាន់យក

ទឹកលាងបាត្រត្រឹមណា នៅបរិភោគបានត្រឹមនោះ ឬឈ្មោះថាជាអ្នកមានអាសនៈក្នុងទីបំផុត ព្រោះមិនទាន់ក្រោកដរាបណា បរិភោគបានដរាបនោះ ។

ដីកា សារត្ថទីបនី ភាគ១ ពន្យល់ថា ៖

*ភេសជ្ជត្ថមេវាតិ ឥមិនា សប្បិអាទីនិ កាលេបិ សតិ បច្ចយេ ភេសជ្ជបរិភោគវសេនេវ បរិភុញ្ជិតុំ វដ្ដតិ ។ ន ច ជិឃច្ឆាបរិហារត្ថន្តិ ទស្សេតិ ។*

ពាក្យថា **ដើម្បីជាភេសជ្ជៈតែម្យ៉ាង** នេះ លោកសម្ដែងថា សប្បិជាដើមនេះ នឹងបរិភោគដោយអំណាចការបរិភោគជាភេសជ្ជៈប៉ុណ្ណោះឯង ក្នុងកាលមានបច្ច័យសូម្បីក្នុងកាល រមែងគួរ, តែនឹងបរិភោគដើម្បីកំចាត់សេចក្ដីឃ្លាន មិនគួរទេ ។

## ការបែកធ្លាយនៃឯកាសនិកង្គៈ

ក៏ធុតង្គនៃភិក្ខុទាំង ៣ ពួកនេះ រមែងបែកធ្លាយ ក្នុងខណៈដែលបរិភោគភោជនក្នុងអាសនៈផ្សេងៗ ។ នេះជាការបែកធ្លាយ ក្នុងឯកាសនិកង្គៈនោះ ។

## អានិសង្សនៃឯកាសនិកង្គៈ

*ក៏អានិសង្សមានយ៉ាងនេះគឺ ភាពជាអ្នកមានអាពាធតិច ១ ភាពជាអ្នកមានជម្ងឺតិច ១ កិរិយាក្រោកឡើងរហ័សរហួន ១ មានកម្លាំង ១ កិរិយានៅជាសុខ ១ មិនមានអាបត្តិព្រោះអនតិរិត្តៈជាបច្ច័យ ១ កិរិយាបន្ទោបង់នូវចំណង់ក្នុងរស ១ ភាពជាអ្នកប្រព្រឹត្តសមគួរដល់អប្បិច្ឆតាគុណជាដើម ១ ។*

*រោគទាំងឡាយមានភោជនជាបច្ច័យ មិនបៀតបៀននូវព្រះយោគី អ្នកត្រេកអរក្នុងការបរិភោគលើអាសនៈតែមួយ អ្នកមិនល្មោភក្នុងរស រមែងមិនញ៉ាំងការងាររបស់ខ្លួនឲ្យសាបសូន្យ, ព្រះយោគីមានចិត្តដ៏បរិសុទ្ធ គប្បីញ៉ាំងសេចក្តីត្រេកអរ ក្នុងការបរិភោគលើអាសនៈតែមួយជាហេតុនៃកិរិយានៅជាសុខ ដែលត្រេកអរហើយ សេចក្តីស្អាត និងកិរិយាដុសខាត់នូវកិលេស ដែលចូលទៅជិតសេពគប់ហើយ គប្បីឲ្យកើតឡើងដោយប្រការដូច្នេះ ។*

## ៣.៦_ពោលដោយបត្តបិណ្ឌិកង្គ

*បត្តបិណ្ឌិកង្គៈ មានកិរិយាសមាទានដោយពាក្យទាំងនេះថា* **“ទុតិយភាជនំ បដិក្ខិបាមិ** *: ខ្ញុំហាមឃាត់នូវភាជនៈទីពីរ”,* **“បត្ត-បិណ្ឌិកង្គំ សមាទិយាមិ** *: ខ្ញុំសមាទាននូវបត្តបិណ្ឌិកង្គៈ” ដូច្នេះ ពាក្យណាមួយក៏បាន ។*

*ឯភិក្ខុអ្នកប្រព្រឹត្តឆាន់តែជុំអាមិសក្នុងបាត្រជាវត្តនោះ កាលបានម្ហូបក្រៀមដែលដាក់ក្នុងភាជនៈ ក្នុងកាលឆាន់បបរ គប្បីឆាន់ម្ហូបក្រៀមមុន ឬឆាន់បបរមុនក៏បាន ។ ប្រសិនបើដាក់ចុះក្នុងបបរ, កាលម្ហូបមានត្រីស្អុយជាដើម ដែលដាក់ចុះហើយ បបររមែងជារបស់គួរខ្ពើម ។ កិរិយាធ្វើមិនឲ្យជារបស់គួរខ្ពើមហើយបរិភោគរមែងគួរ ។ ព្រោះហេតុនោះ ពាក្យនេះ លោកពោលសំដៅម្ហូបក្រៀមបែបនោះ ។ បើវត្ថុណា មានទឹកឃ្មុំនិងស្ករក្រាមជាដើមជារបស់មិនគួរខ្ពើម គប្បីដាក់វត្ថុនោះជាមួយចុះ ។ តែកាលទទួលគប្បីទទួលឲ្យល្មមប្រមាណ ។ អន្ទក់ស្រស់និងមើមជំឡូង យកដៃកាន់ឆាន់ ក៏គួរ ។ បើមិនធ្វើដូច្នោះទេ គប្បីដាក់ក្នុងបាត្រទៅចុះ ។*

ន័យមួយទៀត ភាជនៈដទៃ សូម្បីតែស្លឹកឈើ ក៏មិនគួរ ព្រោះខ្លួនឃាត់ភាជនៈទីពីរហើយ ។ នេះជាវិធីនៃបត្តបិណ្ឌិកង្គៈនោះ ។

## ប្រភេទនៃបត្តបិណ្ឌិកង្គៈ

បើតាមប្រភេទ អ្នកកាន់ធុតង្គនេះ មាន ៣ ពួក ។ ក្នុង ៣ ពួកនោះ អ្នកកាន់យ៉ាងឧក្រិដ្ឋ នឹងចោលសម្រាម វៀរចាកវេលាឆាន់អំពៅ មិនគួរទេ ។ កិរិយាបំបែកដុំបាយត្រីសាច់ និងនំទាំងឡាយហើយឆាន់ មិនគួរ ។ អ្នកកាន់យ៉ាងកណ្តាលនេះ ឈ្មោះថា **ហត្ថយោគី** (អ្នកធ្វើឲ្យគួរដោយដៃ) ។ អ្នកកាន់យ៉ាងទន់ខ្សោយ ឈ្មោះថា **បត្តយោគី** (អ្នកធ្វើឲ្យគួរក្នុងបាត្រ) ។ វត្ថុណាដែលភិក្ខុនោះអាចដើម្បីដាក់ចុះក្នុងបាត្របាន និងបំបែកវត្ថុទាំងអស់នោះ ដោយដៃ ឬដោយធ្មេញទាំងឡាយ ហើយឆាន់ ក៏គួរ ។

ដីកា សារត្ថទីបនី ភាគ១ ពន្យល់ថា ៖

ពាក្យថា **ហត្ថយោគី** (អ្នកធ្វើឲ្យគួរដោយដៃ) សេចក្តីថា អ្នកមានប្រក្រតីប្រើដៃបំបែកអាហារហើយដាក់មាត់, មិនមែនប្រើធ្មេញកាត់ទេ ។ ពាក្យថា **បត្តយោគី** (អ្នកធ្វើឲ្យគួរក្នុងបាត្រ)

សេចក្តីថា អ្នកមានប្រក្រតីប្រើដៃបំបែក ឬធ្មេញកាត់ វត្ថុដែលមាននៅក្នុងបាត្រ ហើយដាក់មាត់ ។

## ការបែកធ្លាយនៃបត្តបិណ្ឌិកង្គៈ

ក៏ធុតង្គរបស់ភិក្ខុទាំង ៣ ពួកនេះ រមែងបែកធ្លាយក្នុងខណៈដែលត្រេកអរនូវភាជនៈទីពីរ ។ នេះជាការបែកធ្លាយក្នុងបត្តបិណ្ឌិកង្គៈនោះ ។

ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ពាក្យថា **ភាជនៈទី ២** សេចក្តីថា ភាជនៈទី ២ សម្រាប់ទទួលអាហារនិងសម្លដែលចាត់ជាអាហារ ។ តែមិនមែនភាជនៈ-ទឹក មានកុណ្ឌីជាដើមទេ ។ តែនឹងត្រេកអរនឹងភាជនៈនោះ ក៏គួរ ព្រោះភាជនៈប្រកបកិច្ចក្នុងការឆាន់ភោជននោះ ។ ក៏លោកពោលពាក្យថា “ធុតង្គ” នេះទុក ដើម្បីវៀរតណ្ហាក្នុងរស ក្នុងការឆាន់ចេញ ។

## អានិសង្សនៃបត្តបិណ្ឌិកង្គៈ

ក៏អានិសង្សមានយ៉ាងនេះគឺ កិរិយាបន្ទោបង់ចំណង់ក្នុងរសផ្សេងៗ ១ កិរិយាលះបង់នូវភាពជាអ្នកមានសេចក្តីប្រាថ្នាលើស

លប់ក្នុងភាជនៈនោះៗ ១ ភាពជាអ្នកឃើញល្មមប្រមាណនៃប្រយោជន៍ក្នុងអាហារ ១ មិនមានសេចក្ដីលំបាកព្រោះកិរិយារក្សានូវវត្ថុមានថាសជាដើម ១ ភាពជាអ្នកបរិភោគមិនសាវារ ១ ភាពជាអ្នកប្រព្រឹត្តសមគួរដល់អប្បិច្ឆតាគុណជាដើម ។

<u>ដីកា</u> សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ព្រោះហេតុនោះ លោកពោលថា បន្ទោបង់តណ្ហាក្នុងរសផ្សេងៗ បាន ។ អធិប្បាយថា "ជាហេតុបន្ទោបង់តណ្ហាក្នុងរសភោជនផ្សេងៗ ដែលលាយគ្នានឹងគ្នាបានរបស់ភិក្ខុនោះ ។ ការៈនៃភិក្ខុអ្នកមានសេចក្ដីប្រាថ្នាក្នុងរសផ្សេងៗ ដែលដាក់នៅក្នុងភាជនៈផ្សេងៗ នោះ ឈ្មោះថា **ភាពជាអ្នកប្រាថ្នាច្រើន**, លះចេញបាននូវភាពជាអ្នកប្រាថ្នាច្រើននោះ ។ ភាពជាអ្នកមានប្រក្រតីឃើញប្រយោជន៍ គឺវត្ថុដែលប្រាថ្នាដែលល្មមប្រមាណ ដែលមាននៅក្នុងរាងកាយ ក្នុងភោជននោះៗឯង ឈ្មោះថា **ភាពជាអ្នកមានប្រក្រតីឃើញប្រយោជន៍** (ក្នុងអាហារ) ។ ថាសនិងស្លឹកឈើជាដើមដែលគួរនឹងដាក់សម្ល ឈ្មោះថា **ថាសជាដើម** គឺភាជនៈមានផ្ដិលទឹកជាដើម ព្រោះផ្ដិលទឹកជាដើមនោះ លោកត្រូវការប្រោកជ ។ ឈ្មោះថា **ភាពជាអ្នកបរិភោគមិនសាវារ** ព្រោះ

*មិនមានការខ្វល់ខ្វាយក្នុងការកាន់យកសម្ល ដែលនៅក្នុងភាជនៈផ្សេងៗ ។*

<u>*គាថាក្នុងគម្ពីរវិសុទ្ធិមគ្គ*</u> ៖

*អ្នកណាមួយ ជាអ្នកកាន់បត្តបិណ្ឌិកង្គធុតង្គ គប្បីលះបង់*
*នូវការសោវារក្នុងភាជនៈផ្សេងៗ មានចក្ខុឱនចុះហើយ*
*បីដូចកាលជីកនូវឫសទាំងឡាយនៃចំណង់ក្នុងរស ជាអ្នក*
*មានវត្តល្អ កាលរក្សានូវសេចក្ដីសន្ដោស បីដូចជារូបកាយ*
*របស់ខ្លួន មានចិត្តរីករាយបរិភោគអាហារ ។*

## ៣.៧ ពោលដោយខលុបច្ឆាភត្តិកង្គ

*ខលុបច្ឆាភត្តិកង្គៈ មានការសមាទានដោយពាក្យទាំងនេះថា* **“អតិរិត្តភោជនំ បដិក្ខិបាមិ** : *ខ្ញុំហាមឃាត់អតិរិត្តភោជន”*, **“ខលុបច្ឆាភត្តិកង្គំ សមាទិយាមិ** *: ខ្ញុំសមាទាននូវអង្គខលុបច្ឆាភត្តិកៈ” ដូច្នេះ ពាក្យណាមួយ ក៏បាន ។*

*ឯខលុបច្ឆាភត្តិកភិក្ខុនោះ ហាមភត្តហើយ មិនត្រូវប្រើគេឲ្យធ្វើភោជនឲ្យគួរ ហើយឆាន់ទៀតទេ ។*

## ប្រភេទនៃខលុបច្ឆាភត្តិកង្គៈ

*បើតាមប្រភេទខលុបច្ឆាភត្តិកភិក្ខុនេះ មាន ៣ ពួក ។ ក្នុង ៣ ពួកនោះ អ្នកកាន់ឧក្រិដ្ឋ មិនឈ្មោះថាហាមឃាត់ដុំទីមួយទេ, តែថា កាលដុំទីមួយនោះ ដែលខ្ជួនលេបទៅ ឈ្មោះថា ហាមឃាត់ នៅដុំដទៃ ព្រោះហេតុនោះ លោកហាមឃាត់យ៉ាងនេះហើយ លេបនូវដុំទីមួយហើយ នឹងឆាន់ដុំទីពីរមិនបាន ។ អ្នកកាន់យ៉ាងកណ្ដាល ហាមឃាត់កោជនណា ឆាន់កោជននោះវិញបាន ។ អ្នកកាន់ទន់ខ្សោយ មិនទាន់ក្រោកចាកអាសនៈដរាបណា បរិភោគបានដរាបនោះ ។*

## ការបែកធ្លាយនៃខលុបច្ឆាភត្តិកង្គៈ

*ក៏ធុតង្គនៃភិក្ខុទាំង ៣ ពួកនេះ រមែងបែកធ្លាយក្នុងខណៈដែលហាមឃាត់រួចហើយ ប្រើគេឲ្យធ្វើជាកប្បិយៈហើយឆាន់ ។ នេះជាការបែកធ្លាយ ក្នុងខលុបច្ឆាភត្តិកង្គៈនោះ ។*

## អានិសង្សនៃខលុបច្ឆាភត្តិកង្គៈ

ក៏អានិសង្សមានយ៉ាងនេះគឺ ភាពជាអ្នកឆ្ងាយចាកអាបត្តិ ព្រោះបរិភោគអនតិរិត្តភោជន ១ មិនមានភាពជាអ្នកមានអាហារតឹងពោះ (ហេលហាល) ១ ភាពជាអ្នកមិនសន្សំអាមិស ១ មិនមានកិរិយាស្វែងរកទៀត ១ ភាពជាអ្នកប្រព្រឹត្តសមគួរដល់អប្បិច្ឆតាគុណជាដើម ១ ។

ព្រះយោគីជាខលុបច្ឆាភត្តិកៈ អ្នកមានប្រាជ្ញា រមែងមិនលំបាក ព្រោះកិរិយាស្វែងរក មិនធ្វើនូវការសន្សំ លះបង់នូវភាពជាអ្នកហេលហាល ព្រោះហេតុនោះ ព្រះយោគីអ្នកប្រាថ្នាដើម្បីកំចាត់បង់នូវទោសទាំងឡាយ គប្បីគប់ (សមាទាន) ធុតង្គនេះ ដែលព្រះសុគតសរសើរហើយ ដែលញុំាងសេចក្ដីចម្រើនដោយគុណ មានសេចក្ដីសន្ដោសជាដើមឲ្យកើតព្រម ។

## ៣.៨-ពោលដោយអារញ្ញិកង្គៈ

*អារញ្ញិកង្គៈ មានកិរិយាសមាទានដោយពាក្យទាំងនេះថា* **“គាមន្តសេនាសនំ បដិក្ខិបាមិ** *: ខ្ញុំហាមឃាត់សេនាសនៈជាយ-ស្រុក”,* **“អារញ្ញិកង្គំ សមាទិយាមិ** *: ខ្ញុំសមាទាននូវអារញ្ញិកង្គៈ” ដូច្នេះ ពាក្យណាមួយក៏បាន ។*

*ក៏អារញ្ញិកភិក្ខុនោះ លះបង់សេនាសនៈជាយស្រុកហើយ គប្បីញុំាងអរុណឲ្យរះឡើងក្នុងព្រៃ ។ ក្នុងពាក្យថា ព្រៃនិងស្រុកនោះ ស្រុកព្រមទាំងឧបចារៈប្រទេសណាមួយ មានផ្ទះមួយខ្នងក្ដី មានផ្ទះច្រើនខ្នងក្ដី មានរបងក្ដី មិនមានរបងក្ដី មានមនុស្សក្ដី មិនមានមនុស្សក្ដី ដោយហោចទៅសូម្បីឈ្នួញរទេះណាមួយ ដែលអាស្រ័យនៅហើយលើសពី ៤ ខែ ឈ្មោះថា* **ស្រុក** *។ បើស្រុកមានរបង ដូចជាក្រុងអនុរាធបុរី មានសសរគោលពីរ, ទីធ្លាក់ចុះនៃដុំដីរបស់បុរសដែលមាន កម្លាំងជាកណ្ដាល ឈរនៅខាងក្នុងសសរគោល (ហើយចោល) ឈ្មោះថា* **ឧបចារៈស្រុក** *។ ព្រះវិន័យធរទាំងឡាយ ពោលថា “សូម្បីលក្ខណៈនៃលេឌ្ឌុបាតនោះ ក៏រួមត្រង់កន្លែងធ្លាក់ចុះនៃដុំដី ដែលបុរសមានកម្លាំងជា*

កណ្តាលបោលទៅ ដូចជាមនុស្សជំទង់ កាលសម្តែងនូវកម្លាំងរបស់ខ្លួន លាតដៃហើយបោលទៅនូវដុំដីយ៉ាងនោះ” ។ ឯភិក្ខុអ្នកទ្រទ្រង់នូវព្រះសូត្រ ពោលថា “ខាងក្នុងទីធ្លាក់ចុះនៃដុំដីដែលគេបោលទៅដោយប្រាថ្នាការពារសត្វក្អែក” ។ ក្នុងស្រុកដែលមិនមានរបង មាតុគ្រាមឈរជិតទ្វារផ្ទះដែលមានក្នុងទីបំផុតទាំងអស់ សាចទៅនូវទឹកណាដោយភាជនៈ ទីធ្លាក់ចុះនៃទឹកនោះឈ្មោះថា **ឧបចារៈនៃផ្ទះ** ។ ការធ្លាក់ចុះនៃដុំដីទី ១ តាមន័យដែលពោលហើយអំពីឧបចារៈនៃផ្ទះនោះមក ឈ្មោះថា **ស្រុក** ។ កិរិយាធ្លាក់ចុះនៃដុំដីទីពីរ ឈ្មោះថា **ឧបចារៈនៃស្រុក** ។ ឯព្រៃតាមសេចក្តីអធិប្បាយក្នុងអភិធម្ម លោកពោលថា “ចេញក្រៅអំពីសសរគោលទៅ ទីទាំងអស់នោះ ឈ្មោះថា ព្រៃ” ។ ក្នុងសេនាសនៈព្រៃ បើតាមសេចក្តីអធិប្បាយរបស់អ្នកទ្រទ្រង់ព្រះសូត្រ (ពោល) លក្ខណៈនេះថា សេនាសនៈ ឈ្មោះថា តាំងនៅព្រៃគឺសេនាសនៈទីបំផុត ៥០០ ធ្នូរធ្នូ ។ លក្ខណៈនោះ សម្រាប់ស្រុកមានរបង គប្បីកំណត់អំពីសសរគោល ដោយធ្នូដែលអាចារ្យលើកឡើងហើយ, សម្រាប់ស្រុកមិនមានរបង គប្បីវាស់

ហើយកំណត់ទុក ចាប់តាំងអំពីកិរិយាធ្លាក់ចុះនៃដុំដីជាដំបូង ដរាបដល់របងវត្ត ។ ក្នុងអដ្ឋកថាវិន័យ លោកពោលថា ប្រសិនបើជាវត្តមិនមានរបង ទីណាមុនគេបង្អស់ គឺសេនាសនៈក្តី សាលា-ភត្តក្តី កន្លែងប្រជុំដ៏ទៀងក្តី ដើមពោធិក្តី ចេតិយក្តី ប្រសិនបើមានក្នុងទីឆ្ងាយអំពីសេនាសនៈ គប្បីធ្វើទីនោះឲ្យជាទីកំណត់ហើយវាស់ចុះ ។ ឯក្នុងអដ្ឋកថា មជ្ឈិមនិកាយ លោកពោលថា គប្បីដកចេញនូវកិរិយាធ្លាក់ចុះនៃដុំដីទាំងពីរ ។ នេះជាប្រមាណក្នុងសេនាសនៈព្រៃនោះ ។

<u>ដីកា</u> សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

លក្ខណៈព្រៃមកហើយ **ក្នុងអទិន្នាទានបារាជិក** ដោយបរិយាយព្រះវិន័យ ព្រោះព្រះថេរៈជាអ្នកទ្រទ្រង់ព្រះសូត្រ ប្រាថ្នាយកស្ថានទី ៥០០ ធ្នូវធ្នូ អំពីសសរគោលតែម្តង ថាជាឧបចារ-ស្រុក។ ពាក្យថា **៥០០ ធ្នូវធ្នូយ៉ាងទាប** នេះ មកហើយក្នុងអរញ្ញិកសិក្ខាបទ ក្នុងព្រះវិន័យសូម្បីក៏ពិត, សូម្បីយ៉ាងនោះលោកពោលពាក្យជាដើមថា "តែក្នុងពាក្យថាព្រៃនេះ" លោកពោលទុកហើយតាមន័យព្រះសូត្រ ព្រោះពាក្យថា ព្រៃ ដែលមកហើយក្នុងអរញ្ញិកសិក្ខាបទនោះ សំដៅដល់ភិក្ខុអ្នកនៅព្រៃជាវត្ត ។ បណ្តា

*ពាក្យទាំងនោះពាក្យថា* **អារោបិតេន** *(លើកឡើង) សេចក្ដីថា ខ្សែធ្នូដែលអាចារ្យបង្អោនហើយ ។ ដោយពាក្យនេះ អាចារ្យសម្ដែងដល់ធ្នូខ្ចី ព្រោះធ្នូកោង ។ ដោយសិល្បៈរៀនធ្នូសម្រាប់អាចារ្យទាំងឡាយប្រមាណធ្នូមិនធំពេក ហេតុនោះ លោកទើបពោលថា* ***ដោយធ្នូរបស់អាចារ្យ*** *។*

តប្បន ឥទានិ មនុស្សានំ ចតុហត្ថប្បមាណំ, អារោបិតំ អឌ្ឍដ្ឋរតនប្បមាណន្តិ វទន្តិ ។ *តែអាចារ្យទាំងឡាយពោលថា ធ្នូនោះប្រមាណ ៤ ហត្ថ របស់មនុស្សឥឡូវនេះ, និងកាលធ្នូនោះត្រូវកោងឡើងប្រមាណ ៧ ចំអាមកន្លះ ។*

*ព្រោះសេចក្ដីដែលពោលដោយធុតង្គ ទាក់ទងដោយព្រះសូត្រ លោកទើបពោលថា នេះជាប្រមាណក្នុងសេនាសនៈព្រៃនោះ ។*

*<u>គម្ពីរវិសុទ្ធិមគ្គ</u> លោកពោលទៀតថា ៖*

*ប្រសិនបើមានស្រុកក្នុងទីជិត ពួកភិក្ខុនៅវត្ត ឮសំឡេងមនុស្សទាំងឡាយ តែមិនអាចដើម្បីទៅដោយត្រង់បាន ព្រោះមានភ្នំ និងស្ទឹងជាដើមខាន់, ផ្លូវណាជាផ្លូវដើរប្រក្រតីសម្រាប់ស្រុកនោះ ប្រសិនបើនឹងគប្បីទៅដោយទូក ក៏គប្បីកាន់យកទី ៥០០*

ជួរធ្នូតាមផ្លូវនោះ ។ ភិក្ខុណាមួយ បិទផ្លូវមកអំពីស្រុកនោះៗ ដើម្បីញុំាងនីងឲ្យសម្រេចជាអង្គនៃស្រុកជិត ភិក្ខុនេះ ឈ្មោះថា ធុតង្គចោរ ។ ក៏ប្រសិនបើឧបជ្ឈាយ៍ ឬអាចារ្យរបស់ភិក្ខុអ្នកនៅក្នុងព្រៃ គប្បីនាំទៅកាន់សេនាសនៈជាយស្រុកហើយបម្រើចុះ ។ តែបើត្រូវចេញទៅអំពីព្រលឹម គប្បីញុំាងអរុណឲ្យរះក្នុងទីដែលប្រកបដោយអង្គ ។ បើក្នុងវេលាអរុណរះ អាពាធរបស់ឧបជ្ឈាយ៍ជាដើមនោះចម្រើនឡើង គប្បីធ្វើកិច្ចដល់ឧបជ្ឈាយ៍ជាដើមនោះចុះ កុំគប្បីជាអ្នកម៉ត់ចត់ក្នុងធុតង្គ ។

## ប្រភេទនៃអារញ្ញិកង្គៈ

បើតាមប្រភេទអារញ្ញិកភិក្ខុនេះ មាន ៣ ពួក ។ ក្នុង ៣ ពួកនោះ អ្នកកាន់ឧក្រិដ្ឋ គប្បីញុំាងអរុណឲ្យរះក្នុងព្រៃគ្រប់កាល ។ អ្នកកាន់កណ្ដាល រមែងបានដើម្បីនៅជាយស្រុកអស់ ៤ ខែ ដែលជារដូវភ្លៀង ។ អ្នកកាន់យ៉ាងធូរថយ រមែងបានដើម្បីនៅជាយស្រុក អស់ ៤ ខែទៀត ដែលជារដូវរងារ ។

ដីកា បរមត្ថមញ្ជូសា ១, ៤១២ ពន្យល់ថា ៖

ពាក្យថា ក្នុងព្រៃគ្រប់កាល សេចក្ដីថា សម្រាប់ភិក្ខុអ្នកកាន់យ៉ាងឧក្រិដ្ឋ ក៏ទាំង ៣ រដូវ សម្រាប់ភិក្ខុអ្នកកាន់យ៉ាងកណ្ដាល ២ រដូវ សម្រាប់ភិក្ខុអ្នកកាន់យ៉ាងខ្សោយ ១ រដូវ ។

## ការបែកធ្លាយនៃអារញ្ញិកង្គ:

ក៏កាលភិក្ខុទាំង ៣ ពួកនេះ មកអំពីព្រៃក្នុងកាលដែលខ្លួនកំណត់ទុកហើយ ស្ដាប់ធម៌ ក្នុងសេនាសនៈជិតស្រុក, កាលអរុណរះឡើង ធុតង្គមិនបែកធ្លាយទេ ។ លុះស្ដាប់ហើយត្រឡប់ទៅ សូម្បីអរុណរះឡើងក្នុងចន្លោះផ្លូវ ក៏មិនបែកធ្លាយ ។ ប្រសិនបើធម្មកថិកក្រោកឡើងហើយ អ្នកកាន់ធុតង្គនិទ្រា ដោយគិតថា យើងទាំងឡាយ នឹងដេកមួយស្របក់សិនហើយសឹមទៅ, អរុណរះឡើង, ញុំាងអរុណឲ្យរះឡើងក្នុងសេនសនៈជិតស្រុក តាមសេចក្ដីគាប់ចិត្តរបស់ខ្លួន ធុតង្គរមែងបែកធ្លាយ ។ នេះជាការបែកធ្លាយក្នុងអារញ្ញិកធុតង្គនោះ ។

ដីកា បរមត្ថមញ្ជូសា ១, ៤១២ ពន្យល់ថា ៖

ពាក្យថា **ធុតង្គមិនបែកធ្លាយ** សូម្បីក្នុងកាលតាមដែលកំណត់ទុកនោះ ក៏ព្រោះសេចក្ដីដែលនៅមានឧស្សាហៈ ។ ពាក្យថា **យើងនឹងដេកមួយស្របក់សិនហើយសឹមទៅ** ជាការដែលលោកអធិប្បាយថា ធុតង្គរមែងបែកធ្លាយបាន ព្រោះសេចក្ដីធូរថយនៃចិត្ត ។

## អានិសង្សនៃអារញ្ញិកធុតង្គៈ

ឯអានិសង្សមានដូចតទៅនេះ ។ ភិក្ខុអ្នកនៅក្នុងព្រៃ កាលធ្វើទុកក្នុងចិត្តនូវអារញ្ញសញ្ញា គួរដើម្បីបានសមាធិ ដែលខ្លួនមិនទាន់បាន ឬដើម្បីរក្សាសមាធិដែលខ្លួនបានហើយ, សូម្បីព្រះសាស្ដា រមែងគាប់ព្រះទ័យចំពោះភិក្ខុនោះ ។ សមដូចទ្រង់សម្ដែងថា "ម្នាលភិក្ខុ ឈ្មោះថា នាគិតៈ ព្រោះហេតុនោះ តថាគតរមែងគាប់ចិត្តដល់ភិក្ខុនោះ ដោយកិរិយានៅក្នុងព្រៃជាវត្ត" ។ ម្យ៉ាងទៀត អារម្មណ៍ទាំងឡាយ មានរូបមិនជាទីសប្បាយជាដើម រមែងមិនរុកកួនចិត្ត របស់ភិក្ខុអ្នកនៅក្នុងសេនាសនៈដ៏ស្ងាត់នោះបាន ។ ជាអ្នកមិនមានសេចក្ដីតក់ស្លុត តែងលះបង់សេចក្ដី

អាឡោះអាល័យក្នុងជីវិត តែងត្រេកអរនូវសេចក្តីសុខដែល, កើតអំពីសេចក្តីស្ងប់ស្ងាត់, មួ៉ាងទៀត សូម្បីភាពនៃភិក្ខុអ្នកទ្រទ្រង់សំពត់បង្សុកូលជាដើម រមែងសមគួរដល់ភិក្ខុអ្នកនៅក្នុងព្រៃជាវត្តនោះដែរ ។

ភិក្ខុអ្នកមានចិត្តស្ងប់ស្ងាត់ មិនប្រឡូកប្រឡំ ត្រេកអរហើយក្នុងសេនាសនៈដ៏ស្ងប់ស្ងាត់ ញ៉ាំងព្រះទ័យនៃព្រះ-លោកនាថ ឲ្យត្រេកអរ ដោយកិរិយានៅក្នុងព្រៃតែម្នាក់-ឯង កាលនៅក្នុងព្រៃ រមែងបាននូវសេចក្តីសុខណា រសនៃសេចក្តីសុខនោះ សូម្បីទេព្តាព្រមទាំងព្រះឥន្ទ្រ ក៏មិនបានជួបប្រទះ ។ មួ៉ាងទៀត ភិក្ខុអ្នកនៅក្នុងព្រៃនេះ កាលទ្រទ្រង់នូវសំពត់បង្សុកូល ដូចជាព្រះរាជាកាលទ្រង់នូវគ្រឿងក្រោះ ទៅកាន់សង្គ្រាម គឺព្រៃ មានធុតង្គធម៌ដ៏សេសដោយយោធា រមែងជាអ្នកអាចដើម្បីឈ្នះមារព្រមទាំងពាហនៈ អស់កាលមិនយូរណាស់ ព្រោះហេតុនោះ បណ្ឌិតគប្បីធ្វើសេចក្តីត្រេកអរ ចំពោះការនៅក្នុងព្រៃចុះ ។

## ៣.៩ ពោលដោយរុក្ខមូលិកង្គៈ

*រុក្ខមូលិកង្គៈ មានកិរិយាសមាទានដោយពាក្យទាំងនេះថា* **“ឆន្នំ បដិក្ខិបាមិៈ** *ខ្ញុំហាមឃាត់នូវទីប្រក់បាំង”,* **“រុក្ខមូលិកង្គំ សមាទិយាមិៈ** *ខ្ញុំសមាទាននូវរុក្ខមូលិកង្គៈ” ដូច្នេះ ពាក្យណាមួយក៏បាន ។*

*ក៏រុក្ខមូលិកភិក្ខុនោះ គប្បីវៀរដើមឈើទាំងនេះ “គឺដើមឈើដែលស្ថិតនៅព្រំដែន ដើមឈើជាចេតិយ ដើមឈើមានជ័រ ដើមឈើមានផ្លែ ដើមឈើមានផ្កា ដើមឈើមានសត្វប្រចៀវ ឬជ្រឹង ដើមឈើមានប្រហោង ដើមឈើដែលស្ថិតនៅក្នុងពាក់កណ្តាលវិហារ” ហើយកាន់យកដើមឈើដែលតាំងនៅ ក្នុងទីបំផុតនៃវិហារ (វត្ត) ។ នេះជាវិធីនៃរុក្ខមូលិកង្គៈនោះ ។*

*<u>ដីកា</u> សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖*

*ពាក្យថា* ***ទីប្រក់បាំង*** *សេចក្តីថា ទីនៅអាស្រ័យដែលប្រក់បាំងដោយឥដ្ឋជាដើម ។ ពាក្យថា* ***សីមន្តរិករុក្ខំ*** *(ដើមឈើដែលស្ថិតនៅព្រំដែន) សេចក្តីថា ដើមឈើដែលឋិតនៅត្រង់រជ្ជសីមារបស់ព្រះរាជា ២ ព្រះអង្គ ។ ក៏ស្ថានទីនោះ ជាទីចូលទៅប្រយុទ្ធគ្នាជាដើមបៀតបៀនគ្នា ។*

## ប្រភេទនៃរុក្ខមូលិកង្គ:

ឯរុក្ខមូលិកង្គ: បើតាមប្រភេទមាន ៣ ពួក ។ ក្នុង ៣ ពួកនោះ អ្នកកាន់ឧក្រិដ្ឋ រមែងមិនបានដើម្បីកាន់យកដើមឈើ តាមគាប់ចិត្តហើយឲ្យជម្រះទេ, គប្បីយកជើងបោសស្ទីកឈើ ហើយសឹមនៅ ។ អ្នកកាន់យ៉ាងកណ្ដាល រមែងបានដើម្បីញ៉ាំងជនទាំងឡាយដែលមកដល់ព្រមហើយនៅទីនោះ ឲ្យជម្រះបាន ។ អ្នកកាន់ធូរថយ នឹងហៅញោមវត្ត និងសាមណេរគ្រោស់ ឲ្យជម្រះ ឲ្យធ្វើឲ្យរាបស្មើ ឲ្យរោយដីខ្សាច់ ឲ្យធ្វើព័ន្ធព័ទ្ធ ឲ្យដាក់ទ្វារហើយគប្បីនៅ ។ តែក្នុងថ្ងៃជាទីធ្ងន់ រុក្ខមូលិកភិក្ខុ មិនត្រូវអង្គុយក្នុងទីកន្លែងនោះទេ, ត្រូវអង្គុយក្នុងទីដទៃ ដែលកំបាំង ។

<u>ដីកា</u> សារត្ថបត្ថជោតនី ភាគ១ ពន្យល់ថា ៖

**បាទេនាតិ ឥទំ បដិជគ្គនេ អព្យាវដំ ទស្សេតុំ វុត្តំ ។ សាខាភង្គាទី គហេត្វា សោធេតុំបិ វដ្ដតេវ ។**

ពាក្យថា **ប្រើជើង** នេះ លោកពោលទុកដើម្បីសម្ដែងដល់សេចក្ដីខ្វល់ខ្វាយក្នុងការបោសសំអាតស្ថានទី ។ សូម្បីចាប់យកមែកឈើដែលបាក់ជាដើមមកជម្រះ ក៏គួរពិត ។

## ការបែកធ្លាយនៃរុក្ខមូលិកង្គៈ

*ក៏ធុតង្គនៃភិក្ខុទាំង ៣ ពួកនេះ រមែងបែកធ្លាយ ក្នុងខណៈដែលសម្រេចការនៅក្នុងទីប្រក់បាំង ។ លោកអ្នកពោលគម្ពីរអង្គុត្តរនិកាយ ពោលថា ធុតង្គនោះ រមែងបែកធ្លាយ និមិត្តហេតុត្រឹមតែដែលខ្លួនដឹង ហើយញុំាងអរុណឲ្យរះឡើង ក្នុងទីប្រក់បាំងៗ នេះជាការបែកធ្លាយក្នុងរុក្ខមូលិកង្គៈនោះ ។*

## អានិសង្សនៃរុក្ខមូលិកង្គៈ

*ក៏អានិសង្សមានដូចតទៅនេះគឺ ភាពជាអ្នកបដិបត្តិសមគួរដល់និស្ស័យ ព្រោះព្រះបាលីថា បព្វជ្ជាអាស្រ័យនូវសេនាសនៈទៀបគល់ឈើ ១ ភាពជាអ្នកមានបច្ច័យដែលព្រះមានព្រះភាគពណ៌នាហើយថា បច្ច័យទាំងនោះតិចផង បានងាយផង ពុំមានទោសផង ១ ភាពជាអ្នកញុំាងអនិច្ចសញ្ញាឲ្យកើតឡើង ដោយកិរិយាឃើញការប្រែប្រួលនៃស្លឹកឈើខ្ចីរឿយៗ ១ កិរិយាមិនមានសេចក្ដីកំណាញ់ក្នុងសេនាសនៈ និងមិនត្រេកអរក្នុងការងារ ១ ភាពជាអ្នកនៅជាមួយទេវតាទាំងឡាយ ១ ភាពជាអ្នកប្រព្រឹត្តសមគួរដល់អប្បិច្ឆតាគុណជាដើម ១ ។*

*ទីលំនៅដែលព្រះពុទ្ធដ៏ប្រសើរ ទ្រង់សរសើរហើយ និង ទ្រង់សម្តែងហើយ ថាជាទីគួរអាស្រ័យនៃព្រះយោគី ជាអ្នក ស្ងប់ស្ងាត់, ទីនៅស្មើដោយគល់ឈើមានពីណា, ព្រោះ ព្រះយោគី កាលនៅទៀបគល់ឈើដ៏ស្ងាត់ ដែលទេវតា រក្សាហើយ ជាគ្រឿងនាំចេញនូវសេចក្តីកំណាញ់អាវាស ជាអ្នកមានវត្តល្អ កាលឃើញស្លឹកឈើខ្ចីទាំងឡាយ មាន ពណ៌ក្រហមឆ្អៅ ពណ៌ខៀវ និងពណ៌លឿង ដែលជ្រុះ ហើយ រមែងបន្ទោបង់នូវសេចក្តីសម្គាល់ថាទៀង, ព្រោះ ហេតុនោះ អ្នកមានប្រាជ្ញា មិនត្រូវមើលងាយគល់ឈើ ដែលស្ងប់ស្ងាត់ ជាមត៌កនៃព្រះពុទ្ធ ដែលជាលំនៅនៃ ព្រះយោគី អ្នកត្រេកអរហើយក្នុងភាវនា ។*

## ៣.១០_ពោលដោយអព្ភោកាសិកង្គៈ

*អព្ភោកាសិកង្គៈ មានកិរិយាសមាទានដោយពាក្យទាំងនេះ ថា* **“ឆន្នញ្ញា បដិក្ខិបាមិ** *: ខ្ញុំហាមឃាត់ទីប្រក់បាំងនិងគល់ឈើ”,*

**“អព្ភោកាសិកង្គំ សមាទិយាមិ** : *ខ្ញុំសមាទាននូវអព្ភោកាសិកង្គៈ” ដូច្នេះ ពាក្យណាមួយក៏បាន ។*

*ក៏អព្ភោកាសិកភិក្ខុនោះ នឹងចូលទៅកាន់រោងឧបោសថ ដើម្បីស្តាប់ធម៌ ឬដើម្បីធ្វើឧបោសថ រមែងគួរ ។ ប្រសិនបើលោកចូលទៅហើយភ្លៀងបង្អុលចុះ, កាលភ្លៀងកំពុងបង្អុលចុះ មិនគប្បីចេញ, គប្បីចេញទៅក្នុងពេលរាំងភ្លៀង ។ ការដែលអព្ភោកាសិកភិក្ខុចូលទៅកាន់រោងភោជន ឬរៀនខ្ទឹងឯង ឬបង្រៀនចូលទៅសូម្បីកាន់ទីប្រក់បាំងក្តី វត្តុទាំងឡាយមានគ្រែនិងតាំងជាដើមដែលគេទុកដាក់មិនល្អខាងក្រៅ នឹងយកចូលទៅខាងក្នុងក្តី រមែងគួរទាំងអស់ ។ បើអព្ភោកាសិកភិក្ខុទៅតាមផ្លូវ ជាអ្នកកាន់បរិក្ខារបស់ភិក្ខុចាស់ជាង, កាលបើភ្លៀងបង្អុលចុះ នឹងចូលទៅកាន់សាលាដែលស្ថិតនៅក្នុងទីពាក់កណ្តាលផ្លូវ រមែងគួរ ។ បើលោកមិនបានកាន់អ្វីទេ នឹងប្រញាប់ចូលទៅដោយគិតថា អញនឹងនៅក្នុងសាលា ដូច្នេះ មិនគួរទេ ។ តែបើលោកដើរតាមធម្មតាចូលទៅហើយ គប្បីស្ថិតនៅដរាបដល់រាំងភ្លៀងហើយទៅចុះ ។ នេះជាវិធីនៃអព្ភោកាសិកភិក្ខុនោះ ។ សូម្បីរុក្ខមូលិកភិក្ខុ ក៏មានន័យដូចគ្នានេះ ។*

*ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖*

*ពាក្យថា* ***ដើម្បីស្ដាប់ធម៌*** *នេះ លោកសម្ដែងថា "អព្ភោ-កាសិកភិក្ខុ សូម្បីមានកិច្ចមានការពោលធម៌ និងធ្វើថ្នាំសម្រាប់អ្នកជម្ងឺជាដើម ចូលទៅកាន់ទីប្រក់ រមែងគួរ" ។*

***បកតិគតិយា គន្ត្វា បរិវេណទ្វារ ឯតេន មគ្គំ អធិដ្ឋាយ បរិសិតព្វន្តិ ទស្សេតិ*** *។ ពាក្យថា* ***ដើរចូលទៅតាមធម្មតា*** *នេះ លោកសម្ដែងថា "គប្បីអធិដ្ឋាននូវផ្លូវ ហើយចូលទៅតាមផ្លូវនោះ" ។*

## ប្រភេទនៃអព្ភោកាសិកង្គៈ

*បើតាមប្រភេទ* ***អព្ភោកាសិកភិក្ខុ*** *នេះ មាន ៣ ពួក ។ ក្នុង ៣ ពួកនោះ អ្នកកាន់ឧក្រិដ្ឋ នៅអាស្រ័យដើមឈើ ភ្នំ ឬផ្ទះ មិនគួរ។ គប្បីធ្វើកុដិចីវរទីវាល ហើយនៅតែម្យ៉ាង ។ អ្នកកាន់ថ្នាក់កណ្ដាល នឹងនៅអាស្រ័យដើមឈើ ភ្នំ និងផ្ទះ មិនចូលទៅខាងក្នុង រមែងគួរ ។ អ្នកកាន់ធូរថយ នឹងនៅអាស្រ័យញកភ្នំដែលគេមិនបានប្រក់បាំងក្ដី មណ្ឌបនៃមែកឈើក្ដី សំពត់ដែលជ្រលក់ដោយមៀវក្ដី ខ្ទមដែលស្ថិតនៅក្នុងទីនោះ ដែលជនអ្នក*

រុក្ខាស្រែជាដើមចោលហើយក្តី រមែងគួរ ។

## ការបែកធ្លាយនៃអព្ភោកាសិកង្គៈ

ឯធុតង្គនៃភិក្ខុ ៣ ពួកនេះ រមែងបែកធ្លាយក្នុងខណៈដែលចូលទៅកាន់ទីប្រក់បាំង និងគល់ឈើ ដើម្បីនៅ ។ លោកអ្នកពោលគម្ពីរអង្គុត្តរនិកាយពោលថា ធុតង្គរមែងបែកធ្លាយ និមិត្តហេតុត្រឹមតែព្រះយោគី ជីងខ្លួនហើយបណ្តោយឲ្យអរុណរះឡើងក្នុងទីនោះ ។ នេះជាការបែកធ្លាយក្នុងអព្ភោកាសិកង្គនោះ ។

## អានិសង្សនៃអព្ភោកាសិកង្គៈ

ឯអានិសង្សដូចតទៅនេះគឺ កិរិយាផ្តាច់បង់នូវកង្វល់ក្នុងអាវាស ១ កិរិយាបន្ទោបង់នូវថីនមិទ្ធៈ ១ ជាអ្នកគួរដល់សេចក្តីសរសើរថាភិក្ខុទាំងឡាយ អ្នកត្រាច់ទៅដោយមិនមានការជាប់ជំពាក់ មិនមានសេចក្តីអាឡោះអាល័យ ដូចជាហ្វូងម្រឹគ ១ ភាពជាអ្នកមិនប្រឡូកប្រឡំ ១ ភាពជាអ្នកប្រាកដក្នុងទិសទាំងបួន ១ ភាពជាអ្នកសមគួរដល់អប្បិច្ឆតាគុណជាដើម ១ ។

ភិក្ខុកាលនៅក្នុងទីវាល ដ៏សមគួរដល់ភាពនៃបុគ្គល មិនមានផ្ទះ ដែលបានឆាយ (មិនមែនបានដោយលំបាក) មានពិតានកែវមណី គឺដួងផ្កាយ ដែលភ្លឺស្វាងដោយប្រទីប គឺព្រះចន្ទ្រ មានចិត្តដូចម្រឹគ បន្ទោបង់នូវចិត្តដែលរួញរា និងងុយងោកងក់ អាស្រ័យភាពជាអ្នកត្រេកអរក្នុងភាវនា រមែងបានសេចក្តីត្រេកអរ ក្នុងរសដែលកើតអំពីសេចក្តីស្ងប់ស្ងាត់ ដោយកាលមិនយូរមែនពិត ព្រោះហេតុនោះឯង អ្នកមានប្រាជ្ញា គប្បីត្រេកអរក្នុងទីវាល ។

## ៣.១១~ពោលដោយសោសានិកង្គៈ

*សោសានិកង្គៈ* មានកិរិយាសមាទានដោយពាក្យទាំងនេះថា **“ន សុសានំ បដិក្ខិបាមិ** *: ខ្ញុំមិនហាមឃាត់ព្រៃស្មសាន”*, **“សោសានិកង្គំ សមាទិយាមិ** *: ខ្ញុំសមាទាននូវសោសានិកង្គៈ”* ដូច្នេះ ពាក្យណាមួយក៏បាន ។

ក៏មនុស្សទាំងឡាយ តាំងទុកនូវស្រុក ហើយកំណត់ថាទីនេះជាព្រៃស្មសាន ដូច្នេះ ភិក្ខុអ្នកនៅក្នុងព្រៃស្មសានជាវត្តនោះ

មិនត្រូវនៅក្នុងទីនោះទេ ។ ព្រោះថា កាលបើសរីរៈដែលស្លាប់ហើយ គេមិនទាន់ដុតទីនោះ មិនឈ្មោះថាព្រៃស្មសានទេ ។ ប្រសិនបើជាទីដែលគេបោះបង់ចោលអស់ ១២ ឆ្នាំ ចាប់ដើមអំពីកាលដែលដុតហើយ ឈ្មោះថា **ព្រៃស្មសាន** ។ ក៏ភិក្ខុអ្នកនៅក្នុងព្រៃស្មសាន នៅក្នុងទីនោះ មិនគប្បីឲ្យគេធ្វើទីចង្ក្រម និងមណ្ឌបជាដើម មិនគប្បីឲ្យគេចាត់ចែងគ្រែនិងតាំង មិនគប្បីឲ្យគេតម្កល់ទឹកឆាន់ ហើយបង្រៀនធម៌ ទើបនៅទេ ។ ព្រោះថា ធុតង្គនេះជារបស់ធ្ងន់ ។ ព្រោះហេតុនោះ ភិក្ខុអ្នកនៅក្នុងព្រៃស្មសាន គប្បីញុំាងសង្ឃត្ថេរ ឬញុំាងនាយស្មៀនស្តេចឲ្យដឹងហើយ គប្បីនៅដោយសេចក្តីមិនប្រមាទ ដើម្បីកំចាត់បង់នូវសេចក្តីអន្តរាយដែលកើតឡើង ។ លោកកាលចង្ក្រម គប្បីមានភ្នែកពាក់កណ្តាលក្រឡេកមើលប៉ាឆា ។ សូម្បីកាលទៅកាន់ព្រៃស្មសាន គប្បីចុះចាកផ្លូវធំ ហើយទៅតាមផ្លូវតូច ។ ភិក្ខុអ្នកនៅក្នុងព្រៃស្មសានត្រូវកំណត់អារម្មណ៍ ក្នុងពេលថ្ងៃឲ្យហើយ ។ ព្រោះថា កាលបើយ៉ាងនេះ អារម្មណ៍នោះ នឹងមិនជារបស់គួរខ្លាចដល់លោកក្នុងរាត្រីទេ ។ ពួកអមនុស្សសូម្បីត្រាច់ស្រែកក្នុងរាត្រី សោសានិក-

ភិក្ខុ មិនត្រូវយកអ្វីមួយប្រហារទេ ។ ការដែលលោកមិនទៅកាន់ព្រៃស្មសានសូម្បីតែមួយថ្ងៃ ក៏មិនគួរ ។ លោកអ្នកពោលគម្ពីរអង្គុត្តរនិកាយ ពោលថា ការដែលសោសានិកភិក្ខុ ញុំាំងមជ្ឈិមយាមឲ្យអស់ទៅក្នុងព្រៃស្មសាន ហើយត្រឡប់វិញក្នុងបច្ឆិមយាមទើបគួរ ។ បង្អែមនិងចង្អាប មានម្សៅលាយល្ង កត្តលាយសណ្តែក ត្រី សាច់ ទឹកដោះ ប្រេង និងស្ករអំពៅជាដើម ជាទីគាប់ចិត្តរបស់ពួកអមនុស្ស, ភិក្ខុអ្នកនៅព្រៃស្មសាន មិនគប្បីឆាន់ទេ ។ សោសានិកភិក្ខុ មិនត្រូវចូលកាន់ខ្ទមអ្នកតាទេ ។

## ប្រភេទសោសានិកង្គៈ

បើតាមប្រភេទ សោសានិកភិក្ខុនេះមាន ៣ ពួក ។ ក្នុង ៣ ពួកនោះ អ្នកកាន់ឧក្រិដ្ឋ គប្បីនៅក្នុងព្រៃស្មសាន ដែលមានការដុតជានិច្ច មានសាកសពជានិច្ច មានការទួញយំជានិច្ច ។ អ្នកកាន់ថ្នាក់កណ្តាល កាលហេតុ ៣ យ៉ាងនោះ មានសូម្បីតែមួយក៏គួរ ។ អ្នកកាន់ជូរថយ នឹងទៅក្នុងទីត្រឹមតែដល់នូវលក្ខណៈនៃព្រៃស្មសាន តាមន័យដែលពោលហើយ ក៏គួរ ។

## ការបែកធ្លាយនៃសោសានិកង្គៈ

ឯធុតង្គនៃភិក្ខុ ៣ ពួកនេះ រមែងបែកធ្លាយដោយកិរិយាសម្រេចការនៅក្នុងទីមិនមែនជាព្រៃស្មសាន ។ លោកអ្នកពោលគម្ពីរអង្គុត្តរនិកាយ ពោលថា ធុតង្គ រមែងបែកធ្លាយ ក្នុងថ្ងៃដែលខ្លួនមិនទៅកាន់ព្រៃស្មសាន ។ នេះជាការបែកធ្លាយ ក្នុងសោសា-និកង្គៈនោះ ។

## អានិសង្សនៃសោសានិកង្គៈ

ឯអានិសង្សមានដូចតទៅនេះគឺ កិរិយាបាននូវមរណស្សតិ ១ ភាពជាអ្នកនៅដោយសេចក្ដីមិនប្រមាទ ១ កិរិយាបាននូវនិមិត្តជាមិនស្អាត ១ កិរិយាបន្ទោបង់សេចក្ដីតម្រេកក្នុងកាម ១ កិរិយាឃើញនូវសភាពនៃកាយរឿយៗ ១ ភាពជាអ្នកច្រើនដោយសេចក្ដីសង្វេគ ១ កិរិយាលះបង់នូវសេចក្ដីស្រវឹង មានស្រវឹងថាមិនមានរោគជាដើម ១ ភាពជាអ្នកអត់ទ្រាំនូវភ័យដ៏ពន្លឹក ១ ភាពជាអ្នកគួរដល់សេចក្ដីគោរពនៃពួកមនុស្ស ១ ភាពជាអ្នកប្រព្រឹត្តសមគួរដល់អប្បិច្ឆតាគុណ ជាដើម ១ ។

ក៏ព្រោះជាដែនកើតនៃមរណានុស្សតិ ទោសគឺសេចក្តីប្រមាទ រមែងមិនប៉ះពាល់នូវសោសានិកភិក្ខុ សូម្បីសិងលក់ហើយ, ម្យ៉ាងទៀត កាលលោកឃើញសាកសពជាច្រើន ចិត្តសូម្បីដល់ហើយនូវអំណាចនៃសេចក្តីតម្រេកក្នុងកាម ក៏មិនមាន, លោករមែងដល់នូវសេចក្តីសង្វេគយ៉ាងច្រើន មិនដល់នូវសេចក្តីស្រវឹងឡើយ, ម្យ៉ាងទៀត ព្រះយោគី កាលស្វែងរកសេចក្តីរលត់ រមែងប្រឹងប្រែងដោយប្រពៃ, ព្រោះហេតុនោះ កុលបុត្រ អ្នកមានហឫទ័យបង្អោនទៅរកព្រះនិព្វាន គប្បីចូលទៅសេពគប់នូវអង្គនៃសោសានិកង្គ ព្រោះជារបស់នាំមកនូវគុណជាអនេក ។

## ៣.១២_ពោលដោយយថាសន្ថតិកង្គ:

យថាសន្ថតិកង្គ: មានកិរិយាសមាទានដោយពាក្យទាំងនេះថា **“សេនាសនលោលុប្បំ បដិក្ខិបាមិ** : ខ្ញុំហាមឃាត់នូវសេចក្តីល្មោភ

*ក្នុងសេនាសនៈ”,* **“យថាសន្តិកង្គំ សមាទិយាមិ** *: ខ្ញុំសមាទាននូវយថាសន្ថតិកង្គៈ” ដូច្នេះ ពាក្យណាមួយក៏បាន ។*

*ឯយថាសន្ថតិកភិក្ខុនោះ គប្បីត្រេកអរដោយសេនាសនៈដែលភិក្ខុអ្នកចែកសេនាសនៈនោះចែកឲ្យហើយ កាន់យកដោយគិតថា សេនសនៈនេះ ត្រូវបានលោក ។ មិនត្រូវឲ្យភិក្ខុដទៃក្រោកចេញទេ ។*

## ប្រភេទនៃយថាសន្តិកង្គៈ

*បើតាមប្រភេទ យថាសន្ថតិកភិក្ខុនេះ មាន ៣ ពួក ។ ក្នុង ៣ ពួកនោះ អ្នកកាន់ឧក្រិដ្ឋ រមែងមិនបានដើម្បីសួរនូវសេនាសនៈដែលដល់ខ្លួនថា ឆ្ងាយឬជិត អមនុស្ស និងទីឃជាតិជាដើមបៀតបៀនឬ ក្តៅ ឬត្រជាក់ ។ អ្នកកាន់ថ្នាក់កណ្តាល រមែងមិនបានដើម្បីសួរ តែមិនបានដើម្បីទៅមើល ។*

*មុទុកោ គន្ត្វា ឱលោកេត្វា សចស្ស តំ ន រុច្ចតិ, អញ្ញំ គហេតុំ លភតិ ។ អ្នកកាន់ធូរថយ រមែងបានដើម្បីទៅមើល បើខ្លួនមិនគាប់ចិត្តទេ កាន់យកសេនាសនៈដទៃបាន ។*

*<u>ដីកា</u> សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖*

***ន រុច្ចតីតិ អត្តនោ បកតិយា វិវេកាទីនំ វិរុទ្ធតាយ ន រុច្ចតិ ។*** *ពាក្យថា មិនគាប់ចិត្ត ឈ្មោះថា មិនគាប់ចិត្ត ព្រោះខុសទៅអំពីទីស្ងាត់ជាដើមតាមប្រក្រតីនៃខ្លួន ។*

## ការបែកធ្លាយនៃយថាសន្តតិកង្គៈ

*ឯធុតង្គនៃភិក្ខុទាំង ៣ ពួកនេះ តែងបែកធ្លាយនិមិត្តហេតុត្រឹមតែសេចក្តីល្មោភក្នុងសេនាសនៈ ។ នេះជាការបែកធ្លាយក្នុងយថាសន្តតិកង្គៈនោះ ។*

## អានិសង្សក្នុងយថាសន្តតិកង្គៈ

*ឯអានិសង្សមានដូចតទៅនេះគឺ កិរិយាធ្វើតាមឱវាទដែលទ្រង់សម្តែងថា ខ្លួនបានវត្ថុណា គប្បីត្រេកអរដោយវត្ថុនោះ ១ ជាអ្នកស្វែងរកប្រយោជន៍ដល់សព្រហ្មចារី ១ កិរិយាលះបង់នូវសេចក្តីកំណត់ថា ថោកទាបនិងថ្លៃថ្លា ១ កិរិយាលះបង់នូវសេចក្តីត្រេកអរនិងសេចក្តីខឹង ១ កិរិយាបិទទ្វារនៃភាពជាអ្នកប្រាថ្នាច្រើន ១ ភាពជាអ្នកប្រព្រឹត្តសមគួរដល់អប្បិច្ឆតាគុណជាដើម ១។*

*ព្រះយោគីជាយថាសន្ថតិកៈ (អ្នកនៅក្នុងសេនាសនៈតាមតែសង្ឃប្រចាំបែង) ត្រេកអរតែនឹងសេនាសនៈដែលខ្លួនបានហើយ ជាអ្នកអស់សេចក្តីកំណាត់ រមែងដេកជាសុខសប្បាយលើកម្រាលស្មៅ, លោកមិនត្រេកអរតែក្នុងសេនាសនៈដ៏ប្រសើរ បានសេនាសនៈដ៏ថោកទាប ក៏មិនខឹង, តែងអនុគ្រោះសព្រហ្មចារីថ្មីៗ ដោយប្រយោជន៍, ព្រោះហេតុនោះ អ្នកមានប្រាជ្ញា គប្បីប្រកបរឿយៗ នូវភាពនៃខ្លួនជាអ្នកត្រេកអរយថាសន្ថតិកង្គធុតង្គ សន្សំភាពជាព្រះអរិយៈ, ដែលព្រះពុទ្ធជាកំពូលនៃអ្នកប្រាជ្ញទ្រង់សរសើរហើយ ។*

## ៣.១៣_ពោលដោយនេសជ្ជិកង្គៈ

*ឯនេសជ្ជិកង្គៈ មានការសមាទានដោយពាក្យទាំងនេះថា* **“សេយ្យំ បដិក្ខិបាមិ** *: ខ្ញុំហាមឃាត់នូវទីដេក,* **“នេសជ្ជិកង្គំ សមាទិយាមិ** *: ខ្ញុំសមាទាននូវនេសជ្ជិកង្គៈ” ដូច្នេះ ពាក្យណាមួយក៏បាន ។ ក៏នេសជ្ជិកភិក្ខុនោះ គប្បីក្រោកចង្រ្កមអស់យាម ១*

ក្នុងយាមទាំង ៣ នៃរាត្រី ។ ព្រោះថា ក្នុងឥរិយាបថទាំងឡាយ ការដេកតែម្យ៉ាងមិនគួរ ។

ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

**សេយ្យន្តិ តិរិយំ បិដ្ឋិកណ្ឌកបសារណឥរិយាបថ-សេយ្យំ** ។ ពាក្យថា **ការដេក** សេចក្តីថា ការដេកព្រមដោយឥរិយាបថសណ្តូកឆ្អឹងសន្ទាក់ខ្នងរាបស្មើទទឹង ។

ព្រះយោគី ឈ្មោះថាមានឥរិយាបថ ៣ ព្រោះហាមឥរិយាបថនេះប៉ុណ្ណោះ លោកពោលថា នេសជ្ជិកះ ដោយអំណាចការអង្គុយយ៉ាងឧក្រិដ្ឋ ព្រោះមិនមានការអង្គុយវៀរចាកការឈរនិងការដើរចេញ ។ ព្រោះហេតុនោះ លោកទើបពោលពាក្យមានជាដើមថា “នេសជ្ជិកភិក្ខុនោះ គប្បីក្រោកចង្រ្កម” ។ ព្រោះថា លោកអធិដ្ឋានថា “យើងកាន់ការអង្គុយជាវត្ត” ហើយក៏អង្គុយរហូតរាត្រីទាំងពួង មិនគប្បីដេក ។ ក៏ព្រះមានព្រះភាគ ទ្រង់អនុញ្ញាតធុតង្គនេះទុក ដើម្បីបន្ទោបង់សេចក្តីលក់ហើយប្រកបនៅក្នុងមនសិការប៉ុណ្ណោះ ព្រោះហេតុនោះ កាលគ្របសង្កត់សេចក្តីខ្ជិលប្រអូស គប្បីក្រោកឡើងចង្រ្កម ។ តែកាលគ្រប

សង្កត់សេចក្ដីលក់ ការចង្រ្កមរហូតទាំងរាត្រី ប្រព្រឹត្តទៅដើម្បីអាពាធផ្លូវរាងកាយ ហេតុនោះ ភិក្ខុអ្នកកាន់ការអង្គុយជាវត្តអង្គុយរហូតយាមកណ្ដាល ដេកលក់ហើយ គប្បីឲ្យមានសតិការប្រព្រឹត្តទៅដោយដើរចង្រ្កម និងអង្គុយតាមសប្បាយក្នុងយាមក្រោយនេះ ។ លោកសំដៅយកសេចក្ដីនេះប៉ុណ្ណោះ ទើបពោលថា "គប្បីក្រោកឡើងចង្រ្កមមួយយាម" ។

## ប្រភេទនៃនេសជ្ជិកង្គៈ

បើតាមប្រភេទនេសជ្ជិកភិក្ខុនេះ មាន ៣ ពួក ។ ក្នុង ៣ ពួកនោះ អ្នកកាន់ឧក្រិដ្ឋ បង្អែក ក៏មិនគួរ, សំពត់សម្រាប់ត្របោម ក៏មិនគួរ, ផ្ទាំងសំពត់សម្រាប់ប្រតោង ក៏មិនគួរ ។ អ្នកកាន់ថ្នាក់កណ្ដាល វត្ថុណាមួយក្នុង ៣ យ៉ាងនេះ រមែងគួរ ។ អ្នកកាន់ធូរថយ បង្អែកក្ដី សំពត់សម្រាប់ត្របោមក្ដី ផ្ទាំងសំពត់សម្រាប់ប្រតោងក្ដី ខ្នើយក្ដី កៅអីមានអង្គ ៥ ក្ដី មានអង្គ ៧ ក្ដី រមែងគួរៗ ជម្មតាកៅអីមានអង្គ ៥ គេធ្វើព្រមដោយបង្អែកខាងខ្នង ។ កៅអីមានអង្គ ៧ គេធ្វើព្រមដោយបង្អែកខាងខ្នង និងដោយក្ទាក់ដៃទាំងពីរខាង ។ បានឮថា ពួកមនុស្សបានធ្វើកៅអីនោះ ដើម្បី

ព្រះចូឡាភយត្ថេរ អ្នកទ្រទ្រង់ព្រះត្រៃបិដក ។ ព្រះថេរៈជាព្រះអនាគាមី បរិនិព្វានហើយ ។

## ការបែកធ្លាយនៃនេសជ្ជិកង្គធុតង្គៈ

ឯធុតង្គនៃភិក្ខុទាំង ៣ ពួកនេះ តែងបែកធ្លាយនិមិត្តហេតុត្រឹមតែសម្រេចការដេក ។

## អានិសង្សនៃនេសជ្ជិកង្គៈ

ឯអានិសង្សមានដូចតទៅនេះគឺ កិរិយាចូលទៅផ្តាច់បង់នូវកិលេសជាគ្រឿងចងធ្នាក់ចិត្ត ដែលទ្រង់សម្តែងថា អ្នកប្រកបរឿយៗ នូវការដេកជាសុខ ផ្អែកជាសុខ លក់ជាសុខ ១ ភាពជាអ្នកសប្បាយក្នុងការប្រកបរឿយៗ នូវកម្មដ្ឋានទាំងអស់ ១ ភាពជាអ្នកមានឥរិយាបថគួរជ្រះថ្លា ១ ភាពជាអ្នកសមគួរដល់កិរិយាប្រារព្ធព្យាយាម ១ កិរិយាបង្កើនសម្មាបដិបត្តិ ១ ។

ព្រះយោគី ពត់ភ្នែនអន្ទុយតម្រង់កាយឲ្យត្រង់ តែងញុំាង
ហឫទ័យមារឲ្យកម្រើក, ភិក្ខុលះការដេកជាសុខ លះការ
លក់ជាសុខ មានសេចក្តីព្យាយាមប្រារព្ធហើយ ត្រេកអរ

ក្រៃពេកក្នុងការអន្ទុយ ញុំាងព្រៃគឺតបៈឲ្យរុងរឿង តែងជួប ប្រទះនូវសេចក្ដីសុខ កើតអំពីបីតិមិនមានអាមិស, ព្រោះ ហេតុនោះ អ្នកប្រាជ្ញគប្បីប្រកបរឿយៗ នូវនេសជ្ជិកវត្ត ។

## ៤ បកិណ្ណកកថានៃធុតង្គ

ឥឡូវនេះ នឹងពណ៌នាដោយអំណាចនៃគាថា ៖ គប្បីជ្រាប សេចក្ដីវិនិច្ឆ័យដោយពួក ៣ នៃកុសល ដោយកិរិយាញែកសត្វ ទាំងឡាយ មានធុតសត្វជាដើម និងទាំងដោយការបំព្រួញ និង ដោយពិស្ដារ ដូច្នេះ ។

### ៤.១ វិនិច្ឆ័យដោយកុសលត្តិកៈ

ក្នុងមាតិកានោះ នឹងវិនិច្ឆ័យត្រង់មាតិកាថា កុសលត្តិកៈ សេចក្ដីពិតថា ធុតង្គទាំងអស់ ជាកុសលក៏មាន ជាអព្យាកតៈ ក៏មាន ដោយអំណាចនៃសេក្ខបុគ្គល បុថុជ្ជន និងព្រះខីណាស្រព ទាំងឡាយ, ធុតង្គជាអកុសលមិនមាន ។ បើអ្នកណា គប្បី ពោលថា ធុតង្គជាអកុសលក៏មានដែរ ព្រោះបាលីជាដើមថា ភិក្ខុមានសេចក្ដីលាមក ច្រើនដោយសេចក្ដីប្រាថ្នា ជាអ្នកនៅ

ក្នុងព្រៃ ដូច្នេះ, បណ្ឌិតគប្បីជំទាស់អ្នកនោះថា យើងមិននិយាយថា "ភិក្ខុមិននៅក្នុងព្រៃដោយអកុសលចិត្តទេ", សេចក្តីពិត ភិក្ខុណានៅក្នុងព្រៃ ភិក្ខុនោះ ឈ្មោះថា អារញ្ញិកៈ, តែថា អារញ្ញិកៈភិក្ខុនោះ ប្រាថ្នាលាមកក៏មាន ប្រាថ្នាតិចក៏មាន, ក៏ធុតង្គទាំងនេះជាអង្គនៃភិក្ខុអ្នកកំចាត់បង់ ព្រោះភាវៈនៃកិលេស គឺលោកកំចាត់បង់ហើយ ដោយសមាទាននោះៗ, ម្យ៉ាងទៀត ញាណដែលមានវោហារបានហើយថា **ធុតៈ** ព្រោះកំចាត់បង់នូវកិលេសកាមជាអង្គនៃគុណជាតិទាំងនោះ ព្រោះដូច្នោះ អង្គនោះ ឈ្មោះថា **ធុតង្គ**, ការសមាទានទាំងនោះ ឈ្មោះថា ធុតៈ ព្រោះកំចាត់បង់នូវធម៌ជាសត្រូវ និងឈ្មោះថា អង្គជាគ្រឿងបដិបត្តិ ដូចអធិប្បាយមកនេះ ទើបឈ្មោះថា ធុតង្គ, ម្យ៉ាងទៀត ការសមាទានទាំងនោះជាអង្គនៃភិក្ខុណា ភិក្ខុនោះណាមួយ មិនឈ្មោះថា កំចាត់បង់ដោយអកុសលទេ, មួយទៀត អកុសលកំចាត់បាបណាមួយមិនបាន អកុសលនោះ ឈ្មោះថា ជាអង្គនៃការសមាទានណា ព្រោះអធិប្បាយនេះ បណ្ឌិតគប្បីពោលការសមាទាននោះ របស់ភិក្ខុទាំងនោះថា ធុតង្គ, អើក៏អកុសល កំចាត់នូវសេចក្តីល្មោភ

ក្នុងចីវរជាដើមមិនបានទេ និងបាត់អង្គនៃការបដិបត្តិ ក៏មិនបាន, ព្រោះហេតុនោះ ពាក្យនេះថា ធុតង្គជាអកុសលមិនមានដូច្នេះ គឺលោកពោលល្អហើយ, ធុតង្គសូម្បីរបស់ភិក្ខុណា ដែលផុតស្រឡះហើយចាកប្រមាណបីនៃកុសល, ដោយសេចក្តី ភិក្ខុទាំងនោះ មិនមានធុតង្គ ។ របស់មិនមាន និងឈ្មោះថា ធុតង្គ ព្រោះកំចាត់បង់នូវអ្វី ? ឯកំហុសព្រោះបាលីថា ភិក្ខុសមាទាននូវធុតង្គគុណហើយប្រព្រឹត្តដូច្នេះ និងត្រូវដល់ភិក្ខុនេះ ដោយហេតុនោះ ពាក្យទាំងនោះ បណ្ឌិតមិនគប្បីកាន់យកទេ ។ ពណ៌នាដោយកុសលត្តិកៈ បណ្ឌិតគប្បីជ្រាបដូចពោលមកនេះចុះ ។

ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ក៏ធុតង្គដែលជាអព្យាកតៈ ដោយអំណាចព្រះខីណាស្រពប៉ុណ្ណោះ ដើម្បីលោកទាំងនោះនៅជាសុខដោយវិវេកដែលប្រាកដក្នុងកាលមិនមានការកំចាត់កិលេសជាបច្ច័យ និងដើម្បីដល់ភាពជាទិដ្ឋានុគតិរបស់ពួកជនដទៃ ។ ក្នុងទីនេះ ធុតង្គនេះ លោកប្រាថ្នាយកដោយការធ្វើយ៉ាងក្រៃលែង ដោយការគ្រដោះបណ្តាញគឺតណ្ហា ។ សម្រាប់ជនដ៏សេស មានធុតង្គដែលជាកុសលប៉ុណ្ណោះ, កុសលធុតង្គនោះ លោកប្រាថ្នាយកក្នុងទីនេះ ។

*សូម្បីបើថា បុគ្គលគប្បីបានវោហារថា “អ្នកនៅព្រៃ” ដោយហេតុត្រឹមតែនៅក្នុងព្រៃដោយកាយ សូម្បីមានចិត្តជាអកុសលសោត តែក្នុងទីនេះ លោកប្រាថ្នាយកថា អារញ្ញិកធុតង្គ សម្រាប់បុគ្គលពួកនោះ, កាលជាដូច្នោះ មិនប្រាថ្នាយកបុគ្គលពួកនោះទេ ហេតុនោះ ដើម្បីសម្តែងសេចក្តីនេះ ដែលធ្លាប់មានការសម្តែងអត្ថរបស់ស័ព្ទធុតង្គ ដែលពោលទុកក្នុងខាងក្រោយ ទើបពោលពាក្យមានជាដើមថា “ដោយការនៅព្រៃនៃភិក្ខុណា” ។*

## ៤.២ វិនិច្ឆ័យដោយវិភាគ

**ធុតាទីនំ វិភាគតោ**តិ ធុតោ វេទិតព្វោ ។ ធុតវាទោ វេទិតព្វោ ។ ធុតធម្មា វេទិតព្វា ។ ធុតង្គានិ វេទិតព្វានិ ។ កស្ស ធុតង្គសេវនា សប្បាយាតិ វេទិតព្វំ ។

*ត្រង់បទថា **ធុតាទីនំ វិភាគតោ** (ដោយវិភាគនៃធុតៈជាដើម) សេចក្តីថា បណ្ឌិតគប្បីជ្រាបធុតៈ ។ គប្បីជ្រាប ធុតវាទ ។ គប្បីជ្រាបធុតធម៌ទាំងឡាយ ។ គប្បីជ្រាបធុតង្គទាំងឡាយ ។ គប្បីជ្រាបបុគ្គលប្រភេទណាសេពធុតង្គ ទើបសប្បាយ ។*

## ធុតះ

តត្ថ **ធុតោ**តិ ធុតកិលេសោ វា បុគ្គលោ កិលេសធុននោ វា ធម្មោ ។ *ក្នុងបទទាំងនោះបទថា* ***ធុតោ*** *(**ធុតះ**) បានសេចក្តីថា បុគ្គលមានកិលេសកំចាត់បង់ហើយ ឬធម៌ជាគ្រឿងកំចាត់បង់នូវកិលេស ។*

*<u>ដីកា</u> បរមត្ថមញ្ជូសា ភាគ១ ពន្យល់ថា ៖*

កាមំ សព្វោបិ អរហា ធុតកិលេសោ, ឥធ បន ធុតង្គសេវនាមុខេន កិលេសេ វិធុនិត្វា ឋិតោ ខីណាសវោ **"ធុតកិលេសោ បុគ្គលោ"**តិ អធិប្បេតោ។ តថា សព្វោបិ អរិយមគ្គោ និប្បរិយាយេន **កិលេសធុននោ ធម្មោ,** វិសេសតោ អគ្គមគ្គោ។ បរិយាយេន បន វិបស្សនាញាណាទិ។ ហេដ្ឋិមបរិច្ឆេទេន ធុតង្គចេតនាសម្បយុត្តញាណំ ទដ្ឋព្វំ ។

*ព្រះអរហន្ត សូម្បីគ្រប់ព្រះអង្គ ឈ្មោះថា ធុតកិលេស-បុគ្គល (បុគ្គលអ្នកកំចាត់កិលេសហើយ) ក៏ពិត, តែថា ក្នុងទីនេះ លោកប្រាថ្នាយកព្រះខីណាស្រពអ្នកកំចាត់កិលេស ដោយមានការសេពធុតង្គជាផ្លូវ តាំងនៅថាជា "ធុតកិលេសបុគ្គល" បុគ្គលអ្នកកំចាត់កិលេសហើយ ។ អរិយមគ្គសូម្បីទាំងអស់ក៏ដូចយ៉ាងនោះ ឈ្មោះថា មគ្គជាគ្រឿងកំចាត់កិលេស ដោយនិប្បរិយាយ*

*(ដោយត្រង់), ដោយពិសេស ក៏បានដល់មគ្គជាន់ខ្ពស់ (អរហត្ត-មគ្គ) ។ ដោយបរិយាយ (ដោយអម) បានដល់ វិបស្សនាញាណជាដើម ។ ដោយការកំណត់យ៉ាងទាប គប្បីឃើញថា បានដល់ញាណដែលសម្បយុត្តនឹងចេតនាក្នុងធុតង្គ ។*

*ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖*

*ពាក្យថា* ធុតកិលេសោ *(បុគ្គលមានកិលេសកំចាត់បង់ហើយ) មានសេចក្ដីថា បុគ្គលអ្នកកំចាត់កិលេសហើយដោយសំដៅដល់ការបដិបត្តិធុតង្គសមាទាន មានកល្យាណបុថុជ្ជនជាដើម មានព្រះខីណាស្រពជាទីបំផុត ។ ពាក្យថា* កិលេសធុននោ *(ធម៌ជាគ្រឿងកំចាត់បង់នូវកិលេស) សេចក្ដីថា កុសលធម៌មានបញ្ញាជាគ្រឿងសមាទានធុតង្គទាំងនោះជាខាងដើម មានអរហត្តមគ្គជាទីបំផុត ។*

## ធុតវាទ

**ធុតវាទោ**តិ ឯត្ថ បន អត្ថិ ធុតោ ន ធុតវាទោ, អត្ថិ ន ធុតោ ធុតវាទោ, អត្ថិ នេវ ធុតោ ន ធុតវាទោ, អត្ថិ ធុតោ ចេវ ធុតវាទោ ច ។

*ក៏ក្នុងបទ* **ធុតវាទោ** *(ធុតវាទ) អធិប្បាយថា បុគ្គលមាន*

ធុតៈ តែមិនមានធុតវាទ ក៏មាន, បុគ្គលមិនមានធុតៈ តែមានធុតវាទ ក៏មាន, បុគ្គលមិនមានធុតៈ និងមិនមានធុតវាទ ក៏មាន, បុគ្គលមាន ទាំងធុតៈ មានទាំងធុតវាទ ក៏មាន ។

ក្នុង ៤ ពួកនោះ បុគ្គលណាកំចាត់បង់នូវកិលេសទាំងឡាយរបស់ខ្លួនដោយធុតង្គ តែមិនទូន្មាន មិនប្រៀនប្រដៅបុគ្គលដទៃ ដោយធុតង្គទេ ដូចព្រះពាកុលត្ថេរ បុគ្គលនេះ ឈ្មោះថា មានធុតៈ (អ្នកកំចាត់បង់នូវកិលេស) តែមិនឈ្មោះថា ធុតវាទ (អ្នកពោលពាក្យជាគ្រឿងកំចាត់បង់នូវកិលេសទេ) ។ ដូចលោកពោលថា ព្រះពាកុលត្ថេរដ៏មានអាយុនោះឯង ឈ្មោះថា អ្នកកំចាត់បង់នូវកិលេស តែមិនឈ្មោះថា ពោលពាក្យជាគ្រឿងកំចាត់បង់នូវកិលេស ។

ន័យមួយទៀត បុគ្គលណា មិនកំចាត់បង់នូវកិលេសរបស់ខ្លួន ដោយធុតង្គ តែទូន្មានប្រៀនប្រដៅបុគ្គលដទៃ ដោយធុតង្គប៉ុណ្ណោះ ដូចព្រះឧបនន្ទត្ថេរ បុគ្គលនេះ មិនឈ្មោះថា កំចាត់បង់នូវកិលេសទេ តែឈ្មោះថា មានវាទៈជាគ្រឿងកំចាត់បង់នូវកិលេស ។ ដូចលោកពោលថា ព្រះឧបនន្ទដ៏មានអាយុនោះឯង

*ជាបុត្រនៃសក្យៈ មិនមែនកំចាត់បង់នូវកិលេសទេ តែមានវាទៈ ជាគ្រឿងកំចាត់បង់នូវកិលេស ។*

*បុគ្គលណាវិបត្តិចាកគុណទាំងពីរ ដូចលោលុទាយី បុគ្គលនេះឈ្មោះថា មិនកំចាត់បង់ និងមិនមានវាទៈជាគ្រឿងកំចាត់បង់នូវកិលេស ។ ដូចលោកពោលថា លោលុទាយីដ៏មានអាយុនោះឯង មិនឈ្មោះថា កំចាត់បង់នូវកិលេស និងមិនមានវាទៈ ជាគ្រឿងកំចាត់បង់នូវកិលេស ។*

*ន័យមួយទៀត បុគ្គលណា បរិបូរណ៍ដោយគុណទាំងពីរ ដូចព្រះធម្មសេនាបតី បុគ្គលនេះ ឈ្មោះថា កំចាត់បង់កិលេស និងមានវាទៈជាគ្រឿងកំចាត់បង់នូវកិលេស ។ ដូចលោកពោលថា ព្រះសារីបុត្រដ៏មានអាយុនោះឯង ឈ្មោះថា កំចាត់បង់នូវកិលេស និងមានវាទៈជាគ្រឿងកំចាត់បង់នូវកិលេស ។*

## ធុតធម៌

**ធុតធម្មា វេទិតព្វា**តិ អប្បិច្ឆតា, សន្តុដ្ឋិតា, សល្លេខតា, បវិវេកតា, ឥទមត្ថិតាតិ ឥមេ ធុតង្គចេតនាយ បរិវារកា បញ្ច ធម្មា "អប្បិច្ឆំយេវ និស្សាយា"តិ អាទិវចនតោ ធុតធម្មា នាម ។

ពាក្យថា **ធុតធម្មា វេទិតព្វា** (គប្បីជ្រាបធុតធម៌ទាំងឡាយ) អធិប្បាយថា ធម៌ ៥ យ៉ាង ជាបរិវារនៃធុតង្គចេតនាទាំងនេះគឺ ភាពនៃសេចក្តីប្រាថ្នាតិច ១ ភាពនៃសេចក្តីសន្តោស ១ ភាពនៃកិរិយាជុះខាត់នូវកិលេស ១ ភាពនៃសេចក្តីស្ងប់ស្ងាត់ ១ ភាពនៃការឃើញថា គុណជាតិនេះមានប្រយោជន៍ ១ ឈ្មោះថា ធុតធម៌ ព្រោះព្រះបាលីថា ព្រោះអាស្រ័យការប្រាថ្នាតិច ដូច្នេះជាដើម ។

ក្នុងធម៌ទាំង ៥ នោះ ភាពនៃសេចក្តីប្រាថ្នាតិច និងភាពនៃសេចក្តីសន្តោស រាប់ចូលក្នុងអលោភៈ (សេចក្តីមិនលោភ), ភាពនៃកិរិយាជុសខាត់នូវកិលេស និងភាពនៃសេចក្តីស្ងប់ស្ងាត់ រាប់ចូលក្នុងធម៌ទាំងពីរគឺ អលោភៈ អមោហៈ (សេចក្តីមិនវង្វេង), ភាពនៃការឃើញថា គុណជាតិនេះមានប្រយោជន៍ (ឥទមត្ថិតា) បានដល់ ញាណនោះឯង ។ បណ្តាអលោភៈ និងអមោហៈនោះ ភិក្ខុអ្នកសមាទានធុតង្គ រមែងឲ្យអលោភៈ កំចាត់បង់សេចក្តីលោភ ក្នុងវត្ថុដែលត្រូវហាមឃាត់, រមែងឲ្យអមោហៈ កំចាត់បង់សេចក្តីវង្វេង ដែលជាគ្រឿងបិទបាំងនូវទោសក្នុងវត្ថុទាំងនោះ ដោយអមោហៈ ។ ម្យ៉ាងទៀត កំចាត់បង់កាមសុខានុយោគ ដែលប្រព្រឹត្តទៅដោយ (អាស្រ័យ) កិរិយាសេពបច្ច័យទាំងឡាយដែលទ្រង់អនុញ្ញាតទុកហើយ ដោយអលោភៈ,

រមែងកំចាត់បង់នូវអត្តកិលមថានុយោគ ដែលប្រព្រឹត្តទៅដោយប្រធាន គឺកិរិយាជុសខាត់ដ៏ក្រៃលែងនូវកិលេស ក្នុងធុតង្គទាំងឡាយ ដោយអមោហៈ ។ ព្រោះហេតុនោះ ធម៌ ៥ យ៉ាងទាំងនេះគប្បីជ្រាបថា **ធុតធម៌** ។

បទថា **ធុតង្គានិ វេទិតព្វានិ** (គប្បីជ្រាបធុតង្គ) គឺគប្បីជ្រាបធុតង្គមាន ១៣ គឺបំសុកូលិកង្គៈ ។ល។ នេសជ្ជិកង្គៈ ។ ធុតង្គទាំងនោះ ខ្ញុំបានពោលទុកដោយអត្ថ និងដោយអាការមានលក្ខណៈជាដើមហើយតែម្ដង ។

បទថា **កស្ស ធុតង្គសេវនា សប្បាយ** (បុគ្គលប្រភេទណាសេពធុតង្គទើបសប្បាយ កែថា ការសេពធុតង្គសប្បាយសម្រាប់បុគ្គលរាគចរិត និងបុគ្គលមោហចរិត ។ ព្រោះហេតុអ្វី ? ព្រោះការសេពធុតង្គ ជាទុក្ខាបដិបទា (បដិបត្តិលំបាក) និងសល្លេខវិហារ ដែលរាគៈ រមែងស្ងប់ ព្រោះអាស្រ័យទុក្ខាបដិបទា, មោហៈ អ្នកដែលមិនប្រមាទ រមែងលះបង់បាន ព្រោះអាស្រ័យសល្លេខបដិបត្តិ ។ម្យ៉ាងទៀត ក្នុងធុតង្គទាំងនោះ ការសេពអារញ្ញិកង្គ និងរុក្ខមូលិកង្គ ជាទីសប្បាយ សូម្បីនៃបុគ្គលទោសចរិត ។ ព្រោះកាលបុគ្គលទោសចរិតនោះ សូម្បីមិនមាន

*អ្នកណាប៉ះទង្គិច នៅក្នុងព្រៃ និងទៀបគល់ឈើនោះ សូម្បីទោសៈក៏រមែងស្ងប់ឯង នេះជាពាក្យពណ៌នាដោយវិភាគសត្វ មានធុតសត្វជាដើម ។*

## ៤.៣ ធុតង្គដោយសង្ខេប

*បទថា* **សមាសព្យាសតោ** *សេចក្តីថា ក៏ធុតង្គទាំងនេះ ដោយសង្ខេបមាន ៨ ទាំងនេះគឺ អង្គដែលជាប្រធាន ៣, ដែលមិនប្រឡំគ្នា ៥ ។ បណ្តាអង្គ ៨ ទាំងនោះ អង្គ ៣ ទាំងនេះគឺ* ***សបទានចារិកង្គៈ ឯកាសនិកង្គៈ និងអព្ភោកាសិកង្គៈ*** *ឈ្មោះថាអង្គដែលជាប្រធាន ។ ព្រោះថា ភិក្ខុកាលរក្សាសបទានចារិកង្គក៏ឈ្មោះថា នឹងរក្សាបិណ្ឌបាតិកង្គផង ។ ក៏កាលលោករក្សាឯកាសនិកង្គ សូម្បីបត្តបិណ្ឌិកង្គ និងខលុបច្ឆាភត្តិកង្គ ក៏នឹងជាអង្គដែលលោកគប្បីរក្សាបានផង ។ កាលលោករក្សា អព្ភោ-កាសិកង្គៈ មានអ្វីឈ្មោះថាដែលត្រូវរក្សាក្នុងរុក្ខមូលិកង្គៈ និងយថាសន្ថតិកង្គៈ ។ ព្រោះហេតុនោះ ធុតង្គទើបមាន ៨ ទាំងនេះ គឺអង្គដែលជាប្រធាន ៣ និងអង្គដែលមិនប្រឡំគ្នា ៥ យ៉ាងនេះគឺ* ***អារញ្ញិកង្គៈ បង្សុកូលិកង្គៈ តេចីវរិកង្គៈ នេសជ្ជិកង្គៈ សោសានិកង្គៈ*** *។*

ម្យ៉ាងទៀត (បំប្រួញចុះមកទៀត) មាន ៤ យ៉ាងនេះគឺ ២ ជាចីវរប្បដិសំយុត្ត, ៥ ជាបិណ្ឌបាតប្បដិសំយុត្ត, ៥ ជាសេនាសនប្បដិសំយុត្ត, ១ ជាវីរិយប្បដិសំយុត្ត ។ ក្នុងធុតង្គទាំងនោះ នេសជ្ជិកង្គ: ជាវីរិយប្បដិសំយុត្ត ។ ធុតង្គក្រៅនេះ ប្រាកដពិត ។

ធុតង្គទាំងអស់មាន ២ ដោយអំណាចនិស្ស័យទៀតគឺ ធុតង្គ ១២ អាស្រ័យបច្ច័យ ១ អាស្រ័យសេចក្ដីព្យាយាម ។

ម្យ៉ាងទៀត មានពីរ ដោយអំណាចនៃធុតង្គគួរសេព និង មិនគួរសេព ។ ព្រោះថា កាលភិក្ខុអង្គណា សេពធុតង្គ កម្មដ្ឋាន រមែងចម្រើន ភិក្ខុអង្គនោះ គប្បីសេព ។ កាលភិក្ខុអង្គណា សេពធុតង្គ កម្មដ្ឋានវិនាស ភិក្ខុអង្គនោះ មិនគួរសេពទេ ។ ម្យ៉ាងទៀត កាលភិក្ខុណា សេពក្ដី មិនសេពក្ដី កម្មដ្ឋាន តែង ចម្រើន មិនសាបសូន្យ សូម្បីភិក្ខុនោះ កាលអនុគ្រោះនូវប្រជុំជន ខាងក្រោយ គប្បីសេព ។ សូម្បីកាលភិក្ខុណាសេពក្ដី មិនសេពក្ដី កម្មដ្ឋានរមែងមិនចម្រើន ភិក្ខុនោះ គប្បីសេពចុះ ដើម្បីប្រយោជន៍ ដល់កិរិយានៅតទៅ ។ ធុតង្គមានពីរយ៉ាង ដោយអំណាចនៃ អង្គដែលគួរសេព និងមិនគួរសេព ដូចពណ៌នាមកនេះ ។

ធុតង្គទាំងអស់មានតែមួយយ៉ាង ដោយអំណាចនៃចេតនាសូម្បីក្នុងអដ្ឋកថា ក៏លោកពោលថា ចេតនាជាហេតុសមាទាននូវធុតង្គតែម្យ៉ាងប៉ុណ្ណោះ ។ ចេតនាជាហេតុសមាទានណា លោកហៅចេតនានោះថា **ធុតង្គ** ។

## ៤.៤ វិនិច្ឆ័យធុតង្គដោយពិស្តារ

បើដោយពិស្តារ ធុតង្គមាន ៤២ គឺ ធុតង្គ ១៣ សម្រាប់ភិក្ខុ, ៨ សម្រាប់ភិក្ខុនី, ១២ សម្រាប់សាមណេរ, ៧ សម្រាប់សិក្ខមានា និងសាមណេរី, ២ សម្រាប់ឧបាសក និងឧបាសិកា ។ ប្រសិនបើថា ព្រៃស្មសានដល់ព្រមដោយអារញ្ញិកៈ មានក្នុងទីវាល ភិក្ខុសូម្បីមួយរូប ក៏អាចដើម្បីប្រើប្រាស់ធុតង្គទាំងអស់បានដោយព្រមគ្នាតែម្តង ។ តែសម្រាប់ភិក្ខុនី ធុតង្គទាំង ២ គឺ អារញ្ញិកង្គៈ និងខលុបច្ឆាភត្តិកង្គៈ ទ្រង់ហាមដោយសិក្ខាបទពិត ។ ធុតង្គទាំង ៣ នេះគឺ អព្ភោកាសិកង្គៈ រុក្ខមូលិកង្គៈ សោសានិកង្គៈ ពួកភិក្ខុនី រក្សាបានដោយលំបាក ។ ព្រោះកិរិយាដែលនាងភិក្ខុនីវៀរភិក្ខុនីជាគម្រប់ពីរហើយនៅ មិនគួរ ។ ម្យ៉ាងទៀត សម្លាញ់-ស្រី ជាគម្រប់ពីរ មានសេចក្តីប្រាថ្នាស្មើគ្នា ក្នុងទីមានសភាព

យ៉ាងនេះ គឺជាបុគ្គលរកបានដោយក្រ ។ ប្រសិនបើបាន ក៏មិនរួចអំពីកិរិយានៅច្រឡូកច្រឡំ ។ កាលបើយ៉ាងនេះមាន ភិក្ខុនីសេពធុតង្គដើម្បីប្រយោជន៍ណា ប្រយោជន៍នោះ មិនសម្រេចដល់នាងឡើយ ។ កាលបើយ៉ាងនេះ គប្បីជ្រាបថា ធុតង្គសម្រាប់ភិក្ខុនីមានតែ ៨ ដោយដក ៥ ចេញ ព្រោះលោកមិនអាចដើម្បីប្រើប្រាស់បាន ។ ក៏ក្នុងធុតង្គដូចដែលពោលហើយ លើកទុកតេចីវរិកង្គៈ គប្បីជ្រាបថា ធុតង្គដ៏សេស ១២ សម្រាប់សាមណេរ ៧ សម្រាប់សិក្ខមានា និងសាមណេរី ។

តែសម្រាប់ឧបាសក និងឧបាសិកា ធុតង្គទាំងនេះ គឺ **ឯកាសនិកង្គៈ** និង**បត្តបិណ្ឌិកង្គៈ**ប៉ុណ្ណោះសមគួរ នឹងអាចប្រើ-ប្រាស់បាន ដូច្នោះ ទើបមានត្រឹមពីរយ៉ាង ។

ធុតង្គ មាន ៤២ ដោយពិស្ដារ ដូចអធិប្បាយមកនេះ ។ នេះជាការពណ៌នាដោយបំប្រួញនិងពិស្ដារ ។

ក៏ដោយហេតុមានប្រមាណប៉ុណ្ណោះ ធុតង្គកថា ដែលបុគ្គលគប្បីសមាទាន ដើម្បីសម្រេចគុណទាំងឡាយ មានអប្បិច្ឆតាគុណ និងសន្តុដ្ឋិតាជាដើម ដែលជាសេចក្ដីផូរផង់នៃសីល មានបការៈ

ដូចដែលយើងពោលហើយក្នុងវិសុទ្ធិមគ្គ ដែលទ្រង់សម្ដែងដោយធម៌ជាប្រធានគឺសីល សមាធិ និងបញ្ញា នៃគាថានេះថា "នរៈប្រកបដោយបញ្ញា តាំងនៅហើយក្នុងសីល" ជាដើម ។

ដីកា សង្ខេបត្ថជោតនី ភាគ១ ពន្យល់ថា ៖

ពាក្យថា **ព្រៃស្មសានដល់ព្រមដោយអារញ្ញិកង្គៈ** មានសេចក្ដីថា ដល់ព្រមដោយអារញ្ញិកង្គៈ ពោលគឺនៅខាងក្រៅអំពីឧបចារស្រុកប្រមាណ ៥០០ ធ្នូ ។ ព្រោះភិក្ខុអ្នកនៅទៀបគល់ឈើជាវត្ត សម្រេច(ការនៅ) ស្ងួប្បីក្នុងទីកណ្ដាលវាលបានដោយការហាមទីប្រក់ចេញ លោកទើបពោលថា "ភិក្ខុស្ងួប្បី ១ រូប ក៏អាចដើម្បីប្រើប្រាស់ធុតង្គទាំងអស់ បានដោយព្រមគ្នាតែម្ដង" ។ ពាក្យថា **ទ្រង់ហាមទុក** សេចក្ដីថា អារញ្ញិកង្គធុតង្គៈ ទ្រង់ហាមទុកដោយអំណាចហាមបដិបត្តិ, ធុតង្គក្រៅនេះ ទ្រង់ហាមទុក ដោយអំណាចមិនបដិបត្តិ ។ មែនពិត ភិក្ខុនីទាំងនោះ មិនមានអារញ្ញិកង្គធុតង្គតែម្ដង ក្នុងទីទាំងពួង ធុតង្គក្រៅនេះ សម្រេចបានដោយសិក្ខាបទនោះឯង ហេតុនោះ ធុតង្គស្ងួប្បីនោះទើបមិនមាន ព្រោះធុតង្គជាអារម្មណ៍នៃការលះសេចក្ដីល្មោភក្នុងវត្ថុជាកប្បិយៈ។ ព្រោះស្ងួប្បីសំពត់ចោមពុង និងសំពត់ងូតទឹករបស់នាងភិក្ខុនី

ក៏ចាត់នៅក្នុងត្រៃចីវរ ព្រមទាំងតេចីវរិកង្គធុតង្គ លោកទើបពោលថា "ទើបមានធុតង្គ ៨ ប៉ុណ្ណោះ" ។ ពាក្យថា **តាមដែលពោលហើយ** សេចក្តីថា ក្នុងធុតង្គ ១៣ ដែលពោលហើយ ដើម្បីភិក្ខុទាំងឡាយ, និងធុតង្គ ៨ ដែលពោលហើយ ដើម្បីភិក្ខុនីទាំងឡាយ ។ ពាក្យថា **ធុតង្គ ១២ សម្រាប់សាមណេរ** សេចក្តីថា ក៏ក្នុងពាក្យនេះ បណ្តាធុតង្គ ១២ ទាំងនេះ ខលុបច្ឆាភត្តិកង្គសម្រេចបានយ៉ាងណា, មែនពិត បវារណាដែលហាមទុក ឬវិនយកម្ម ដែលជាអតិរិត្ត ក្នុងសិក្ខាបទដែលហាមទុក មិនមានដល់សាមណេរពួកនោះ, ម្យ៉ាងទៀត គួរពិចារណាដល់ការដែលលោកមិនហាមធុតង្គនេះ ដែលមានការហាមភោជនដ៏លើសលុប និងដែលបានបវារណាទុកហើយ ហាមប្រមាណនៃភោជនដទៃទៀត ព្រោះមានបានសូម្បីដល់ឧបាសកជាដើម ។

ធុតង្គនិទ្ទេស ទី២ ចប់ ។

។ ចប់ ។

# នាមពុទ្ធបរិស័ទចូលរួមបោះពុម្ពសៀវភៅវិសុទ្ធិមគ្គបត្ថម្ភក

-បច្ច័យនៅសល់ពីផ្សាយធម៌តាមប៉ុស្តិ៍ វិទ្យុ នៅខេត្តព្រះសីហនុ ............. ៤០០ ដុល្លា

-លោក ជាម ហួរហុង ឧបាសិកា សុខ គាង ព្រមទាំងកូនចៅ ............. ៣០០ ដុល្លា

-ឧបាសក គួច គួងឡេង ឧបាសិកា តាំង យូគាង ព្រមទាំងកូនចៅ ........ ២០០ ដុល្លា

-ឧបាសិកា ហេង ហ្គេចឆែ ព្រមទាំងបុត្រ ........................................ ២០០ ដុល្លា

-ជា សុផាន់ណា សេង ស្រីមុំ ........................................................ ៨០០,០០០៛

-ក្រុមកឋិនទានសាមគ្គី ឧបាសក ហួន វុំឌ្ឍី ឧបាសិកា ឯកវ៉ាន់ឌី និងបុត្តធីតា

ឧ.ស. សន ជិនឡេង ឧ.សិ. ហ៊ា សុខនី និងញាតិព្រះធម៌ ១១០ ដុល្លា + ៤០,០០០៛

-ឧបាសិកា យឹម សុផល ................................................................ ១០០ ដុល្លា

-ឧបាសក អ៊ុក ចិត្រា ឧបាសិកា វ៉ិន ចិន្តា ព្រមទាំងកូនចៅ .................... ១០០ ដុល្លា

-ឧបាសិកា មាឃ សំអុល ............................................................. ១០០ ដុល្លា

-ឧបាសក អោក បូរ៉ា + ភរិយា ...................................................... ១០០ ដុល្លា

-ឧបាសក ស៊ីវ សៅ ឧ.សិ. ស្រ៊ាង សុខម៉េង ឧ.សិ. ស្រ៊ាង វួចលាង ....... ១០០ ដុល្លា

-លោក អ៊ី ដានិត និងភរិយា .......................................................... ១០០ ដុល្លា

-ក្រុមឧ.សិ. តាំង ទ្រៀន ............................................... ៥០ ដុល្លា + ៣០០,០០០៛

-លោកយាយ សយ សួច .............................................................. ២៥០,០០០៛

-សា. ឡាយ សារ៉ាក់ .................................................... ៣០ ដុល្លា + ១០០,០០០៛

-ឧបាសក ជា សុខុម និង ឧបាសិកា អ៊ុនពូន ..................................... ២០០,០០០៛

-ឧបាសក សាំង សេង និងភរិយា .................................................. ៥០ ដុល្លា

-ឧបាសិកា ពៅ នារី និងស្វាមី + បុត្រ ........................................... ៥០ ដុល្លា

-ឧបាសក អ៊ាគាង ឧបាសិកា តាត់ យូ + កូនចៅ ............................. ៣០ ដុល្លា

-ឧបាសិកា ចេង គាង ...... ៣០ ដុល្លា -ឧបាសិកា កែវ ស៊ុនលាង ..... ៣០ ដុល្លា

-ឧ.សិ. ថៃ សុខឌីម និងកូន សាវិកា ដឹប ស្រីពេជ្រ .......................... ៣០ ដុល្លា

# នាមពុទ្ធបរិស័ទ

-ឧបាសិកា ម៉ិញ ស៊ីដារ៉ា និង ឧបាសិកា ម៉ិញ កញ្ញារ័ត្ន ........................... ២៥ ដុល្លា

-ឧបាសិកា តាំង ទ្រៀន ព្រមទាំងបងប្អូននិង ក្មួយៗ ............................ ២៥ ដុល្លា

-ឧបាសិកា ម៉ៅ វណ្ណា និងកូនចៅ ..................................................... ២៥ ដុល្លា

-ពុទ្ធបរិស័ទ វត្តព្រៃស្វាយ ...... ១១០,០០០៛ -ក្រុមវេន ឧ.ស. ហាមតិ .... ១០០,០០០៛

-ក្រុមវេនបិណ្ឌថ្ងៃ ១០រោច ........................................................ ១០០,០០០៛

-លោក ទ្រី សេងហុង ឧ.សិ. ជា សុខា ............................................. ១០០,០០០៛

-លោក ហុង បូរី ឧ.សិ. ជា នីតា .................................................... ១០០,០០០៛

-លោក ឡូវ ម៉េងទី ឧ.សិ. ជា សុគន្ធា ............................................. ១០០,០០០៛

-លោក អ៊ុំ សុខអៀង ......... ១០០,០០០៛ ឧ.សិ. ហុង ចេង .............. ៨០,០០០៛

-ឧ.សិ. ជា ដាណុច ..... ២០ ដុល្លា -លោក អោក អ៊ុម ឧ.សិ. យឹម សុផានី ២០ ដុល្លា

-ឧ.សិ. មុំ អឿន និងចៅ លឹម ឆាយដា + ហ៊ិន សុផនី ............................. ២០ដុល្លា

-ឧ.ស. ជា រដ្ឋសាវ៉ុន និងភរិយា ព្រមទាំងបុត្រ ..................................... ២០ ដុល្លា

-ឧ.ស. អ៊ួន សុង + ឧ.សិ. ឆាយ ម៉ាឡែត និងបុត្រ ................................ ២០ ដុល្លា

-សាមណេរ វុធ ម៉ៅ ...... ៥៥,០០០៛ -ឧ.សិ. អ៊ឹង សុខឃុន .......... ៥០,០០០៛

-ឯកឧត្តមបណ្ឌិត ស៊ិន ម៉េងស្រ៊ុន និងលោកជុំទាវបណ្ឌិត ជុំ បូស៊ិន ............ ៥០,០០០៛

-ឯកឧត្តម ឆេង សារឿន និងលោកជុំទាវ ជុំ វុឌ្ឍី ព្រមទាំងកូនចៅ ............ ៥០,០០០៛

-អ្នកស្រី ជុំ ណារ៉ា +ក្រុមគ្រួសារ ... ៥០,០០០៛ -ឧ.សិ. គង់ យឹម +កូន .... ៥០,០០០៛

-ឧ.សិ. ហេង ស៊ីវខេង +បងប្អូន ... ៥០,០០០៛ -កូនលោកយាយ ហួយ ..... ៥០,០០០៛

-សាមណេរ វុធ ម៉ៅ ៤០,០០០៛ -ឧ.ស. ទៀវ កូឡា និងឧ.សិ. លឿង លៀងហួរ ៤០,០០០៛

-សាមណេរ ញ៉ោ រ៉ាវី ៤០,០០០៛ -ឧ.សិ. ខេង លាភានី (អាភា) និងអ្នកម្តាយ ៤០,០០០

-សាមណេរ មិន សុជាត ៤០,០០០៛ - ឧ.សិ. ប៊ុន សឿន +បងប្អូនកូនចៅ ៤០,០០០៛

-ពុទ្ធបរិស័ទ កោះឧកញ៉ាតី ... ១០ ដុល្លា + ៥០០០៛ -ឧ.សិ. ឈិន ណារី +កូន ១០ ដុល្លា

# នាមពុទ្ធបរិស័ទ

-លោកគ្រូ ហួន វុឌ្ឍី ឧ.សិ. ឯករ៉ាន់ឌី ... ៤០,០០០៛ -ឧ.សិ. ម៉ែន សាន .... ៤០,០០០៛

-ឧ.សិ. ម៉ែន យឿឡខៃ លាងជូ ... ៤០,០០០៛ -លោក កែវ វណ្ណដេត ... ៤០,០០០

-ឧ.សិ. ជា យ៉ាន់ + កូនចៅ .......... ៤០,០០០៛ -ឧ.សិ. ជា កែន + កូនចៅ ៤០,០០០៛

-ឧ.ស. ប្រាក់ សំណាង និងភរិយា កូនចៅ .......................... ៤០,០០០៛ + ១៥០០០៛

-ឧ.សិ. អួន ហេមារ៉ា + ឧ.សិ. ឆាយ លន់ ................................................ ៤០,០០០៛

-ឧ.សិ. គុជ មុំ និងកូនចៅ ....... ១០ ដុល្លា -ឧ.សិ. អ៊ុំ សំណាង + កូនចៅ ...... ១០ ដុល្លា

-ឧ.សិ. អួន ហេម៉ារ៉ា ... ១០ ដុល្លា -ឧ.សិ. ហួរ អ៊ី ... ១០ ដុល្លា -ឧ.សិ. ធិម រិន ១០ ដុល្លា

-ឧ.ស. ដែង ពិសិដ្ឋ ឧ.សិ. ហ៊ឹម ម៉ាលី ... ១០ ដុល្លា -ឧ.សិ. វ៉ូ ទីស៊ីមអ៊ន ...... ១០ ដុល្លា

-ឧ.សិ. លី វណ្ណថន + បុត្រ លី ច័ន្ទរាត្រី ... ១០ ដុល្លា -ឧ.សិ. ទុយ ហ៊ុច ........ ១០ ដុល្លា

-លោក ស្វាយ យឿន ឧ.សិ. មុំ ស៊ីថា ..... ១០ ដុល្លា -ឧ.សិ. ចេង ហុង ...... ១០ ដុល្លា

-លោក កែវ ប៊ុណ្ណារ៉ា និងលោកស្រី លឹម សុធារី ... ១០ ដុល្លា -ឧ.សិ. មុំ រឿន ... ១០ ដុល្លា

-ឧ.សិ. មាឃ សំអុល (យាយម៉ៅ) ១០ ដុល្លា -ឧ.សិ. គួយ ចាន់មុនី ............ ១០ ដុល្លា

-លោក ជា យ៉ាន់ និងអ្នកស្រី ហ៊ាង ម៉ាក់លី ... ៣០,០០០៛ -សា. យ៉យ ហ៊ុល ៣០,០០០៛

-ឧ.សិ. ឡុន ម៉មរុ្យខៀវ សាមុនី ៣០,០០០៛ -ឧ.សិ. យៀប ភំ ឧ.ស. ស៊ីម ៣០,០០០៛

-ឧ.សិ. យៀប ភំ ឧ.ស. ស៊ីម ... ៣០,០០០ -ថោង កន្និកា ................... ២៨,៥០០៛

-ឧ.សិ. សាធ ចន្ថា ................ ២២,៨០០៛ -ឧ.សិ. លឹម ស្រីពៅ ......... ២២,៨០០៛

## ~ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗចំនួន ២០,០០០៛

-សា. រ៉ុន ពីយ៉ាង -សា. ចយ សីហា -សា. សេក វ៉ាឆាន់ -សា. ធង់ សុជាត -ភិ. រ៉េន ភារ

-សា. ពិន វុទ្ធារិទ្ធ -សា. សុខ ប្រុស -សា. វ៉ា សុខចាន់ -សា. ឡុង វាសនា -ជា សំ អឿន

-សា. ព្រឹង កុសល -សា. យ៉ាំ ស៊ូគិ -ឧ.សិ. ហាម ស្រីបួយ -ឧ.សិ. លឹម ផិចហៀង +កូនចៅ

-ឧ.ស. អ៊ុក អុល និងឧ.សិ. បូ រស់ -ឧ.សិ. គិត គីមហេង -ឧ.សិ. ខៀវ នឿន

-ឧ.ស. កា កាន និងឧ.សិ. អ៊ុន សុខ -តា ឃឹម យ៉ុង យាយ ចាន់ ឡុង សួង

# នាមពុទ្ធបរិស័ទ

-ឧ.សិ. ប៉ាល់ ធីតា និងស្វាមី+កូនចៅ -ឧ.ស. ឈិន សារិន + ឧ.សិ. សោម ចាន់នី

-ឧ.ស. សៅ សួន និង ឧ.សិ. ស៊ាម ណៃអេង -ឧ.ស. តាំង ហាំង ឧ.សិ. លីម ស៊ូគាង

-ឧ.សិ. ហែម ចន្ទ័គីមនី ស្វាមី +កូន -ឧ.សិ. ជុន គង់ +កូន -ឧ.សិ. មាន សារឿន

-ឧ.សិ. ភូ និ និងបងប្រុស ភូ មៀន -ឧ.សិ. មាន សារឿន -ឧ.ស. កែវ ណៃអ៊ីម

-ឧ.សិ. ហ៊ាម ខេមនិត +បុត្រ -ពេទ្យ ស៊ុក និងភរិយា +កូន -ឧ.សិ. ចាន់ សាម៉ន

-ឧ.សិ. សេង ឈន់លាង -ឧ.សិ. យិម ថុល +កូនចៅ -ឧ.សិ. ហេង ប៊ុនហុង -ឧ.សិ. ចាន់ ថន

-ឧ.សិ. ឡេង សុទ្ធចន្ទី -ឧ.សិ. ញឹក ចន្ទ័ធី -យាយ ឈឹម ឡក់ -ឧ.សិ. លន់ ណាត +កូន

## ~ពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗចំនួន ០៥ ដុល្លា

-ឧ.សិ. គីម ហ៊ន ឧ.ស. លី ហ័ង +កូន -ឧ.សិ. ឯម សារៈ -លោក ជា មាន និងភរិយា +បុត្រ

-ឡាយ ស្រី -ឧ.សិ. ហែម ឈើយ -ឧ.សិ. មុំ វួច +គ្រួសារ -ឧ.សិ. ងួន ស៊ីណង +កូនចៅ

-ឧ.សិ. លីម ផិចហៀង +កូនចៅ -ឧ.សិ. ឆន ឆប ឧ.ស. ម៉ៅ មួន

-លោក កែវ សុវណ្ណដា និងលោកស្រី ជៀប រ៉ាវីលី +បុត្រ -ឧ.សិ. សៅ ឧ.ស. ថន +កូនចៅ

-ឧ.សិ. យុង នីណា ... ១៥,០០០៛ -ភិ. ពុទ្ធ ប៊ូរីម ... ១៥,០០០៛

-ឧ.សិ. យីវ សុខម និង សៀវ ខេង ១២,០០០៛ -ហេង គីមធនិន ....... ១១,៤០០៛

-ឧ.សិ. អួន ១១,៤០០៛ -ឧ.សិ. គង់ ទុំ +ស្វាមី ១១,៤០០៛ -ឧ.សិ. អាន +ចាម ១១,៤០០៛

## នាមពុទ្ធបរិស័ទចូលបោះពុម្ព ម្នាក់ៗ ចំនួន ១០,០០០៛

-សា. លីន បូរ៉េត -សា. អ៊ុន ជ័យ -សា. ប៊ន ណេត -សា. យ័ន សារ៉ាត -សា. អៀត រ៉ាយុ

-សា. បង សម្បត្តិ -សា. សាក់ ម៉េងឡុង -សា. ណាង សុផានិត -សា. ខៀប សុវណ្ណរុន

-សា. រ័ត្ន សារ៉ាយ -សា. ផុន សឹង ហេង -សា. ហ៊ួន រ៉ា -សា. វីរ វុទ្ធី -សា. បូ រតនា

-សា. ប៊ុ ពន្លឺ -សា. នី ស៊ីណៃ -សា. អុល ស៊ីនឿន - សា. យ៉ូន តារា -សា. ទេព មនោ

-ភិ. គឿន គុណ -សា. ឈិត សុវណ្ណារ៉ាន់ -សា. ណាក់ ចាន់រិទ្ធ -សា. ថុល សារបុត្រ

-ស៊ីន ស៊ីណាត និងស្វាមី +បុត្រ -ឧ.សិ. សំ ចេង និងកូនចៅ -ឧ.សិ. សេក ហេង -ប៊ុន នី

# នាមពុទ្ធបរិស័ទ

-ឧ.សិ. គាម ថាវី និងកូនចៅ -សាន ចិន្តា -ឧ.ស. អ៊ុច បូ អ៊ុង រឿងរិទ្ធ -ឧ.សិ. ទឹម ម៉ាច
-ឧ.ស. អេង វណ្ណា និង ឧ.សិ. សៅ ណារី +កូនចៅ -លោក យាយ ហេង -ជឹម ស៊ីវគា
-ឧ.សិ. មាស គីមស៊ូ -ឧ.សិ. ទុយ ស្រីពៅ និងកូនចៅ -អ៊ិន ហាន និង ហោ គីម ថាន
-ឧ.សិ. ហ៊ួត ណៃឈីម និងស្វាមី +បុត្រ -ឧ.សិ. មាស គឹមសួ -ឧ.សិ. អ៊ិត ស៊ីវហេង
-ឧ.សិ. តិក លីម -ឧ.សិ. គឹម ហួ និងប្អូន +កូនចៅ -ឧ.សិ. ស្រ៊ុន កែន -អ៊ួយ គឹម ស៊ីវ
-ឧ.ស. យិន សុខ និង ឧ.សិ. ម៉ា រ៉េត +កូនចៅ -ឧ.សិ. ហែម ណយ បុត្រ និងចៅ -ជឹម ជីន
-ឧ.សិ. ហែម ណាន បុត្រ និងចៅ -សួន សុផានី ស្វាមី +បុត្រ -ឧ.សិ. ប៉ាន់ យុឡេង
-ឧ.សិ. ប៊ូ សារ៉េត + ស្វាមី និងបុត្រ -ឧ.សិ. មាន លីណា -ឧ.សិ. ស នាងណូ, ឆន ឌឹម
-ឧ.សិ. យុង រត្នវតី -ឧ.សិ. ងន គ្រី -ឧ.សិ. ឱ ស្រីពៅ -ឈាង ហួតលាន -ឧ.សិ. ស៊ាម រ៉ុង
-ព្រំ ឌឿន -ឧ.សិ. ផល សុមាលី -ឧ.សិ. មៀក មុំ -ឧ.សិ. មៀក សំអល់ -ឧ.សិ. សៅ
-ឧ.សិ. ស -លោកគ្រូ ញឹក ឈុនឆាត -ឧ.សិ. ឈិន វ៉េត -ឧ.សិ. ស តាហ៊ុ, យាយ យ៉ន
-ឧ.សិ. នាង អយ -ឧ.សិ. ស សេង, យាយ អ៊ុន -ឧ.ស. តុង ហៃ -ឧ.ស. តែក ប៊ុនធឿន
-ឧ.សិ. ហ៊ុយ សុខម៉ៅ +បុត្រ -ឧ.សិ. ហ៊ុយ រ៉ាវី -ឧ.សិ. ជុន អ៊ីម -ឧ.សិ. ឃុន ស៊ីវគីម
-ឧ.សិ. ខៀវ ស៊ីណៃ -ឧ.សិ. សៀក ឡាយ -ឧ.ស. ខៀវ សារិត -ឧ.សិ. ឈៀង មករា
-ឧ.សិ. ឈួយ ដារ៉ុង -ឧ.ស. ដួង រិន -ឧ.ស. នុន និត, ចាក់ ជ្រឹប -ឧ.សិ. ឆេង ហ៊ួន
-ឧ.សិ. អ៊ីន សុវណ្ណដារ៉ា + ស្វាមី និងបុត្រ -ឧ.សិ. គួច គឹមសាន -ឧ.សិ. ឯម សុភ័ក្រនាត
-ឧ.សិ. អៀ ស្រីទុន សិ. ផាន់ សុផល -តា ម៉ាច និងយាយ យន -គ្រូ តូ និងយាយ ណៃ
-ឧ.សិ. ឋិន ម៉ៅ -ឧ.ស. ប៉ូ លាង -ឧ.ស. ងឿន តន -ឧ.សិ. អ៊ុំ សុផល -ឧ.សិ. អ៊ុន សុក
-ឧ.សិ. ប៊ុន ថេង្សពៀន តាន់ អេង -ឧ.សិ. បួយ ស៊ីម -ឧ.សិ. ភឹន ម៉ក់ -គាន់ អួន និងភរិយា
-ឧ.ស. គឹម ម៉ាឡា -ឧ.សិ. ជុន អ៊ី -ឧ.សិ. មួយ ហ៊ឹង -ឧ.ស. មាស ប៉ុនលេង -ឧ.សិ. សៀម
-ឧ.ស. សៀ សមអន់ -ឧ.សិ. អ៊ូ ទៀង -ឧ.សិ. មួយ ស៊ីម -ឧ.សិ. ឡៅ សិត និងបុត្រ
-ឧ.សិ. សាមណោរ ឈឹន កែវឡុង -ឧ.សិ. ប៊ុន យៀ -ឧ.សិ. គង់ សុរម និង ទេព សារិរៈ

# នាមពុទ្ធបរិស័ទ

-ឧ.ស. ខេត ប្រុក និងកូនចៅ -ឧ.ស. សុខ សុផាត និងភរិយា +បុត្រ -ឧ.សិ. លី ឈន់

-ឧ.សិ. អួន វណ្ណា ហៅ ពៅ សុធានី -លោកគ្រូធំ និងភរិយា +បុត្រ -ឧ.សិ. ឃុន លីរតនា

-ឧ.ស. ចាន់ រតនា និងភរិយា +បុត្រ -ឧ.សិ. លី គឹមសេង -ឧ.សិ. ម៉ួង សុខ -ឧ.សិ. ប៊ុន រដ្ឋា

-ឧ.សិ. ថៃ សុគន្ធារត្ន៍ -ស្រី លីស និង កាញ្ញ វិទ្ធ -កុមារី ឡៅមេងជូ -ឧ.សិ. អ៊ុច សុវណ្ណា

-ឧ.សិ. ពេជ្រ -ឧ.សិ. មាស -ឧ.សិ. វី លក្ខិណា + បុត្រ -ឧ.សិ. ស៊ូ ហេង -ឧ.សិ. ថង ជន់

-ឧ.សិ. សឹង ស៊ីវឆេង -ឧ.សិ. សេង សេរីរត្ន័ -ឧ.ស. អ៊ុក អឿន -ឧ.សិ. ដៀង ញេត

-ឧ.សិ. ឆាយ រស់ +បុត្រ -ឧ.សិ. យឹម សាន -ឧ.សិ. ឡួន សុភា -ឧ.សិ. យឹម ជៀង

-ឧ.សិ. ម៉ិច ម៉ាច -ឧ.សិ. យឹម ភមរា +លឹម លាងហូ -ឧ.សិ. ផល មុំ -ឧ.សិ. អ៊ុំ សុភាព

-ឧ.សិ. មិន រ៉ាវី -ឧ.សិ. គង់ ផល្លីន -ឧ.សិ. វ៉ាន់ ដាលីស -ឧ.សិ. ជា ចាន់ ស្វាមីនិងបុត្រ

-ឧ.សិ. សុខ ចន្ទ័ មុកកី -ឧ.សិ. ពេ ស្រីយ៉ាន -ឧ.ស. ខៀវ កូឡា និង លឿង លាងហួរ

-ឧ.សិ. បូ ណារា + លិទី + លីហាក់ ហេងលី + មី ហៀង -ឧ.សិ. លឹម សុភី -ឧ.សិ. ឈូនី

-ឧ.សិ. រស់ ស៊ីមន និង វ៉ាន់ វុធធាវី -ឧ.សិ. បូ សៀ និង គឹម សួក +បុត្រ -ឧ.ស. បូ រតនា

-ឧ.សិ. ហម រួន -ឧ.សិ. ឱ ស្រីពៅ -ឧ.សិ. គួច ផៃ និងក្មួយ -ឧ.ស. ឃុន ឆាយ ភរិយា +បុត្រ

-ឧ.ស. ហួន ចន្ទថូ ឧ.សិ. នុត សុខា -ឧ.ស. ហួន វុឌ្ឍថាន់ ឧ.សិ. រិន សុភាព -ឧ.សិ. នង គ្រី

-ឧ.ស. ហួន វុឌ្ឍិន -កុមារា ហួន ធន័រត្ន -ឧ.សិ. ម៉េន ពិសី -ឧ.សិ. ស្រី ទិន សាវត្តី +គ្រួសារ

-ឧ.សិ. គុជ កុសល និង ចន្ទ័ដាវី ៩000៛ -ឧ.សិ. កោ សេង ៩000៛

-ឧ.សិ. ហែម បូរី និង ចន្ទ័ស៊ីមូលី ៩000៛ -ឧ.សិ. អៀម វុទ្ធី ៩000៛

-ឧ.ស. ណាង ហុង +គ្រួសារ ៨000៛ -ឧ.សិ. អ៊ុន ស៊ីម៉ន + រស់ សុវណ្ណារត្ន៍ ២ ដុល្លា

-ឧ.សិ. កែវ បញ្ញា ៦,000៛ -ឧ.សិ. ប៉ែន សារី ៦,000៛ -ឧ.សិ. ពេជ សារ៉េត ៦,000៛

-ព្រមទាំងពុទ្ធបរិស័ទចូលរួមចំនួន ៥,000៛ ជាដើម ជាច្រើននាក់ទៀត ។

**សូមពុទ្ធបរិស័ទ អនុមោទនាធម្មទាន!!!**